ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ម៉ាន់ ពីនី
- ចំណងកុម្មុយនិស្តខ្មែរក្រហម និង វៀតណាម

លេខ០៥ ខែឧសភា ឆ្នាំ២០០០

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៧ ខែឧសភា ឆ្នាំ២០០១


## មាតិកា


- សំបុត្រៈ ខ្មែរក្រហមបន្តធ្វើអាជីវកម្មលើជនរងគ្រោះ................ ១

**ផ្នែកឯកសារ**

- វ៉ាន់ ពីនី.................................................................. ២
- រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម................ ៧
- សុន្ទរកថារបស់សមមិត្ត សុន សេន....................................... ៩
- កំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហម.............................. ១៤
- តួនាទីដែលគួរឲ្យសង្ស័យរបស់ស្ថានទូតចិន............................ ១៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

- សម្លេងពីមន្ទីរស-២១ ..................................................២២
- ជនដៃដល់ ឬ ជនរងគ្រោះ? ..........................................២៦
- ជនជាតិថៃដែលត្រូវបានសម្លាប់.........................................៣០
- រង្វាស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ............................៣២

**ផ្នែកច្បាប់**

- តម្លៃនៃភ័ស្តុតាង......................................................... ៣៥
- បញ្ហាបន្ថែមនៅក្រោមច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ.........................៣៩
- សេចក្តីព្រាងច្បាប់ខ្មែរក្រហម.............................................៤១

**វេទិកាពិភាក្សាសាធារណៈ**

- ជនកុម្មុយនិស្តខ្មែរក្រហមនិងវៀតណាម.................................៤៣
- ទីបញ្ចប់នៃបដិវត្តន៍.........................................................៤៧
- ការអួតសរសើរបដិវត្តន៍...................................................៥០
- កំណត់ហេតុស្តីអំពីអង្គប្រជុំរបស់សភាជាតិ............................៥៤

**ធំព័រស្វែងរកគ្រួសារ**

- រឿងចាស់ ប៉ុន្តែថ្មីចំពោះខ្ញុំ.................................................. ៦០

**សិល្បៈខ្មែរក្រហម**

- ចម្រៀងៈ រស្មីកម្ពុជាថ្មី ភ្លឺស្រែយើងថ្មីល្អណាស់............ក្របក្រោយ




ញ៉ែម អេន កម្មាភិបាលផ្នែកថតរូបអ្នកទោសនៅមន្ទីរ ស-២១


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**(រូបថតក្របមុខផ្តល់ឲ្យដោយ ហ្វូលីយ៉ូ ហេលជីលជ្រេស)**

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***វាគ្មិនលេខនេះ:*** *ដេវីត ឆេនដល័រ, អៀ ម៉េងទ្រី, អេលីហ្សាប៊ែត វ៉ាន់ស្កាក់, ដេវីដ អាស្ហូលី, ចន ឆរឆីអាវី, មិទ្រី មូសយ៉ាកូវ, អៀ សុផល, ដេង ពង្សរ៉ាស៊ី* ***អ្នកនិពន្ធនិងស្រាវជ្រាវ:*** *សាន់ កល្យាណ, លី សុផល, ដួង សុភារិទ្ធ* ***ជំនួយការនិពន្ធនាយក:*** *អែម សុខឃីម* ***និពន្ធនាយករងទី១:*** *ដាត កុសល* ***និពន្ធនាយករងទី២:*** *ស៊ីម សុរិយ៉ា* ***អ្នកបកប្រែ:*** *សួ ប៊ុនស៊ូ* ***និពន្ធនាយកទូទៅ:*** *ឆាំង យុ* ***ក្រាហ្វិកកុំព្យូទ័រ:*** *ស៊ឹម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយ:*** *ទ្រី សុភក្តិ*

*សំបុត្រ:*

# ខ្មែរក្រហមបន្តធ្វើអាជីវកម្មលើជនរងគ្រោះ

អតីតកម្មាភិបាលខ្មែរក្រហមម្នាក់មកពីតំបន់អន្លង់វែង បានយករូបថត ប៉ុល ពត និងមេដឹកនាំខ្មែរក្រហមមួយចំនួនទៀតដែលថតនៅក្រោយឆ្នាំ១៩៧៩ ចំនួនពីរសៀវភៅ និងកាស្សែតវីដេអូ“សម្ងាត់”ចំនួនមួយស្តីអំពីការជួបប្រជុំរវាងមេដឹកនាំគណបក្សនយោបាយជាមួយនិងមេដឹកនាំខ្មែរក្រហម ដែលនៅក្នុងនោះមានតាម៉ុកជាអ្នកចូលរួមផង មកលក់ឲ្យខ្ញុំ ។ រូបថតមួយសន្លឹកមានតម្លៃ១៥០០ដុល្លារសហរដ្ឋអាមេរិក ។ ចំណែកឯកាស្សែតវីដេអូមានតម្លៃ៣៥០០ដុល្លារសហរដ្ឋអាមេរិក ។ អតីតកម្មាភិបាលខ្មែរក្រហមរូបនេះបានប្រាប់ខ្ញុំថា អ្នកយកព័ត៌មានបរទេសជាច្រើនបានឲ្យតម្លៃរូបថតនិងកាស្សែតវីដេអូខ្ពស់ជាងនេះទៅទៀត ប៉ុន្តែគាត់មិនព្រមលក់ ។ គាត់បានប្រាប់ខ្ញុំថាដោយមូលហេតុចង់ចូលរួមចំណែកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីស្វែងរកការពិតនិងយុត្តិធម៌ជូនអ្នកស្លាប់រាប់លាននាក់ទើបគាត់យករបស់ទាំងនេះមកលក់ឲ្យខ្ញុំក្នុងតម្លៃទាបបំផុត ។

ចាប់តាំងពីមានការចាប់ផ្តើមនៃកិច្ចការស្រាវជ្រាវនៅឆ្នាំ១៩៩៥ មជ្ឈមណ្ឌលឯកសារកម្ពុជាមិនដែលបានទិញរូបថត កាស្សែតវីដេអូ ហ្វីលភាពយន្ត ឯកសារ វត្ថុអនុស្សាវរីយ៍ ឬរបស់របរទាំងឡាយដែលសេសសល់ពីរបបខ្មែរក្រហមម្តងណាឡើយ ។ មូលហេតុចម្បងគឺថា ការចងចាំរបស់ជនរងគ្រោះនិងអ្វីដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម មិនអាចយកមកដោះដូរជាប្រាក់កាសបានទេ ។ ករណីអតីតខ្មែរក្រហមម្នាក់នេះគឺជាការទទួលខុសត្រូវរបស់តុលាការក្នុងការគូសបញ្ជាក់ឲ្យបានច្បាស់ថា តុលាការត្រូវការប្រមែប្រមូលឯកសារទាំងអស់នោះសម្រាប់ដំណើរការរកយុត្តិធម៌ជូនដល់ជនរងគ្រោះ ។

ក្រុមគ្រួសារសាច់ញាតិរបស់ខ្ញុំ និងប្រជាជនកម្ពុជារាប់លាននាក់ ដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម គ្មាននរណាម្នាក់ក្នុងលោកនេះអាចយកមាសប្រាក់មកសងជំនួសវិញបានឡើយ ។ ផ្ទុយទៅវិញ អតីតកម្មាភិបាលខ្មែរក្រហមម្នាក់នេះពុំមានវិប្បដិសារីបន្តិចណាទាល់តែសោះចំពោះអ្នកទោសជាងមួយម៉ឺននាក់ដែលខ្លួនបានថតរូបដោយផ្ទាល់ដៃនៅមន្ទីរស-២១ មុននឹងត្រូវបានដឹកទាំងឡានៗយកទៅសម្លាប់ចោលនៅឯ “វាលពិឃាត” បឹងជើងឯក ។ ខ្ញុំចេះតែសញ្ជឹងគិតថា សមាជិកក្រុមគ្រួសារសាច់ញាតិរបស់ខ្ញុំណាម្នាក់ប្រហែលជាស្ថិតនៅក្នុងចំណោមរូបថតដែលថតដោយអតីតកម្មាភិបាលខ្មែរក្រហមម្នាក់នេះហើយ ។

ដោយហេតុតែមិនដែលឲ្យតម្លៃដល់ជីវិតមនុស្សទាល់តែសោះ ទើបបានជាមនុស្សរាប់លាននាក់បានស្លាប់ដូចសត្វធាតុក្រោមស្នាដៃរបស់ខ្មែរក្រហម ។

អតីតខ្មែរក្រហមម្នាក់នេះកំពុងតែមានសេរីភាពដើរឆ្កេចឆ្កាចយកការឈឺចាប់និងការចងចាំរបស់ជនរងគ្រោះធ្វើជាថ្នូរនឹងប្រាក់ដុល្លារ ។ សូម្បីតែខ្មែរក្រហមដែលនៅក្នុងគុកក៏ត្រូវបានជំរុញឲ្យធ្វើអាជីវកម្មទៅលើការស្លាប់យ៉ាងអាណោចអាធ័មរបស់ប្រជាជនកម្ពុជា ។ ទន្ទឹមនឹងនេះដែរ ខ្សែភាពយន្តឯកសារប្រវត្តិសាស្ត្រស្តីអំពីរបបខ្មែរក្រហមមានរយៈពេលរាប់រយម៉ោងដែលបានដឹកចេញពីប្រទេសកម្ពុជាទៅទុកនៅប្រទេសបារាំងក្រោមកិច្ចសន្យាដ៏ស្រពិចស្រពិលមួយនោះពុំទាន់ត្រូវបានយកត្រឡប់មកកម្ពុជាវិញនៅឡើយទេ ។

ខ្មែរក្រហមបានយកជីវិតខ្មែររាប់លាននាក់មកធ្វើអាជីវកម្មនយោបាយរបស់ខ្លួន ។ ខ្មែរក្រហមបាននិងកំពុងបន្តយកព្រលឹងអ្នកស្លាប់ទាំងអស់នោះ ព្រមទាំងការឈឺចាប់របស់ជនរងគ្រោះដែលមានជីវិតរស់នៅក្នុងពេលបច្ចុប្បន្ន មកធ្វើអាជីវកម្មដោះដូរជាប្រាក់ដុល្លារនិងឥទ្ធិពលក្នុងសង្គមខ្មែរ ។ ប្រហែលជាមិនយូរប៉ុន្មានឡើយ ប្រសិនបើការអនុញ្ញាតចេះតែបន្តឲ្យមាន ខ្មែរក្រហមប្រហែលជានិងយកគំនរឆ្អឹងដេះដង់នៃសាកសពជនរងគ្រោះមកធ្វើអាជីវកម្មក្រោមទ្រឹស្តីកសិកម្មមហាលោតផ្លោះមហាអស្ចារ្យរបស់ខ្លួនថែមទៀតមិនខាន ។ ខ្មែរក្រហមមិនយល់បានទាល់តែសោះថាជីវិតនិងការចងចាំរបស់មនុស្សមានតម្លៃពុំអាចកាត់ថ្លៃបានឡើយ ។

**ឆាំង យុ**

# វ៉ាន់ ពីនី៖
# គណៈមន្ទីរ ក-១៧ ផ្នែករណសិរ្ស



រូបឆ្វេង៖ ហួត សម្បត្តិ ឯកអគ្គរដ្ឋទូតប្រចាំនៅប្រទេស អាល់បានី, រូម៉ានី និងយូហ្គោស្លាវី ។ រូបបន្ទាប់៖ វ៉ាន់ ពីនី ឧបរដ្ឋមន្ត្រី ក្រសួងការបរទេសនៃរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជា ។
(ថតនៅក្រសួងការបរទេស ប្រទេសអាល់បានី)

វ៉ាន់ ពីនី ឈ្មោះក្នុងជួរបដិវត្ត ទិត អាយុ៣៧ឆ្នាំ (ឆ្នាំ១៩៧៧) ស្រុកកំណើតនៅភូមិស្វាយពល ឃុំស្វាយពល ស្រុកពារាំង (បច្ចុប្បន្ន ឃុំរកា ស្រុកព្រះស្ដេច) ខេត្តព្រៃវែង ។ ឪពុកឈ្មោះ វ៉ាន់ ប៊ុនថាន់ អភិបាលស្រុក ស្លាប់ដើមឆ្នាំ១៩៧៤ ។ ម្ដាយឈ្មោះ រស់ បូផា មុនឆ្នាំ១៩៧៥រស់នៅភ្នំពេញ ។ ពីនី ជាកូនទី៣ក្នុងចំណោមបងប្អូន៩នាក់ ស្រី៤នាក់ ប្រុស៥នាក់ ។ ប្រពន្ធរបស់ ពីនី ឈ្មោះ គួន វឌ្ឍណា ហៅ ចាន់ ។

មុនពេលដែលប្រទេសកម្ពុជាធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ពីនី ធ្វើការជាលេខាស្ថានទូតខ្មែរនៅប្រទេសបារាំង ។ បន្ទាប់មក ពីនី ក៏ផ្លាស់ទៅធ្វើការជាមួយរណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងប៉េកាំង ។ ពីនី ត្រូវបានអង្គការខ្មែរក្រហមហៅចូលមកក្នុងប្រទេសកម្ពុជាវិញនៅខែ៩ ឆ្នាំ១៩៧៥ ។ ក្រោយពេលមកដល់ប្រទេសកម្ពុជា ពីនី ត្រូវបានបញ្ជូនទៅមន្ទីរ ក-១៧ ជាមន្ទីរកែប្រែដែលមានទីតាំងនៅវិទ្យាល័យបឹងត្របែកបច្ចុប្បន្ន ។ ពីនី បានទទួលនាទីជាគណៈមន្ទីរ ក-១៧ រហូតដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ហើយត្រូវបានអង្គការចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១ ។

ឯកសារចម្លើយសារភាពរបស់ វ៉ាន់ ពីនី ដែលបន្សល់ទុកមានចំនួន១១០ទំព័រ បានបង្ហាញឲ្យឃើញអំពីសកម្មភាពមួយចំនួនរបស់ ពីនី ដូចតទៅ៖

វ៉ាន់ ពីនី បានចូលរៀននៅវិទ្យាល័យស៊ីសុវត្ថិក្នុងឆ្នាំ១៩៥៦ ។ នៅឆ្នាំ១៩៦១ ពីនី ប្រឡងជាប់មហាវិទ្យាល័យច្បាប់ ។ ក្នុងរយៈកាលរៀននៅមហាវិទ្យាល័យច្បាប់ ពីនី បានឆ្លៀតបង្រៀននៅសាលាឯកជនខេមរា (ដែលមាន ភោគ ឆាយ ជាចាងហ្វាង) និងសាលាចំរើនវិជ្ជា ។ ក្រៅពីនោះ ពីនី ឆ្លៀតសរសេរអត្ថបទឲ្យកាសែតឡាដេប៉ែស ។

នៅចុងឆ្នាំ១៩៦២ ពីនី ត្រូវបានជនជាតិបារាំងពីរនាក់ឈ្មោះ រ៉ូប៉ូ និង គួរ ជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់ រួមជាមួយ សារិន ឆាក អូសទាញឲ្យធ្វើសកម្មភាពបម្រើឲ្យអង្គការ ស្ដេស **(SDECE-French Secret Service)** ដែលជាអង្គការភ្នាក់ងារសម្ងាត់មួយរបស់បារាំង ។ ភារកិច្ចដែល ពីនី ត្រូវបំពេញគឺ ១) កសាង កម្លាំងនៅក្នុងមជ្ឈដ្ឋាននិស្សិតនិងបញ្ញាជន ២) ពន្យល់ឲ្យមហាជន ឃើញពីអត្ថប្រយោជន៍ក្នុងការបន្តទំនាក់ទំនងជាមួយប្រទេសបារាំង និង ៣) ធ្វើសកម្មភាពប្រឆាំងនឹងពួកចម្រើន ។ («ពួកចម្រើន» ក្នុងពេលនេះគឺហៅចំពោះកម្លាំងខ្មែរក្រហមដែលនៅពេលនោះជាចលនាតស៊ូប្រឆាំងនឹងរដ្ឋាភិបាល ។ ខ្មែរក្រហមបានហៅខ្លួនឯងថា «ពួកចម្រើន» ។ កម្លាំងនេះមានបង្កប់នៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ជាពិសេសនៅតាមសាលារៀននិងក្រសួងមន្ទីរនានា) ។ ប្រាក់បៀវត្សរ៍ដែល ពីនី ទទួលបាន ពីអង្គការស្ដេសគឺ ៦ ០០០ រៀល ក្នុងមួយខែ ។

នៅខែមីនា ឆ្នាំ១៩៦៣ ពីនី ប្រឡងជាប់រៀននៅមហាវិទ្យាល័យភូមិន្ទរដ្ឋបាល ប៉ុន្តែ ពីនី បន្តធ្វើកិច្ចការនៅមហាវិទ្យាល័យច្បាប់ដដែល ។ សកម្មភាពរបស់ ពីនី នៅមហា

វិទ្យាល័យច្បាប់គឺចាត់កម្លាំងតាមដានការបង្រៀនរបស់សាស្ត្រាចារ្យណាដែលមាននិន្នាការ «ចម្រើននិយម»។ ប្រសិនបើឃើញថាសាស្ត្រាចារ្យណាម្នាក់ឃោសនាក្រៅពីកម្មវិធីសិក្សា ពីនី នឹងទៅរាយការណ៍ឲ្យនាយកសាលាថាសាស្ត្រាចារ្យនោះធ្វើការឃោសនាឲ្យកុម្មុយនិស្តដើម្បីឲ្យនាយកសាលាហៅសាស្ត្រាចារ្យនោះទៅព្រមានឬបញ្ឈប់លែងឲ្យបង្រៀន។ នៅក្នុងឆ្នាំ១៩៦៣ នោះ ឌុក រ៉ាស៊ី ជាចាងហ្វាងមហាវិទ្យាល័យច្បាប់ ហើយគាត់គឺជាមនុស្សប្រឆាំងនឹង «ពួកចម្រើននិយម» ដូច្នេះសាស្ត្រាចារ្យ «ពួកចម្រើននិយម» មិនអាចធ្វើសកម្មភាពអ្វីក្នុងមហាវិទ្យាល័យច្បាប់បានទេ។ នៅមហាវិទ្យាល័យច្បាប់ មនុស្សសំខាន់ៗដែល ពីនី គិតថា ជា «ពួកចម្រើននិយម» រួមមាន ហ៊ូ យន់, ហូ នឹម, អ៊ុច វ៉េន និងភោគ ឆាយ (ភោគ ឆាយ ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៧-សេចក្ដីសង្ខេបនៃចម្លើយសារភាពរបស់ ភោគ ឆាយ ត្រូវបានចុះផ្សាយរួចហើយក្នុងទស្សនាវដ្ដីស្វែងរកការពិតលេខ៥និងលេខ៦)។ អ្នកទាំង៤នេះមិនដែលធ្វើសកម្មភាពអ្វីឲ្យ ពីនី អាចកត់សម្គាល់បានទេ។ ចំណែកបក្សពួករបស់ ពីនី មាន អាំង ប៊ុនថៃ, ហ៊ូ ប៊ុនឡាយ, ម៉ៅ ដាត់ និង សាយ បូរី ។

នៅសាលាឯកជនខេមរា ពីនី បានស្គាល់ លៀវ ធានអ៊ិម និង សោម សារី ជាខ្មែរប្រជាចលនានៅក្នុងសាលានោះ។ សោម សារី ជាគ្រូបង្រៀនភាសាខ្មែរនៅសាលាខេមរា។ លៀវ ធានអ៊ិម ជាមនុស្សបង្កប់របស់ លន់ ណុន (ប្អូនប្រុសរបស់លោកសេនាប្រមុខនៃរបបសាធារណរដ្ឋខ្មែរ លន់ ណុល)។ ពីនី ត្រូវបាន លៀវ ធានអ៊ិម អូសទាញចូលរួមក្នុងប្រជាចលនា និងបានណែនាំឲ្យស្គាល់ ហង់ ធុនហាក់ (សាស្ត្រាចារ្យសាលាល្ខោនជាតិ) ឌុក រ៉ាស៊ី (ចាងហ្វាងមហាវិទ្យាល័យច្បាប់ ក្រោយមកផ្លាស់ទៅធ្វើអគ្គរដ្ឋទូតនៅប្រទេសអង់គ្លេស) អ៊ឹង ម៉ឹង, ចៅ បាន, ឃី តាំងលឹម និង សុន ចាន់។

ឆ្នាំ១៩៦៤ ពីនី ចូលរួមជាមួយ ភោគ ឆាយ, ទូន សុខផល្លា ឈុន សុខងួន និង ប៉ុក កាណែល បង្កើតសមាគមទូទៅនៃនិស្សិតខ្មែរនៅភ្នំពេញ។ សមាគមទូទៅនៃនិស្សិតខ្មែរបោះឆ្នោតជ្រើសតាំង ភោគ ឆាយ ជាប្រធាន និង ពីនី ជាអនុប្រធាន។

ខែ៤ ឆ្នាំ១៩៦៥ ពីនី បានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យភូមិន្ទរដ្ឋបាល និងបានការងារធ្វើនៅក្រសួងការបរទេសផ្នែកនយោបាយ។ ពីនី សារភាពថាបានទាក់ទងជាមួយ ស៊ុម ម៉ានិត ហើយបានចូលរួមក្នុងអង្គការសេ.អ៊ី.អា តាមរយៈ ស៊ុម ម៉ានិត ដោយមាន អុង ឃុយគ្រេង ទទួលស្គាល់ និង វ៉ា គិមហុង ជាអ្នកដឹងឮ។ ក្នុងការធ្វើសកម្មភាពបម្រើឲ្យសេ.អ៊ី.អា ពីនី ទទួលបានប្រាក់បៀវត្សរ៍១ម៉ឺនរៀលក្នុងមួយខែ។ បន្ទាប់មក ពីនី បានទាក់ទង ធុច វុធី ទីប្រឹក្សាទូតប្រចាំនៅអង្គការសហប្រជាជាតិ (ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ធុច វុធី មានតួនាទីជាឯកអគ្គរដ្ឋទូតនៅអាមេរិកខាងត្បូង)។ កម្លាំងដំបូងដែល ពីនី កសាងចូលជាសេ.អ៊ី.អា គឺកម្លាំងនៅក្នុងអង្គការស្ដេសនិងប្រជាចលនាដែល ពីនី កសាងបានក្នុងពេលមុន។

ពីនី បានសារភាពបន្តថា ក្រោយពីចាប់កំណើតបានមួយរយៈ សមាគមទូទៅនៃនិស្សិតខ្មែរមានការទាក់ទងជាហូរហែជាមួយស្ថានទូតចិននៅភ្នំពេញ។ សមាគមនេះបានយកឯកសារពីប្រទេសចិន និងបទនិពន្ធរបស់ ម៉ៅ សេ ទុង ទៅដាក់នៅបន្ទប់អានរបស់សមាគម។ អ្នកដែលចេញមុខខ្លាំងក្នុងការងារនេះគឺ ភោគ ឆាយ, ទូន សុខផល្លា និង ឈុន សុខងួន។ នៅចុងឆ្នាំ១៩៦៥ អុង ឃុយគ្រេង ផ្លាស់ទៅធ្វើការនៅប្រទេសបារាំង។ ពីនី ក៏ទាក់ទងជាមួយ អៀម កាឌុល (នាយកការិយាល័យក្រសួងសន្តិសុខ) ទិត ហួន និង វ៉ាន់ ស (ធ្វើការនៅក្រសួងគិញ)។

ខែតុលា ឆ្នាំ១៩៦៦ ភោគ ឆាយ ដែលនៅពេលនោះគឺជាអគ្គនាយកក្រុមហ៊ុនសូណាព្រីម បានហៅ ពីនី ឲ្យទៅធ្វើការនៅក្រុមហ៊ុនសូណាព្រីមជាមួយគាត់ ប៉ុន្ដែ ពីនី ជាប់ទៅធ្វើកម្មសិក្សានៅប្រទេសបារាំង។ ទម្រាំតែ ពីនី ត្រឡប់មកពីប្រទេសបារាំងវិញនៅខែ៤ ឆ្នាំ១៩៦៧ ភោគ ឆាយ បានលាឈប់ពីក្រុមហ៊ុនសូណាព្រីមរួចទៅហើយ។ ដល់ខែ៨ ឆ្នាំ១៩៦៨ ពីនី ក៏ត្រូវផ្លាស់ទៅធ្វើលេខាស្ថានទូតខ្មែរប្រចាំនៅប្រទេសបារាំង។

## រយៈកាលបំពេញការងារនៅប្រទេសបារាំង (១៩៦៦-១៩៧០)

ចម្លើយសារភាពរបស់ វ៉ាន់ ពីនី ពុំបាននិយាយលម្អិតអំពីសកម្មភាពសំខាន់ៗនៅប្រទេសបារាំងទេ។ នៅក្នុងចម្លើយ

សារភាពលើកទី៣ និយាយអំពីការបង្កើតរណសិរ្សនៅប្រទេសបារាំងបន្ទាប់ពីសម្តេច នរោត្តម សីហនុ ប្រកាសពីទីក្រុងប៉េកាំងនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ថាឲ្យមានការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា គឺរយៈពេល៥ថ្ងៃបន្ទាប់ពីលោកសេនាប្រមុខ លន់ ណុល បានធ្វើរដ្ឋប្រហារទម្លាក់ទ្រង់ចេញពីរាជបល្ល័ង្ក ។ ពីនី បានសរសេរថា ការបង្កើតរណសិរ្សនៅប្រទេសបារាំងមានទំនាស់ខ្លះក្នុងជួរនិស្សិតនៃសហព័ន្ធនិស្សិតខ្មែរ UEK (*Union des Etudiants Khmers*) ព្រោះ ពីនី គិតថា UEK ជាប់និន្នាការជាមួយបក្សកុម្មុយនិស្តបារាំង ។ ហេតុដូច្នេះ ពីនី ក៏ប្រមូលគ្នាបង្កើត UEK ដែលមាននិន្នាការលម្អៀងទៅខាងចិន ដូចជាសមាគមទូទៅនៃនិស្សិតខ្មែរ AGEK (*Association Generale des Etudiants Khmers*) នៅភ្នំពេញដែរ ។ UEK គ្រាន់តែចាត់តាំងជាការិយាល័យបណ្តោះអាសន្នដែលមាន ចាន់ យូរ៉ាន់ ជាប្រធាន វ៉ាន់ ពីនី ជាអនុប្រធាន និង អ៊ិន សុភាព ជាអគ្គលេខា ។ UEK បានបោះពុម្ពផ្សាយជាសម្ងាត់នូវព្រឹត្តិបត្រមួយដោយមានជំនួយខបត្តម្ភផ្នែកថវិកាពីស្ថានទូតចិនប្រចាំនៅទីក្រុងប៉ារីស ។ ការិយាល័យរណសិរ្សទើបតែដំណើរការបានមួយរយៈខ្លី ស្រាប់តែ ឌិក សាគុន បង្ហាញក្រឹត្យតែងតាំងពីទីក្រុងប៉េកាំងដែលបញ្ជាក់ថាខ្លួនគាត់ត្រូវបានតែងតាំងជាតំណាងរណសិរ្សប្រចាំនៅប្រទេសបារាំង ។ ដូច្នេះសកម្មភាពរបស់ ពីនី ក៏ត្រូវបានបញ្ចប់ ។ ពីនី ក៏ធ្វើដំណើរមកទីក្រុងប៉េកាំងនៅពាក់កណ្តាលខែតុលា ឆ្នាំ១៩៧០ ។

## រយៈកាលធ្វើការនៅប៉េកាំង (១៩៧០-១៩៧៥)

ពាក់កណ្តាលខែតុលា ឆ្នាំ១៩៧០ ពីនី បានចេញទៅទីក្រុងប៉េកាំង ទទួលតួនាទីជាអនុរដ្ឋមន្ត្រីក្រសួងការបរទេស ដោយមានការចាត់តាំងពីរណសិរ្សរួបរួមជាតិកម្ពុជា ។ ពីនី បានសរសេរក្នុងចម្លើយសារភាពថា ខ្លួនបានខិតខំធ្វើយ៉ាងណាដើម្បីផ្តាច់ក្រសួងការបរទេសឲ្យដាច់ពីផ្នែកឯទៀតនៃរណសិរ្សនៅទីក្រុងប៉េកាំង ដើម្បីងាយស្រួលបញ្ចូលកម្លាំងរបស់ខ្លួននិងធ្វើសកម្មភាពសម្ងាត់ក្នុងការទាក់ទងក្នុងនិងក្រៅប្រទេស ។ នៅទីក្រុងប៉េកាំង ពីនី ប្រមូលពត៌មានពីមជ្ឈដ្ឋានជុំវិញខ្លួនដោយមាន កែ មាស ជាជំនួយការដ៏សំខាន់ ។ ក្នុងពេលនោះ កែ មាស គឺជាអគ្គរដ្ឋទូតរណសិរ្សរួបរួមជាតិប្រចាំនៅទីក្រុងប៉េកាំង និងមានការទាក់ទងច្រើនជាមួយទូតបរទេសផងៗ មិនតែប៉ុណ្ណោះសោត កែ មាស ជាមនុស្សជំនិតរបស់សម្តេច នរោត្តម សីហនុ ថែមទៀត ។

ពីនី បានសរសេរថា នៅដើមឆ្នាំ១៩៧១ សម្តេច នរោត្តម សីហនុ កាន់តែបង្ហាញភាពធុញថប់ក្នុងការដែលត្រូវស្នាក់នៅទីក្រុងប៉េកាំងតទៅទៀត ។ ឯអ្នកដឹកនាំរណសិរ្សនៅក្នុងប្រទេស ចង់ឲ្យសម្តេច នរោត្តម សីហនុ និងរដ្ឋមន្ត្រីដែលនៅខាងក្រៅប្រទេស មករស់នៅជួបជុំគ្នានៅទីក្រុងប៉េកាំងទាំងអស់ ដើម្បីផ្តល់លក្ខណៈសម្បត្តិគ្រប់យ៉ាងដល់ការដឹកនាំចលនាតស៊ូនៅក្រៅប្រទេស ។

ពីនី បានរៀបរាប់បន្តថា នៅខែមករា ឆ្នាំ១៩៧១ អៀង សារី បានធ្វើដំណើរទៅទីក្រុងប៉េកាំងដោយសម្ងាត់ ។ បេសកកម្មរបស់ អៀង សារី នៅពេលនោះគឺមករាយការណ៍ឲ្យរណសិរ្សក្រៅប្រទេសអំពីសភាពការណ៍តស៊ូនៅក្នុងប្រទេសលើគ្រប់ផ្នែក ។ ពីនី បានបញ្ជាក់អំពីការគិតរបស់ខ្លួនចំពោះបេសកកម្មរបស់ អៀង សារី នៅពេលនោះថា "ខ្ញុំគិតថា ច្បាស់ជាគាត់មានបេសកកម្មអ្វីសម្ងាត់ជាមួយអ្នកដឹកនាំចិនហើយ ពិសេសចំពោះបញ្ហាជំនួយផ្សេងៗសម្រាប់បម្រើសង្គ្រាមបដិវត្តក្នុងប្រទេស" ។ នៅខែ១០ ឆ្នាំ១៩៧១ដដែល អៀង សារី បានបើកវគ្គអប់រំសមាជិករណសិរ្សនៅប៉េកាំងជាលើកដំបូង ដោយយកឯកសារពីក្នុងប្រទេសទៅប្រើប្រាស់ជាមូលដ្ឋាន និងមានឆ្លងជីវទស្សន៍ផងៗ បន្ទាប់ពីបញ្ចប់វគ្គអប់រំនេះ អៀង សារី បានណែនាំឲ្យបង្កើតគណៈកម្មាធិការរណសិរ្សនៅទីក្រុងប៉េកាំងដែលជាអង្គការមហាជនមានភារកិច្ចអប់រំមហាជន និងដោះស្រាយគ្រប់បញ្ហាទាំងអស់ក្នុងជួរមហាជន ។ ការធ្វើបែបនេះផ្ទុយនឹងផែនការរបស់ ពីនី ដែលមានបំណងឲ្យក្រសួងការបរទេសទទួលខុសត្រូវគ្រប់បែបយ៉ាង ។ ដូច្នេះ ពីនី ក៏ចាប់ផ្តើមជំទាស់គ្រប់គំនិតដែលបានស្នើឡើងដោយក្រុមរបស់ អៀង សារី ។ ប៉ុន្តែការជំទាស់ទាំងអស់មិនបានសម្រេច ។

ឆ្នាំ១៩៧២ សមាសភាពក្រុមរបស់ ពីនី មួយចំនួនត្រូវបានផ្លាស់ប្តូរ ។ យុគ ចាន់ថា ត្រូវផ្លាស់ទៅធ្វើទូតនៅប្រទេសតង់សានី ។ ប៉ែន ញ៉ាច ទៅធ្វើទូតនៅប្រទេសអេហ្ស៊ីប ។ ង៉ោ

តាំងទីតា ធ្វើការនៅប៉េកាំងបានមួយរយៈក៏ផ្លាស់ទៅប្រទេសរ៉ូម៉ានី ។ អ៊ិត ហេង ទៅបន្តវិជ្ជាពេទ្យនៅប្រទេសរ៉ូម៉ានី ។ ស្វាយ បូរី គាំ លៀងហាក់ និង លៀង ហុងសួ មកធ្វើការនៅក្រសួងការបរទេស (ចាត់តាំងឡើងដោយរណសិរ្សរួបរួមជាតិកម្ពុជា) នៅទីក្រុងប៉េកាំង ។ ហេង ពេជ និង អ៊ី ម៉ុងគាត ត្រូវចូលទៅតំបន់រំដោះនៅក្នុងប្រទេស ។ ចំណែក ទេព សំអាន ដែលទើបតែចូលមកទីក្រុងប៉េកាំងបានមួយរយៈខ្លី ក៏ត្រូវផ្លាស់ទៅប្រទេសអាល់សេរីវិញដែរ ។ នៅពាក់កណ្តាលឆ្នាំ១៩៧២ ផ្ទុះឡើងនូវទំនាស់យ៉ាងខ្លាំងក្លារវាងសម្តេច នរោត្តម សីហនុ ជាមួយនឹងខ្មែរក្រហម ប៉ុន្តែ ពីនី មិនបានបញ្ជាក់ថាដោយសារមូលហេតុអ្វីឡើយ ។ ដល់ចុងឆ្នាំ១៩៧២ អ្នកដឹកនាំចលនាតស៊ូក្នុងប្រទេសចង់តែងតាំង អៀង សារី ជាឧបនាយករដ្ឋមន្ត្រី ។ សារិន ឆាក បានស្នើជាមួយ ប៉ែន នុត និងសម្តេច នរោត្តម សីហនុ ឲ្យរារាំងគំនិតនេះ ។ ការតែងតាំង អៀង សារី ជាឧបនាយករដ្ឋមន្ត្រី ក៏ត្រូវបានផ្អាកទៅវិញ ។

តាមចម្លើយសារភាពរបស់ ពីនី ថានៅក្នុងឆ្នាំ១៩៧២នេះ ដែរថ្នាក់ដឹកនាំវៀតណាមឈ្មោះ ឡេ ឌឹកថូ បានមកជួបសម្តេច នរោត្តម សីហនុ ប៉ែន នុត និង អៀង សារី នៅទីក្រុងប៉េកាំង បំណងឲ្យមានការចចារអំពីបញ្ហាកម្ពុជាក៏ដូចជាបញ្ហាវៀតណាម ។

ពីនី បានសរសេរថា ឆ្នាំ១៩៧៣ បន្ទាប់ពីវិលត្រឡប់ពីទស្សនកិច្ចតំបន់រំដោះនៅប្រទេសកម្ពុជាវិញ សម្តេច នរោត្តម សីហនុ ចាប់ផ្តើមបង្ហាញឲ្យអ្នកនៅទីក្រុងប៉េកាំងដឹងថា ទ្រង់បានទទួលការទុកចិត្តយ៉ាងពេញទំហឹងពីសំណាក់អ្នកដឹកនាំចលនាតស៊ូក្នុងប្រទេស ហេតុនេះទ្រង់មិនចង់ឲ្យមាននរណាជាស្ពានរវាងទ្រង់និងអ្នកនៅខាងក្នុងប្រទេសទេ ។ មិនតែប៉ុណ្ណោះ ទ្រង់ថែមទាំងមិនចង់ឲ្យ អៀង សារី មានវត្តមាននៅទីក្រុងប៉េកាំងជិតទ្រង់ទៀតផង ។ ដូច្នេះនៅចុងឆ្នាំ ១៩៧៣ អៀង សារី ក៏វិលត្រឡប់ចូលក្នុងប្រទេសវិញ ។

ដើមឆ្នាំ១៩៧៤ មានការផ្ទេរតំណែងរដ្ឋមន្ត្រីដែលជាសមាជិករដ្ឋាភិបាលនៅបរទេសមួយចំនួន (ជាពិសេសអ្នកដែលធ្វើទូតផង ដូចជា ចាន់ យូរ៉ាន់ និង ហួត សម្បត្តិ ឲ្យទៅធ្វើការនៅក្នុងប្រទេសវិញ ដើម្បីស្របតាមសភាពការណ៍ជាក់ស្តែងនៃការតស៊ូនៅក្នុងប្រទេស ។ គាត ឈន់ យកសំណើពីក្នុងប្រទេសទៅថ្វាយសម្តេច នរោត្តម សីហនុ និងជូន ប៉ែន នុត នៅក័ងតុង ដើម្បីរៀបចំធ្វើក្រឹត្យមួយតែងតាំងសមាជិករដ្ឋាភិបាលថ្មីនេះជាផ្លូវការ ។ ពីនី សារភាពថាខ្លួនបានស្នើឲ្យ ពុង ប៉េងចេង អុជអាលសម្តេច នរោត្តម សីហនុ ឲ្យផ្អាកការឡាយព្រះហស្តលេខាលើក្រឹត្យនេះ ដោយសំអាងលេសថាពួកក្រហមបីនាក់នៅទីក្រុងប៉េកាំងគឺ ជួន មុម្ម, ជួន ប្រាសិទ្ធ និង គាត ឈន់ មិនទាន់បានផ្ទេរតំណែងឲ្យទៅសមាជិកថ្មីនៅក្នុងប្រទេសនៅឡើយទេ ។ បញ្ហានេះនាំឲ្យមានទំនាស់យ៉ាងខ្លាំងក្លានៅក្នុងរណសិរ្សរហូតដល់ខែ៤ ឆ្នាំ១៩៧៤ ខៀវ សំផន និង អៀង សារី ដឹកនាំគណៈប្រតិភូទៅទីក្រុងប៉េកាំងដើម្បីចរចាសម្រុះសម្រួល ទើបរឿងនេះបានស្ងប់មកវិញ ។

នៅក្នុងខែតុលា ឆ្នាំ១៩៧៤ អៀង សារី ដឹកនាំគណៈប្រតិភូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅទីក្រុងប៉េកាំង ក្នុងទិសដៅទាក់ទងខាងជំនួយនិងពាណិជ្ជកម្មជាមួយប្រទេសចិន ។ ព្រមជាមួយនេះក៏មានការទាក់ទងក្នុងការបោះពុម្ពក្រដាសប្រាក់សម្រាប់ប្រើប្រាស់ក្នុងតំបន់រំដោះ ។ នៅខែ១២ ឆ្នាំដដែល ផែនការរួមបារាំង-អាមេរិកក្នុងការទាក់ទងចរចាជាមួយសម្តេច នរោត្តម សីហនុ ហៀបតែនឹងបានសម្រេចទៅហើយ ស្រាប់តែត្រូវផ្អាកទៅវិញដោយមូលហេតុកងទ័ពបដិវត្តន៍បើកការវាយសម្រុកខ្លាំងទៅលើសមរភូមិនានានៅក្នុងប្រទេសកម្ពុជានៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥ ។ ចូលដល់ដើមឆ្នាំ១៩៧៥ អៀង សារី មានបំណងដឹកនាំគណៈប្រតិភូទៅប្រទេសជាមិត្តមួយចំនួនដើម្បីទាក់ទងសុំជំនួយជាថវិកាខ្លះ ប៉ុន្តែត្រូវបានអង្គការហៅត្រឡប់ចូលក្នុងប្រទេសវិញនៅខែ៣ ក្នុងឆ្នាំដដែលនោះ ។

## *រយៈកាលវិលមករស់នៅក្នុងប្រទេសកម្ពុជាវិញ (១៩៧៥-១៩៧៨)*

បន្ទាប់ពីខ្មែរក្រហមដណ្តើមបានអំណាចគ្រប់គ្រងប្រទេសទាំងមូល ពីនី សម្រេចចិត្តវិលមករស់នៅក្នុងប្រទេសវិញ ។ ពីនី ក៏ធ្វើដំណើរចូលក្នុងប្រទេសកម្ពុជាជាមួយសម្តេច នរោត្តម សីហនុ និង ប៉ែន នុត នៅខែ៩ ឆ្នាំ១៩៧៥ ។ អ្នកឯទៀត ក៏មកស្រុកខ្មែរតាមក្រោយជាបន្តបន្ទាប់ ។ អ្នកណាដែលមិនព្រម

ចូលក្នុងប្រទេសក៏ត្រូវក្រសួងការបរទេសហៅចូលវិញក្នុងនោះ យុគ ចាន់ថា ក៏ត្រូវបានហៅចូលក្នុងប្រទេសវិញដែរ ។ នៅក្នុងខែតុលា ឆ្នាំ១៩៧៥ អ្នកដែលមកពីទីក្រុងប៉េកាំងទាំងប៉ុន្មានត្រូវចូលរួមក្នុងវគ្គសិក្សាមួយដែលខុទ្ទេសនាមដោយ ខៀវ សំផន ។ បន្ទាប់ពីបញ្ចប់វគ្គសិក្សា សិក្ខាកាមទាំងអស់ក៏ត្រូវបានបញ្ជូនឲ្យចុះទៅមូលដ្ឋាននៅភូមិភាគពាយ័ព្យ ។ ពីនី ត្រូវបញ្ជូនទៅស្រុកថ្មគោល ធ្វើការនៅមន្ទីរកសិកម្មរដ្ឋភ្នំសំពៅ ក្រោមការគ្រប់គ្រងរបស់ប្រធានមន្ទីរឈ្មោះ ឆាំ ។ ពាក់កណ្តាលខែ១២ ពីនី ត្រូវចុះទៅច្រូតស្រូវនៅស្រែរដ្ឋភ្នំសំពៅ ។ ចប់ភារកិច្ចនេះ ពីនី មើលខុសត្រូវក្នុងការលើកភ្លឺស្រែថ្មីនៅស្រែរដ្ឋភ្នំសំពៅដដែល ។ ខែមីនា ឆ្នាំ១៩៧៦ ឆាំ ដាក់ទិសឲ្យ ពីនី ទៅលើកភ្លឺស្រែនៅស្រែរដ្ឋបឹងត្រាវ ។ ការងាររបស់ ពីនី គឺដូចជាប្រជាជនថ្មីទូទៅដែរ ។ ពេលបុណ្យឯករាជ្យនៅខែមេសា ឆ្នាំ១៩៧៦ អង្គការភូមិភាគចាត់តាំងឲ្យ ពីនី និងអតីតសមាជិករណសិរ្សដែលមកពីក្រៅប្រទេសទាំងអស់ ទៅលើកទំនប់ដីកប្រឡាយធំៗ នៅតំបន់៥ ។ ខែ៧ ឆ្នាំ១៩៧៦ អង្គការហៅ ពីនី ឡើងមករៀនសូត្រនៅក្រសួងការបទេសភ្នំពេញ ។ ចប់វគ្គរៀនសូត្រ ពីនី ត្រឡប់ទៅភូមិភាគពាយ័ព្យវិញដដែល ។ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៧៦ អង្គការដាក់ទិសឲ្យអតីតសមាជិករណសិរ្ស និងទូតដែលត្រូវបញ្ជូនទៅពាយ័ព្យនោះ ត្រឡប់មកភ្នំពេញវិញហើយឲ្យមកនៅមន្ទីរ ម-១ ប្រាំងចំរេះ ។ ពីនី បានជួបមិត្តភក្តិចាស់ៗដែលធ្វើការនៅស្ថានទូតពីមុនដូចជា សាយ បូរី, ស៊ីវ សាផុន, ប៉ែន ញ៉ាច, យុគ ចាន់ថា និង ភូរិស្សរ៉ា ។ ក្រុមគ្រួសាររបស់ទូតមួយចំនួនក៏ត្រូវបានបញ្ជូនមកទីនេះដែរ ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៧ ក្រុមដែលមកពីរណសិរ្សទាំងប៉ុន្មានត្រូវអង្គការបញ្ជូនទៅនៅមន្ទីរមួយទៀត គឺមន្ទីរ ក-១៧ ។ ពីនី ត្រូវបានតែងតាំងជាគណៈមន្ទីរ ក-១៧ ផ្នែករណសិរ្ស ។ ពីនី បានសារភាពថាបានទាក់ទងបក្ខពួកចាស់ឡើងវិញរួមនឹងកម្លាំងថ្មីមួយចំនួនទៀត ដូចជា ចែម ស្នួន, តូច ខាំឌឿន, សៀង ប៉ូសែ, ចៅ សេង និង ហោ ណាំហុង ហើយបានប្រើប្រាស់ផ្ទះរបស់ ភូរិស្សរ៉ា ដើម្បីជួបប្រជុំគ្នាពិភាក្សាអំពីការធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ។

ក្រោយពីមកដល់មន្ទីរ ក-១៧ បានចំនួន២ខែ នៅខែមេសា ឆ្នាំ១៩៧៧ ភូរិស្សរ៉ា ត្រូវអង្គការផ្លាស់ទៅកន្លែងថ្មីទៀត ។ មិនយូរប៉ុន្មាន ម៉ី ផាត់ ក៏ត្រូវអង្គការផ្លាស់ទៅកន្លែងថ្មីដែរ ប៉ុន្តែមិនដឹងថាតើអ្នកទាំងពីរត្រូវផ្លាស់ទៅទីណាទេ ។ មកដល់ខែ១១ ឆ្នាំដដែល ចៅ សេង ក៏ត្រូវអង្គការផ្លាស់ចេញ ប៉ុន្តែមិនដឹងជាទៅទីណា ។

នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៧ អង្គការបានហៅ ពីនី ឲ្យទៅធ្វើការនៅក្រសួងការបរទេស ។ ធាតុពិត ពីនី ត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១ (គុកទួលស្លែង) ។

បន្ទាប់ពីត្រូវនាំខ្លួនមកដល់មន្ទីរ ស-២១ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ការសួរចម្លើយ ពីនី ក៏ប្រព្រឹត្តទៅនៅថ្ងៃនោះភ្លាមនិងថ្ងៃបន្តបន្ទាប់ទៀត ដែលសរុបទាំងអស់មានចំនួន៥លើក ។ បន្ទាប់មក ពីនី ត្រូវបានអង្គការយកទៅកម្ទេចចោល ។

ក្នុងសភាពហាក់ដូចជាស្រឡាំងកាំងដោយត្រូវអង្គការបោកបញ្ឆោត ចម្លើយសារភាពលើកទី១របស់ ពីនី មិនបានរៀបរាប់លម្អិតអំពីសកម្មភាពក្បត់តាមដែលអង្គការចង់បានទេ ។ ផ្ទុយទៅវិញ ពីនី បានសម្តែងនូវការភ្ញាក់រឭកនិងសោកស្តាយចំពោះកំហុសឆ្គងដែលបានប្រព្រឹត្តក្នុងរយៈកាលកន្លងមក និងអង្វរករសុំក្តីមេត្តាប្រណីទោសពីបក្ស ដែលមានឃ្លាប្រយោគដូចតទៅ÷

“ជាថ្មីម្តងទៀតខ្ញុំសុំសារភាពថា សកម្មភាពខ្ញុំកន្លងមកនៅប្រទេសបារាំងក្តី នៅប្រទេសចិនក្តី ជាសកម្មភាពខ្មាំងដែលប៉ះពាល់ពេញទីដល់ចលនាបដិវត្ត ។ ទោសនេះធ្ងន់ណាស់ ហើយចំពោះបញ្ហាផ្សេងទៀតដែលបក្សពិនិត្យឃើញទៀត ខ្ញុំសុំទទួលទាំងអស់ ។ ឈរលើជំនឿជាក់លើការដឹកនាំដ៏ត្រឹមត្រូវនិងភ្លឺស្វាងរបស់បក្ស និងជំហរស្មោះត្រង់ដាច់ខាតចំពោះបក្សដែលខ្ញុំបានកសាងជាបន្តបន្ទាប់តាំងពីចូលមកប្រទេស ខ្ញុំសុំបក្សអនុគ្រោះឲ្យយើងខ្ញុំមានជីវិតតទៅទៀត ដើម្បីបម្រើបក្ស បម្រើប្រជាជនរហូតអវសាននៃជីវិត” ។

នៅលើឯកសារចម្លើយសារភាពលើកទី១របស់ ពីនី មានចំណាររបស់ ចាន់ ប្រធានក្រុមសួរចម្លើយនៅមន្ទីរ ស-២១ ដែលសរសេរថា “ចម្លើយវាមិនទាន់ **(តទៅទំព័រទី៤២)**

# រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម

ក្រុមដែនទីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរទៅខេត្តកំពង់ចាមកាលពីខែឧសភា ឆ្នាំ២០០០ ដើម្បីធ្វើការស្រាវជ្រាវបន្តលើស្រុកចំនួនបីគឺ ស្រុកចម្ការលើ ស្រុកព្រៃឈរ និងស្រុកបាធាយ ។

## ស្រុកចម្ការលើ

**១) ទីតាំងសម្លាប់ និង មន្ទីរសន្តិសុខនៅចម្ការស្វាយចន្ទី លេខកូដភូមិសាស្ត្រ ០៣០២០៧,០៣០២០៨**

ចម្ការស្វាយចន្ទីមានចម្ងាយប្រហែល២០០ម៉ែត្រទិសខាងលិចសាលារៀនស្វាយទាបដែលស្ថិតនៅក្នុងភូមិវាលវីលិច ឃុំស្វាយទាប ស្រុកចម្ការលើ ខេត្តកំពង់ចាម និងមានទំហំដីចំនួនប្រហែល៤ហិកតា ។ ព្រៃឫស្សីក្រាស់ឃ្មឹកបាននិងកំពុងដុះជារបងនៃចម្ការនេះ ។ បច្ចុប្បន្នចម្ការស្វាយចន្ទីត្រូវបានប្រែក្លាយទៅជាដីដំណាំល្ង ល្ហុង ស្វាយ ម៉ាក់ប្រេង និងម៉ាក់ប្រាង ។ ទីតាំងនេះត្រូវបានកត់ទុកតាមរយៈម៉ាស៊ីនកត់ត្រាទីតាំងពិភពលោកតាមផ្កាយរណបនូវចំណុចខ្សែស្រប N: ១២° ១៧' ២៦ៈ១២" និងរយៈបណ្តោយ E: ១០៥° ១៦' ៣១ៈ៨៥" ។ នៅលើទំហំដីដ៏ធំល្វឹងល្វើយនៃចម្ការមិនបានបន្សល់ស្លាកស្នាមច្បាស់លាស់ឡើយ ។ ចំណែកឯវត្ថុតាងនៃការសម្លាប់ក៏មិនមានសេសសល់ដែរ ។ ក្នុងអំឡុងពេលខ្មែរក្រហមកាន់អំណាច ចម្ការស្វាយចន្ទីត្រូវបានយកធ្វើជាមន្ទីរសន្តិសុខនិងជាកន្លែងពិឃាតមនុស្សយ៉ាងព្រៃផ្សៃបំផុត ។ ប្រធានឃុំស្វាយទាបឈ្មោះលោក គឹង យ៉ាត អាយុ៥១ឆ្នាំ បាននិយាយថាក្នុងចន្លោះពីឆ្នាំ១៩៧៥ និងពាក់កណ្តាលឆ្នាំ១៩៧៨ ចម្ការស្វាយចន្ទីក្លាយជាមន្ទីរសន្តិសុខប្រចាំឃុំស្វាយទាប បន្ទាប់ពីរយៈពេលនោះរហូតមកដល់ជិតបែកឆ្នាំ១៩៧៩ ចម្ការស្វាយចន្ទីជាកន្លែងសម្លាប់មនុស្សយ៉ាងសាហាវបំផុត ។ លោក លី ឃិន អាយុ៥៦ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិវាលវីលិច ឃុំស្វាយទាប ស្រុកចម្ការលើ បានរៀបរាប់ថា តាំងពីខែមិថុនា ឆ្នាំ១៩៧៥ ដល់ពាក់កណ្តាលឆ្នាំ១៩៧៨ មន្ទីរសន្តិសុខចម្ការស្វាយចន្ទីបានឃុំឃាំងមនុស្សច្រើនតែប្រភេទអ្នកជាប់និន្នាការនយោបាយតាំងពីជំនាន់ សីហនុ លន់ណុល អ្នកមិនមកធ្វើការ និងអ្នកខុសសីលធម៌ ។


ឡុង សុខខៃ

លោក ឡុង សុខខៃ អាយុ៥១ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិវាវីកើត ឃុំស្វាយទាប បាននិយាយថា នៅខែជេស្ឋបុអាសាឍ (ខែ៦-៧) ក្នុងឆ្នាំ១៩៧៨ ប្រជាជននៅតាមភូមិជាច្រើនក្នុងឃុំស្វាយទាប ដូចជាភូមិចិន ភូមិត្រពាំងបេង ភូមិព្រឹក្ស ត្រូវបានខ្មែរក្រហមបញ្ឆោតឲ្យមកចម្ការស្វាយចន្ទី រួចហើយក៏ត្រូវបានសម្លាប់ចោលទាំងយប់តែម្តង ។ លោក សុខខៃ ប្រាប់ថា កាលនោះខ្លួនគាត់ត្រូវបានប្រធានកង (មិនស្គាល់ឈ្មោះ) បញ្ជាឲ្យមកយាមនៅទិសខាងលិច


ធ្មេញរបស់ជនរងគ្រោះដែលនៅសេសសល់ក្នុងរណ្តៅ

ចម្ការស្វាយចន្ទី (ជាប់របងឫស្សី) ។ លោក សុខខៃ បានឮស្នូរកាប់ដីនៅក្នុងចម្ការ ហើយបានលបមើលឃើញហេតុការណ៍សម្លាប់មនុស្សនាយប់នោះ ។

ខ្មែរក្រហមបានអនុវត្តការសម្លាប់ជាបីដំណាក់កាលគឺ÷

◆ ដំណាក់កាលទី១៖ យកជនជាតិវៀតណាមនិងអ្នកជាប់ខ្សែវៀតណាមមកសម្លាប់មុន ។

◆ ដំណាក់កាលទី២៖ យកប្រជាជនខ្មែរជាបុរសដែលមានមាឌធំមាំៗមកសម្លាប់ ដោយបញ្ឆោតថាឲ្យមកជួយរៀបចំផ្ទះ ។ ក្រោយមកក៏យកទាំងគ្រួសារប្រពន្ធកូនមកសម្លាប់តាមក្រោយទៀត ដោយប្រាប់ថាឲ្យមកជួបជុំគ្រួសារ ។

◆ ដំណាក់កាលទី៣៖ យកប្រជាជនគ្រប់ភូមិក្នុងឃុំស្វាយទាបមកសម្លាប់រួម ។

ចំពោះវិធីសម្លាប់ លោក សុខខៃ អធិប្បាយថា “ជនរងគ្រោះត្រូវបានចងស្លាបសេក រួចឲ្យលុតជង្គង់នៅមាត់រណ្តៅជាជួរៗ បន្ទាប់មកពួកខ្មែរក្រហមប្រើដែកបំពង់ទឹប គល់ឫស្សី ឬពូថៅ វាយសម្លាប់ជនរងគ្រោះម្នាក់ទៅក្នុងរណ្តៅ ។ រយៈពេលនៃការសម្លាប់គឺឆាប់បំផុត” ។ លោក សុខខៃ បញ្ជាក់ថា “សូម្បីតែកងចល័តជាង២០០នាក់ក៏ប្រើរយៈពេលសម្លាប់តែមួយថ្ងៃ ។ ប្រជាជនក្នុងភូមិទាំង១៣ក្នុងឃុំស្វាយទាប ក៏ប្រើរយៈពេលសម្លាប់តែមួយថ្ងៃ” ។


ហម គីមស្ងួត៍

លោក ហម គីមស្ងួត៍ អាយុ ៥៩ឆ្នាំ បច្ចុប្បន្នជាប្រធានភូមិវាលរីកើត ក៏បានឲ្យដឹងថា ខ្មែរក្រហមបានបញ្ជាឲ្យគាត់ដឹកមនុស្សចេញពីភូមិថ្នល់បែកកើត ឆ្ពោះទៅទីតាំងសម្លាប់មនុស្សនៅចម្ការស្វាយចន្ទី ប៉ុន្តែគាត់ដឹកបានតែចម្ងាយ៣០-៤០ម៉ែត្រពីភូមិប៉ុណ្ណោះ ក៏មានគណៈកងផ្សេងមកដឹកមនុស្សបន្តទៅចម្ការស្វាយចន្ទី ។

លោកឈុន ឡា ជាប៉ូលិសស្រុកចម្ការលើ បាននិយាយថា កាលពីជំនាន់ ប៉ុល ពត គាត់បានឃើញខ្មែរក្រហមចងមនុស្សអូសយកទៅសម្លាប់នៅចម្ការស្វាយចន្ទី ។ តាមការមើលឃើញរបស់លោក ឈុន ឡា ខ្មែរក្រហមបានប្រើពូថៅដែលមាន


ឈុន ឡា

ផ្លែវែងជងខ្ទីជាឧបករណ៍សម្លាប់មនុស្ស ។

អំពីរណ្តៅនិងចំនួនសាកសព លោក សុខខៃ ប្រាប់ថា ជនរងគ្រោះដែលបានស្លាប់នៅចម្ការស្វាយចន្ទី មានចំនួនប្រមាណ ពី៥០០០ ទៅ ៧០០០នាក់ ។ មានរណ្តៅធំៗចំនួនបី ដែលរណ្តៅនីមួយៗមានទំហំទទឹង២ម៉ែត្រ និងបណ្តោយ៣០ម៉ែត្រ មានគម្លាតពីគ្នា៥ម៉ែត្រ រៀងគ្នាតាមបណ្តោយរបងឫស្សីជ្រុងខាងលិចចម្ការ និងមានរណ្តៅតូចៗជាច្រើនទៀតដែលអាចដាក់ជនរងគ្រោះបានពី២ទៅ៥នាក់ក្នុងមួយរណ្តៅ ។ ក្រៅពីនេះ មានរណ្តៅបីផ្សេងទៀតជារណ្តៅគ្រាប់បែក ។ រណ្តៅនីមួយៗមានអង្កត់ផ្ចិតប្រវែង៥ទៅ៦ម៉ែត្រ ជម្រៅ២ម៉ែត្រ និងមានសាកសពជនរងគ្រោះជាង២០០នាក់ ។ សាកសពនៅក្នុងរណ្តៅគ្រាប់បែកសុទ្ធសឹងជាសមាជិកកងចល័តដែលត្រូវខ្មែរក្រហមយកមកសម្លាប់មុនប្រជាជនក្នុងឃុំស្វាយទាប ។

អដ្ឋិធាតុជនរងគ្រោះនៅចម្ការស្វាយចន្ទីត្រូវបានប្រជាជនជីកគាស់ចេញពីរណ្តៅ រួចហើយសង់ជាកូនខ្ទមដាក់នៅក្បែរមាត់រណ្តៅធំនោះ ។ បច្ចុប្បន្នអដ្ឋិធាតុទាំងនោះត្រូវបានបាត់បង់អស់ទៅហើយ ដោយមូលហេតុពុំមានលទ្ធភាពក្នុងការថែរក្សា ។

**ផេង ពង្សរ៉ាស៊ី**

# សេចក្តីកែតម្រូវ

ទស្សនាវដ្តី “ស្វែងរកការពិត” លេខ១៦ ខែមេសា ឆ្នាំ២០០១ ទំព័រទី៧ អត្ថបទស្តីអំពី “រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម” កូឡោនទី១ បន្ទាត់ខាងក្រោមបង្អស់ដែលសរសេរថា “ទីតាំងនេះស្ថិតនៅក្នុងភូមិពព្រេង ឃុំស្ពឺ ស្រុកកំពង់ចាម” សូមកែថា “ទីតាំងនេះស្ថិតនៅក្នុងភូមិពព្រេង ឃុំស្ពឺ ស្រុកចម្ការលើ ខេត្តកំពង់ចាម” វិញ ។

សូមអរគុណ

## សុន្ទរកថារបស់សមមិត្ត សុន សេន សមាជិកត្រៀមនៃគណៈកម្មាធិការអចិន្ត្រៃយ៍ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងកិច្ចការការពារប្រទេស ប្រធានគណៈកម្មាធិការនៃអគ្គលេខាធិការកងទ័ពបដិវត្តន៍កម្ពុជា ប្រធានគណៈប្រតិភូយោធានៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ក្នុងឱកាសពិធីជប់លៀងស្វាគមន៍ គាក់តែងដោយ សមមិត្ត ស៊ី សៀង សៀន អនុប្រធានគណៈកម្មការយោធានៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារប្រទេសនៃសាធារណរដ្ឋប្រជាមានិតចិន

*ប៉េកាំង ខែកក្កដា ឆ្នាំ១៩៧៨*

*សមមិត្តអនុប្រធាន តឹង ស៊ាវ ភីង ជាទីគោរពស្នេហា*

*សមមិត្តឧបនាយករដ្ឋមន្ត្រី ស៊ី សៀង សៀន ជាទីគោរពស្នេហា*

*សមមិត្តអ្នកដឹកនាំ និងកម្មាភិបាលកងទ័ពរំដោះប្រជាជនចិន ជាទីស្នេហា*

*សមមិត្តនិងមិត្តទាំងឡាយជាទីស្នេហា*

*គណៈប្រតិភូយោធានៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ យើងខ្ញុំមានបីតិសោមនស្សរីករាយក្រៃលែងដោយបានមកដល់ទឹកដីដ៏រុងរឿងនៃប្រទេសចិនជាបងប្អូន ពាំនាំជាមួយនូវមនោសញ្ចេតនាមិត្តភាពបដិវត្ត និងទឹកចិត្តស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅបំផុតរបស់ប្រជាជនកម្ពុជា យុទ្ធជន យុទ្ធនារី និងកម្មាភិបាលនៃកងទ័ពបដិវត្តកម្ពុជា មកជូនដល់វីរកងទ័ពរំដោះប្រជាជនចិន និងប្រជាជនចិនជាបងប្អូន និងជាយុទ្ធមិត្ត ។*

*យើងខ្ញុំរំភើបក្នុងចិត្តណាស់ដោយមកដល់រដ្ឋធានីប៉េកាំងភ្លាមយើងខ្ញុំបានទទួលបដិសណ្ឋារកិច្ច និងពរស្វាគមន៍យ៉ាងស្និទ្ធស្នាលកក់ក្តៅបំផុត ក្នុងឋានៈជាយុទ្ធមិត្តផង ជាបងប្អូនវណ្ណៈផងពីសំណាក់សមមិត្តអនុប្រធាន តឹង ស៊ាវ ភីង សមមិត្តឧបនាយក ស៊ី សៀង សៀន សមមិត្តអ្នកដឹកនាំកងទ័ពរំដោះប្រជាជនចិនព្រមទាំងពីសំណាក់យុទ្ធមិត្តចិនជាច្រើនឯទៀត និងប្រជាជនចិន ។*

*យប់នេះទៀត គណៈកម្មការយោធានៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន និងក្រុមប្រឹក្សាកិច្ចការរដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន ក៏បានតាក់តែងពិធីជប់លៀងស្វាគមន៍យ៉ាងស្និទ្ធស្នាលកក់ក្តៅ និងយ៉ាងឱឡារិក ជូនជាកិត្តិយសដល់គណៈប្រតិភូយើងខ្ញុំ ហើយអម្បាញ់មិញ សមមិត្តឧបនាយក ស៊ី សៀង សៀន ក៏បានថ្លែងសុន្ទរកថាពោរពេញទៅដោយមនោសញ្ចេតនាភាតរៈបដិវត្តយ៉ាងកក់ក្តៅនិងជ្រាលជ្រៅបំផុត វាយតម្លៃខ្ពស់ លើកទឹកចិត្ត និងឧបត្ថម្ភគាំទ្រយ៉ាងខ្លាំងក្លាដល់ការតស៊ូបច្ចុប្បន្នរបស់កងទ័ពបដិវត្តន៍កម្ពុជាយើងខ្ញុំ និងប្រជាជនកម្ពុជាយើងខ្ញុំ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សកុម្មុយនិស្តកម្ពុជានិងសមមិត្តលេខា ប៉ុល ពត ។*

*ចំពោះប្រការទាំងនេះ ក្នុងនាមបក្សកុម្មុយនិស្តកម្ពុជា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ កងទ័ពបដិវត្តកម្ពុជា និងប្រជាជនកម្ពុជា យើងខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះបក្សកុម្មុយនិស្តចិន រដ្ឋាភិបាលកងទ័ពរំដោះប្រជាជនចិន និងប្រជាជនចិន ដែលមានសមមិត្តប្រធាន ហ្វា គួហ្វឹង ជាអគ្គមគ្គុទ្ទេសក៍ដ៏ភ្លឺស្វាង ។*

សមមិត្តនិងមិត្តទាំងឡាយជាទីស្នេហា

ទស្សនកិច្ចរបស់គណៈប្រតិភូយើងខ្ញុំពេលនេះប្រព្រឹត្តឡើង ចំពេលដែលទ័ពរំដោះប្រជាជាតិប្រារព្វខួបទី៥១នៃកំណើតរបស់ខ្លួន ។ យើងខ្ញុំសូមឆ្លៀតឱកាសដ៏ប្រសើរនេះសូមប្រសិទ្ធិពរជូនចំពោះកងទ័ពរំដោះប្រជាជនចិន ជាយុទ្ធមិត្តជិតស្និទ្ធបំផុតរបស់យើងខ្ញុំ សូមទទួលជ័យជំនះដ៏ត្រចះត្រចង់ថ្មីទៀតក្នុងភារកិច្ចបដិវត្តដ៏ខ្ពង់ខ្ពស់របស់ខ្លួន ។

ម្យ៉ាងទៀត បុណ្យខួបនេះក៏ជាឱកាសឲ្យយើងខ្ញុំរំឭកឡើងវិញ និងរៀនសូត្រពីប្រវត្តិដ៏រុងរឿងរបស់កងទ័ពរំដោះប្រជាជនចិន ក្រោមការដឹកនាំរបស់សមមិត្តប្រធាន ម៉ៅ សេ ទុង អគ្គមគ្គុទ្ទេសក៍ដ៏មហិមានិងមហស្ចារ្យរបស់ប្រជាជនចិនក្នុងរយៈកាល៥១ឆ្នាំកន្លងទៅនេះ ។

កងទ័ពរំដោះប្រជាជនចិនដែលសមមិត្តប្រធាន ម៉ៅ បានបង្កើតឡើងនិងអប់រំថែបំប៉នដោយផ្ទាល់ បានរីកធំធាត់យ៉ាងឆាប់រហ័សលើគ្រប់ផ្នែក សតិអារម្មណ៍ នយោបាយ ចាត់តាំង និងបច្ចេកទេសប្រយុទ្ធ ហើយបានលត់ដំនិងសាកល្បងជាច្រើនលើកច្រើនគ្រាក្នុងភ្លក់ភ្លើងដ៏ក្តៅគគុកនៃការតស៊ូបដិវត្តដ៏សន្ធោសន្ធៅនិងយូរលង់ ហើយបានប្រែក្លាយទៅជាកងកម្លាំងប្រដាប់អាវុធបដិវត្តដ៏មហិមាខ្លាំងពូកែ ជាកំពែងថែបដែលការពារបានទាំងស្រុងនូវអធិបតេយ្យភាពនិងបូរណភាពដែនដីនៃសាធារណរដ្ឋប្រជាមានិតចិន ។

កងទ័ពរំដោះប្រជាជនចិនបង្កើតបាននូវស្នាដៃដ៏មហិមានិងគុណបំណាច់ជាច្រើន ផ្តល់វិភាគទានដ៏ថ្លៃថ្លារបស់ខ្លួនក្នុងការសម្រេចជ័យជំនះនៃបដិវត្តប្រជាធិបតេយ្យថ្មីនៅប្រទេសចិន ។ ក្រោយពីសាធារណរដ្ឋប្រជាមានិតចិនចាប់បដិសន្ធិ កងទ័ពរំដោះប្រជាជនចិនបានវាយកម្ទេចជាបន្តបន្ទាប់អំពើបង្ករឿងនិងរំលោភឈ្លានពានរបស់កម្លាំងវាតទីនិយម ចក្រពត្តិនិយម និងបក្ខពួក ។ ព្រមជាមួយនេះ កងទ័ពរំដោះប្រជាជនចិនបានបំពេញតួនាទីរបស់ខ្លួនជាឧបករណ៍ប្រដាប់អាវុធនៃផ្តាច់ការវណ្ណៈអធនយ៉ាងត្រឹមត្រូវនិងស័ក្តិសិទ្ធិបំផុត ធានារ៉ាប់រងដោយជោគជ័យដល់កិច្ចការបន្តធ្វើបដិវត្តន៍សង្គមនិយមនិងការកសាងសង្គមនិយម ។

ខ្មាំងសត្រូវណាជាវាតទីនិយម ជាចក្រពត្តិនិយម ឬជាបក្ខពួកវា ហ៊ានចូលមករំលោភឈ្លានពានសាធារណរដ្ឋប្រជាមានិតចិន ប្រាកដជាត្រូវខ្ទេចខ្ទីវិនាសអន្តរាយមិនខានឡើយ ។ ជនលោភលន់ឬក្បត់បដិវត្តណាចង់វាយរំលំរបបផ្តាច់ការវណ្ណៈអធន ចង់ប្លន់អំណាចក្នុងបក្សឬក្នុងកងទ័ព ប្រាកដជាទទួលបរាជ័យយ៉ាងអាម៉ាស់មិនខាន ដោយត្រូវកងទ័ពរំដោះប្រជាជនចិនវាយកម្ទេច និងវាយកម្ចាត់ ។

បច្ចុប្បន្ននេះ ក្រោមការដឹកនាំដ៏ត្រឹមត្រូវនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន និងគណៈកម្មការយោធានៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន ដែលមានសមមិត្តប្រធាន ហ្វា គួ ហ្វឹង ជាអគ្គមគ្គុទ្ទេសក៍ និងជាអគ្គបញ្ជាការដ៏ភ្លឺស្វាង កងទ័ពរំដោះប្រជាជនចិនកំពុងជ្រោងទង់បដិវត្តដ៏មហិមារបស់សមមិត្តប្រធាន ម៉ៅ សេ ទុង បន្តអនុវត្តគោលការណ៍ជាយុទ្ធសាស្ត្រដែលថាត្រូវគ្រប់គ្រងរដ្ឋ និងដឹកនាំកងទ័ពដោយយកការតស៊ូវណ្ណៈជាស្នូល បន្តជំរុញចលនាមហាជន រៀនសូត្រតាមឡឺ ហ្វឹង តាមកងអនុសេនាធំលេខ៦ និងតាមកងពលអាកាសលេខ១ ជំរុញទិសបដិវត្តភាវូបនីយកម្ម និងទំនើបភាវូបនីយកម្មក្នុងកងទ័ព ត្រៀមរៀបចំសង្គ្រាម ត្រៀមរៀបចំរំដោះតៃវ៉ាន់ ។

ក្រោមពន្លឺដ៏ត្រចះត្រចង់នៃមាគ៌ាបដិវត្តរបស់សមមិត្តប្រធាន ម៉ៅ និងក្រោមការដឹកនាំនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន និងសមមិត្តប្រធាន ហ្វា កងទ័ពរំដោះប្រជាជនចិនកំពុងរួមចំណែកយ៉ាងខ្លាំងក្លាជាមួយប្រជាជនចិនទាំងមូល បន្តធ្វើបដិវត្តន៍ក្រោមផ្តាច់ការវណ្ណៈអធនដើម្បីសម្រេចភារកិច្ចបដិវត្តដ៏ឧត្តុង្គឧត្តមដែលមហាសន្និបាតលើកទី១១នៃបក្សកុម្មុយនិស្តចិន និងមហាសន្និបាតលើកទី៥នៃសភាតំណាងប្រជាជនទូទាំងប្រទេសចិន បានលើកឡើងសម្រាប់រយៈកាលថ្មីនៃបដិវត្តសង្គមនិយម និងការកសាងសង្គមនិយម ។ ការបញ្ចប់ដោយមហាជោគជ័យនូវមហាបដិវត្តវប្បធម៌វណ្ណៈអធនលើកទី១ ដែលពង្រឹងទីតាំងផ្តាច់ការវណ្ណៈអធនដោយវាយកម្ទេចទីបញ្ជាការនាយទុនជាបន្តបន្ទាប់ ពិសេសក្រុម៤នាក់បានជំរុញចលនាបដិវត្តធំ៣ និងចលនាមហាជន រៀនសូត្រតាមកងផលិតធំតាចាយខាងកសិកម្ម រៀនសូត្រតាមអណ្តូងប្រេងតាឈីងខាងឧស្សាហកម្ម ឲ្យមានសន្ទុះផុសផុលក្លៀវក្លាទូទាំងប្រទេស ។

សភាពការណ៍ដ៏ល្អប្រសើរនេះ រឹតតែធ្វើឲ្យយើងខ្ញុំមានជំនឿជឿជាក់លើជ័យជំនះដ៏ត្រចះត្រចង់ថ្មីៗទៀតរបស់ប្រជាជនចិន និងកងទ័ពរំដោះប្រជាជនចិន ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សកុម្មុយនិស្តចិន និងសមមិត្តប្រធាន ហ្វា គួ ហ្វឹង ដែលប្រាកដជាសម្រេចទំនើបភាវូបនីយកម្ម៤យ៉ាង កសាងប្រទេសចិនឲ្យទៅជាប្រទេសសង្គមនិយមមហិមាខ្លាំងពូកែ និងទំនើបនៅមុនដំណាច់សតវត្សរ៍នេះ ។

យើងខ្ញុំរីករាយពេញចិត្តណាស់ដោយឃើញថាកិត្យានុភាពនៃសាធារណរដ្ឋប្រជាមានិតចិនឡើងខ្ពស់ត្រដែតត្រដឹមលើឆាកអន្តរជាតិ ។ បក្សកុម្មុយនិស្តចិននិងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិនបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននិងត្រឹមត្រូវបំផុតនូវមាគ៌ាបដិវត្តរបស់សមមិត្តប្រធាន ម៉ៅ សេ ទុង ខាងកិច្ចការបរទេស រួមសាមគ្គីយ៉ាងជិតស្និទ្ធ និងឧបត្ថម្ភគាំទ្រឥតងាករេដល់ការតស៊ូរបស់ប្រជាជននិងប្រទេសនានាដែលត្រូវមហាអំណាចចក្រពត្តិនិយមវាគទីនិយមនិងបក្ខពួកជិះជាន់សង្កត់សង្កិន ។ ក្នុងការទាក់ទងជាមួយប្រទេសជិតឆ្ងាយទាំងអស់ តូចក្ដី ធំក្ដី សាធារណរដ្ឋប្រជាមានិតចិនដើរតួជាគំរូក្នុងការគោរពលក្ខការណ៍ស្មើភាព គោរពឯករាជ្យភាព អធិបតេយ្យភាព បូរណភាពដែនដីគ្នា មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្នា និងមានផលប្រយោជន៍ទៅវិញទៅមក ។ គោលជំហរបដិវត្តដ៏ខត្តុង្គខត្តមនិងស្មារតីអន្តរជាតិនិយមវណ្ណៈអធនដ៏បរិសុទ្ធនេះរបស់បក្សកុម្មុយនិស្តចិន រដ្ឋាភិបាលចិន កងទ័ពរំដោះប្រជាជនចិន និងប្រជាជនចិន បានលើកទឹកចិត្តនិងជំរុញយ៉ាងខ្លាំងដល់ការតស៊ូរបស់ប្រជាជន និងប្រទេសដែលត្រូវគេជិះជាន់សង្កត់សង្កិនលើសកលលោក ពិសេសប្រទេសតតិយលោក និងប្រទេសមិនចូលបក្សសម្ព័ន្ធ ។ គោលជំហរបដិវត្តនិងស្មារតីអន្តរជាតិនិយមវណ្ណៈអធននេះ បានទទួលការ គោរពនិងកោតសរសើរពីសំណាក់ប្រជាជននិងប្រទេសទាំងនោះ ។

សមមិត្តនិងមិត្តទាំងឡាយ

ក្រោយពីបានរំដោះប្រទេសជាតិ និងរំដោះប្រជាជនកម្ពុជាទាំងស្រុងនិងជាស្ថាពរនាថ្ងៃ ១៧ មេសា ១៩៧៥ មក កងទ័ពបដិវត្តកម្ពុជាយើងខ្ញុំបន្តរួមសាមគ្គីយ៉ាងជិតស្និទ្ធជាធ្លុងមួយជាមួយប្រជាជនកម្ពុជាទាំងមូល ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សកុម្មុយនិស្តកម្ពុជា និងសមមិត្តលេខា ប៉ុល ពត បន្តលើកជ្រោងទង់ប្រយុទ្ធយ៉ាងមោះមុតដាច់ខាតបន្តធ្វើពលិកម្មតទៅទៀត ដើម្បីបំពេញភារកិច្ចបដិវត្ត ការពារជ័យផលបដិវត្ត ការពាររដ្ឋអំណាចកម្មករកសិករសមូហភាពរបស់បក្ស ការពារកម្ពុជាប្រជាធិបតេយ្យ ការពារកិត្តិយសជាតិ ការពារសិទ្ធិចាត់ចែងវាសនាខ្លួនឯង ការពារពូជសាសន៍កម្ពុជាឲ្យស្ថិតស្ថេរគង់វង្សជារៀងរហូត ។ ទន្ទឹមនឹងនេះ កងទ័ពបដិវត្តកម្ពុជាយើងខ្ញុំក៏មានភារកិច្ចរួមចំណែកជាមួយប្រជាជនកម្ពុជាយើងខ្ញុំបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមដោយប្រកាន់ខ្ជាប់នូវគោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ។

សព្វថ្ងៃ កងទ័ពបដិវត្តយើងខ្ញុំ និងប្រជាជនកម្ពុជាយើងខ្ញុំរក្សាការពារបានទាំងស្រុងពេញទីនិងដោយម្ចាស់ការនូវឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដីកម្ពុជាប្រជាធិបតេយ្យ រដ្ឋអំណាចកម្មករកសិករសមូហភាពរបស់បក្ស ដោយវាយកម្ទេចនិងបំបាក់ជាបន្តបន្ទាប់នូវអំពើរំលោភឈ្លានពានវិទ្ធង្សនា និងការប៉ុនប៉ងធ្វើរដ្ឋប្រហាររបស់ខ្មាំងសត្រូវ ពិសេសរបស់ខ្មាំងយួនឈ្លានពានវាគទីលេបទឹកដី ។ តាមរយៈការប្រយុទ្ធតឹងតែងស្វិតស្វាញប្រកបដោយជោគជ័យនេះ កងទ័ពបដិវត្តកម្ពុជានិងប្រជាជនកម្ពុជាយើងខ្ញុំ បានលើកជ្រោងយ៉ាងខ្ពស់នូវទង់ឯករាជ្យ ទង់អធិបតេយ្យភាព ទង់កិត្តិយសជាតិ ឲ្យបានគង់វង្សស្ថិតស្ថេរ ហើយបានវាយបំបាក់ជាបន្តបន្ទាប់នូវទង់ឈ្លានពានគេ ទង់វាគទីនិយម ទង់លេបទឹកដី និងបក្ខពួកពិសេសរបស់យួនឈ្លានពានវាគទីលេបទឹកដី ។

ដោយមានបក្សកុម្មុយនិស្តកម្ពុជានិងសមមិត្តលេខា ប៉ុល ពត យកចិត្តទុកដាក់អប់រំថែបំប៉នទាំងខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងជាប់ជានិច្ច កងទ័ពបដិវត្តកម្ពុជាយើងខ្ញុំដែលកកើតឡើងតាំងពីបាតដៃទទេក្នុងភ្លើងដ៏សន្ធោសន្ធៅនិងក្ដៅគគុកនៃសង្គ្រាមប្រជាជន បានសាកល្បងនិងឆ្លងកាត់ព្យុះសង្ឃរាគ្រប់បែបយ៉ាង និងសភាពការណ៍តឹងតែងស្មុគស្មាញបត់បែនលំបាកវេទនាជាច្រើនលើច្រើនគ្រាកន្លងមក ។ ដោយប្រកាន់យ៉ាងខ្ជាប់នូវមាគ៌ាយោធារបស់បក្ស ហើយអនុវត្ត


សុន សេន

មាគ៌ាសង្រ្គាមប្រជាជន និងមាគ៌ាប្រយុទ្ធរបស់បក្សយ៉ាងត្រឹមត្រូវដោយស្មារតីច្នៃប្រឌិតយ៉ាងរស់រវើក កងទ័ពបដិវត្តកម្ពុជាយើងខ្ញុំបានផ្តល់វិភាគទានដ៏សមរម្យរបស់ខ្លួនក្នុងការសម្រេចជ័យជំនះនៃបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យកន្លងមក ក៏ដូចក្នុងការសម្រេចជ័យជំនះជាបន្តបន្ទាប់ក្នុងរយៈកាលថ្មី ការពារប្រទេស បន្តធ្វើបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៃបដិវត្តន៍កម្ពុជាបច្ចុប្បន្ននេះ ។ សព្វថ្ងៃ កងទ័ពបដិវត្តកម្ពុជាយើងខ្ញុំបានក្លាយខ្លួនទៅជាឧបករណ៍ផ្តាច់ការប្រដាប់អាវុធដ៏ស្មោះត្រង់បំផុតរបស់បក្សកុម្មុយនិស្តកម្ពុជាយើងខ្ញុំ និងរបស់វណ្ណៈកម្មករកសិករកម្ពុជាយើងខ្ញុំគ្រប់កាលៈទេសៈ ។ សីលធម៌ប្រយុទ្ធគោលជំហរមោះមុតដាច់ខាតជាមួយខ្មាំងសត្រូវ គោលជំហរលះបង់ខ្ពស់ និងគោលជំហរគោរពអង្គការវិន័យរបស់បក្សដោយឥតលក្ខខណ្ឌ និងដោយភ្ញាក់រឭកបដិវត្តខ្ពស់ បានលេចឡើងត្រដែតត្រដឹម ជាពិសេសក្នុងការប្រយុទ្ធតបតវិញនឹងសង្រ្គាមឈ្លានពានដ៏កំណាចឃោរឃៅព្រៃផ្សៃរបស់ខ្មាំងយួនវាតទីលេបទឹកដី ។

បច្ចុប្បន្ននេះក៏ដូចជាតទៅអនាគត កងទ័ពបដិវត្តកម្ពុជាយើងខ្ញុំបន្តលើកកម្ពស់ស្មារតីប្រុងប្រយត្ន័បដិវត្តឲ្យខ្ពស់ជាប់ជានិច្ច បន្តពង្រឹងនិងសម្រួចគោលជំហរប្រយុទ្ធឲ្យកាន់តែស្រួចស្រាលមោះមុតដាច់ខាតថែមទៀត ដើម្បីម្ចាស់ការជាមុនលើគ្រប់យថាហេតុនិងគ្រប់កាលៈទេសៈ ព្រោះខ្មាំងសត្រូវគ្រប់ប្រភេទពិសេសខ្មាំងយួនឈ្លានពានវាតទីលេបទឹកដី វាមិនបោះបង់ចោលមហិច្ឆតាដ៏អាក្រក់ ខំត្រដរបន្តអនុវត្តយុទ្ធសាស្ត្រ“សហព័ន្ធឥណ្ឌូចិន” របស់វា ក្នុងគោលបំណងលេបកម្ពុជា និងបំបាត់ពូជសាសន៍កម្ពុជា ។ ក្នុងឋានៈម្ចាស់ការជាមុនជាប់ជានិច្ច កងទ័ពបដិវត្តកម្ពុជាយើងខ្ញុំក៏ម្ចាស់ការក្នុងការរើកម្ទាត់និងរើកម្ទេចនូវគ្រប់ខ្មាំងសត្រូវណាដែលហ៊ានរំលោភឈ្លានពានកម្ពុជាប្រជាធិបតេយ្យ ។

សមមិត្តនិងមិត្តទាំងឡាយជាទីស្នេហា

យើងខ្ញុំរីករាយពេញចិត្តណាស់ដោយកន្លងមកមហាមិត្តភាពបដិវត្តនិងមហាយុទ្ធសាមគ្គីភាពរវាងកងទ័ពបដិវត្តយើងទាំងពីរ

រដ្ឋាភិបាលប្រទេសយើងទាំងពីរ និងប្រជាជនយើងទាំងពីរ កម្ពុជានិងចិន ក្រោមការដឹកនាំរបស់បក្សយើងទាំងពីរ បានរីកលូតលាស់ស្រស់បំព្រង រឹងប៉ឹងខ្លាំងឡើងៗ ពិសេសក្រោយពីទស្សនកិច្ចមិត្តភាពជាផ្លូវការរបស់គណៈប្រតិភូបក្សនិងរដ្ឋាភិបាលកម្ពុជាយើងខ្ញុំ ដឹកនាំដោយសមមិត្តលេខា ប៉ុល ពត នៅប្រទេសចិនជាបងប្អូន កាលពីខែកញ្ញា ឆ្នាំ១៩៧៧ មុននេះ ។

មហាមិត្តភាពនិងមហាយុទ្ធសាមគ្គីភាពនេះ បានពង្រឹងពង្រីកយ៉ាងល្អប្រសើរយ៉ាងនេះ ព្រោះកងទ័ពយើងនិងប្រជាជនយើងទាំងពីរមានឧត្តមគតិបដិវត្តដូចគ្នា គោរពគ្នា ស្រឡាញ់រាប់អានគ្នា និងឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមកដោយអស់ពីចិត្តពីថ្លើម ដោយឈរជាប់លើមូលដ្ឋានសមភាព គោរពអធិបតេយ្យភាពគ្នាទៅវិញទៅមកយ៉ាងត្រឹមត្រូវនិងបរិសុទ្ធបំផុត ។

ក្នុងឱកាសដ៏មហាប្រសើរនេះ ក្នុងនាមបក្សកុម្មុយនិស្តកម្ពុជា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ កងទ័ពបដិវត្តកម្ពុជានិងប្រជាជនកម្ពុជា យើងខ្ញុំសូមសម្តែងសាជាថ្មីទៀតនូវអំណរគុណយ៉ាងស្មោះសរនិងជ្រាលជ្រៅបំផុត ជូនចំពោះបក្សកុម្មុយនិស្តចិន រដ្ឋាភិបាលចិន កងទ័ពរំដោះប្រជាជនចិន និងប្រជាជនចិនជាបងប្អូន ដែលគោរពយ៉ាងខ្ជាប់ខ្ជួននិងត្រឹមត្រូវបំផុតដំបូន្មានរបស់សមមិត្តប្រធាន ម៉ៅ និងអនុវត្តតាមការណែនាំរបស់សមមិត្តនាយក ជូ អេនឡាយ និងសមមិត្តប្រធាន ហួ គួ ហ្វឹង បានផ្តល់ដល់យើងខ្ញុំជាបន្តបន្ទាប់នូវការឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងដោយឥតលក្ខខណ្ឌ ក្នុងស្មារតីអន្តរជាតិនិយមវណ្ណៈអធនដ៏បរិសុទ្ធ ញ៉ាំងឲ្យយើងខ្ញុំរឹតតែឯករាជ្យម្ចាស់ការថែមទៀត ។

ប្រជាជនកម្ពុជាយើងខ្ញុំដែលធ្លាប់រងទុក្ខក្នុងខ្ទះឈាមនិងភក់ជ្រាំយ៉ាងជោកទាបបំផុត ក្រោមការជិះជាន់របស់វណ្ណៈជិះជាន់និងពួកអាណានិគមនិយម ចក្រពត្តិនិយម និងវាតទីនិយមគ្រប់ប្រភេទ អស់រយៈកាលយ៉ាងយូរមុន ១៧ មេសា ១៩៧៥ វាយតម្លៃយ៉ាងខ្ពស់នូវមិត្តភាពនិងសាមគ្គីភាពដ៏បរិសុទ្ធរបស់កងទ័ពរំដោះប្រជាជនចិន និងរបស់ប្រជាជនចិនជាបងប្អូន ចំពោះកងទ័ពបដិវត្តកម្ពុជានិងប្រជាជនកម្ពុជាយើងខ្ញុំ ដោយឈរយ៉ាងត្រឹមត្រូវបំផុតលើលក្ខការណ៍ស្មើភាពនិងគោរពឯករាជ្យនិងអធិបតេយ្យភាពគ្នាទៅវិញទៅមក ។ យើងខ្ញុំរីករាយនិងពេញចិត្តណាស់នឹងមិត្តភាពនិងសាមគ្គីភាពនេះ ហើយយើងខ្ញុំនឹងខិតខំថែរក្សានិងពង្រឹងពង្រីកមហាមិត្តភាពបដិវត្ត និងមហាយុទ្ធសាមគ្គីភាពកម្ពុជា-ចិននេះ ឲ្យកាន់តែស្រស់បំព្រងនិងរឹងប៉ឹងខ្លាំងក្លាថែមទៀត ។

យើងខ្ញុំមានជំនឿជឿជាក់ថា ទស្សនកិច្ចរបស់គណៈប្រតិភូយើងខ្ញុំលើកនេះ នឹងរឹតតែពង្រឹងពង្រីកមហាមិត្តភាពបដិវត្តនិងមហាយុទ្ធសាមគ្គីភាពរវាងបក្សយើង កងទ័ពយើង និងប្រជាជនយើងទាំងពីរ កម្ពុជានិងចិន ឲ្យរីកលូតលាស់ស្ថិតស្ថេរចីរកាលដរាបតរៀងទៅ ។

គឺក្នុងមនោសញ្ចេតនានេះហើយ ដែលយើងសូមស្នើលើកកែវឡើងប្រសិទ្ធពរ÷

◆ សូមឲ្យមហាមិត្តភាពបដិវត្ត និងមហាយុទ្ធសាមគ្គីភាពរវាងកងទ័ពរដ្ឋាភិបាលនិងប្រជាជនយើងទាំងពីរ ក្រោមការដឹកនាំនៃបក្សយើងទាំងពីរ កម្ពុជានិងចិន ស្ថិតស្ថេរចីរកាល ។

◆ សូមឲ្យកងទ័ពរំដោះប្រជាជនចិន និងប្រជាជនចិនដណ្តើមបានជ័យជំនះដ៏ត្រចះត្រចង់ថ្មីៗទៀត ។

◆ សូមឲ្យសមមិត្តប្រធាន ហួ គួ ហ្វឹង អគ្គមគ្គុទ្ទេសក៍ដ៏ភ្លឺស្វាងរបស់ប្រជាជនចិន មានសុខភាពល្អបរិបូរ អាយុយឺនយូរនិងប្រកបដោយជ័យជំនះ ។

◆ សូមឲ្យសមមិត្តអនុប្រធាន តឹង ស៊ាវ ភីង មានសុខភាពល្អបរិបូរនិងអាយុយឺនយូរ ។

◆ សូមឲ្យសមមិត្តឧបនាយក ស៊ី សៀង សៀន មានសុខភាពល្អបរិបូរ ។

◆ សូមឲ្យសមមិត្តចិនទាំងអស់មានសុខភាពល្អបរិបូរ

◆ សូមឲ្យសមមិត្តនិងមិត្តទាំងអស់នៅទីនេះមានសុខភាពល្អបរិបូរ ។

## សីលធម៌កុម្មុយនិស្ត

◆ ចេះគិតគូរអ្នកផង លំបាកវេទនាមុនអ្នកផង

តែទទួលផលក្រោយអ្នកផង។

(ដកស្រង់ពីសៀវភៅសមមិត្ត កែវ)

# កំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហម

*(តពីលេខមុន)*

### ៣) គោលជំហរធ្វើការងារនៅខាងក្រៅជាគោលជំហរៈ

១) យើងនៅក្រៅប្រទេស នៅក្នុងប្រទេសជាមិត្តជិតស្និទ្ធ ។ ក៏មិនមែនមានន័យថាយើងមិនឯករាជ្យម្ចាស់ការ ។ តែកុំភ្លេចថាយើងនៅប្រទេសគេ ។ ក្នុងធ្វើការកុំភ្លេចនឹងឲ្យសោះ មិនមែនរណបគេទេ ។ ត្រូវធ្វើសម្បទានទៅវិញទៅមក ។

២) ក្រសួងនេះជាក្រសួង១មានការគ្រប់គ្រងរបស់អង្គការគ្មានក្រុមទេ គឺជាក្រសួង១ក្នុងនឹងមានៈ

- អ្នកទទួលខុសត្រូវភ្លេង
- អ្នកទទួលខុសត្រូវអាន
- អ្នកទទួលខុសត្រូវមន្ទីរ
- អ្នកទទួលខុសត្រូវ romain

ឲ្យឯកភាពតែមួយ កុំឲ្យឃើញតែក្រុម១ៗ បើឃើញតែក្រុមៗជាកម្មសិទ្ធិឯកជន ។ លើកកម្ពស់ស្មារតីទទួលខុសត្រូវមែនទែន ។ ការងារសម្រេចរួម តែបុគ្គលត្រូវហ៊ានទទួលខុសត្រូវ ។

ខាងដឹកនាំរួម តំណាងមជ្ឈិមមានការងារដោយឡែកច្បាស់ទាក់ទងបក្សពលករវៀតណាម តែក៏ដើម្បីបម្រើខ្មែរដែរ ។

៣) ចាំបាច់មែនទែន ត្រូវមានអង្គការវិន័យមែនទែន ។ កុំរំលោភអង្គការវិន័យឲ្យសោះ ។ កុំឲ្យអនាធិបតេយ្យ ។ បុគ្គលយើងមានកម្មសិទ្ធិផ្ទាល់ខ្លួនលុះតែយើងមិននៅក្នុងអង្គការ ។ អង្គការវិន័យត្រូវអនុវត្តដោយភ្ជាក់រឭកឥតណាបន្ធូរទេ ។

៤) ស្និទ្ធស្នាលស្រឡាញ់គ្នាដូចបងប្អូន ចេញចូលផ្ទះគ្នាទៅវិញទៅមក ក្រៅពីការរក្សាសម្ងាត់របស់អង្គការ គ្មានរបាំងអ្វីទេ ។ គ្មានក្រុមគ្មានពួកអីទេ ។ ស្និទ្ធស្នាលមិនមែនថាឲ្យខូចសីលធម៌ទេ ។ គោរពរក្សាសីលធម៌ឲ្យបានល្អ ។

### ៤) ភារកិច្ចចំពោះមុខ

១) បញ្ហានិយាយៈ ឲ្យស្មាហាប់ ចេះដកឃ្លា ចេះដកដង្ហើម ចេះបញ្ចប់ កុំស្រែក កុំឲ្យយើងព្រួយបុគ្គល ។ ជាសតិអារម្មណ៍គឺនិយាយដើម្បីបម្រើចលនា បម្រើបដិវត្តន៍ ខំអស់សមត្ថភាពបម្រើសមរភូមិ ។

២) សិល្បៈ ខំធ្វើឲ្យស្វាហាប់ថែមទៀត បទបំពេរ ស្មូត្របន្ទន់ក្អែក កំណាព្យ បទណាមិនស្វាហាប់យើងឈប់ ។

៣) គិតគូរសម្រួលកម្មវិធី ធ្វើឲ្យបានល្អថែមទៀត ។ អាចលុបចោលអានឃឹតបាន ។ ដើម្បីដំណើរការ តើគោរពកែច្នៃផ្ទៃក្នុងចាត់តាំងបែបម្តេច ។

បង...: ១) យើងឯកភាពគ្នាជាធ្លុង១ ដាច់ខាតស្លាប់រស់ជាមួយគ្នា បម្រើបក្សកុម្មុយនិស្តកម្ពុជា ។

២) ឯការខុះខាតនៅត្រង់ទម្លាប់ដើមជាពួកជាក្រុម ជួនកាលចូលគ្នាទៅមករកហើយ តែមានរបាំងគ្នាវិញ ។ ធ្វើម្តេចឲ្យរលាយគ្នាជាសាច់ឈាមតែ១ ។

៣) កម្រិតណាយើងត្រូវប្រាប់អង្គការ បើខាងសមូហភាពយើងមិននិយាយ ឲ្យអ្នកណាដឹង ។ រឿងច្រើនអ្នកមកពីក្រៅដឹងច្រើនជាងអ្នកទទួលខុសត្រូវនៅទីនេះ ។

៤) ខំដូរឈ្មោះសម្ងាត់ តែយើងបែរជាទៅនិយាយប្រាប់គេអស់ប្រវត្តិរូបយើង ។

៥) យើងមិនកសាងគ្នាក្នុងប្រជុំ ទៅជាខ្សឹបខ្សៀវក្រៅប្រជុំ ។

៦) យល់ច្រឡំបុគ្គលនិងចាត់តាំង ថាយើងជាម្ចាស់បុគ្គលយើងស្ងួនតួយើង ក្រុមយើង ។

៧) យើងនៅប្រទេសជាមិត្ត យើងកុំភ្លេចឲ្យសោះ យើងធ្វើល្អគេចាប់អារម្មណ៍ល្អ ។ យើងសេរីក៏គេចាប់អារម្មណ៍ដែរ ។

បងថុងៈ ពាក្យស្លោកក្នុងស្រុក «និយាយអ្វីចំណេញដល់បដិវត្តន៍ចាំនិយាយ បើមិនចំណេញដល់បដិវត្តន៍កុំនិយាយ» ។

**ថ្ងៃទី ២១-២-៧៥**

ផ្ញើ *déclaration minafets* ឲ្យសមមិត្ត *T. Sinh* ។

**ថ្ងៃទី ២៣-២-៧៥** ជួបជាមួយបងថុង

៣០-៣-១៩៦៧ ផ្ទុះអាវុធនៅខាងត្បូងសានដែលយើងថាជាថ្ងៃកំណើតកងទ័ព ។ ២៥-២-៦៨ ថ្ងៃកំណើតកងទ័ពជាថ្ងៃកុប្បកម្មទូទៅ ។ ចូលទៅត្រៀមរៀបចំតស៊ូអាវុធពី១៩៦០

មក ។ តែចំហសព្វថ្ងៃនេះយើងថាថ្ងៃ ២៣-៣-៧០ ថ្ងៃកំណើត រណសិរ្សកំណើត DAPLNK តែថ្ងៃក្រោយយើងកាន់អំណាច យើងនិយាយការពិត ។ ព្រោះអំណាចគឺអ្នកណាកាន់អាវុធ អ្នកណាកាន់កាំភ្លើង ។ ចម្រៀងដៃកាន់អាវុធៈ ១៩៦៧ ។ កងទ័ពសេរីកា ១៩៦៨ ។ កងទ័ពយើងក្រោកឡើងតស៊ូអង់អាច តើអត្ថការសព្វថ្ងៃយ៉ាងណា?

**I)** វាវិវត្តចូលមកដល់ទីចុងក្រោយបំផុតហើយ យើងឡើងជិតដល់កំពូលហើយ ។ យើងហត់ បែកញើស តែវាជិតណាស់ហើយ ។ តែបើនិយាយជាប្រវត្តិសាស្ត្រគឺមិននិយាយខែ-ឆ្នាំទេ ។ ព្រោះតស៊ូយូរអង្វែង ។ ខាងយោធាយើងកំពុងហ៊ុមព័ទ្ធរដ្ឋធានីជាក្បាលម៉ាស៊ីនរដ្ឋ ។ យើងកំពុងតែប្រយុទ្ធចាប់កវា ។

**វាយរដ្ឋធានីៈ**

១) កងទ័ពពីក្រៅសម្រុកចូល ប្រជាជនពីក្នុងបះឡើងយកអំណាច ។ តែបែបនេះមានតិចទេ នៅប៉េកាំងវាយតិចទេ តែកងទ័ពវាចុះចូល ។

២) ប្រយុទ្ធចាប់កវា ១ផ្នែកវាយអ្នកលឿង ១ផ្នែកទៀតវាយពោធិចិនតុង ។ បើយើងប្រយុទ្ធចាប់កវាអឺចឹងបាន១ប្រាំងហើយ ១វស្សាទៀត ប្រាំងក្រោយច្បាស់ជាវាដួល នេះពិតប្រាកដណាស់ ។ មិនបាច់មាន... មិនបាច់មានកងទ័ពវាយពីក្រៅខ្លាំងដែរ ។ វិធីវាយប្លែកៗគ្នា ។ បើខាងយោធាយើងច្នៃប្រឌិតណាស់ បើធ្វើតាមសៀវភៅយើងមិនម្ចាស់ការទេ ។ យើងដំណើរការមិនតាមសៀវភៅ មិនតាមក្រឹត្យក្រម គឺតាមសភាពការណ៍ជាក់ស្តែង យក M.L មកពិនិត្យតាមសភាពការណ៍ជាក់ស្តែងរបស់យើង ។ យើងឯករាជ្យម្ចាស់ការ ។ ខាងនយោបាយក៏យើងឯករាជ្យម្ចាស់ការ មហាសន្និបាតជាតិលើកទី២ជាព្រនង់មួយវាយពួកអាក្សត់ ។ ខាងសេដ្ឋកិច្ចក៏យើងឯករាជ្យម្ចាស់ការ ។ ការតស៊ូយើងបើប្រៀបធៀបចិន វៀតណាម យើងលោតផ្លោះមែនទែន ។

**មូលហេតុៈ**

១) បក្សយើងមានមាគ៌ាត្រឹមត្រូវ ឯករាជ្យម្ចាស់ការ

២) ពិសោធន៍បក្សវៀតណាម ចិន

៣) យុទ្ធជនយើងអង់អាចក្លាហាន កម្មករកសិករក្រ បញ្ញាជនបដិវត្តរបស់យើង ។

៤) យើងប៉ាន់ប្រមាណការវិវត្តន៍របស់សភាពការណ៍កម្ពុជាៈ ១៩៥៨ បក្សថារដ្ឋប្រហារមុខជាមានឡើង ។ ១៩៥៩ អាដាប ឈួន វាធ្វើតែបរាជ័យ ជ័យជំនះមិនត្រឡប់ថយក្រោយទេ ឈានទៅមុខ ១ថ្ងៃឈាន ១ថ្ងៃឈាន ។ យើងឈ្នះច្បាស់ទោះ...ឲ្យលុយចូលទ័ពក៏ដោយ ។

**II) តើបញ្ហាអ្វីចោទឡើងជិតពេលចប់សង្គ្រាម?**

១) ឧបាយកលខ្មាំងៈ ច្រើនហើយពិលពុលទៀត ។ ខ្មាំងមុនស្លាប់វាក្រាញរកគ្រប់វិធីទាំងអស់ ។ តែយើងប្តេជ្ញាចិត្តកម្ទេចវាតែម្តង ។ ឧបាយកលធំជាងគេទាំងអស់គឺយោធា (ធាតុពិតចក្រពត្តិអាមេរិកនិងបរិវារ) ហើយបើចាញ់យើងវាគិតគូរចង់រក្សាយោធាវា ។ ឧទាហរណ៍ អ្នកលឿងទាល់តែយើងកម្ទេចវាតែម្តង ។ សព្វថ្ងៃចក្រពត្តិអាមេរិកគោងជាប់អាណុល មិនងាយចោលអាណុលទេ ។ តែទន្ទឹមនឹងវាអាចដំណើរការបង្កើតរដ្ឋាភិបាលអត់អា៧នាក់ ហើយសម្តេចទាំង២ទៅភ្នំពេញ ឲ្យហៅយើងទៅរួបរួមគ្នាបែបលាវ ។ យើងប្រាប់ហើយថាយើងមានលក្ខណៈសម្បត្តិតែ១ទេ គឺទាល់តែវាដាក់អាវុធ ។

២) ឧបាយកលទូតៈ ទាក់ទាញប្រទេសជាមិត្តយើងឲ្យមានជំហរស្មោក់ស្មើរ គោងប្រុងប្រយ័ត្នបដិវត្តឲ្យខ្ពស់មែនទែន ។ ឧបាយកលយោធានិងទូត...ក្នាវាមុខជាធ្វើមិនខាន ។

៣) សន្តិសម្ព័ន្ធៈ ឲ្យចរចាវាយគោលជំហរតស៊ូរបស់យើងតែម្តង ឲ្យយើងខ្ទេចខ្ទាំ ហូរឈាម ។ កូនចៅកសិករក្រីក្របានធ្វើពលិកម្មច្រើនដើម្បីជាតិ ។ យើងរស់នៅសព្វថ្ងៃក៏ដោយសារគេពលី ។ គោងប្តេជ្ញាតស៊ូដល់ចប់ ។

**បញ្ហា១ទៀតចោទឡើងជិតចប់សង្គ្រាមៈ**

១) មានមនុស្សខ្លះទ្រាំទ្រការលំបាកមិនបាន ។

២) បង្កើតចេញជាទ្រឹស្តី១ថា សង្គ្រាមសព្វថ្ងៃមិនមែនសង្គ្រាមរំដោះជាតិ រំដោះប្រជាជន គឺសង្គ្រាមមនោគមវិជ្ជាពួកកុម្មុយនិស្តចង់កាន់អំណាចចេះតែជំរុញឲ្យប្រជាជនទៅមុខ ។

៣) ពួកអា សឺង ង៉ុកថាញ់, ហង់ ធុនហាក់, គាំ រ៉េត គង់ជន ធ្វើ ។ គោងយើងក្តាប់ឲ្យជាប់ មាគ៌ាបដិវត្តន៍យើងគឺបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ (ប្រជាធិបតេយ្យប្រជាជនមិនមែននាយទុនទេ) ។ **(នៅមានត)**

# គួនាទីដែលគួរឱ្យសង្ស័យរបស់ស្ថានទូតចិននៅទីក្រុងហាណូយ១៩៧៨

**(តពីលេខមុន)** ជិន ជឿង ហ្សាង និងខ្ញុំ ទទួលខុសត្រូវចែកចាយឯកសារទាំងនេះដោយមានគោលដៅពីរយ៉ាង ទីមួយគឺលើកឡើងអំពីអ៊ីដែលនាំដល់ការដឹងឮអំពីលទ្ធិផ្តាច់ការរបស់ប្រទេសធំៗ នៅក្នុងមហាជនជាតិហ៊័រ និងទីពីរគឺដើម្បីរៃអង្គាសប្រាក់យកទៅទិញមាសផ្ញើទៅប្រទេសចិន ។

នៅខែសីហា ឆ្នាំ១៩៧៦ រាល់ការរៀបចំទាំងអស់ត្រូវបានធ្វើឡើង ហើយខ្សែបណ្តាញត្រូវបានបង្កើតឡើងក្នុងចំណោមក្រុមផ្សេងៗ ។ ឯកសារប្រភេទទីមួយមកពីប្រទេសចិននិងស្ថានទូតចិនប្រចាំនៅទីក្រុងហាណូយ ចាប់ផ្តើមមកដល់ទីក្រុងហាណូយជាបណ្តើរៗ ហើយ ។

## ១៩៧៧: ផ្សព្វផ្សាយឃោសនាដំណឹងមិនពិតស្តីអំពីកម្ពុជា

លី ង៉ៀប ភូ បន្តទៀតថា «នៅដើមឆ្នាំ១៩៧៧ ជិន ហ៊័ត បានមកពីទីក្រុងហូជីមិញ ដោយនាំមកឲ្យខ្ញុំនូវសៀវភៅពុម្ពកាសែត និងឯកសារជាច្រើនថែមទៀត ព្រមទាំងការអបអរសាទរពីសំណាក់ស្ថានទូតចិនទៀតផង ។ ការណែនាំថ្មីពីស្ថានទូតចិនសង្កត់ធ្ងន់ថា: ក្រៅពីធ្វើឃោសនាដើម្បីប្រទេសចិន និងពង្រីកឥទ្ធិពលរបស់ស្ថានទូតចិនទៅលើសហគមន៍ជនជាតិហ៊័រនៅទីក្រុងសៃហ្គនចឹឡឹន ចាំបាច់ត្រូវតែធ្វើឲ្យប្រជាជនទាំងនោះជឿជាក់ថាសង្គ្រាមរវាងកម្ពុជានិងវៀតណាមផ្ទុះឡើង ហើយចិននឹងផ្តល់ការគាំទ្រយ៉ាងពេញទំហឹងចំពោះប្រទេសកម្ពុជា ចំណែកឯវៀតណាមនិងចិនមានការប៉ះទង្គិចគ្នាយ៉ាងខ្លាំង ហើយស្ថានភាពនឹងស្ថិតនៅក្នុងភាពកាន់តែអាក្រក់សម្រាប់ជនជាតិហ៊័រនៅក្នុងប្រទេសវៀតណាម ។ ដោយឈរលើការវិភាគនេះ យើងនឹងជំរុញឲ្យជនជាតិហ៊័រទទួលយកសញ្ជាតិចិនឡើងវិញ ហើយវិលត្រឡប់ទៅប្រទេសចិនវិញ ។ ជនជាតិហ៊័រក៏ត្រូវបានឃោសនាឲ្យជឿថាខ្លួនបានទទួលផលប្រយោជន៍ច្រើន ដោយយកទ្រព្យសម្បត្តិរបស់ខ្លួនទាំងអស់ត្រឡប់មកប្រទេសចិនដើម្បីជួយកសាងប្រទេសរបស់ខ្លួន ជាជាងស្នាក់នៅនិងប្រែក្លាយតាមរបៀបសង្គមនិយមនៅក្នុងប្រទេសវៀតណាម ។ ជនជាតិហ៊័រក៏នឹងត្រូវបានប្រាប់ដែរថា ស្ថានទូតជាតំណាងឲ្យមាតុភូមិ អ្នកណាដែលបដិសេធមិនព្រមធ្វើតាមការអំពាវនាវរបស់មាតុភូមិឲ្យវិលត្រឡប់ទៅប្រទេសវិញទេ នឹងត្រូវចាត់ទុកជាជនក្បត់ ។ ខ្ញុំដឹងថាយើងមិនមែនជាក្រុមតែមួយនៅក្នុងទីក្រុងហូជីមិញដែលធ្វើប្រតិបត្តិការសម្រាប់ស្ថានទូតទេ ។ អ្នកដទៃទៀតត្រូវបានចាត់តាំងឲ្យទទួលបេសកកម្មសំខាន់ៗថែមទៀត ហើយមានអ្នកខ្លះទៀតធ្វើការឲ្យភ្នាក់ងារនៅក្រៅស្ថានទូត ។ ក្រុមរបស់យើងធ្វើការឃោសនាបានជោគជ័យច្រើនណាស់ដូចជា លក់សារពត៌មានរៃអង្គាសប្រាក់ និងទិញមាស ។ នៅពេលសមាជិកក្រុមនៅភាគខាងជើងធ្វើដំណើរមកទីក្រុងហូជីមិញ អ្នកទាំងនោះមិនដែលភ្លេចនាំមកប្រាប់យើងនូវសេចក្តីណែនាំនានានិងសេចក្តីអំណរពីសំណាក់ស្ថានទូតចិន និងពាក្យលើកទឹកចិត្តពីប្រធានថ្មីរបស់យើងឡើយ ។ ខ្ញុំបានប្រើរថយន្តរបស់ខ្ញុំផ្ទាល់ដើម្បីដឹកលក់សារពត៌មាននិងឯកសារជិតបីរយគីឡូក្រាម ហើយខ្ញុំតែងតែប្រមែប្រមូលប្រាក់បានមកពីការលក់នេះទិញជាមាសផ្ញើទៅទីក្រុងប៉េកាំងតាមទីក្រុងហាណូយ ។

«នៅខែមីនា ឆ្នាំ១៩៧៨ ជិន ជឿង ហ្សាង ហៅខ្ញុំនិងវឿង គ័ន ធាន ទៅជួបប្រជុំម្តងទៀត ដើម្បីទទួលនូវសេចក្តីណែនាំមួយទៀតមកពីស្ថានទូតចិន ។ ទាំង ជិន ជឿង ហ្សាង និង វឿង គ័ន ធាន គឺជាសិស្សរួមថ្នាក់របស់ខ្ញុំនៅឯសាលាបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់អាណិកជនចិននៅទីក្រុងហាណូយ ។ ក្រោយពីបានទទួលសញ្ញាប័ត្រហើយ វឿង ទៅបង្រៀននៅខេត្តគ័ងមិញ ចំណែកឯ ជិន ជឿង ហ្សាង បង្រៀននៅសាលា

មធ្យមសិក្សាចិននៅទីក្រុងហាណូយ ហើយធ្វើជានាយកសាលានេះ ប៉ុន្តែក្រោយមកត្រូវបានបណ្តេញចេញដោយរដ្ឋអំណាចវៀតណាមពីបទចោទប្រកាន់ថាបានសមគំនិតជាមួយក្រុម "សោហ្វាន" ដើម្បីធ្វើ"បដិវត្តន៍វប្បធម៌"នៅទីក្រុងហាណូយ ក្រោយពីមានសង្គ្រាមអាកាសរបស់រដ្ឋការលោក ចន សុន ប្រឆាំងនឹងវៀតណាមភ្លាម ។ ជិន ហ៊ីត គឺជាអាណិកជនចិនរស់នៅប្រទេសកម្ពុជាដែលធ្វើដំណើរទៅវៀតណាមខាងត្បូងជាមុន រួចហើយបង្ហួសទៅវៀតណាមខាងជើងក្នុងនាមជាកម្មាភិបាលតស៊ូ ដែលផ្តុំកម្លាំងជាក្រុមសាឡើងវិញនៅក្រោមកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ។ ឪពុកម្តាយរបស់ ជិន ហ៊ីត មានចម្ការម្រេចយ៉ាងធំនៅក្នុងប្រទេសកម្ពុជា ។ គាត់ត្រូវដេញចេញពីការងារ ប៉ុន្តែចេះតែរស់នៅជាមួយគ្រួសារយ៉ាងសុខស្រួលដោយមានការជួយឧបត្ថម្ភពីស្ថានទូតចិន ។ ជិន ហ៊ីត តែងតែចូលរួមប្រជុំជាមួយយើងក្នុងនាមជាស្ថានទូតចិន ។ ជិន ហ៊ីត បញ្ជាក់ថា "នៅក្នុងសភាពការណ៍ថ្មីនេះ សៃហ្គនចឹឡឹនត្រូវតែធ្វើឲ្យបានរហ័ស ហើយប្រើប្រាស់គ្រប់ឱកាសដើម្បីឃោសនាជនជាតិហ៊ឺរ ហើយបង្កភាពចលាចលនៅក្នុងចំណោមអ្នកទាំងនោះ មិនត្រឹមតែនៅទីក្រុងហូជីមិញទេ តែថែមទាំងនៅខេត្តដុងណាយ ឡឹមដុង ដាឡាក់ គ័ងណាម ដាណាំង និងខេត្តផ្សេងៗទៀតនៅក្នុងភាគខាងត្បូងដែលមានជនជាតិហ៊ឺររស់នៅ ។ គោលបំណងរបស់យើងគឺប្រឆាំងជាមួយនឹងការកែទម្រង់សង្គមនិយមរបស់វៀតណាមតាមតែអាចធ្វើទៅបាន ទោះជាត្រូវចំណាយអ្វីក៏ដោយ ហើយបង្កភាពច្របូកច្របល់នៅក្នុងទីក្រុងហូជីមិញ ដោយសហការជាមួយយោធារបស់រដ្ឋអំណាចនៃប្រទេសកម្ពុជា ។

"សេចក្តីណែនាំនិងវិធានការផ្សេងៗក្នុងផែនការដែលនាំយកមកដោយ ជិន ហ៊ីត ពីភាគខាងជើង ត្រូវបានបែងចែកដោយផ្អែកលើបទពិសោធន៍នៅក្នុងអំឡុងយុទ្ធនាការឃោសនានៅក្នុងចំណោមជនជាតិហ៊ឺរនៅទីនោះ ។ យើងចែកជាក្រុមតូចៗដើម្បីដើរឃោសនាអំពីដំណឹងមិនពិតតាមវិធីច្រើនយ៉ាងដូចជាៈ ការឲ្យយោបល់ណែនាំ បញ្ចុះបញ្ចូល បន្ទុចកេរ្តិ៍ឈ្មោះ និងមួលបង្កាច់ ព្រមទាំងគំរាមកំហែងនៅពេលណាចាំបាច់ដែលត្រូវធ្វើ ។ យើងដើរពីផ្ទះមួយទៅផ្ទះមួយ ហើយជជែកលេងជាមួយប្រជាជនម្តងម្នាក់ ម្តងពីរនាក់ ម្តងបីនាក់ ដើម្បីជះឥទ្ធិពលទៅលើអ្នកទាំងនោះតាមតែអាចធ្វើទៅបាន ។ ដោយការប្រើមនុស្សម្នាក់ឲ្យទៅឃោសនាបញ្ចុះបញ្ចូលមនុស្សម្នាក់ទៀត មិនយូរប៉ុន្មានយើងក៏ទទួលបានជោគជ័យក្នុងការបង្កើតបរិយាកាសមួយដែលពោរពេញទៅដោយការមិនស្រណុកក្នុងចិត្ត ភ័យខ្លាចនិងភាពស្ទន់ស្ទោនៅក្នុងចំណោមជនជាតិហ៊ឺរ ។ អ្នកដែលនៅតែមិនដាច់ស្រឡះឬទាក់ទើមិនចង់ត្រឡប់ទៅប្រទេសចិនវិញ បានទទួលសំបុត្រដែលភ្នាក់ងាររបស់យើងដើរដាក់តាមផ្ទះដើម្បីបំភ័យ ឬមកសួរភ្នាក់ងារយើងនៅពេលដែលមេគ្រួសារនីមួយៗត្រូវបានប្រាប់ថា "រដ្ឋាភិបាលចិនមានភ្នែកនិងត្រចៀកច្រើនណាស់នៅទីនេះ ហើយដឹងថាអ្នកណាមិនចង់ទៅ ។ អ្នកណាបដិសេធមិនចង់ទៅគឺជាអ្នកក្បត់មាតុភូមិ និងមិនអាចទុកឲ្យរស់នៅសុខស្រួលទេ" ។ យើងបានបោះខិតប័ណ្ណស្ងាត់ៗនិងដើរបិទពាក្យស្លោកនៅកន្លែងដែលមានប្រជាជនហ៊ឺររស់នៅច្រើនដើម្បីប្រឆាំងនឹង"ការមិនទទួលស្គាល់ជាសមាជិកសង្គមនិងបណ្តេញ" ជនជាតិហ៊ឺរចេញពីប្រទេសវៀតណាម ។ យើងក៏បានបោះពុម្ពផ្សាយនូវសំណុំបែបបទក្នុងការវិលត្រឡប់ទៅប្រទេសចិនវិញដោយចម្លងតាមគំរូថ្មីមកពីស្ថានទូតចិន ហើយយកទៅទីក្រុងហូជីមិញដោយឈ្មោះ ជិន ហ៊ីត ។ ក្រោយពីមានការពិភាក្សាជាច្រើនដងមក នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៨ ខ្ញុំក៏សរសេរសំបុត្រមួយច្បាប់ផ្ញើទៅ ជិន ហ៊ីត និងប្រពន្ធ នៅផ្ទះលេខ២៤ វិថីហាងបៀម ទីក្រុងហាណូយ និងមួយច្បាប់ទៀតឲ្យ អុង ធិញ ណាម និង លី ដោ ឡេ រស់នៅគ័ងមិញ ដើម្បីជំរុញឲ្យអ្នកទាំងនេះរៀបចំបណ្តាញទាក់ទងឲ្យឆាប់រហ័សពីទីក្រុងហូជីមិញទៅទីក្រុងហាណូយ និងពីហាណូយទៅព្រំដែន សម្រាប់បង្កការងាយស្រួលដល់អ្នកដែលចង់ត្រឡប់ទៅប្រទេសចិនវិញដោយស្ងាត់ៗ ។ ខ្ញុំនិង អុង ធិញ ណាម យល់ស្របជាមួយគ្នាក្នុងការហៅខ្សែរយៈជាឈ្មោះសម្ងាត់ថា "មាគ៌ារបស់គណៈដឹកនាំ" ។ តាមទំនៀមទម្លាប់នៅទីក្រុងចឹឡឹន ជនជាតិហ៊ឺររូបណាដែលចង់ទៅ ត្រូវតែចូលរួមវិភាគទានជាមាសប្រាក់ជាថ្លៃធ្វើដំណើរ ។ មួយផ្នែកនៃមាសនេះត្រូវចំណាយសម្រាប់ការចាយ

រវាយខ្លួនយើង ហើយសល់ពីនោះយើងត្រូវផ្ញើទៅ"គណៈកម្មការមជ្ឈិមចិនប្រចាំនៅបរទេស" ។ នៅពេលដែលប្រជាជនយើងនៅភាគខាងជើងរៀបចំជាខ្សែសង្វាក់នៅទីនោះ នៅភាគខាងត្បូងយើងរៀបចំការចេញដំណើរ ។ មុខសញ្ញាទីមួយរបស់យើងគឺទីប្រជុំជនមូលធនជាតិហឺរដែលខ្លាចបាត់បង់ទ្រព្យសម្បត្តិរបស់ខ្លួននៅក្នុងប្រទេសវៀតណាម ។ ដើម្បីឲ្យអ្នកទាំងនេះសម្រេចចិត្តឲ្យបានឆាប់ យើងបានប្រើគ្រប់វិធីសាស្ត្របញ្ចុះបញ្ចូល ។ ដើម្បីបង្កើនការជឿជាក់របស់អ្នកទាំងនោះមកលើយើងកាន់តែខ្លាំងថែមទៀត យើងបាននិយាយថ្ងៃស្វាត់ៗ ។ ក្នុងខណៈនោះដែរ ដើម្បីជំរុញយុទ្ធនាការនេះឲ្យទៅមុខ ខ្ញុំបានរៀបចំឲ្យប្អូនប្រុសនិងប្អូនស្រីខ្ញុំដែលរស់នៅទីក្រុងហាណូយ ចាកចេញទៅប្រទេសចិនជាបន្ទាន់ ។ នៅពេលកំពុងរៀបចំដំណើរការឲ្យបងប្អូនរបស់ខ្ញុំ ដូចជាលក់គ្រឿងសង្ហារឹមផ្សេងៗនិងរបស់របរដទៃទៀត ក្រុមរបស់យើងក៏ដើរពីផ្ទះមួយទៅផ្ទះមួយឃោសនាឲ្យជនជាតិហឺរដទៃទៀតចូលរួមជាមួយខ្លួន ។ គោលបំណងរបស់យើងគឺបង្កបរិយាកាសភ័យស្លន់ស្លោក្នុងចំណោមជនជាតិហឺរ ។ គ្រួសាររបស់ខ្ញុំនៅភាគខាងជើងមានសមាជិក៦នាក់ដែលរៀបខ្លួនហើយស្រេចដើម្បីចេញដំណើរទៅប្រទេសចិនបានបញ្ចុះបញ្ចូលជនជាតិហឺរមួយចំនួនទៀតឲ្យទៅជាមួយដែរ ។

"ការធ្វើរបៀបនេះក៏ដើម្បីឲ្យជនជាតិហឺរជឿជាក់ថាវៀតណាមកំពុងតែអនុវត្តគោលនយោបាយបណ្តេញ ធ្វើទុក្ខបុកម្នេញ និងបង្ខំអាណិកជនចិន ។ អត្ថបទឃោសនាខ្លីៗរបស់គណៈកម្មការមជ្ឈិមចិនប្រចាំនៅបរទេស បានចែងច្បាស់ៗនៅក្នុងសេចក្តីណែនាំពីស្ថានទូតចិន" ។

### ១៩៧៨៖ យុទ្ធនាការ "Nanchiao"

លី ធៀប ភួៈ "ប្រហែលជាចុងខែមីនា ឆ្នាំ១៩៧៨ នៅពេលដែលទីក្រុងហូជីមិញចាប់ផ្តើមកំណែទម្រង់សង្គមនិយមក្នុងទ្រង់ទ្រាយធំ យើងបានទទួលបញ្ជាឲ្យធ្វើការជាបន្ទាន់ ។ យើងបានហៅអាណិកជនចិនមកប្រជុំ ។ អាណិកជនទាំងនោះគឺជាអ្នកដែលធ្លាប់បានធ្វើប្រតិបត្តិការជាមួយខ្ញុំនៅក្នុងប្រទេសកម្ពុជា និងត្រូវបានបញ្ជាពីប៉េកាំងឲ្យមកទីក្រុងសៃហ្គនចឺឡឹននៅឆ្នាំ១៩៧៥ ។ កិច្ចប្រជុំត្រូវបានរៀបចំឡើងនៅផ្ទះលេខ៥៣៨/៤៨ វិថីធៀនចាយ ស្រុកលេខ៥ ស្របពេលជាមួយកិច្ចប្រជុំធ្វើឡើងនៅផ្ទះលេខ៣៣៨ ប្លុកសេ ដីឡូត៍ផ្ទះមិញម៉ាងរវាងមូលធនធំៗជនជាតិហឺរដែលមិនយល់ស្របនឹងរបបដែលខ្លួនកំពុងរស់នៅ ។

"នៅពេលប្រជុំដំបូង ខ្ញុំបានលើកឡើងអំពីបទពិសោធន៍របស់យើងកន្លងមកក្នុងការធ្វើ"មហាបដិវត្តន៍វប្បធម៌" នៅទីក្រុងហាណូយ ហៃហ្វុង និងគ័ងមិញ...នៅក្នុងអំឡុងពេលនៃការតស៊ូរបស់វៀតណាមប្រឆាំងនឹងអាមេរិកាំងដែលមានការដាក់ទិសដៅពីស្ថានទូតចិន ហើយពត៌មានស្តីអំពីសកម្មភាពទាំងអស់នេះគឺបានមកពី ជិន ជឿង ហ្សាង, ជិន ហ៊ីត, វឿង គ័ន ធៀន, លីវ ខាក ហៀន, ហ័ង ហ្សឿង ថាញ់ និង វឿង ញូ ។

"ខ្ញុំបានប្រាប់អ្នកទាំងនេះថា កាលពីមុន បដិវត្តន៍វប្បធម៌អធនបានបរាជ័យនៅក្នុងប្រទេសវៀតណាមមែន តែឥឡូវប្រហែលជាទទួលបានជោគជ័យច្រើនជាង ។ ខ្ញុំនៅចាំបានថានៅពេលស្ថានទូតចិនរៀបចំដំណើររបស់ខ្ញុំទៅប្រទេសចិនក្នុងខែកញ្ញា ឆ្នាំ១៩៧៦ និងឲ្យខ្ញុំស្នាក់នៅសណ្ឋាគារសម្រាប់ប្រជាជនចិននៅបរទេសដែលនៅទីក្រុងគ័ងតុង តំណាងរបស់គណៈកម្មការមជ្ឈិមចិនប្រចាំនៅបរទេសបានប្រាប់ខ្ញុំគ្រប់ពេលដែលគាត់បានជួបខ្ញុំថា "ភាពអស្ចារ្យនៃបដិវត្តន៍វប្បធម៌អធនគឺថា បដិវត្តន៍នេះអាចធ្វើបានមិនត្រឹមតែនៅប្រទេសចិនទេ តែអាចធ្វើបាននៅភាគផ្សេងៗទៀតនៃពិភពលោកយើងនេះ ជាពិសេសគឺនៅភូមិភាគអាស៊ី-អគ្នេយ៍ ។ ប្រទេសចិនដែលជាប្រទេសធំជាងគេនិងមានអំណាចខ្លាំងជាងគេនៅក្នុងទ្វីបអាស៊ី ត្រូវតែដើរតួនាទីដ៏សំខាន់នៅក្នុងភូមិភាគអាស៊ី-អគ្នេយ៍ ។ ដើម្បីសម្រេចគោលដៅនេះ ជាការចាំបាច់ណាស់ក្នុងការលើកកម្ពស់មហាបដិវត្តវប្បធម៌អធន ផ្សព្វផ្សាយជាសាធារណៈនូវគំនិតរបស់ ម៉ៅ សេ ទុង ឲ្យបានជ្រួតជ្រាបសុសសាយដោយប្រើប្រាស់អាណិកជនចិនជាស្នូល ជាការជំរុញ និងជាកម្លាំងស្រួចនៅក្នុងចលនានេះ ទិញជនជាតិដើមទាំងអស់ ព្រមទាំងបញ្ចុះបញ្ចូលមហាជនដែលងាយស្រួលដឹកនាំ ក្នុងគោលបំណងដើម្បីធ្វើឲ្យបដិវត្តន៍នេះសុសសាយដូចជាភ្លើងឆេះវាលស្មៅនៅក្នុងប្រទេសនៅភូមិភាគអាស៊ី-អគ្នេយ៍ ដោយបង្ខំរដ្ឋាភិបាលរបស់ប្រទេសទាំងអស់ឲ្យដើរតាម

ប្រទេសចិន ។ ទីក្រុងប៉េកាំងបានបញ្ជូនខ្ញុំមកទីក្រុងភ្នំពេញ ហើយបេសកកម្មមួយក្នុងចំណោមកិច្ចការផ្សេងៗទៀតរបស់ខ្ញុំគឺជំរុញដំណើរការធ្វើបដិវត្តន៍វប្បធម៌នៅទីនោះ ។

មនោគមវិជ្ជានៃបដិវត្តវប្បធម៌មិនអាចមានឥទ្ធិពលបានទេ ទោះជាមានទឹកចិត្តរឹងមាំដាច់ខាតរបស់ប្រជាជននៅឥណ្ឌូចិនប្រឆាំងនឹងអាមេរិកាំងយ៉ាងណាក៏ដោយ ។ ប៉ុន្តែឥឡូវមានការប្រែប្រួលខុសពីមុន ពីព្រោះប្រទេសចិនបានក្តាប់កម្ពុជាយ៉ាងណែនក្នុងដៃ ។ វិធីសាស្រ្តក៏មានការផ្លាស់ប្តូរដែរ ឥឡូវនេះមានលក្ខណៈងាយស្រួលក្នុងការផ្លាស់ប្តូរបត់បែនតាមកាលៈទេសៈ មិនសូវផ្ទាល់ៗពេកមានការប្រុងប្រយ័ត្ននិងមានប្រសិទ្ធិភាពជាងមុន ។

«នៅក្នុងអំឡុងពេលប្រជុំទាំងពីរលើកជាមួយមូលធនជនជាតិហ៊័រដែលមិនមានការពេញចិត្ត ខ្ញុំបានលើកមកពិភាក្សានូវការណែនាំរបស់ស្ថានទូតចិនដែលទាក់ទងទៅវិញទៅមកដោយឈ្មោះ ជិន ហ៊័ត ។ ខ្ញុំបានប្រាប់អ្នកទាំងនោះថា ប្រសិនបើចិនបានដើរតួនាទីដឹកនាំនៅក្នុងភូមិភាគអាស៊ី-អគ្នេយ៍ នោះចិននឹងលុបបំបាត់រាល់ឥទ្ធិពលរបស់សហភាពសូវៀតនៅក្នុងតំបន់ ។ ដោយសារប្រទេសចិនមិនអាចធ្វើកិច្ចការដ៏ធំតែម្នាក់ឯងបានចិនត្រូវសហការជាមួយនឹងសហរដ្ឋអាមេរិក ។ វៀតណាមនិងឡាវនៅតែរក្សាជំហរឯករាជ្យរបស់ខ្លួននិងមិនព្រមដើរតាមមាគ៌ារបស់ចិន ។ ដូច្នេះយើងត្រូវប្រើការគាបសង្កត់គ្រប់បែបយ៉ាង ដើម្បីបង្ខំឲ្យវៀតណាមនិងឡាវដើរតាមចិន ។ ទាក់ទងនឹងវៀតណាម ទីមួយយើងត្រូវយកជនជាតិហ័រជាចលនាជំរុញការអនុវត្តនយោបាយទូទៅជាលក្ខណៈជាតិ ។ ចិននឹងជួយកម្ពុជាក្នុងការបង្កសង្រ្គាមព្រំដែន មិនត្រឹមតែធ្វើឲ្យវៀតណាមមានគ្រោះថ្នាក់ទេ ប៉ុន្តែថែមទាំងបង្កភាពច្របូកច្របល់នៅក្នុងចំណោមជនជាតិហ៊័រ ដោយប្រើគ្រោះថ្នាក់នៃសង្រ្គាមដើម្បីជំរុញឲ្យប្រជាជនហ៊័រ ប្រមែប្រមូលយកទ្រព្យសម្បត្តិកេរអាកររបស់ខ្លួនយកទៅប្រទេសចិន ដើម្បីបញ្ឈប់កិច្ចខិតខំប្រឹងប្រែងរបស់វៀតណាមក្នុងការកសាងប្រទេសឡើងវិញក្រោយពីមានសង្រ្គាមខ្ទេចខ្ទាំអស់ជាច្រើនទសវត្សរ៍ ។ ក្រោយពីការឃោសនាប្រជាជាតិហ៊័រជាច្រើនឲ្យចេញទៅប្រទេសចិនរួចមក យើងនឹងធ្វើការតវ៉ាប្រឆាំងនឹង«ការមិនទទួលស្គាល់ឲ្យចូលក្នុងសង្គម ការធ្វើទុក្ខបុកម្នេញ និងការបណ្តេញ» អាណិកជនចិនចេញពីប្រទេសវៀតណាម ដើម្បីបង្កើតការគាបសង្កត់មួយទៀត ។ ប្រសិនបើយើងទទួលបានជោគជ័យក្នុងការបង្ខំឲ្យវៀតណាមចុះចាញ់ក្រោមព្រនង់របស់ចិន ប្រទេសផ្សេងៗទៀតនៅក្នុងភូមិភាគអាស៊ី-អគ្នេយ៍នឹងដើរតាម ពីព្រោះវៀតណាមជាប្រទេសខ្លាំងនិងមានភាពចចេសរឹងរូសមិនព្រមធ្វើការផ្លាស់ប្តូរជាងបណ្តាប្រទេសនានានៅក្នុងតំបន់ ។ សហរដ្ឋអាមេរិកបានបាក់មុខបាក់មាត់ដោយសារចាញ់សង្រ្គាមវៀតណាម ។ ប្រសិនបើចិនអាចធ្វើឲ្យវៀតណាមបរាជ័យនោះ វាកាន់តែជាសក្ខីភាពបញ្ជាក់ពីសុឆន្ទៈរបស់យើងចំពោះសហរដ្ឋអាមេរិក ហើយនិងបង្ហាញថាចិនពិតជាខ្លាំងមែន ។

«នៅក្នុងកិច្ចប្រជុំនេះ ជិន ហ៊័ត បាននិយាយប្រាប់យើងត្រួសៗអំពីវិធានការជាក់ស្តែងដែលផ្តល់ដោយគណៈកម្មាធិការនៃយុទ្ធនាការដឹកនាំដោយឯកអគ្គរដ្ឋទូត ឈិន : ការផ្តោតទៅលើការផ្សព្វផ្សាយការភ័យខ្លាចសង្រ្គាមក្នុងគោលបំណងរំខានដល់ជីវិតសង្គម ។ គណៈកម្មាធិការបានឃោសនាពាក្យចចាមអារ៉ាមថា កងទ័ពចិនជាអ្នកបើករថក្រោះ ហើយកូរ៉េជាអ្នកបើកយន្តហោះមកជួយកម្ពុជា ដើម្បីធ្វើសង្រ្គាមប្រឆាំងនឹងវៀតណាម ។ នៅពេលទន្ទឹមគ្នានេះ យើងក៏រៀបចំផ្សព្វផ្សាយពាក្យចចាមអារ៉ាមគំរាមថា វៀតណាមនឹងរឹបអូសយកមាសរបស់ប្រជាជនម្នាក់ៗយកទៅទិញអាវុធយុទ្ធភណ្ឌ គ្រាប់រំសេវនិងប្រេងឥន្ធនៈ ដើម្បីធ្វើសង្រ្គាមជាមួយកម្ពុជា ។ ភាពច្របូកច្របល់នឹងកើតមានឡើង ។ ដោយសារចិននឹងជួយកម្ពុជាពង្រីកសង្រ្គាមម្នាក់ៗត្រូវបានជំរុញឲ្យស្តុកស្បៀងអាហារទុកត្រៀមបង្ការក្រែងមានហេតុការណ៍អ្វីកើតឡើង ។

«ប្រទេសចិនមានកម្លាំងខ្លាំងក្លាណាស់ ហើយដោយហេតុនេះហើយបានជាកម្ពុជាដែលមានប្រជាជនចំនួន៨លាននាក់ប៉ុណ្ណោះហ៊ានប្រឈមមុខនឹងវៀតណាម ។ នៅក្នុងចំណុចរបត់នេះ អ្វីដែលអាណិកជនត្រូវធ្វើគឺវិលត្រឡប់ទៅប្រទេសចិនវិញ ។ ការណ៍នេះនឹងធ្វើឲ្យអ្នកទាំងនេះទទួលបាននូវគុណសម្បត្តិជាជាអ្នកស្នេហាជាតិ ហើយរួចចាកផុតពី«ការមិនទទួលស្គាល់ជាសមាជិកសង្គម ការធ្វើទុក្ខបុកម្នេញ និងការបង្ខំឲ្យចេញ»

ពីសំណាក់អាជ្ញាធរវៀតណាម ។

«នៅពេលដែលខ្ញុំនិយាយអំពីនយោបាយចិនទៅលើកិច្ចសហប្រតិបត្តិការជាមួយនឹងសហរដ្ឋអាមេរិកនៅក្នុងពេលជួបប្រជុំជាមួយមូលធនជនជាតិហ័រធំៗ ម្នាក់ៗមើលទៅសុទ្ធតែមានការពេញចិត្ត ទោះបីជាគ្មានអ្នកណាម្នាក់មានបំណងចង់វិលត្រឡប់ទៅប្រទេសចិនវិញយ៉ាងណាក៏ដោយ» ។ នេះគឺជាការលាតត្រដាងមួយដែលគួរឲ្យភ្ញាក់ផ្អើល÷ «ទាំង ជិន ហ័គ និង ជិន ជឿងហ្វាងបានប្រាប់ខ្ញុំថា ទោះបីជាខ្ញុំប្រើវិធីសាស្ត្រអ្វីក៏ដោយ ក៏ខ្ញុំមិនភ្លេចឆ្នាំក្រហមវ័យក្មេងនៅក្នុងសាលា «មើលថៃ» និងផ្ដោតសំខាន់ទៅលើសិស្សានុសិស្សជនជាតិហ័រ ។ ខ្ញុំត្រូវទាញយកសមត្ថភាពរបស់គ្រូបង្រៀននិងបញ្ញវន្តជនជាតិហ័រដើម្បីជះឥទ្ធិពលដល់សិស្សនិងមាតារបស់សិស្ស ។ មិនដែលភ្លេចម្ដងណាឡើយថា ឆ្នាំក្រហមវ័យក្មេងនេះហើយដែលធ្វើឲ្យសភាពការណ៍មានការផ្លាស់ប្ដូរនៅក្នុងប្រទេសចិននៅសម័យមុនពេលមានបដិវត្តន៍វប្បធម៌ចិន ។ ប្រសិនបើយើងអាចយកឆ្នាំក្រហមវ័យក្មេងរបស់យើងមកដាក់នៅតាមវិថីនៅក្នុងទីក្រុងនេះ ម៉្លេះសមមិនដឹងជាអស្ចារ្យយ៉ាងណាទេ» ។

### តួនាទីរបស់ឆ្នាំក្រហមវ័យក្មេង

ក្នុងតួនាទីជាឆ្នាំក្រហមវ័យក្មេងដែលជាអ្នកសង្គ្រោះអ្នកជំនួញធំៗជនជាតិហ័រ លី វ៉ានកៀន ដែលជាអ្នករួមការជាមួយនឹង លី ឌៀបភូ បានធ្វើចម្លើយសារភាពដូចនេះថា÷ «ខ្ញុំជានាយកសាលា មិញឌឹក ស្ថិតនៅក្នុងស្រុក១១ទីក្រុងហូជីមិញ ។ នេះជាសាលាដ៏ធំមួយដែលមានគ្រូបង្រៀនចំនួន១០៥នាក់និងសិស្សនុសិស្សចំនួន៤៥០០នាក់ ភាគច្រើនមានដើមកំណើតជាជនជាតិហ័រ ។ យើងជាផ្នែកមួយនៅក្នុងគម្រោងការចូលរួមធ្វើឲ្យមានភាពច្របូកច្របល់ក្នុងគោលបំណងយកជាលេសបន្ថែមសម្រាប់ចោទប្រកាន់វៀតណាមចំពោះអំពើ«មិនចាត់ចូលក្នុងសង្គមការធ្វើទុក្ខបុកម្នេញ និងការបណ្ដេញជនជាតិចិន» ចេញពីប្រទេសខ្លួន និងជំរុញឲ្យជនជាតិហ័រត្រឡប់ទៅប្រទេសចិនវិញតាមការអំពាវនាវពីមាតុភូមិ ។ យើងបានកសាងកម្លាំងជនជាតិហ័រ បានជាច្រើនដែលធ្វើការនៅក្នុងការិយាល័យរោងចក្រនានានិងគ្រូបង្រៀនជនជាតិ ព្រមទាំងបានធ្វើឲ្យមានការតវ៉ាជាច្រើនប្រឆាំងនឹងរបបថ្មីនេះ ដើម្បីពង្រីកបណ្ដាញឲ្យបានកាន់តែធំឆាយស្រួលក្នុងការធ្វើការជាមួយនឹងសហគមជនជាតិហ័រ ។ ខ្ញុំប្រាប់អ្នកចូលថ្មីថា «ចិនបានយល់ព្រមជាមួយសហរដ្ឋអាមេរិក ដើម្បីដាក់ការគាបសង្កត់ទៅលើប្រទេសវៀតណាមផ្ដល់អាវុធទៅឲ្យប្រទេសកម្ពុជា ដោយបញ្ជូនអ្នកជំនាញការនិងទីប្រឹក្សាឲ្យទៅជួយបង្ហឹកកងទ័ពកម្ពុជាព្រមទាំងពង្រីកសង្គ្រាមទល់នឹងវៀតណាម ។ ជាការច្បាស់ណាស់ការណ៍នេះនឹងនាំទៅដល់សង្គ្រាមធំផ្ទុះឡើងរវាងចិននិងវៀតណាម ។ នៅពេលសង្គ្រាមផ្ទុះឡើងវៀតណាមនឹងធ្វើឲ្យជនជាតិហ័រធ្លាក់ទៅក្នុងថ្លុកឈាមពុំខាន ។ ប្រសិនបើជនជាតិចិនមិនព្រមវិលត្រឡប់ទៅស្រុកយើងវិញទេ នៅពេលមកដល់ក្លាមកងទ័ពចិននិងកម្ពុជានឹងសម្លាប់យើងចោលទាំងអស់ ។ ដូច្នេះយកល្អពេលនេះជនជាតិហ័រគួរតែរកផ្លូវត្រឡប់ទៅស្រុកកំណើតវិញទៅកាន់តែឆាប់កាន់តែល្អ ។ អ្នកវិលត្រឡប់មុនគេនឹងមានសិទ្ធិសេរីភាព និងអភ័យឯកសិទ្ធគ្រប់បែបយ៉ាងទាំងអស់ ។ ចំណែកអ្នកមកបន្ទាប់មិនត្រឹមតែត្រូវបដិសេធមិនធ្វើទិដ្ឋាការឲ្យចេញទៅប្រទេសអាឡឺម៉ង់ខាងលិច កាណាដា ចក្រភពអង់គ្លេស បារាំងទេ ប៉ុន្តែថែមទាំងត្រូវបញ្ជូនឲ្យទៅធ្វើស្រែចម្ការនៅជនបទឆ្ងាយៗបំផុតទៀត ។ ត្រូវយកហេតុផលថា មាន«ការមិនចាត់ចូលក្នុងសង្គមការធ្វើទុក្ខបុកម្នេញ និងការបង្ខំអាណិកជនចិន» ។ បើគេឲ្យទៅតំបន់សេដ្ឋកិច្ចត្រូវបដិសេធដាច់ខាត ។ ប្រសិនបើវៀតណាមនៅតែបន្តបញ្ជូនទៅទៀត អ្នកឯងត្រូវប្រឆាំងតវ៉ាថា វៀតណាមកំពុងតែ «មិនចាត់ចូលក្នុងសង្គមនិងការបណ្ដេញអាណិកជនចិន» ។

«គ្រូបង្រៀនជនជាតិចិន និងសិស្សានុសិស្សវិទ្យាល័យនិងអនុវិទ្យាល័យដែលមានអាយុលើសពី១៨ឆ្នាំ និងត្រូវកាន់អត្តសញ្ញាណប័ណ្ណ ត្រូវតែបដិសេធមិនបំពេញទម្រង់បែបបទ ។ ធ្វើរបៀបនេះអាចឲ្យសិស្សានុសិស្សទាំងនោះរួចផុតពីកាតព្វកិច្ចក្នុងការគោរពច្បាប់នៃប្រទេសវៀតណាម ព្រមទាំងបង្ហាញថាខ្លួនពិតជាស្រលាញ់ និងមានភក្តីភាពចំពោះមាតុភូមិដូចដែលបានណែនាំកន្លងមកតាមរយៈស្ថានទូតចិនប្រចាំនៅទីក្រុងហាណូយ ។ ត្រូវយកចិត្តទុកដាក់ចំពោះគ្រួសារជនជាតិហ័រដែលមានកូនចូលបម្រើក្នុងជួរកងទ័ពវៀតណាមឬចូលរួមចលនាប្រឆាំងនឹងការឈ្លានពានរបស់សហរដ្ឋអាមេរិក ។ ស្ថានទូតចិនបានបញ្ជាក់ច្បាស់ថារាល់អំពើណាក៏ដោយ ទោះតូចក្ដី ធំក្ដីដែលរារាំងដល់កិច្ចខិតខំប្រឹងប្រែងកសាងប្រទេសវៀតណាមសាជាថ្មី

ឡើងវិញ និងធ្វើឲ្យសង្គមច្របូកច្របល់ នៅពេលនេះនឹងត្រូវបានចាត់ទុកថាជាសកម្មភាពស្នេហាជាតិ ដាក់ស្តែងដូចជាការគាំទ្រដល់មិត្តកម្ពុជាដែលបានបង្ហូរឈាមដើម្បីប្រទេសចិនក្នុងការប្រឈមមុខជាមួយនឹងវៀតណាម ។ ជាងនេះទៅទៀត យើងត្រូវប្រឆាំងនឹងការបម្រើយោធា ។ ការណ៍នេះនឹងមានសារប្រយោជន៍ពីរយ៉ាង: ទី១ ដើម្បីយកចិត្តចិន ទី២ កុំឲ្យកូនចៅយើងមានគ្រោះថ្នាក់នៅក្នុងសមរភូមិ ព្រមទាំងឲ្យកូនចៅអាចបន្តរស់នៅទីក្រុងដោយសុខសាន្ត ។ យើងត្រូវតែបង្កការធ្វើកូដកម្មរបស់និស្សិតនិងសិស្ស ហើយឲ្យសិស្សនិងនិស្សិតធ្វើសកម្មភាពតាមថ្នល់នានាដើម្បីធ្វើឲ្យខូចសណ្តាប់ធ្នាប់សាធារណៈ និងញុះញង់ឲ្យកម្លាំងសន្តិសុខបើកការវាយប្រហារ ធ្វើដូចនេះដើម្បីយកលេសធ្វើបាតុកម្មប្រឆាំងនឹង«ការមិនចាត់ចូលក្នុងសង្គម ការធ្វើទុក្ខបុកម្នេញ និងការបង្ខំអាណិកជនចិន» ។

នៅក្នុងម៉ោងរៀន លោកគ្រូអ្នកគ្រូត្រូវតែព្យាយាមបញ្ចូលចំណុចទាំងអស់នេះពន្យល់ដល់សិស្សានុសិស្សបង្កឲ្យមានអារម្មណ៍ស្រឡាញ់ប្រទេសធំៗ ប្រកាន់ជាតិសាសន៍ និងអមិត្ត និងកសាងគំនិតប្រឆាំងនឹងវៀតណាម ។ យើងត្រូវជ្រើសរើសសិស្សណាដែលមានកំហឹងឲ្យសរសេរខិត្តប័ណ្ណ និងពាក្យស្លោកហើយដើរបិទនៅទីប្រជុំជនជនជាតិហ័រ ក្នុងគោលបំណងមួលបង្កាច់នយោបាយរបស់វៀតណាមក្នុងការទម្រង់ពាណិជ្ជកម្មមូលធន និងប្រែក្លាយពាណិជ្ជករមូលធនឲ្យក្លាយជាអ្នកផលិតវិញប្រឆាំងចំពោះការបម្រើយោធានិងយុទ្ធនាការបង្កើតតំបន់សេដ្ឋកិច្ចថ្មី ។ នៅក្នុងសាលារៀនចិនបើមានធ្វើការពិនិត្យឈាមដើម្បីចាក់ថ្នាំការពាររបេង យើងត្រូវតែធ្វើឲ្យមានការតវ៉ាពុះកញ្ជ្រោលឡើងប្រឆាំងនឹង«ការរៀបចំផែនការបង្ខំឲ្យបរិច្ចាគឈាមសម្រាប់ទាហានរងរបួសដោយសារសង្គ្រាមព្រំដែនជាមួយកម្ពុជា» ។ ពេលនោះឪពុកម្តាយ ឬអាណាព្យាបាលរបស់សិស្សនឹងមកសាលាមូលមីរដេរដាសនៅតាមរបងសាលា ដើម្បីទាមទារកូនរបស់ខ្លួនមកវិញដោយបង្កើតជាភាពរញ៉េរញ៉ៃនៅក្រៅសាលារៀនជាមិនខាន ។ ទន្ទឹមពេលនេះដែរ យើងនឹងអំពាវនាវឲ្យមានការបរិច្ចាគឈាមជាសម្ងាត់នៅក្នុងចំណោមជនជាតិហ័រដើម្បីបញ្ជូនឲ្យមិត្តយើងនៅក្នុងប្រទេសកម្ពុជា ។ សិស្សានុសិស្សទាំងនោះត្រូវរៀបចំជាស្រេចសម្រាប់ការចាកចេញរបស់ជនជាតិហ័រចាកចេញ និងប្រាប់ប្រជាជនទាំងអស់នោះថាកប៉ាល់ចិននឹងមកដល់កំពង់ផែសៃហ្គនមកដឹកអាណិកជនចិនត្រឡប់ទៅស្រុកវិញ ហើយថាកប៉ាល់នឹងអមដំណើរដោយនាវាចំបាំងដែលបំពាក់ដោយអាវុធទំនើបៗមិនធម្មតាទេ ។ ឆ្នាំក្រហមវ័យក្មេងនឹងហុច «សៀវភៅខៀវ»ស្រង់គំនិតរបស់ ម៉ៅ សេទុង តៗគ្នា និងថតជាខ្សែអាត់នូវប្រសាសន៍របស់មេដឹកនាំប៉េកាំងហាត់ច្រៀងចម្រៀងចិន និងស្រែកជយឃោសពាក្យស្លោកចិនព្រមទាំងរៀបចំជាកម្លាំងអាណិកជនចិននៅពេលដែលកប៉ាល់មកដល់» ។

## សច្ចាប្រណិធានរបស់ឆ្នាំក្រហមវ័យក្មេង

លី ជុង កៀន បានបន្តទៀតថា÷«សាលាមិញឌឹករបស់ខ្ញុំនិងសាលាដទៃទៀតសិស្សានុសិស្សជនជាតិចិនជាច្រើនដូចជាកាម ឡុង, ជិន ទាន និង ហុ ហ្សាង សុទ្ធតែបានជោគជ័យជាច្រើនក្នុងការធ្វើឲ្យចលនាប្រឆាំងនឹងវៀតណាមផ្ទុះឡើងដូចដែលគណៈកម្មាធិការដឹកនាំនៃស្ថានទូតចិនបានប៉ងប្រាថ្នាទុក ។ យើងបានបំភ័យជនជាតិហ័រថា «អ្នកទាំងនោះបានលក់ទ្រព្យសម្បត្តិចោលអស់ ហើយទិញជាមាសនិងពេជ្រ ឥឡូវនេះនៅចាំតែកប៉ាល់មកដឹកយកទៅប៉ុណ្ណោះ ។ ខ្ញុំដឹងថានៅតាមសាលាបង្រៀនភាសាចិនមួយចំនួនបានធ្វើការដោះស្រាយឲ្យគ្រូបង្រៀន និងសិស្សសាលាបានចេញទៅទីក្រុងហាណូយដោយយកលេសថាសុំច្បាប់ទៅលេងបងប្អូន ឬទៅដើរលេងមើលទេសភាពនៅរដ្ឋធានី រួចអ្នកទាំងនោះនឹងបានចូលទៅទាក់ទងជាមួយនឹងស្ថានទូតចិនឬបន្តឆ្លងកាត់តាមព្រំដែនទៅ ឡៅ កាយ និង ម៉ុង កាយ ដោយសំបុត្រអនុញ្ញាតក្លែងក្លាយ ។

«គ្រូបង្រៀនមិនគួរនិយាយភូតកុហកទេ ហើយការបញ្ចុះបញ្ចូលឲ្យប្រជាជនប្រព្រឹត្តបទឧក្រិដ្ឋគឺជាអំពើអមនុស្សធម៌និងប្រឆាំងនឹងបដិវត្តន៍ ប៉ុន្តែយើងមិនអាចជួយបានទេ ។ ស្ថានទូតចិនបានចេញបញ្ជាមកយើង ហើយមាតុភូមិកំពុងតែដង្ហើយហៅយើងទៀត ។

«នៅខាងជើងមិនមានសាលាជនជាតិហ័រច្រើនឬសាលាដែលមានសិស្សសាលារៀនច្រើន ដូចនៅទីក្រុងសៃហ្គនចិឡឹនទេ ។ ដូច្នេះវិធីសាស្ត្រធ្វើឲ្យសិស្សសាលាជនជាតិហ័រចាកចេញទៅប្រទេសចិន មិនអាចបើកចំហទូលាយដូចនៅខាងត្បូងបានទេ» ។

**(នៅមានត)**

**(តពីលេខមុន)** នៅក្នុងខែមេសា និងខែឧសភា ឆ្នាំ១៩៧៧ កម្មាភិបាលមកពីភូមិភាគពាយ័ព្យត្រូវបានចាប់ផ្តើមនាំយកមកមន្ទីរស-២១ ។ មានអ្នកខ្លះមានទំនាក់ទំនងជាមួយនឹង«អ្នកបេះដូង» ហើយអ្នកខ្លះទៀតត្រូវបានបោសសម្អាតដោយសារខ្លួនធ្វើការបំផ្លាញផែនការបួនឆ្នាំ ។ នៅដំណាច់ឆ្នាំ១៩៧៧ លេខានិងអ្នកជំនួយការទាំងអស់នៅតំបន់ទាំង៧ក្នុងភូមិភាគពាយ័ព្យត្រូវបានបោសសម្អាត ហើយប្រជាជនរាប់សែននាក់ត្រូវបានសម្លាប់ចោល ។ មុនដំណាច់ឆ្នាំ ប្រជាជនមូលដ្ឋានជាច្រើនពាន់នាក់(ពោលគឺអ្នកដែលមិនបានរស់នៅក្រោមការគ្រប់គ្រងរបស់ លន់ ណុល ក្នុងពេលសង្គ្រាមស៊ីវិល) ត្រូវបាននាំយកមកពីភូមិភាគនិរតី ទៅភូមិភាគពាយ័ព្យតាមរថភ្លើង ។ ប្រជាជននៅភូមិភាគបស្ចិមនិងនិរតី ត្រូវបានយកមកបន្តបន្ទាប់តាមក្រោយ ហើយស្រុកទាំងឡាយនៅក្នុងភូមិភាគពាយ័ព្យត្រូវបានកម្មាភិបាលខ្មែរក្រហមទាំងនេះធ្វើការបោសសម្អាតនិងផ្លាស់អ្នកដឹកនាំ«ដែលគ្មានភក្តីភាព» ចេញ ។ នៅតាមស្រុកខ្លះ កម្មាភិបាលរៀបចំឲ្យមានការហូបបាយរួមដាក់ការងារយ៉ាងធ្ងន់ឲ្យប្រជាជនធ្វើនៅតាមជនបទ ។ ការបោសសម្អាតនិងនយោបាយឃោរឃៅរបស់អ្នកមកដល់ថ្មីបណ្តាលឲ្យមានជនភៀសខ្លួនរាប់រយនាក់នាំមកនិយាយប្រាប់អ្នកកាសែត និងអ្នកការទូតនៅក្នុងប្រទេសថៃ ។




**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី៣: ការជ្រើសរើសសត្រូវ**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដ្លឺរ**

ពេញមួយឆ្នាំ១៩៧៧ ទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមបានធ្លាក់ចុះដោយសារតែវៀតណាមបដិសេធមិនព្រមចរចាអំពីបញ្ហាព្រំដែនទៅតាមលក្ខខណ្ឌរបស់កម្ពុជាប្រជាធិបតេយ្យ ។ កម្ពុជាប្រជាធិបតេយ្យបានបង្កើនការគាបសង្កត់ទៅលើប្រទេសវៀតណាមតាមរយៈការផ្សព្វផ្សាយតាមរលកធាតុអាកាសឃោសនាប្រឆាំងនឹងវៀតណាម និងការវាយលុកតាមព្រំដែន ។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ឯកអគ្គរដ្ឋទូតវៀតណាមប្រចាំនៅកម្ពុជាប្រជាធិបតេយ្យឈ្មោះ ផាន់ វ៉ាន់បា បាននិយាយជាមួយ ប៉ុល ពត ដោយលើកយកបញ្ហាទាក់ទងនឹងការអះអាងដែលថា របបកម្ពុជាប្រជាធិបតេយ្យចង់«វាយយកវិញ» នូវទឹកដីនៅភាគខាងត្បូងប្រទេសវៀតណាមដែលប្រជាជនកម្ពុជាហៅថា «កម្ពុជាក្រោម» ។ ប៉ុល ពត បានឆ្លើយតបទៅវិញថា «នេះមិនមែនជាគោលបំណងពិតប្រាកដរបស់យើងទេ ។ បញ្ហាគឺថាយើងមានខ្មាំងនៅក្នុងជួរយើង» ។

ការឆ្លើយតបរបស់ ប៉ុល ពត ជាការជំទាស់ទៅនឹងការវិភាគមួយដែលថា តើ «ខ្មាំងនៅក្នុងជួរយើង» ជាមនុស្សដែលចង់វាយវៀតណាមឬជាមនុស្សដែលធ្វើឲ្យ ប៉ុល ពត វាយប្រហារវៀតណាម? ហើយតើធ្វើម៉េចទើបវៀតណាមនឹងអាចកំណត់បានអំពីបំណងពិតប្រាកដរបស់កម្ពុជា?

## សង្គ្រាមជាមួយវៀតណាម

នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ នៅក្នុងសុន្ទរកថាមួយផ្សាយតាមរលកធាតុអាកាសវិទ្យុជាតិកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត បានប្រកាសនិងរំឭកដល់តួនាទីរបស់បក្សកុម្មុយនិស្តកម្ពុជានៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ ការសម្រេចចិត្តរបស់ ប៉ុល ពត ក្នុងការបើកចំហមុខបក្សកុម្មុយនិស្តកម្ពុជា ប្រហែលជាមានការបង្ខំពីប្រទេសចិនដែលហៀបនឹងមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ។ សុន្ទរកថារបស់ ប៉ុល ពត ត្រូវបានផ្សាយតាមរលកវិទ្យុនាថ្ងៃទី៣០ ខែកញ្ញា ជូនពេលនឹងបុណ្យរំឭកខួបលើកទី១៧ នៃការបង្កើតបក្សដែរ ។ នៅពេលនោះ ប៉ុល ពត បានទៅដល់ទីក្រុងប៉េកាំងរួចទៅហើយ ។ នៅក្នុងការថ្លែងសុន្ទរកថានោះ ប៉ុល ពត បាននិយាយដល់ «ពួកប្រតិកិរិយាមួយក្តាប់តូច» ដែលកំពុងតែបង្កប់ខ្លួននៅក្នុងកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមិនបានរៀបរាប់ឈ្មោះនិងមិនបាន

កត់សម្គាល់ដោយមានលក្ខណៈសុទិដ្ឋិនិយម សមតាមឱកាសនោះឡើយ ។ ស្របពេលនោះដែរ កម្លាំងប្រដាប់អាវុធនៅភូមិភាគបូព៌ាបានចាប់ផ្តើមការវាយប្រហារស្ងាត់ៗទៅលើប្រទេសវៀតណាម ។

នៅចុងខែតុលា ពោលគឺមួយរយៈខ្លីក្រោយពីការវិលត្រឡប់របស់ ប៉ុល ពត មកពីប្រទេសចិន កងទ័ពវៀតណាមបានវាយប្រហារយ៉ាងធ្ងន់ធ្ងរមកលើប្រទេសកម្ពុជា ។ កងទ័ពវៀតណាមស្ថិតនៅក្នុងទឹកដីកម្ពុជាម្តុំខេត្តស្វាយរៀងរហូតដល់ដំណាច់ឆ្នាំ ហើយវៀតណាមបានកេណ្ឌអ្នកទោសរាប់រយនាក់ (មួយចំនួនធំប្រហែលជាអ្នកដែលរត់ចេញពីប្រទេសកម្ពុជា) ទៅក្នុងប្រទេសវៀតណាមនៅពេលដែលប្រតិបត្តិការរបស់ខ្លួនត្រូវបានបញ្ចប់ ។ ប្រទេសទាំងពីរមិនបានផ្សព្វផ្សាយជាសាធារណៈអំពីជម្លោះនេះឡើយ ប៉ុន្តែមុនពេលដែលកងទ័ពវៀតណាមដកចេញពីកម្ពុជានៅដើមខែមករា ឆ្នាំ១៩៧៨ភ្លាម កម្ពុជាប្រជាធិបតេយ្យក៏បានកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយនឹងទីក្រុងហាណូយ ។ បន្តិចក្រោយមកមជ្ឈិមបក្សក៏បានប្រកាសជ័យជម្នះជាផ្លូវការរបស់ខ្លួន ។ ប៉ុល ពត បានចុះទៅដល់មន្ទីររបស់ សោ ភឹម នៅឃុំសួង ដើម្បីប្រារព្ធពិធីនេះ ។ ប៉ុល ពត បានអំពាវនាវអ្នកចូលរួមស្តាប់ទាំងអស់ឲ្យធ្វើសង្គ្រាមតាមគ្រប់មធ្យោបាយប្រឆាំងនឹងវៀតណាមដោយរំពុកឡើងវិញនូវឯកសារបន្កទំនាស់មួយមានចំណងជើងថា «មតិបំភ្លឺរបស់៨៧០» ដែលចេញផ្សាយនៅក្នុងខែនោះ ។ឯកសារនេះបានប្រៀបធៀបកងទ័ពវៀតណាមទៅនឹង «ស្វាដែលស្រែកចេចចាចនៅក្នុងព្រៃ» ហើយបានសង្កត់ធ្ងន់ថា ប្រសិនបើយុទ្ធជនខ្មែរម្នាក់អាចសម្លាប់វៀតណាមចំនួន៣០នាក់ នោះយើងនឹងឈ្នះដោយងាយ ។ បន្ទាប់មកទៀត នៅក្នុងខែដដែលនេះដែរ ប៉ុល ពត បានលើកឡើងថា «កំហឹងជាតិនិងកំហឹងវណ្ណៈ» គឺជាអាវុធនៅក្នុងការតស៊ូ ។ នៅក្នុងសៀវភៅកំណត់ហេតុរបស់ ទុយ និង ប៊ុន ប៉ុល ពត បាននិយាយទៅកាន់ អ្នកគាំទ្រខ្លួនកាលពីថ្ងៃទី១៧ ខែមករា ថា «ពេលវ៉ៃវៀតណាម បើអ្នកឯងវ៉ៃជើង វាមិនអាចវារបានទេ ។ ប្រសិនបើវ៉ៃដៃ វានៅតែអាចដើរបានដដែល» ។ ប៉ុល ពត បានទុកឲ្យអ្នកចូលរួមស្តាប់កំណត់ថាតើជើងនៅទីណាដៃនៅទីណា ។

គំនិតជាតិនិយមដែលផ្អែកទៅលើវប្បធម៌បានក្លាយជាមូលដ្ឋាននៃការឃោសនារបស់កម្ពុជាប្រជាធិបតេយ្យ ហើយ «ខ្មាំង» ដែលយកមកដាក់នៅក្នុងមន្ទីរស-២១នៅក្នុងឆ្នាំ១៩៧៨ ភាគច្រើនលើសលប់គឺត្រូវបានចោទប្រកាន់ថាជាអ្នកសមគំនិតជាមួយនឹងវៀតណាម ។ សុន សេន និងលេខាភូមិភាគកណ្តាល (អតីតភូមិភាគឧត្តរ) ឈ្មោះ កែ ពក ដែលត្រូវបានបញ្ជូនទៅភូមិភាគបូព៌ានៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ ឲ្យទៅមើលការខុសត្រូវចំពោះការប្រយុទ្ធគ្នា ត្រូវបានស្នើឲ្យស្ថិតនៅទីនោះដើម្បីរៀបចំកម្លាំងប្រដាប់អាវុធឡើងវិញ និងបោសសម្អាតអ្នកណាដែលត្រូវបានគិតថាបាន «ឧបត្ថម្ភ» ដល់វៀតណាម ។ នៅត្រឹមខែកុម្ភៈ វៀតណាមបានរៀបចំផែនការសម្ងាត់ដើម្បីផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យ ទាំងតាមវិធីផ្ទៃក្នុងនិងតាមវិធីប្រើកម្លាំង ។ គ្មានភស្តុតាងណាមួយបញ្ជាក់ថាមជ្ឈិមបក្សដឹងអំពីការសម្រេចចិត្តនេះឡើយ ។ ប៉ុន្តែសុបិនដ៏អាក្រក់ ពោលគឺការដែលថាវៀតណាមនឹងលេបទឹកដីកម្ពុជា បាននិងកំពុងក្លាយទៅជាការពិត ។

នៅពាក់កណ្តាលឆ្នាំ១៩៧៨ «ខ្មាំង» ដែលជាមុខសញ្ញារបស់មជ្ឈិមបក្សគឺជាមនុស្សដែលត្រូវបាននិយាយជារឿយៗថា «ក្បាលយួនខ្លួនខ្មែរ» ។ ចំណែកឯនៅមន្ទីរស-២១វិញ អ្នកទោសចបេសរីងរូសមួយចំនួនត្រូវបានបង្ខំឲ្យថ្វាយបង្គំរូបគំនូរដែលមានក្បាលហូជីមិញ ។ «អ្នកក្បត់» ភាគច្រើនត្រូវបានគិតថាមកពីភូមិភាគបូព៌ា ជាកន្លែងដែលការវាយប្រហាររបស់វៀតណាមបានទទួលជោគជ័យ ហើយជាកន្លែងដែលកម្មាភិបាលជើងចាស់រាប់ពី សោ ភឹម ចុះក្រោម មានប្រវត្តិទាក់ទងជាមួយនឹងវៀតណាមចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០មក ។

សោ ភឹម ជាមនុស្សមានប្រជាប្រិយមួយរូបនៅក្នុងភូមិភាគនេះ ។ គាត់ក្លាយជាជនកុម្មុយនិស្តចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០មកម៉្លេះ ។ ទោះបីជាមានការងាយស្រួលជាមួយនឹងលទ្ធិម៉ាក្ស-ឡេនីនដែលគាត់បានយល់យ៉ាងច្បាស់ក៏ដោយ ក៏ សោ ភឹម នៅងឹងអក់មិនដាក់ឲ្យអនុវត្តនូវចំណុចផ្សេងៗដែលមាននៅក្នុងនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាដែរ ដូចជាការហូបបាយរួមនៅក្នុងតំបន់នេះជាដើម ។

នៅតាមតំបន់មួយចំនួន សោ ភឹម បានអនុញ្ញាតឲ្យប្រជាជនស្លៀកពាក់ខោអាវរបស់ខ្លួនប្រើប្រាស់ខោអាវសេរី គឺមិនមែនខោអាវឯកសណ្ឋានជាកសិករឡើយ ។ នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ ពេលគឺក្រោយពីការធ្វើ អត្តឃាតរបស់ សោ ភឹម ជាច្រើនខែមកឧបនាយករដ្ឋមន្ត្រី សុក ធួក (ហៅ វន វើត) បានសារភាពថាបាននិយាយទាក់ទងគ្នាជាមួយ សោ ភឹម នៅក្នុងឆ្នាំ ១៩៧៧ ជាពេលដែលអ្នកទាំងពីរត្រូវបានចោទប្រកាន់ថាជាសមាជិកបក្សពលករកម្ពុជាប្រឆាំងនឹងបក្សកុម្មុយនិស្ត ។ «គាត់បានប្រាប់ខ្ញុំអំពីសភាពការណ៍ល្អនៅភូមិភាគបូព៌ា ។ បក្សពលករកម្ពុជាបានកសាងខ្លួនឯងនៅតាមជួរកងទ័ពនិងប្រជាជន ។ សហករណ៍ត្រូវបានបង្កើតរួចហើយ ប៉ុន្តែការច្រូតកាត់ប្រមូលផលមានលក្ខណៈរគាត់រគាយ ហើយមានការរស់នៅឯកជនតាមការទាមទាររបស់ប្រជាជនដែលមិនចង់ហូបរួម ពីព្រោះធ្វើដូច្នេះគឺមានការខ្វះខាតសព្វបែបយ៉ាង ។ ប្រសិនបើប្រជាជន...រស់នៅជាលក្ខណៈឯកជនដូចជានៅប្រទេសចិន ប្រជាជនច្បាស់ជាមានការសប្បាយចិត្តខ្លាំងណាស់» ។ វន វើត បន្តទៀតថា «គំនិតចង់ដើរតាមគំរូសង្គមនិយមរបស់ចិនត្រូវបានផ្សព្វផ្សាយក្នុងចំណោមប្រជាជន...ជាពិសេសនៅក្នុងភូមិភាគបូព៌ា ភូមិភាគពាយ័ព្យនិងភូមិភាគនិរតី ។ យុទ្ធនាការឃោសនាត្រូវបានចាប់ផ្តើមនៅចុងឆ្នាំ១៩៧៧ ពេលគឺជាពេលដែលជនជាតិកម្ពុជាបានចាប់ផ្តើមឲ្យអាទិភាពនៅលើការកសាងសង្គមនិយម» ។

នៅក្នុងរវាងខែមីនា និងខែឧសភា ឆ្នាំ១៩៧៨ នៅពេលដែលការវាយប្រហារប៉េះប៉ោះប្រឆាំងនឹងវៀតណាមនៅមិនទាន់ចប់នៅឡើយនោះ មជ្ឈមបក្សក៏បន្តការបោសសម្អាតនៅក្នុងភូមិភាគបូព៌ា ។ សោ ភឹម ហាក់ដូចជាដឹងអ្វីដែលកំពុងកើតឡើង ប៉ុន្តែមិនអាចបង្កើនអំណាច ឬប្រមូលកម្លាំងដើម្បីតស៊ូប្រឆាំង ។ នៅក្នុងខែមីនា សោ ភឹម មានជំងឺក្រពះនិងរមាស់ ។ ដោយដឹងថាខ្លួនជាមុខសញ្ញារបស់មជ្ឈមបក្ស សោ ភឹម បានចំណាយពេលមួយចំនួនដើម្បីដើរក្រឡឹងមើលនៅពេទ្យ១៧មេសា ស្ថិតនៅក្នុងទីក្រុងភ្នំពេញ មុនពេលជិះរថភ្លើងទៅភូមិភាគពាយ័ព្យជាមួយនឹងលេខាតំបន់ឈ្មោះ ញ៉ែម រស់ ។

នៅថ្ងៃទី២៥ ខែមីនា ក្នុងខណៈដែល សោ ភឹម កំពុងតែសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យឬប្រហែលជាចុះពិនិត្យមើលភូមិភាគពាយ័ព្យ លេខាតំបន់បស្ចិមឈ្មោះ ជូ ជេត ហៅ ស៊ី ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ។ នៅក្នុងចំណោម ញ៉ែម រស់ និង សោ ភឹម, ជូ ជេត គឺជាអ្នកមុខអ្នកការចាប់តាំងពីមុនសម័យបដិវត្តន៍របស់ ប៉ុល ពត មកម្ល៉េះ ។ អ្នកធ្វើការជាមួយ ជូ ជេត នៅក្នុងជួរបក្សកុម្មុយនិស្តកម្ពុជាតាំងពីពេលនោះមក ដូចដែលយើងឃើញស្រាប់ ត្រូវបានបោសសម្អាតនៅក្នុងឆ្នាំ ១៩៧៦ ។ ជូ ជេត ហាក់ដូចជាអ្នកបដិវត្តដែលមានភក្តីភាពមិនចង់ទទួលយកនូវការឃោសនារបស់របបនេះ ហើយមានការព្រួយបារម្ភចំពោះសុខទុក្ខរបស់ប្រជាជន ។ ប្រពន្ធរបស់ ជេត ឈ្មោះ អ៊ឹម ណន កាន់តំណែងដ៏សំខាន់ ពេលគឺជាលេខាបក្សតំបន់៣២នៅភូមិភាគឧត្តរ ។ ទាំងពីរនាក់ប្តីប្រពន្ធត្រូវបានចាប់ខ្លួនក្នុងពេលជាមួយគ្នា ។ នៅក្នុងចម្លើយសារភាពរបស់ខ្លួន ណន និយាយថាជាអ្នកដាំបាយឲ្យ ប៉ុល ពត នៅក្នុងមន្ទីរ១០០ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ហើយបានព្យាយាមជាច្រើនលើកក្នុងការបំពុល ប៉ុល ពត ប៉ុន្តែមិនបានសម្រេច ។

ពេលនោះមជ្ឈមបក្សក៏បានចេញបញ្ជាឲ្យធ្វើការបោសសម្អាតជាទ្រង់ទ្រាយធំនូវកម្មាភិបាលនៅក្នុងភូមិភាគបូព៌ា ។ នៅក្នុងខែមេសា ឆ្នាំ១៩៧៨ ហើយមានកម្មាភិបាលជាច្រើននាក់ត្រូវបានចាប់បញ្ជូនមកមន្ទីរស-២១ ។ បើតាមការស្មានអ្នកទោសទាំងអស់ត្រូវសម្លាប់ដោយមិនមានការសួរចម្លើយអ្វីទាំងអស់ ។ ការបោសសម្អាតត្រូវបានធ្វើឡើងដោយសមាជិកជាន់ខ្ពស់របស់បក្សកុម្មុយនិស្តកម្ពុជាដឹកនាំដោយ សុន សេន និងគាំទ្រដោយកងកម្លាំងពោរពេញទៅដោយភក្តីភាពដែលពង្រាយពីភូមិភាគនិរតី និងភូមិភាគកណ្តាលក្រោមការគ្រប់គ្រងរបស់ កែ


កែ ពក

ពក ។

នៅពាក់កណ្តាលខែឧសភា ឆ្នាំ១៩៧៨ កែ ពក បានហៅកម្មាភិបាលជាន់ខ្ពស់ នៅភូមិភាគបូព៌ា រាប់ពី សោ ភឹម ចុះមកក្រោមរហូតដល់ថ្នាក់វរសេនាតូច មកប្រជុំនៅមន្ទីររបស់ សោ ភឹម នៅឃុំស្ទួង ដែលកាន់កាប់ដោយ កែ ពក និងមានការពង្រីកមូលដ្ឋានទ័ពដោយមានរថក្រោះនិងកងទ័ពថ្មើរជើងមកពីភូមិភាគដទៃៗ ។ ដោយដឹងថានេះជាការដាក់អន្ទាក់ សោ ភឹម បានបដិសេធមិនព្រមទៅចូលរួមប្រជុំឡើយ ។ អ្នកដែលទៅចូលរួមប្រជុំទាំងប៉ុន្មាន ត្រូវបានចាប់ខ្លួនទាំងអស់ ហើយមានអ្នកខ្លះត្រូវសម្លាប់នៅនឹងកន្លែងតែម្តង ។ មេបញ្ជាការកងពលធំ និងលេខាតំបន់២០,២១ និង២២ ត្រូវបានប្រមូលបញ្ជូនមកមន្ទីរស-២១ ។ ប៉ុន្មានថ្ងៃក្រោយមក កែ ពក បានបញ្ជូនសំបុត្រកោះហៅ សោ ភឹម មក ប្រជុំ ។ កូនចៅដែល សោ ភឹម បញ្ជូនឲ្យទៅសួរបញ្ជាក់ពីគោលបំណងពិតប្រាកដរបស់ កែ ពក ត្រូវបានចាប់ខ្លួនម្តងមួយៗ ។ នៅពេលមិនឃើញកូនចៅរបស់ខ្លួនត្រឡប់មកវិញ សោ ភឹម ក៏ចាប់ផ្តើមសង្ស័យ ។ ដោយមិនអាចឬមិនចង់ជឿថា ប៉ុល ពត ស្ថិតនៅក្រោយការវាយប្រហារទាំងនេះ សោ ភឹម គិតថា សុន សេន និង កែ ពក ជាអ្នកក្បត់ ។

នៅថ្ងៃទី២៥ ខែឧសភា កែ ពក បានធ្វើការវាយប្រហារពីឃុំស្ទួងទៅលើអង្គភាពភូមិភាគបូព៌ាដែលប្រឆាំងជំទាស់នឹងខ្លួន ។ កែ ពក ត្រូវបានវាយតបតមកវិញ ហើយក្រោយមកក៏ត្រូវបានហៅថាជាការបះបោរប្រឆាំងនឹងការកាន់កាប់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ ។ នៅថ្ងៃទី៣១ ខែឧសភា សោ ភឹម ក៏សម្រេចចិត្តមកជួប ប៉ុល ពត នៅភ្នំពេញដើម្បីប្រាប់ពីបុព្វហេតុរបស់ខ្លួន ។ នៅពេលទៅដល់ជ្រោយចង្វារដែលនៅទល់មុខនឹងទីក្រុងភ្នំពេញ និងបានបញ្ជូនសារអំពីការមកដល់របស់គាត់ មានកងកម្លាំងជាច្រើនត្រូវបានបញ្ជូនតាមទូកមកពីភ្នំពេញដើម្បីរកចាប់ខ្លួន សោ ភឹម ។ ពេលនោះ សោ ភឹម ក៏រត់គេចខ្លួនតាមរថយន្តម៉ាកហ្ស៊ីបមួយគ្រឿង រួចចូលលាក់ខ្លួននៅក្នុងវត្តមួយ ។ នៅពេលទន្ទឹមគ្នានេះដែរ ឧទ្ធម្ភាគចក្រជាច្រើនដែលត្រូវបានបញ្ជូនមកពីទីក្រុងភ្នំពេញ បានទម្លាក់ខិត្តប័ណ្ណនៅទូទាំងភូមិភាគ ដោយហៅ សោ ភឹម ថាជាជនក្បត់ ហើយឲ្យយុទ្ធជនទាំងអស់ទម្លាក់អាវុធចុះ ។ បីថ្ងៃក្រោយមកនៅពេលដែលកង៣០០ដែល ត្រូវបានជ្រើសរើសតាមមូលដ្ឋានហៀបនឹងមកចាប់គាត់ សោ ភឹម ក៏បានបាញ់សម្លាប់ខ្លួនឯង ។ ការប្រយុទ្ធគ្នារវាងកងកម្លាំងប្រដាប់អាវុធរដ្ឋាភិបាលនិងអង្គភាពភូមិភាគបូព៌ាចេះតែបន្តទៅអស់ជាច្រើនសប្តាហ៍ ហើយនៅពេលនោះកម្មាភិបាលភូមិភាគបូព៌ាជាច្រើននាក់ រួមទាំងមេបញ្ជាការកងពល ហេង សំរិន (ដែលក្រោយមកក្លាយជាគណៈប្រធានរដ្ឋ) បានរត់ទៅជ្រកកោននៅក្នុងប្រទេសវៀតណាម ដែលនៅទីនោះកម្មាភិបាលទាំងអស់នោះ ក៏ចូលរួមកសាងជាកម្លាំងទ័ពមកវាយលុកចូលប្រទេសកម្ពុជាវិញ ។ នៅខែមិថុនា និងខែកក្កដា នៅក្នុងអ្វីដែលលោក ស៊ីវ ហេឌ័រ បានហៅថា "ការបោសសម្អាតដោយមិនរើសមុខនៅក្នុងជួរបក្ស កងទ័ពនិងប្រជាជនធម្មតា" កងកម្លាំងប្រដាប់អាវុធដែលគាំទ្ររដ្ឋាភិបាលបានសម្លាប់វង្គាលមនុស្សរាប់ពាន់នាក់នៅក្នុងភូមិភាគបូព៌ា ។ នៅក្នុងការផ្ទុះឡើងនូវអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំ និងជាលក្ខណៈប្រព័ន្ធដែលឧបត្ថម្ភគាំទ្រដោយរដ្ឋាភិបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យកងកម្លាំងប្រដាប់អាវុធបានសម្លាប់ប្រជាជនទាំងគ្រួសារៗដែលត្រូវបានសង្ស័យថាជាអ្នកលាក់បាំង និងផ្តល់ជម្រកដល់ "ពួកក្បត់" ។ កងកម្លាំងរដ្ឋាភិបាលបានជម្លៀសជនស៊ីវិលរាប់ម៉ឺននាក់ពីភូមិភាគបូព៌ា ហើយប្រាប់ប្រជាជនថានឹងរកកន្លែងថ្មីឲ្យនៅ ។ ប្រជាជនភាគច្រើនត្រូវបានសម្លាប់នៅតាមផ្លូវខ្លះនិងនៅពេលទៅដល់ភូមិភាគនិរតីជាភូមិភាគដែលបញ្ជូនកម្មាភិបាលមកធ្វើការបោសសម្អាតភូមិភាគបូព៌ាយ៉ាងច្រើនលើសលប់ ។ មានអ្នកខ្លះមកតាំងទីលំនៅនៅភូមិភាគពាយ័ព្យ ។

**(នៅមានត)**

## ពាក្យស្លោកខ្មែរក្រហម

◆ គ្រប់សរសៃញាក់នៃស្នូលគួនិងស្នូលគ្រួ ត្រូវស្ថិតនៅក្រោមស្នូលរួមរបស់ប្រជាជាតិ ខណ្ឌៈ ប្រជាជន និងបដិវត្តន៍ ជាដាច់ខាត។

◆ ខាយសម្រុកលើកស្ទួយនិងកែចម្រើនជីវភាពប្រជាជនឱ្យបានឆាប់រហ័សបំផុត ខាងស្បៀងអាហារ សំលៀកបំពាក់ ផ្ទះសំបែង សុខភាព និងសិក្សាអប់រំ។

(ដកស្រង់ពីសៀវភៅលេខ ០៧៦ កណហ)




***(តពីលេខមុន)***

*ឪពុកម្តាយគ្មានសិទ្ធិគ្រប់គ្រងកូនរបស់ខ្លួនទេ ។ បក្សបានបំពេញការងារជាឪពុកម្តាយរបស់កុមារ ហើយកុមារទាំងអស់ត្រូវតែដឹងគុណនិងគោរពបញ្ជារបស់បក្ស ។ យ៉ាន អះអាងថា ជាការឥតប្រយោជន៍ក្នុងការសុំការលើកលែងណាមួយពីបក្ស ។ យ៉ាន ឲ្យហេតុផលថា សេចក្តីសម្រេចចិត្តត្រូវបានធ្វើឡើងដោយកម្មាភិបាលជាន់ខ្ពស់របស់បក្ស ។ ពេលដែល យ៉ាន សុំតាខ្មៅ ឲ្យកូនរបស់គាត់ឈ្មោះ ធីម បានរស់នៅជាមួយគាត់នៅក្នុងភូមិ តាខ្មៅ ចោទប្រកាន់ថាគាត់ចង់លូកដៃប្រឆាំងនឹងកងប្រវត្តិ-សាស្ត្ររបស់បក្ស ។*

*មុនពេលចាកចេញពីភូមិ សៀ បានទៅជួបឪពុកឈ្មោះ សាយ ហើយប្រាប់ឪពុកអំពីការដែលខ្លួនត្រូវចាត់តាំងឲ្យទៅធ្វើការនៅកន្លែងផ្សេងឆ្ងាយពីភូមិ ។ សៀ បានប្រាប់ឪពុកឲ្យប្រយ័ត្នប្រយែង ហើយប្រឹងប្រែងធ្វើការឲ្យខ្លាំង ។ ពូ សាយ រំឭកអំពីកូនរបស់គាត់ដែលបានស្លាប់បាត់ទៅហើយនោះថា "ខ្ញុំមិនអាចប្រាប់អំពីទីកន្លែងដែលកូនប្រុសខ្ញុំត្រូវទៅ ឬការងារដែលវាត្រូវធ្វើឡើយ ពីព្រោះខ្ញុំគ្មានសិទ្ធិ ។ គ្មានជម្រើសផ្សេងទៀតសម្រាប់កូនខ្ញុំឡើយ ។ ហើយខ្ញុំក៏មិនអាចរកជំនួយពីប្រធានភូមិបានទៀតផង ។ ខ្ញុំដឹងថាកូនប្រុសខ្ញុំមិនចង់ចេញពីភូមិទេ ប៉ុន្តែខ្ញុំមិនអាចជួយវាបាន" ។*

*រូន បានឃើញកូនប្រុសរបស់គាត់ឈ្មោះ ម៉ាត់ ហៅ សុខ នៅមុខសាលាស្រុកកំពង់ត្រឡាច ពេលដែលគាត់វិលត្រឡប់មកពីធ្វើការវិញ ។ ខណៈនោះ ម៉ាត់ បានលួចប្រាប់ឪពុករបស់ខ្លួនអំពីការប្រុងប្រៀបធ្វើដំណើររបស់ខ្លួនចេញទៅធ្វើការនៅភូមិផ្សេង ។*

*ទោះបីជា រូន មិនចង់ឲ្យកូនប្រុសរបស់គាត់ទៅក៏ដោយ ក៏គាត់មិនអាចជួយកូនប្រុសរបស់គាត់បានដែរ ។ រូន បានរំឭករឿងរបស់កូនប្រុសដែលបានស្លាប់បាត់នោះថា "ពេលនោះខ្ញុំមិនដឹងថាក្រុមកងឈ្លបក្មេងៗទាំងអស់ប្រុងប្រៀបចេញដំណើរទៅទីណាទេ ។ ខ្ញុំឃើញកងឈ្លបទាំងនោះជុំគ្នានៅមុខសាលាស្រុក ។ កូនខ្ញុំនៅទីនោះជាមួយនឹងកងឈ្លបក្មេងដទៃទៀតដែរពេលហ្នឹង ។ ខ្ញុំឃើញឡានធំៗបីបែរក្បាលតម្រង់ទៅត្បូង (ខាងមជ្ឈិម) ខ្ញុំដឹងថាខ្មែរក្រហមរៀបចំបញ្ជូនកូនប្រុសខ្ញុំទៅធ្វើការឆ្ងាយ តែខ្ញុំមិនដឹងធ្វើយ៉ាងម៉េច ។ ខ្ញុំចង់ចូលសុំគណៈស្រុកឲ្យកូនខ្ញុំបាននៅក្នុងភូមិដែរ តែខ្ញុំមិនហ៊ានព្រោះខ្លាច ហើយម្យ៉ាងទៀតខ្ញុំដឹងថាខ្ញុំមិនអាចប្រឆាំងនឹងការចាត់តាំងរបស់ថ្នាក់លើបានឡើយ" ។*

*ឪពុកម្តាយមួយចំនួនបានស្លាប់ចោលកូនរបស់ខ្លួនឲ្យរស់នៅក្រោមការថែរក្សារបស់សាច់ញាតិបងប្អូន ។ កុមារកំព្រាមួយចំនួននេះក៏ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យចូលរួមក្នុងចលនាបដិវត្ត ហើយចេញពីភូមិទៅធ្វើការនៅទីឆ្ងាយៗដូចកុមារឯទៀតដែរ ។*

*ថាច់ និង ហន់ ជាកុមារកំព្រាដែលឪពុកម្តាយបាត់បង់ជីវិតក្នុងសង្គ្រាម ។ ហន់ ត្រូវបានចាត់តាំងឲ្យទៅបម្រើយោធារបស់ខ្មែរក្រហម ចោលបងស្រីឲ្យរស់នៅតែម្នាក់ឯង ។ គ្រាដែលប្អូនប្រុសរបស់គាត់ទៅបម្រើជាយោធាខ្មែរក្រហម ថាច់ ក៏ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យចូលក្នុង"កងនារី" ។ ហន់ លែងបានត្រឡប់មកវិញរហូត ។ ហន់ បានស្លាប់បន្ទាប់ពីបញ្ជូនទៅដល់មជ្ឈិម ។ ថាច់ បានរំឭកឡើងវិញថាៈ "មុនពេលចាកចេញទៅបម្រើការនៅកន្លែងផ្សេងឆ្ងាយពីភូមិ ហន់ បានស្កាត់មកជួបខ្ញុំ ហើយប្រាប់ថា វាត្រូវអង្គការចាត់តាំងឲ្យទៅធ្វើការឆ្ងាយ ។ វាបានផ្តាំខ្ញុំឲ្យថែរក្សាខ្លួន ពីព្រោះវាលែងបាននៅក្នុងភូមិជាមួយខ្ញុំទៀតហើយ ។ ចាប់តាំងពីពេលនោះមក វាមិនដែលបានវិលមកផ្ទះវិញទេ ប្អូនខ្ញុំលាខ្ញុំរហូត" ។*

### ការបំពាក់បំប៉នមនោគមវិជ្ជា

### ការបណ្តុះបណ្តាលផ្នែកយោធា

*មុនពេលចាប់ផ្តើមការកិច្ចជាយុទ្ធជននៅស្ថាប័នខ្មែរក្រហមដែលមានឈ្មោះថា មន្ទីរ ស-២១ យុទ្ធជនវ័យក្មេងគ្រប់រូបត្រូវ*

បានខ្មែរក្រហមចាត់តាំងឲ្យទៅហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រយោធា នៅតាខ្មៅ (មន្ទីរស-២១ក) ។ យុទ្ធជនទាំងអស់ត្រូវហ្វឹកហាត់ក្បួនយោធានិងធ្វើការងារមួយចំនួនទៀត ដូចជាការដាំដុះនិងចិញ្ចឹមសត្វ ។ ក្នុងរយៈពេលនៃការបណ្តុះបណ្តាលនេះ យុទ្ធជនវ័យក្មេងទាំងអស់ធ្វើការងារនិងរស់នៅក្រោមការគ្រប់គ្រងរបស់ប្រធានក្រុមដ៏ឃោរឃៅ ប្រឈមមុខនឹងការធ្វើទារុណកម្ម ការហូបចុកមិនគ្រប់គ្រាន់ ជំងឺតម្កាត់ និងការបាត់បង់ជីវិត ។

ខ្មែរក្រហមតម្រូវឲ្យយុទ្ធជនវ័យក្មេងទាំងអស់សរសេរជីវប្រវត្តិនៃជីវិតនិងបទពិសោធន៍ផ្ទាល់ខ្លួន ។ តាមជីវប្រវត្តិរបស់យុទ្ធជនវ័យក្មេងនៅមន្ទីរស-២១ ព្រមជាមួយពត៌មានបន្ថែមដែលប្រមូលបានពីបទសម្ភាសន៍ បានឲ្យដឹងថា គ្មានយុទ្ធជនណាម្នាក់ធ្វើដំណើរត្រង់ចេញពីភូមិរបស់ខ្លួនមកធ្វើការក្នុងមន្ទីរស-២១ ភ្លាមនោះទេ ។ បន្ទាប់ពីមកដល់ភ្នំពេញភ្លាម ឈ្លបវ័យក្មេងទាំងអស់ត្រូវបានបញ្ជូនមកនៅបឹងទំពុន (មន្ទីរស-២១គ) ដែលស្ថិតនៅខាងត្បូងទីក្រុងភ្នំពេញ និងនៅព្រៃស (មន្ទីរស-២១ឃ) នៅក្នុងស្រុកដង្កោ ។ នៅទីនោះ យុទ្ធជនវ័យក្មេងទាំងអស់ត្រូវចាត់តាំងឲ្យធ្វើការងារក្នុងកសិដ្ឋានចិញ្ចឹមសត្វ លើកទំនប់ ធ្វើស្រែ និងយាមល្បាត ។

បន្ទាប់ពីឆ្លងកាត់រយៈពេលលត់ដំការងារនៅបឹងទំពុននិងព្រៃសរួចមក យុទ្ធជនវ័យក្មេងត្រូវបញ្ជូនទៅតាខ្មៅដើម្បីបណ្តុះបណ្តាលមុខជំនាញយោធារយៈពេល៤ខែ ។ ក្នុងសាលាបច្ចេកទេសយោធា យុទ្ធជនទាំងអស់ត្រូវហ្វឹកហាត់អំពីយុទ្ធសាស្ត្រទ័ព ដូចជាការបាញ់ ការដាក់គ្រាប់បែក និងបច្ចេកទេសប្រយុទ្ធផ្សេងៗ ។

អតីតយុទ្ធជនវ័យក្មេងមន្ទីរស-២១ដែលបានធ្វើសម្ភាសន៍ គ្មាននរណាម្នាក់និយាយអំពីភាពរីករាយនៃវគ្គបណ្តុះបណ្តាលក្នុងសាលាបច្ចេកទេសយោធានៅតាខ្មៅឡើយ ។ ផ្ទុយមកវិញ អ្នកទាំងនោះបានត្អូញត្អែរអំពីការងារលំបាកធ្ងន់ធ្ងរនិងការហ្វឹកហាត់ដ៏តឹងរ៉ឹង ។ ឡា អតីតយុទ្ធជនផ្នែកចិញ្ចឹមសត្វនៅមន្ទីរស-២១ មកពីភូមិល្វា ឃុំអញ្ចាញរូង ស្រុកបរិបូណ៌ បានរៀបរាប់បទពិសោធន៍ដែលគាត់បានឆ្លងកាត់នៅសាលាបច្ចេកទេសយោធានៅតាខ្មៅថាៈ «គ្មាននរណាម្នាក់សប្បាយចិត្តទេអំឡុងពេលហ្វឹកហាត់យោធានៅតាខ្មៅ ពីព្រោះពេលយើងកំពុងធ្វើការហ្វឹកហាត់វាគឺជាពេលវេលាដ៏លំបាកបំផុតសម្រាប់យើង ។ អ្វីៗទាំងអស់គឺនៅក្រោមការរឹតបន្តឹងនិងបទបញ្ជាដ៏តឹងរ៉ឹង» ។

បន្ទាប់ពីមកដល់ភ្នំពេញ ពៅ ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅបម្រើការងារនៅអង្គភាពចិញ្ចឹមជ្រូកនៅបឹងទំពុនអស់រយៈពេលជាច្រើនខែ ។ បន្ទាប់មក យុទ្ធជនក្នុងក្រុមជាមួយ ពៅ ចំនួន៣០នាក់ ត្រូវចាត់តាំងឲ្យទៅហ្វឹកហាត់យុទ្ធសាស្ត្រទ័ពនៅស្ទឹងព្រែកត្នោត ស្រុកតាខ្មៅ ខេត្តកណ្តាល ។ ពៅ ក៏ជាប់ឈ្មោះក្នុងចំណោមយុទ្ធជនទាំង៣០នាក់នោះដែរ ។ ***ពៅ នៅចាំបានថា គ្រូបង្ហាត់ធំបង្អស់ជាជនជាតិចិនឈ្មោះ ហ៊ូ វ៉ាន់ ហ៊ីង ។ ពៅ រំឭកថាៈ «អំឡុងពេលដំណើរការបណ្តុះបណ្តាលផ្នែកយោធា យើងទាំងអស់គ្នាត្រូវធ្វើការជាទម្ងន់ទាំងថ្ងៃទាំងយប់ ។ ខ្ញុំបានចំណាយពេលមួយឆ្នាំហ្វឹកហាត់វិធីប្រើចំពុះទុង វិធីបាញ់ស៊ីប និងក្បាច់គុនកាំភ្លើង ។ យើងប្រឹងប្រែងហាត់រៀនយ៉ាងខ្លាំងដោយមិនគិតឈឺចុកចាប់ ថ្ងៃឬយប់ឡើយ***» ។

ខ្មែរក្រហមបង្ខំឲ្យយុទ្ធជនវ័យក្មេងទាំងអស់ធ្វើការធ្ងន់ៗនិងហ្វឹកហាត់ផងក្នុងពេលជាមួយគ្នា ។ បន្ថែមពីលើនេះ យុទ្ធជនទាំងអស់ត្រូវបំពេញភារកិច្ចយាមល្បាតនៅពេលយប់ទៀត ។ សកម្មភាពក្រោកធ្វើការពីព្រលឹមរហូតដល់យប់ ពីមួយថ្ងៃទៅមួយថ្ងៃ បង្កភាពតានតឹងចំពោះយុទ្ធជនទាំងអស់ ដូចដែល សំ អតីតយុទ្ធជនការពារនៅមន្ទីរ ស-២១ មកពីភូមិប្រកសង្កែ បានប្រាប់ថាៈ «អំឡុងពេលបណ្តុះបណ្តាលយោធា យើងធ្វើការធ្ងន់ៗទាំងពេលថ្ងៃនិងពេលយប់ ។ យើងចាប់ផ្តើមការងារពីម៉ោង៧ព្រឹករហូតដល់ម៉ោង១១ថ្ងៃត្រង់ និងពីម៉ោង១២ថ្ងៃត្រង់រហូតដល់ម៉ោង៥ល្ងាច ។ លើសពីនេះ យើងត្រូវយាមល្បាតថែមទៀត» ។

នៅក្នុងសាលាបច្ចេកទេសយោធាតាខ្មៅ របបអាហារមានលក្ខណៈអាក្រក់បំផុតបើប្រៀបទៅនឹងកន្លែងធ្វើការផ្សេងៗទៀតដែលយុទ្ធជនទាំងអស់ធ្លាប់បានឆ្លងកាត់ ។ លក្ខខណ្ឌធ្វើការងារនៅក្នុងសាលាបណ្តុះបណ្តាលបច្ចេកទេសយោធាបានធ្វើឲ្យយុទ្ធជនទាំងអស់ខ្សោះកម្លាំង ហើយត្រូវការចាំបាច់នូវអាហារដែលមានជីវជាតិគ្រប់គ្រាន់ដើម្បីទ្រទ្រង់បាននូវថាមពលឡើង

វិញ ។ ផុយទៅវិញ យុទ្ធជនទាំងនោះទទួលបានតែបបរលាយដើមចេក គល់ចេក និងគល់ល្ហុង សម្រាប់បរិភោគ ។ “ភាព” ត្អូញត្អែរអំពីរបបអាហារនៅសាលាហ្វឹកហ្វឺនថា យុទ្ធជនទាំងអស់ហូបតែដើមចេក គល់ចេក និងគល់ល្ហុង រៀងរាល់ថ្ងៃ ។ ដោយសារការហេវហត់អត់ឃ្លាន យុទ្ធជនក្នុងសាលាបច្ចេកទេសយោធានាំគ្នាស៊ីសត្វល្អិតគ្រប់ប្រភេទដែលខ្លួនអាចរកបាន ។ ឡា និយាយប្រាប់យើងទាំងក្រៀមក្រំថា “នៅតាខ្មៅ ពួកយើងនាំគ្នាស៊ីទាំងអស់ សូម្បីតែសត្វកន្លាតក៏ស៊ីដែរ ។ យើងគ្មានគិតអ្វីទាំងអស់ព្រោះយើងឃ្លានពេក យើងស៊ីដើម្បីរស់” ។

ជាម អតីតយុទ្ធជនចិញ្ចឹមសត្វ មកពីភូមិថ្មឥដ្ឋ ឃុំថ្មឥដ្ឋ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ក៏បានត្អូញត្អែរអំពីរបបចំណីអាហារនៅតាខ្មៅថាៈ “ពេលខ្ញុំមកដល់មជ្ឈិម ខ្មែរក្រហមបញ្ជូនខ្ញុំទៅហ្វឹកហាត់យោធានៅតាខ្មៅ ។ ខ្ញុំធ្លាក់ខ្លួនស្គមហើយខ្សោយពីព្រោះខ្ញុំធ្វើការងារធ្ងន់ៗ ហ្វឹកហាត់ ដាំបន្លែ និងយាមកាមរាល់យប់ ។ ឯរបបអាហារវិញគួរឲ្យសង្វេគណាស់ យើងហូបតែបបរលាយគល់ចេកគល់ល្ហុងប៉ុណ្ណោះ” ។

ដោយសារការហូបចុកមិនគ្រប់គ្រាន់និងធ្វើការហួសកម្លាំង យុទ្ធជនវ័យក្មេងទាំងអស់ទទួលរងនូវការបៀតបៀនពីជំងឺគ្រប់ប្រភេទ ។ ឡា បានរៀបរាប់ថាៈ “ពេលខ្ញុំហាត់បច្ចេកទេសយោធានៅសាលាបណ្តុះបណ្តាលនៅតាខ្មៅបានមួយខែកន្លះ ខ្ញុំមានជំងឺគ្រុនចាញ់ ហើយត្រូវដឹកយកទៅព្យាបាលនៅមន្ទីរពេទ្យភ្នំពេញ ។ គ្រប់គ្នាគិតថាខ្ញុំស្លាប់បាត់ទៅហើយ ពីព្រោះនៅពេលនោះសក់របស់ខ្ញុំជ្រុះអស់ពីក្បាល ។ សំណាងល្អ ខ្ញុំបានជាវិញបន្ទាប់ពីដេកពេទ្យនៅភ្នំពេញបានមួយខែ ហើយក៏វិលត្រឡប់មកសាលាបច្ចេកទេសយោធាវិញ ។ ខ្ញុំធ្លាក់ខ្លួនឈឺព្រោះកាលនោះខ្ញុំធ្វើការធ្ងន់ហួសហេតុ ហើយហូបតែបបររាវលាយនឹងគល់ចេកនិងគល់ល្ហុង” ។

ក្នុងករណីធ្លាក់ខ្លួនមានជំងឺធ្ងន់ធ្ងរ យុទ្ធជនវ័យក្មេងភាគច្រើនត្រូវប្រឈមមុខនឹងសេចក្តីស្លាប់ ព្រោះខ្វះការថែទាំនិងថ្នាំសង្កូវសម្រាប់ព្យាបាល ។

បន្ថែមពីលើសម្តីរបស់យុទ្ធជនវ័យក្មេងមកពីតំបន់ ៣១ ដែលពណ៌នាអំពីលក្ខខណ្ឌរស់នៅនិងធ្វើការងារយ៉ាងអមនុស្សធម៌នៅសាលាហ្វឹកហាត់យោធានៅតាខ្មៅ ចម្លើយសារភាពរបស់ប្រធានក្រុមបង្ហាត់និងផ្គត់ផ្គង់របបហូបចុកនៅសាលាបណ្តុះ

សកម្មភាពហ្វឹកហាត់ក្បាច់ប្រយុទ្ធ របស់យុទ្ធជនមន្ទីរ ស-២១



បណ្តាលនៅតាខ្មៅ ក៏បានបញ្ជាក់អំពីស្ថានភាពការងារធ្ងន់ធ្ងរ កង្វះខាតចំណីអាហារ ការធ្វើទុក្ខទោស និងការប្រហារជីវិត ដែលកើតឡើងចំពោះយុទ្ធជននារីយក្មេងក្នុងសាលាបច្ចេកទេសយោធានៅតាខ្មៅដែរ ។ ចម្លើយសារភាពរបស់ប្រធានក្រុមរូបនោះបានសរសេរថា "ខ្ញុំបង្ខំយុទ្ធជនក្មេងៗក្នុងសាលាបច្ចេកទេសយោធាឲ្យធ្វើការដោយគ្មានពេលវេលាសម្រាក ។ ខ្ញុំវាយទាត់ធាក់ធ្វើបាបពេលណាយុទ្ធជនក្មេងៗទាំងនោះយឺតយ៉ាវក្នុងការងារឬមានកំហុសអ្វីមួយក្នុងពេលហាត់រៀន លើសពីនេះទៀត ខ្ញុំឲ្យយុទ្ធជនក្មេងៗទាំងនោះហូបតែបបរលាយជាមួយអំបិលប៉ុណ្ណោះ" ។

យុទ្ធជននារីយក្មេងទាំងអស់ប្រឹងប្រែងធ្វើការដើម្បីគេចផុតពីការគំរាមកំហែងធ្វើទារុណកម្ម ។ ការអស់កម្លាំងល្ហិតល្ហៃធ្វើឲ្យយុទ្ធជនទាំងអស់មិនអាចបំពេញការងារតាមផែនការ ។ យុទ្ធជនខ្លះងោកងុយនិងដេកលក់ក្នុងពេលកំពុងយាម ។ គុណវិបត្តិទាំងនេះត្រូវទទួលការស្តីបន្ទោសនិងដាក់ទណ្ឌកម្មពីសំណាក់ប្រធានក្រុម ។ យុទ្ធជនមួយចំនួនបានស្លាប់ដោយការធ្វើទណ្ឌកម្ម ។ សំ បានឲ្យដឹងថា មិត្តរបស់គាត់ម្នាក់បានស្លាប់ដោយការធ្វើទោស ហើយ សំ ខ្លួនឯងមានសំណាងបានរស់រានមានជីវិតពីទណ្ឌកម្មបន្តុតបាយមួយសប្តាហ៍ ។ សំ បានរំឭកថាៈ "កាលនោះពួកម៉ាកខ្ញុំម្នាក់ត្រូវប្រធានក្រុមនៅសាលាបច្ចេកទេសយោធាចាប់វ៉ៃដោយចោទវាថាខ្ជិលហាត់រៀន ។ ពួកម៉ាកខ្ញុំត្រូវដឹបងយ៉ាងខ្លាំងរហូតធ្លាក់ខ្លួនឈឺ ។ មួយខែក្រោយមកវាក៏ងាប់បាត់ទៅ ។ ខ្ញុំក៏ត្រូវប្រធានក្រុមបន្តុតបាយមួយអាទិត្យរហូតដល់ជិតងាប់ខ្លួនដែរ ព្រោះខ្ញុំងោកក្នុងពេលយាម ។ នរណាទ្រាំបាន បើហាត់ផងធ្វើការផង ហើយយាមយប់ទៀត" ។

នៅពេលដែលយុទ្ធជននារីយក្មេងទាំងអស់ត្រូវបានបញ្ជូនចូលសាលាបណ្តុះបណ្តាលនៅតាខ្មៅ អ្នកទាំងនោះបានក្លាយជាជនរងគ្រោះភ្លាមដែរ ។ យុទ្ធជននារីយក្មេងទាំងអស់ត្រូវខ្មែរក្រហមបង្ខំឲ្យហ៊ីកហ៊ឺនដោយគ្មានអាហារគ្រប់គ្រាន់ លើសពីនេះត្រូវប្រឈមមុខនឹងជំងឺដែលកើតឡើងដោយកង្វះអាហារ ក៏ដូចជាការធ្វើទោស និងការប្រហារជីវិត ។

**ចប់វគ្គទី១**

## ឯកសារលេខ D ១០៧៤: របាយការណ៍របស់ សមមិត្ត ហ៊ឹម ហ៊ុយ ហៅ យូ ហ៊ុយ ហៅ ហ៊ុយតូច

*ប្រធានក្រុមសួរចម្លើយនៅមន្ទីរស-២១*



ហ៊ុម ហ៊ុយ ឆ្នាំ១៩៧៦

ខ្ញុំសូមរាយការណ៍ជូនបង ថ្ងៃ ២៦-៧៨ បងកំណត់ថាយួន៣នាក់ តែយួននោះគឺ២នាក់ ហើយខ្មែរ៣នាក់ ខ្ញុំយកមកហើយ ដល់ថ្ងៃ ២៧-៤-៧៨ បងកំណត់ ៦ក្បាល ពេលខ្ញុំទៅម៉ោង ១២កន្លះ ទៅដល់ស្វាយរៀង ម៉ោង៥កន្លះ ចូលសួរនៅសន្តិសុខបង មុំ ដែលកន្លែងទុករាល់ដង ឈ្មោះ វុធី ថាមិនទាន់មកដល់ ហើយម្នាក់មិនស្គាល់ឈ្មោះថាមិនដឹងទេ មនុស្សនោះមកដល់ម៉ោង៧ល្ងាច ។ ខ្ញុំសួររករាល់ម៉ោងក៏ថាមិនទាន់មកដល់ សួររកដល់ម៉ោង១យប់ក៏អត់ទៀត បងប្អូននៅចាំទល់ភ្លឺ ម៉ោង៦កន្លះព្រឹក បាននិរសាមកប្រាប់ថាមកដល់យូរហើយ ខ្ញុំសួរឈ្មោះបងធាន សន្តិសុខ មួយយប់ក៏មិនដឹង ម៉ោង៦កន្លះព្រឹក បាន វុធី នោះប្រគល់ឱយ តែម្នាក់គឺឈ្មោះ ទា ផល ខ្មែរ នៅត-២៣ ។

២៨-៤-៧៨, ហ៊ុយតូច



ហ៊ឹម ហ៊ុយ ឆ្នាំ១៩៩៦

## អត្ថន័យនៃពាក្យខ្មែរក្រហម

- **មហាអស្ចារ្យៈ** ធ្វើឲ្យបានល្អផងហើយឲ្យបានត្រឹមត្រូវតាមមាគ៌ារបស់បក្សផង ។ ពោលគឺមហាអស្ចារ្យគ្រង់ដែលធ្វើបានល្អ បានលឿន បានច្រើន ហើយមិនខុស ។ មិនខុសទាំងក្នុងន័យមាគ៌ានយោបាយរបស់បក្ស ក៏ដូចក្នុងន័យបច្ចេកទេសការងារ ។

*(យុវជននិងយុវនារីបដិវត្តន៍ លេខ២ ខែកុម្ភៈ ឆ្នាំ១៩៧៦)*

# ជនជាតិថៃ ដែលត្រូវបាន



# សម្លាប់នៅមន្ទីរស-២១














នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ ជនជាតិថៃចំនួន៣១រូបដែលមានរូបថតនៅទីនេះ ត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួននៅតំបន់កំពង់សោម ហើយបញ្ជូនមកកាន់មន្ទីរស-២១ ដែលមានសមមិត្ត ឌុច ជាអ្នកគ្រប់គ្រង។ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៦ របបកម្ពុជាប្រជាធិបតេយ្យ បានសម្រេច “កម្ទេច” ជនជាតិថៃទាំង៣១រូប។ ឯកសារពាក់ព័ន្ធចំពោះជនជាតិថៃទាំង៣១រូបមានតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ មកទល់នឹងថ្ងៃនេះ គឺមានរយៈពេល២៦ឆ្នាំគត់ ដែលក្រុមគ្រួសារនៃជនរងគ្រោះទាំង៣១រូបមិនត្រូវបានផ្តល់ជូននូវយុត្តិធម៌ដ៏ពិតប្រាកដមួយនៅឡើយទេ។

**ឆាំង យុ**

# វង្វាស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងប្រទេសកម្ពុជា

**(តពីលេខមុន)**

ជារឿយៗ តួលេខរាយការណ៍ដោយមាត់ទទេនេះ ក្រោយមកទៀតត្រូវបានផ្ទៀងផ្ទាត់ជាមួយនឹងចំនួនលលាដ៍ក្បាលសាកសពជនរងគ្រោះដែលតម្កល់ទុកនៅក្បែរទីតាំងនោះ និងឯកសារនៃការគាស់រណ្តៅ ។ ពេលខ្លះទៀត ឯកសារកត់ត្រាអំពីការកាប់សម្លាប់ពិតៗដែលចងក្រងដោយជនដៃដល់ផ្ទាល់ ត្រូវបានរកឃើញ ។ មិនតែប៉ុណ្ណោះ អ្នកស៊ើបសួរដែលមានបទពិសោធន៍ខ្ពស់ដែលបានឃើញរណ្តៅសាកសពរាប់សែន បានធ្វើការប៉ាន់ស្មានដោយខ្លួនឯង ដោយផ្អែកទៅលើចំនួន ប្រភេទ និងខ្នាតរបស់រណ្តៅ ។ ប៉ុន្តែនៅក្នុងករណីផ្សេងទៀតដូចដែលបានរៀបរាប់ខាងដើម ការរាប់ចំនួនជនរងគ្រោះគឺផ្អែកទៅលើកសិណសាក្សីជាជនដៃដល់ ហើយជនដៃដល់ពិតជាមិនបំផ្លើសចំនួនដែលខ្លួនបានសម្លាប់ឡើយ ។

នៅក្នុងដំណើរចុះធ្វើផែនទីមួយកាលពីឆ្នាំ១៩៩៦ អ្នកនិពន្ធបានអមដំណើរក្រុមផែនទីទៅស្រុកស្អាង ខេត្តកណ្តាល ក្នុងគោលបំណងធ្វើអធិការកិច្ចសំណេរ ។ ក្រុមផែនទីត្រូវបានជួយណែនាំផ្លូវទៅដល់ទីតាំងគុករបស់ខ្មែរក្រហមដ៏ធំមួយ និង “វាលពិឃាត” មួយ ដោយអភិបាលស្រុកស្អាងដែលបញ្ជាក់ច្បាស់ថាមានសាកសពជនរងគ្រោះជាច្រើននាក់ត្រូវបានជីកគាស់ពីរណ្តៅនៅទីនោះ ហើយសាកសពមានជាប់ក្រណាត់ចងមុខ និងខ្សែជាប់នឹងកដៃនៅឡើយ ។ របាយការណ៍ផ្ទាល់មាត់របស់អភិបាលស្រុកអំពីចំនួនជនរងគ្រោះ គឺស្តាប់ទៅហាក់ដូចជាមិនសមហេតុផល ហើយមានចំនួនច្រើនទៀតផង ប្រហែលជា ១២១ ៣១៧ ។ អ្នកស៊ើបសួរពត៌មានរបស់ក្រុមផែនទីមិនបានសួរដេញដោលអំពីការអះអាងដ៏គួរឲ្យសង្ស័យនេះទេ ប៉ុន្តែសុំទៅមើលបូជនីយដ្ឋានដែលស្ថិតនៅក្បែរនោះ ។ នៅបូជនីយដ្ឋានតម្កល់អដ្ឋិធាតុ ក្រុមផែនទីបានរាប់ចំនួនលលាដ៍ក្បាលសាកសពសរុបទៅមានចំនួនប្រហែល២៥០ ។ មើលទៅហាក់ដូចជាថា លលាដ៍ក្បាលមួយចំនួនធំបានបាត់នៅឆ្នាំកន្លងមក ពីព្រោះចំនួននិងទំហំរណ្តៅដែលត្រូវបានជីកយកអដ្ឋិធាតុមើលទៅហាក់ដូចជាបញ្ជាក់ថាមានអដ្ឋិធាតុច្រើនជាង២៥០ ទោះបីចំនួននេះតិចជាងចំនួនដែលបញ្ជាក់ដោយអភិបាលស្រុកក៏ដោយ ។ ដូច្នេះដោយសារតែភាពខុសគ្នានេះ និងការខកខានរបស់ក្រុមផែនទីមិនបានធ្វើការប៉ាន់ស្មានឲ្យច្បាស់លាស់ ទីតាំងនេះត្រូវបានកត់ចូលជាឯកសារថាគ្មានជនរងគ្រោះស្លាប់ឡើយ ។ ឧទាហរណ៍មួយទៀតនៃបញ្ហានេះគឺ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបាននូវកសិណសាក្សីពីជនដៃដល់ជាឆ្មាំសន្តិសុខដែលបានសម្លាប់និងកប់ជនរងគ្រោះប្រមាណ២-៣ពាន់នាក់ នៅកន្លែងអតីតវាលមួយនៅជាប់គុកទួលស្លែងភាគខាងលិច ។ ប៉ុន្តែដោយសារតែទីតាំងនេះត្រូវបានអ្នកមករស់នៅសាងសង់ផ្ទះសម្បែងពីលើជាយូរណាស់មកហើយ ហើយអ្នកផ្តល់ពត៌មានដែលជាជនដៃដល់មិនអាចចងចាំពីចំនួនជនរងគ្រោះស្លាប់ច្បាស់លាស់ យើងមិនអាចដឹងទាំងចំនួនរណ្តៅសាកសពនិងចំនួនជនរងគ្រោះ ។

ឧទាហរណ៍ចុងក្រោយមួយទៀតគឺនិយាយអំពីវិធីសាស្ត្រប្រមូលទិន្នន័យក្នុងឆ្នាំ១៩៩៩ក្នុងខេត្តបន្ទាយមានជ័យ ។ នៅខេត្តបន្ទាយមានជ័យ មន្ត្រីខេត្តបានអះអាងថាចំនួនជនរងគ្រោះនៅទីតាំងគុកនិងទីតាំងរណ្តៅសាកសពដែលស្ថិតនៅក្បែរគុកមាន៨០០០នាក់ ។ ប៉ុន្តែភ័ស្តុតាងអដ្ឋិធាតុដែលនៅត្រូវបានគាស់ចេញមក បញ្ជាក់ថាចំនួនជនរងគ្រោះមានតែ៧០០នាក់តែប៉ុណ្ណោះ ដូច្នេះចំនួនជនរងគ្រោះដែលកត់ត្រាទុកជាឯកសារគឺមានតែ៧០០នាក់ ទោះបីជារណ្តៅសាកសពមើលទៅហាក់ដូចជាមានទំហំធំអាចផ្ទុកជនរងគ្រោះបានច្រើនជាងនេះក៏ដោយចុះ ។ ហេតុដូចនេះមជ្ឈមណ្ឌលឯកសារកម្ពុជាមានការប្រុងប្រយ័ត្នយ៉ាងខ្លាំង ។ ក្រុមផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានដឹងច្បាស់ជាងអ្នកណាទាំងអស់នៅលើពិភពលោកនេះ អំពីការនិយាយបំផ្លើសរបស់អ្នកផ្តល់ពត៌មាននៅតាមមូលដ្ឋានហើយវិធីសាស្ត្ររបស់ក្រុមនេះក៏បានគិតពីបញ្ហានេះដែរ ។

ចំណុចសំខាន់មួយនៅក្នុងគម្រោងធ្វើផែនទីរបស់មជ្ឈ-

មណ្ឌលឯកសារកម្ពុជា គឺការចម្លងទិន្នន័យដែលជាមូលដ្ឋានមួយដែលមានលក្ខណៈវិទ្យាសាស្ត្រ ។ ទីតាំងនីមួយៗតែងតែដាក់បញ្ចូលក្នុងឧបករណ៍កំណត់ទីតាំងភូមិសាស្ត្រ ហៅថា "ជីភីអេស" ដែលកំណត់ជាខ្សែកូអរដោនេភូមិសាស្ត្រយ៉ាងច្បាស់លាស់ ។ នេះមានន័យថាអ្នកស៊ើបពត៌មានដែលបានមកដល់ទីតាំងម្តងហើយ លើកក្រោយនឹងអាចបញ្ជាក់ច្បាស់នូវប្រភពដើមនៃទិន្នន័យដោយខ្លួនឯង ដោយរកឃើញទីតាំងនិងស្វែងរកពត៌មានស្តីពីទីតាំងនោះ ។ នេះជាអ្វីដែលថ្មីហើយមានលក្ខណៈវិទ្យាសាស្ត្រជាងកិច្ចខិតខំប្រឹងប្រែងកាលពីពេលកន្លងទៅក្នុងការដោះស្រាយរឿងចំនួនមនុស្សស្លាប់ដោយស្នាដៃខ្មែរក្រហម ។ នៅក្នុងទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា អ្វីៗត្រូវបានថតទុកជាឯកសារ ហើយអ្វីៗរួមទាំងឈ្មោះនិងអាសយដ្ឋានរបស់សាក្សីត្រូវបានបោះពុម្ពផ្សាយជារបាយការណ៍ប្រចាំឆ្នាំដូចជានៅពេលបច្ចុប្បន្ននេះដែរ ។ ទិន្នន័យនៅក្នុងឧបករណ៍កំណត់ទីតាំងភូមិសាស្ត្រ "ជីភីអេស" ដែលប្រមូលនៅក្នុងដំណើរចុះធ្វើផែនទីត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធពត៌មានទីតាំងភូមិសាស្ត្រដែលតាមរយៈប្រព័ន្ធកុំព្យូទ័រនេះនឹងមានការបង្កើតនូវផែនទីច្បាស់មួយបង្ហាញពីទីតាំងនៃទិន្នន័យដែលត្រូវបានប្រមូល ។ ផែនទីដែលបង្ហាញពីទិន្នន័យអាចប្រើប្រាស់បានតាមរយៈប្រព័ន្ធអ៊ីនធឺណេត *http://www.yale.edu/cgp/cgdb/cgdbmain.htm* ឬ *http://www-cgp.sistm.unsw.edu.au/cbio.htm* ឬ *http://welcome.to/dccam* ។

ចំនួនរណ្តៅសាកសពជាច្រើនត្រូវបានជីកគាស់អស់ជាច្រើនឆ្នាំ ដោយរដ្ឋអំណាចមូលដ្ឋានរបស់រដ្ឋាភិបាលកម្ពុជាដែលចង់ទទួលបានលទ្ធផលល្អនៅក្នុងការងាររបស់ខ្លួន ទោះបីជាមិនអាចឈានដល់ការធ្វើកោសល្យវិច័យជាលក្ខណៈវិទ្យាសាស្ត្រក៏ដោយចុះ ។ ទន្ទឹមគ្នានេះដែរក៏មានរណ្តៅសាកសពជាច្រើនទៀតត្រូវបានជីកគាស់ដោយប្រជាជនក្នុងមូលដ្ឋានដើម្បីកកាយរកវត្ថុដែលខ្លួនត្រូវការដោយគ្មានការផ្ចិតផ្ចង់ឡើយ ។ របាយការណ៍ផែនទីឆ្នាំ១៩៩៩ មានកិច្ចសម្ភាសន៍ជាមួយនឹងប្រជាជនម្នាក់ដែលបានជីកគាស់រណ្តៅសាកសព ។ ការជីកគាស់ទាំងពីរបែបទៅលើរណ្តៅសាកសពមានប្រយោជន៍ក្នុងការជួយដល់ក្រុមស៊ើបសួរពត៌មានក្នុងការបង្កើតជាតម្រុយតាមផ្លូវច្បាប់ដើម្បីបញ្ជាក់ថាតើប្រភេទរណ្តៅសាកសពប្រភេទណាដែលផ្ទុកនូវចំនួនសាកសពក្នុងចំនួននេះ ។ ពេលដឹងហើយនឹងនាំឲ្យមានការវិភាគដែលគួរឲ្យទុកចិត្តបានទៅលើការប៉ាន់ស្មានចំនួនជនរងគ្រោះសរុប ។

លោក វិកយ័រី ទាញហេតុផលថា ការធ្វើកោសល្យវិច័យគឺមានលក្ខណៈចាំបាច់ណាស់ក្នុងការបញ្ជាក់ពីពេលវេលាច្បាស់លាស់ ហើយមនុស្សម្នាក់អាចបន្ថែមពីមូលហេតុនៃការបាត់បង់ជីវិតរបស់ជនរងគ្រោះនៅក្នុងរណ្តៅសាកសពដែលទទួលការធ្វើកោសល្យវិច័យនោះ ។ វិធីនេះនឹងបន្ថែមចំណុចសំខាន់ដែលមានលក្ខណៈជាក់លាក់មួយទៀតទៅក្នុងទិន្នន័យនៃការធ្វើផែនទី ។ តាមពិត មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងស្វែងរកជំនួយថវិកាសម្រាប់គម្រោងការធ្វើកោសល្យវិច័យបែបនរវិទ្យាតាំងពីឆ្នាំ១៩៩៦មកម្ល៉េះ ។ បញ្ហានេះត្រូវបានពិភាក្សាដោយមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹងអ្នកជំនាញការនៃទីពិសោធន៍រកអត្តសញ្ញាណកម្មរបស់កងទ័ពសហរដ្ឋអាមេរិក ហៅកាត់ថា ស៊ី.អាយ.អែល នៅហូណូលូលូ រដ្ឋហាវ៉ៃ ដែលជាអាជ្ញាធរមួយបង្កើតឡើងមុនគេបង្អស់នៅលើពិភពលោកដើម្បីធ្វើការពិនិត្យសាកសពនៅក្នុងភូមិភាគអាស៊ី-អគ្នេយ៍ ។ មន្ត្រី ស៊ី.អាយ.អែល ជឿជាក់ថា ទោះបីជាដីនៅប្រទេសកម្ពុជាមានជាតិប្រៃងាយនឹងធ្វើឲ្យឆ្អឹងឆាប់ពុកផុយយ៉ាងណាក៏ដោយ ក៏ក្រុមអ្នកជំនាញការអាចកំណត់ច្បាស់នូវពេលវេលានិងមូលហេតុនៃការស្លាប់របស់ជនរងគ្រោះដែរ ហើយក្នុងករណីខ្លះសូម្បីតែអត្តសញ្ញាណរបស់ជនរងគ្រោះក៏អាចដឹងច្បាស់ដែរ ទោះបីជាជនរងគ្រោះនោះបានបាត់បង់ជីវិតអស់ជាច្រើនឆ្នាំក៏ដោយ ។

មជ្ឈមណ្ឌលឯកសារកម្ពុជានៅតែសង្ឃឹមថានឹងរ៉ាប់រងនូវគម្រោងធ្វើកោសល្យវិច័យនេះនៅពេលអនាគត ។ ប្រសិនបើមានការអនុវត្តជាក់ស្តែងនិងពេញទំហឹងនូវគម្រោងកោសល្យវិច័យមែន វានឹងបន្ថែមជើងទីបួនទៅលើកៅអីដែលមានតែជើងបីនៃភស្តុតាងដែលត្រូវបានប្រមូលបានមកដល់សព្វថ្ងៃនេះ ដោយផ្អែកលើកសិណសាក្សី (ទាំងជនរងគ្រោះ ទាំងជនដៃដល់) ឯកសារសន្តិសុខសម្ងាត់របស់ខ្មែរក្រហមដែលមាននិយាយអំពី

មន្ទីរសន្តិសុខ ហើយជួនកាលមានបញ្ជីសម្លាប់នៅតាមទីតាំងផ្សេងៗជាច្រើន ព្រមទាំងភស្តុតាងជាក់ស្តែងប្រមែប្រមូលនិងកាន់ដោយផ្ទាល់ដៃដោយអ្នកស៊ើបសួរពត៌មានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ក្រៅពីកង្វះខាតនូវការបញ្ជាក់បានមកពីការធ្វើកោសល្យវិច័យទៅលើកិច្ចការចុះធ្វើផែនទី ក៏មានភាពខ្វះចន្លោះមួយចំនួនរបស់ទិន្នន័យរណ្តៅសាកសព ហើយក្នុងចំណោមកង្វះខាតទាំងអស់មានមួយចំនួនផ្ទុកនូវការរិះគន់របស់លោក វីកយ័រី ដែលធ្វើឡើងអស់ជាង១៥ឆ្នាំមកហើយ ។ មូលហេតុសំខាន់ៗមួយចំនួនដូចដែលលោក វីកយ័រី បានលើកឡើង គឺការពិបាកកំណត់ច្បាស់ថា ចំនួនសាកសពប៉ុន្មានភាគរយដែលស្លាប់ដោយការកាប់សម្លាប់ ប៉ុន្មានភាគរយស្លាប់ដោយជំងឺ ហើយប៉ុន្មានភាគរយស្លាប់ដោយការអត់អាហារ ។ ការលំបាកនេះចេះតែបន្តកើតឡើងចំពោះក្រុមធ្វើផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក្រុមផែនទីមិនអាចទប់ទល់នូវការលំបាកដែលកើតឡើងនេះតាមមធ្យោបាយវិទ្យាសាស្ត្រឡើយ ។ ឧទាហរណ៍នៅក្នុងទិន្នន័យនៃការចុះធ្វើផែនទីនៅក្នុងខេត្តបន្ទាយមានជ័យ នៅឆ្នាំ១៩៩៩ រណ្តៅសាកសពជាច្រើននៅម្តុំទីចាត់ការស្រុកថ្មពួកត្រូវបានអ្នកស្រុកនិយាយប្រាប់ថា ពោរពេញទៅដោយសាកសពជនរងគ្រោះបន្សល់ទុកពីអតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ។ ប៉ុន្តែសាក្សីក៏បានរៀបរាប់បន្ថែមអំពីពេទ្យមួយនៅជិតមន្ទីរសន្តិសុខដែលមានភាពទ្រុឌទ្រោមទៅហើយ ។ សាក្សីម្នាក់ដែលធ្លាប់បានធ្វើការនៅក្នុងមន្ទីរពេទ្យនោះនិយាយថា "ភាគច្រើននៃអ្នកជំងឺមកព្យាបាលនៅមន្ទីរពេទ្យនេះត្រូវស្លាប់បាត់បង់ជីវិត" ។ ចំពោះចំនួនជនរងគ្រោះដែលស្លាប់បាត់បង់ជីវិតដោយសារមន្ទីរពេទ្យផ្ទាល់ និងដោយស្នាដៃឆ្មាំសន្តិសុខពីរនាក់នៅក្នុងទីតាំងតែមួយ វាគ្មានអ្វីគួរឲ្យច្បាស់លាស់ទាល់តែសោះថាតើជនរងគ្រោះស្ថិតក្នុងប្រភេទណាមួយពិតប្រាកដ ។ ភាពមិនប្រាកដប្រជានេះទោះបីវាជាលក្ខណៈលើកលែងយ៉ាងណាក៏ដោយ ក៏អាចបង្កើតជាបញ្ហាស្តីអំពីភាពច្បាស់លាស់ជាក់លាក់នៃទិន្នន័យ ។ អ្នកសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវការសម្រិតសម្រាំងនូវកង្វះខាតពីទិន្នន័យរបស់ខ្លួន ។

ប៉ុន្តែទោះបីជាមានការកំណត់ទិន្នន័យពីមុននិងការខកខានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានទទួលនូវឱកាសសម្រាប់គម្រោងការធ្វើកោសល្យវិច័យយ៉ាងណាក៏ដោយ ប៉ុន្តែជាការច្បាស់ណាស់ថា ទិន្នន័យរណ្តៅសាកសពជាពត៌មានដែលត្រូវបានប្រមែប្រមូលយ៉ាងយកចិត្តទុកដាក់ដើម្បីកត់ចូលក្នុងប្រវត្តិសាស្ត្រ ក្នុងគោលបំណងបញ្ជាក់ទៅលើបញ្ហាចំនួនមនុស្សស្លាប់បាត់បង់ជីវិតនៅក្នុងជំនាន់ខ្មែរក្រហមកាន់កាប់ ។ ទិន្នន័យនេះមិនមានការប៉ាន់ស្មានតាមរយៈស្ថិតិបានមកពីកិច្ចសម្ភាសន៍នៅក្នុង១ឬ២-៣ទីតាំងដូចជាកិច្ចខិតខំប្រឹងប្រែងនៅពេលមុនៗក្នុងការប៉ាន់ស្មានចំនួនមនុស្សស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមកាន់កាប់ឡើយ ។ ទិន្នន័យរណ្តៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាទិន្នន័យបណ្តោះអាសន្ន បញ្ជាក់ពីទីតាំងច្បាស់លាស់ប្រមូលមកពីទីកន្លែងផ្សេងៗនៅទូទាំងប្រទេសអាចផលិតសាឡើងវិញបាន និងបើកឲ្យប្រើប្រាស់ជាសាធារណៈ ។ គ្មានអ្វីក្រៅពីនេះទៀតទេ ។

## ការទាត់ចោលនូវការបដិសេធថាគ្មានអំពើប្រល័យពូជសាសន៍កើតឡើង

មានកិច្ចការច្រើនណាស់ដែលត្រូវធ្វើបន្តទៅទៀតមុនពេលដែលការធ្វើផែនទីនៅតាមទីតាំងក្នុងប្រទេសកម្ពុជាមិនទាន់ត្រូវបានបញ្ចប់ ។ ខេត្តព្រះវិហារមិនទាន់ត្រូវបានចុះត្រួតពិនិត្យនៅឡើយទេមកទល់នឹងពេលនេះ ។ កិច្ចការធ្វើផែនទីរណ្តៅសាកសពនៅក្នុងខេត្តមណ្ឌលគិរីនិងរតនគិរីទើបតែចាប់ផ្តើមប៉ុណ្ណោះ ហើយការងារនេះនៅបន្សល់ទុកជាច្រើននៅតាមខេត្តផ្សេងៗដូចជាខេត្តបាត់ដំបងនិងខេត្តបន្ទាយមានជ័យ ។ សរុបទាំងអស់មានស្រុកចំនួន២០នៅតាមទីតាំងផ្សេងៗទូទាំងប្រទេសកម្ពុជាដែលមិនទាន់ចាប់ផ្តើមដំណើរការស្រាវជ្រាវនៅឡើយ ។ នៅក្នុងស្រុកជាច្រើនដែលបានក្រុមផែនទីបានចុះសិក្សាស្រាវជ្រាវខ្លះៗហើយ នៅសល់ឃុំមួយចំនួនទៀតដែលមិនទាន់ចុះទៅដល់ដើម្បីធ្វើផែនទី ។ ឃុំជាច្រើនក្នុងចំណោមឃុំទាំងអស់ដែលមិនទាន់ត្រូវបានធ្វើផែនទីរួច មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលពត៌មានដែលបញ្ជាក់ពីទីតាំងរណ្តៅសាកសពហើយ ។

**(នៅមានត)** **របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា**

# តម្លៃនៃភ័ស្តុតាង

**(តពីលេខមុន)** ១) អំពើប្រល័យពូជសាសន៍

អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ដែលចូលជាធរមាននៅក្នុងឆ្នាំ១៩៥១ បានចែងអំពីវិធានមួយចំនួនហាមប្រាមមិនឲ្យមានអំពើប្រល័យពូជសាសន៍ ។ ប្រទេសកម្ពុជាគឺជាប្រទេសហត្ថលេខីមួយដោយគ្មានការបម្រុងចាប់តាំងពីឆ្នាំ១៩៥១មកម្ល៉េះ ។ នៅឆ្នាំ១៩៧៥ ការហាមប្រាមអំពើប្រល័យពូជសាសន៍ ក៏គឺជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិ ទោះបីជាទម្រង់ពិតប្រាកដរបស់ច្បាប់នេះមិនមានលក្ខណៈច្បាស់លាស់នៅឡើយយ៉ាងណាក៏ដោយ ។ អ្នកវិភាគស្ទើរតែទាំងអស់យល់ថា អំពើប្រល័យពូជសាសន៍ក៏គឺជាប្រធានបទមួយនៃបទដ្ឋាន (jus cogens) ដែរនៅត្រឹមឆ្នាំ១៩៧៥ ។

មាត្រាទី II នៃអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ចែងធាតុផ្សំជាមូលដ្ឋាននៃបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដូចតទៅ÷ ១)ចេតនាក្នុងការបំផ្លាញទាំងស្រុងឬដោយផ្នែកចំពោះប្រជាជាតិ ជាតិពន្ធ ពូជសាសន៍ ឬក្រុមសាសនា ២) ការប្រព្រឹត្តនៅក្នុងពេលមានសន្តិភាពឬពេលមានសង្គ្រាម ។ អំពើមួយក្នុងចំណោមអំពីដូចខាងក្រោមចំពោះមនុស្សមួយក្រុមក្នុងចំណោមក្រុមមនុស្សទាំងឡាយដែលបានលើកឡើងខាងលើៈ ក) ការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម ខ) បង្កការឈឺចាប់និងខូចខាត ជាដំណាំខាងផ្នែករាងកាយឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម គ) បង្កឡើងដោយចេតនានូវមហន្តរាយឬការហិនហោចដល់ស្ថានភាពរស់នៅក្នុងសង្គមនុស្សដោយកម្ទេចបំផ្លិចបំផ្លាញក្រុមទាំងមូលឬផ្នែកខ្លះៗនៃសង្គម ឃ) ដាក់បង្ខំនូវវិធានការណ៍នានាដែលបង្ករមិនឲ្យមានកំណើតទារកនៅក្នុងសង្គម ង) យកកូនក្មេងចេញពីសង្គមមួយទៅដាក់នៅក្នុងសង្គមមួយទៀតដោយបង្ខិតបង្ខំ ។

២) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

មាត្រាទី ៦ (គ) នៃធម្មនុញ្ញរបស់តុលាការនៅនូរិមប៊ឺកមានបញ្ចូលនិយមន័យទីមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ មានករណីសំខាន់ៗជាច្រើនទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែមិនមាននិយមន័យផ្នែកច្បាប់ច្បាស់លាស់ទេ ។ គណៈកម្មាធិការច្បាប់អន្តរជាតិ មានបំណងធ្វើសេចក្តីព្រាងអនុសញ្ញាមួយទាក់ទងជាមួយនឹងអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងត្រូវបានពន្យារពេល ហើយនៅត្រឹមឆ្នាំ១៩៧៩ ពុំមានអនុសញ្ញាណាមួយត្រូវបានបញ្ចប់សព្វគ្រប់ឡើយ ។ អ្នកសិក្សាជាន់ខ្ពស់ភាគច្រើនស្ទើរតែទាំងអស់យល់ស្របថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយចំនួនគឺជាផ្នែកមួយនៃច្បាប់ទម្លាប់ជាតិនៅត្រឹមឆ្នាំ១៩៧៥ ប៉ុន្តែវិសាលភាពនៃច្បាប់ទម្លាប់នៅពេលនោះគ្មានកម្រិតច្បាស់លាស់ឡើយ ។ ការលំបាកដូចគ្នានេះដែរនៅក្នុងការកំណត់វិសាលភាពនៃវិធានដែលអាចយកមកអនុវត្តបាន គឺកើតឡើងនៅពេលវិភាគបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្រោមប្រភពនៃច្បាប់អន្តរជាតិ ។ ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅឆ្នាំ១៩៧៥មិនមានលក្ខណៈច្បាស់លាស់ទេ ។ ផ្អែកទៅលើភ័ស្តុតាងនៃធម្មនុញ្ញនូរិមប៊ឺក គណៈកម្មាធិការច្បាប់អន្តរជាតិ សេចក្តីព្រាងអនុសញ្ញា និងប្រភពផ្សេងៗទៀត ធាតុផ្សំដែលអាចបង្កើតបាននៅឆ្នាំ១៩៧៥មានដូចខាងក្រោម÷ ១) ការប្រព្រឹត្តនៅក្នុងអំឡុងពេលមានសង្គ្រាមឬសន្តិភាព នូវអំពើអមនុស្សធម៌ផ្សេងៗដូចជា ឃាតកម្ម ការសម្លាប់បំផុតពូជ ទាសភាព ការបណ្តេញចេញ ឬការធ្វើទុក្ខបុកម្នេញ ២) ប្រឆាំងនឹងប្រជាជនស៊ីវិលទាំងឡាយដោយហេតុផលសង្គម នយោបាយ ពូជសាសន៍ សាសនា ឬវប្បធម៌ ៣) ដោយអាជ្ញាធរនៃរដ្ឋឬបុគ្គលដែលប្រព្រឹត្តអំពើទាំងនេះដោយមានការជំរុញ ឬដោយមានការបណ្តោយតាមរបស់អាជ្ញាធរនៃរដ្ឋនោះ ។ នៅឆ្នាំ១៩៧៥ ដើម្បីបង្ហាញថាអំពើមួយត្រូវបាន

ប្រព្រឹត្តមកលើប្រជាជនស៊ីវិល លុះត្រាតែមានចំនួនជនរងគ្រោះច្រើនសន្ធឹកសន្ធាប់ឬការចេញនយោបាយជាប្រព័ន្ធណាមួយ ។

ដូចដែលបានរៀបរាប់មកនៅក្នុងកថាខ័ណ្ឌខាងលើមកហើយ ខ្ញុំបានសន្មតថានៅឆ្នាំ១៩៧៥ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនត្រូវការឲ្យមានសម្ព័ន្ធភាពប្រដាប់អាវុធទេ ។ ក្នុងខណៈដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានទទួលស្គាល់ជាទូទៅថាសព្វថ្ងៃនេះគ្មានតម្រូវការឲ្យមានសម្ព័ន្ធភាពប្រដាប់អាវុធទេនោះ លក្ខណៈច្បាប់នៅឆ្នាំ១៩៧៥មិនមានអ្វីច្បាស់លាស់ឡើយ ។ ការសន្និដ្ឋានរបស់ខ្ញុំមានសារសំខាន់ណាស់ទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ពីព្រោះអំពើឃោរឃៅភាគច្រើនស្ទើរតែទាំងអស់របស់បក្សកុម្មុយនិស្តកម្ពុជាត្រូវបានទាញហេតុផលថាបានប្រព្រឹត្តឡើងក្នុងលក្ខណៈជាកម្មវិធី «បោសសម្អាត» ក្នុងស្រុក មិនមែនជាលក្ខណៈជម្លោះប្រដាប់អាវុធប្រឆាំងនឹងប្រទេសវៀតណាម ថៃឬអ្នកបះបោរនៅភូមិភាគបូព៌ាឡើយ ។ ទោះបីជាខ្មែរក្រហមពិតជាបានប្រព្រឹត្តបទល្មើសជាច្រើនរាប់មិនអស់ទាក់ទងនឹងជម្លោះទាំងអស់នោះយ៉ាងណាក៏ដោយ ក៏តម្រូវការសម្ព័ន្ធជម្លោះប្រដាប់អាវុធអាចមានឥទ្ធិពលយ៉ាងសំខាន់ទៅលើករណីព្រហ្មទណ្ឌប្រឆាំងនឹងអតីតមេដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជាដែរ ។

៣) ឧក្រិដ្ឋកម្មសង្គ្រាម

លិខិតូបករណ៍ទំនើបសំខាន់នៃអន្តច្បាប់ដែលមានតាំងពីយូរណាស់មកហើយនោះ គឺអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ អនុសញ្ញាទីក្រុងហ្សឺណែវទាំងបួនទាក់ទងនឹងអ្នកមានរបួសហើយមានជំងឺ ឈ្លើយសឹក អ្នកមានរបួសនិងមានជំងឺហើយលិចកប៉ាល់នៅក្នុងសមុទ្រ និងជនស៊ីវិលនៅពេលសង្គ្រាម ។ ពិធីការចំនួនពីរ ពោលគឺពិធីការI និងពិធីការII ត្រូវបានបន្ថែមទៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវនៅឆ្នាំ១៩៧៧ ទោះបីជាមិនមានភាពច្បាស់លាស់ថា ពិធីការទាំងពីរនេះអាចស្រាយបំភ្លឺនូវច្បាប់ទម្លាប់ដែលមានស្រាប់ដែរឬទេយ៉ាងណាក៏ដោយ ។ ទោះបីជាប្រកាន់យកយ៉ាងទូលំទូលាយយ៉ាងណាក៏ដោយ វាក៏នៅតែមិនច្បាស់ដែរថា តើក្រោយឆ្នាំ១៩៧៧ ពិធីការទាំងពីរមានការស្រាយបំភ្លឺបញ្ជាក់អំពីច្បាប់ទម្លាប់ដែលមានស្រាប់ឬទេ ។ ធម្មនុញ្ញរបស់តុលាការនៅនូរិមប៊ឺក និងតុលាការដែលត្រូវបានបង្កើតឡើងនៅក្រោយសង្គ្រាមលោកលើកទី២ បានបន្ថែមទៅលើវិសាលភាពនៃឧក្រិដ្ឋកម្មសង្គ្រាមដែលមកដល់ឥឡូវនេះ ហើយនៅក្នុងករណីខ្លះនៅឆ្នាំ១៩៧៥ ត្រូវបាននិយាយថាជាប្រធានបទនៃច្បាប់ទម្លាប់អន្តរជាតិ ។

អនុសញ្ញាក្រុងហ្សឺណែវ ធម្មនុញ្ញរបស់តុលាការនៅនូរិមប៊ឺក និងប្រភពផ្សេងៗទៀតបង្ហាញថា នៅអំឡុងពេលជម្លោះប្រដាប់អាវុធ ដូចជាប្រទូសភាពតាមព្រឹត្តន័យ (de facto hostilities) (ឬការកាន់កាប់) ដែលពាក់ព័ន្ធនឹងជនជាតិបរទេស សកម្មភាពទាំងឡាយដូចរៀបរាប់ខាងក្រោមនេះនឹងចូលក្នុងតម្រូវការនៃអំពើពិរុទ្ធ **(actus reus)** នៃឧក្រិដ្ឋកម្មសង្គ្រាម÷ ១) ក) ការសម្លាប់ដោយចេតនា ខ) ទារុណកម្មឬអំពើអមនុស្សធម៌ ឬ គ) ការបង្កដោយចេតនានូវការឈឺចាប់ឬរបួសដល់រាងកាយឬសុខភាពរបស់អ្នកមានរបួសហើយមានជំងឺ និងលិចកប៉ាល់នៅឯសមុទ្រ ឈ្លើយសឹក ឬក្រុមមនុស្សដែលត្រូវបានការពារ (ជាទូទៅជនស៊ីវិល) ២) ការបំផ្លិចបំផ្លាញនិងការរឹបអូសទ្រព្យសម្បត្តិរបស់អ្នកមានរបួសហើយមានជំងឺ ឬក្រុមមនុស្សដែលត្រូវបានការពារ ៣) បង្ខំឈ្លើយសឹកឬជនស៊ីវិលឲ្យបម្រើការនៅក្នុងកងកម្លាំងបង្កជម្លោះ ៤) ការដកហូតដោយចេតនានូវសិទ្ធិរបស់ឈ្លើយសឹក ឬក្រុមមនុស្សដែលត្រូវបានការពារ មិនឲ្យមានការជម្រះក្តីក្នុងលក្ខណៈយុត្តិធម៌និងត្រឹមត្រូវ ៥)ក) ការនិរទេសឬផ្ទេរពីកន្លែងមួយទៅកន្លែងផ្សេងទៀតដោយខុសច្បាប់ ឬ ខ) ការឃុំឃាំងក្រុមមនុស្សដែលត្រូវបានការពារ ៦) ការចាប់ជាចំណាប់ខ្មាំង និង ៧) ការប្រើអាវុធជាតិពុល ការបំផ្លិចបំផ្លាញយ៉ាងព្រៃផ្សៃ ឬការប្លន់យកទីក្រុង និងការបង្កឲ្យខូចខាតអគារ ឬកិច្ចការផ្សេងៗពិសេសៗ ។ តម្រូវការទូទៅនៃបំណងឧក្រិដ្ឋ **(mens rea)** អនុវត្តចំពោះឧក្រិដ្ឋកម្មសង្គ្រាម ។

៤) អំពើទាសភាព និង ការបង្ខំឲ្យធ្វើការងារ

អំពើទាសភាពគឺជាប្រធានបទយ៉ាងជាក់ច្បាស់នៃបទដ្ឋាន (jus cogens) នៅត្រឹមឆ្នាំ១៩៧៥ ។ អនុសញ្ញាជាច្រើនត្រូវបានចុះហត្ថលេខាដោយហាមប្រាមអំពើទាសភាព ដែលនៅក្នុងអនុសញ្ញាទាំងនោះមានភ្ជាប់ជាមួយនូវការទទួលខុសត្រូវចំពោះ

មុខច្បាប់ចំពោះការប្រព្រឹត្តនូវអំពើនេះ ។ អនុសញ្ញាស្តីពីអំពើទាសភាព ការជួញដូរទាសករ និងការបង្កើតទាសករ ព្រមទាំងការអនុវត្តដែលមានលក្ខណៈប្រហាក់ប្រហែលអំពើទាសភាព (ដែលក្នុងនោះប្រទេសកម្ពុជាភាគីចុះកិច្ចសន្យាចាប់តាំងពីឆ្នាំ១៩៧៥) គឺជាអនុសញ្ញាដែលមានសារសំខាន់បំផុត ។

ការហាមប្រាមមិនឲ្យមានការបង្ខំធ្វើការងារគឺជាបទដ្ឋានទាក់ទងគ្នាមួយដែលត្រូវបានបង្កើតឡើងឲ្យទៅជាច្បាប់ទម្លាប់ដោយអនុសញ្ញាឆ្នាំ១៩៣០ ។ ទាក់ទងនឹងការបង្ខំឲ្យធ្វើការងារ (ដែលប្រទេសកម្ពុជាជាភាគីមួយដែរ) ក៏មានសេចក្តីហាមប្រាមការធ្វើការងារដោយបង្ខំដែរ ទោះបីជាការប្រព្រឹត្តអំពើនេះត្រូវបានចាត់ទុកថាមានលក្ខណៈខុសច្បាប់ ហើយកតិកាសញ្ញានិងអនុសញ្ញាទាំងពីរនេះដែលដូចគ្នាទៅនឹងអនុសញ្ញាឆ្នាំ១៩៣០ មានការលើកលែងមួយចំនួនក៏ដោយចុះ ។ ហេតុដូចនេះវិសាលភាពនៃសកម្មភាពធ្វើការងារដោយបង្ខំដែលជាបទឧក្រិដ្ឋចាប់ពីឆ្នាំ១៩៧៥ គឺមិនមានលក្ខណៈច្បាស់លាស់ទេ ។

ចំណុចខាងក្រោមនេះគឺចូលជាបទដ្ឋាននៃអំពើទាសភាព÷ ១) ការទាញយកជាកម្មសិទ្ធិជាលក្ខណៈប្រពៃណី និងការជួញដូរទាសករ ឬស្ត្រីនិងកុមារ ឬ ២) ការអនុវត្តជាក់ស្តែងដែលមានលក្ខណៈប្រហាក់ប្រហែលនឹងអំពើទាសភាព រួមទាំងអំពើទាសភាពដែលកើតចេញពីបំណុល ។ តម្រូវការបទដ្ឋាន (*actus reus*) ចំពោះការធ្វើការងារដោយបង្ខំគឺមិនសូវមានលក្ខណៈច្បាស់លាស់ប៉ុន្មានទេ ពីព្រោះវិសាលភាពនៃឧក្រិដ្ឋភាពក្នុងការបង្ខំមនុស្សម្នាក់ឬច្រើននាក់ធ្វើពលកម្មដោយគ្មានការស្ម័គ្រចិត្តមិនមានច្បាស់លាស់ទេ ។ ចាប់តាំងពីឆ្នាំ១៩៧៥មក មានតែការអនុវត្តការបង្ខំឲ្យធ្វើការងារដែលមានលក្ខណៈដូចគ្នាទៅនឹងអំពើទាសភាព (ដូចជាអំពើដែលមានសញ្ញាបញ្ជាក់អំពីកម្មសិទ្ធិ ឬការផ្លាស់ប្តូរនៅក្នុងលក្ខណៈច្បាប់របស់កម្មករ) បានធ្វើឲ្យមានការទទួលខុសត្រូវចំពោះមុខច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ នៅក្នុងខណៈដែលតម្រូវការនៃបំណងឧក្រិដ្ឋ (*mens rea*) ទូទៅអនុវត្តទាំងចំពោះឧក្រិដ្ឋកម្មទាសភាពនិងការបង្ខំធ្វើការងារនោះ ចេតនាក្នុងការដាក់ទណ្ឌកម្មឬគាបសង្កត់ក្រុមណាមួយ ដោយផ្អែកលើលក្ខណៈសម្បត្តិនយោបាយ សាសនា ជនជាតិ ជាតិពន្ធ ឬជាតិ គឺមានលក្ខណៈទាក់ទងគ្នាក្នុងការកំណត់កម្រិតនៃការបង្ខំឲ្យធ្វើការងារដែលមានលក្ខណៈដូចគ្នាទៅនឹងអំពើទាសភាព ។

៥) ទារុណកម្ម

ដូចជាអំពើទាសភាពដែរ ទារុណកម្មគឺជាប្រធានបទនៃបទដ្ឋាន (*jus cogens*) គិតត្រឹមឆ្នាំ១៩៧៥ ។ មតិឯកច្ឆ័នទៅលើសេចក្តីប្រកាសស្តីអំពីទារុណកម្មធ្វើឡើងដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ១៩៧៥ បង្ហាញថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះទារុណកម្មគឺប្រហែលជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិគិតត្រឹមឆ្នាំ១៩៧៥ ។ បញ្ហានេះមិនពិតប្រាកដទាំងស្រុងនោះទេ ពីព្រោះអនុសញ្ញាប្រឆាំងនឹងទារុណកម្មនិងអំពើអមនុស្សធម៌ឬអំពើដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស ឬការដាក់ទណ្ឌកម្មដែលភ្ជាប់ជាមួយការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ មិនទាន់ចូលជាធរមាននៅឡើយទេរហូតដល់ឆ្នាំ១៩៨៤ ។

ធាតុផ្សំនៃបទឧក្រិដ្ឋ"ទារុណកម្ម"មានដូចខាងក្រោមនេះ÷ ១) ការបង្កដោយចេតនាចំពោះមនុស្សនូវអំពើដែលប៉ះពាល់ធ្ងន់ធ្ងរផ្នែកសតិបញ្ញានិងរាងកាយ ២) ធ្វើឡើងដោយខ្លួនឯងឬដោយមានការជំរុញពីមន្ត្រីសាធារណៈ ៣) ក្នុងគោលបំណងៈ ក) ជម្រិតយកពីជននោះឬជនទីបីនូវព័ត៌មានឬចម្លើយសារភាព ខ) ដាក់ទណ្ឌកម្មចំពោះជននោះចំពោះអំពើដែលខ្លួនបានប្រព្រឹត្តឬត្រូវបានសង្ស័យថាបានប្រព្រឹត្ត គ) សម្លុតបំភ័យជននោះឬអ្នកដទៃទៀត ។

៦) ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌

ចាប់តាំងពីឆ្នាំ១៩៦២មក ប្រទេសកម្ពុជាគឺជាហត្ថលេខីនៃអនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩៥៤ ស្តីអំពីការការពារទ្រព្យសម្បត្តិវប្បធម៌ ដែលចាត់ទុកថាជាការខុសច្បាប់ចំពោះការបំផ្លិចបំផ្លាញដោយចេតនាទៅលើសម្បត្តិវប្បធម៌ និងដែលត្រូវបានបន្ថែមដោយពិធីសារឆ្នាំ១៩៧៧ចំនួនពីរចំណុចទៀត ។ ក៏ប៉ុន្តែនៅក្រោមច្បាប់ទម្លាប់អន្តរជាតិ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ ជាទូទៅគ្រាន់តែជាបទល្មើសមួយដែលអាចផ្តន្ទាទោសនៅក្នុងពេលមានជម្លោះប្រដាប់អាវុធតែប៉ុណ្ណោះ ។

ឧក្រិដ្ឋកម្មនៃការបំផ្លាញសម្បត្តិវប្បធម៌គឺជាអំពើទាំងឡាយណាដែលនាំដល់ការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ ដូចជាកិច្ចការ

សិល្បៈដែលមានតម្លៃ ឬស្ថាបត្យកម្មមុនឬក្នុងពេលមានជម្លោះប្រដាប់អាវុធ ។ គោលការណ៍នៃបំណងឧក្រិដ្ឋកម្មធម្មតា (mens rea) អនុវត្តចំពោះករណីនេះ ។

៧) ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព

ធម្មនុញ្ញអង្គការសហប្រជាជាតិដែលជាផ្នែកមួយនៃបទដ្ឋាន (jus ad bellum) ដែលមានតាំងពីបុរាណ បានបង្កើតភាពខុសច្បាប់ប្រឆាំងនឹងអំពើឈ្លានពានជាបទដ្ឋាន (jus cogens) នៅក្នុងច្បាប់អន្តរជាតិ ។ នៅក្រោមធម្មនុញ្ញនូរិមប៊ឺក អំពើឈ្លានពានមួយចំនួនបានធ្វើឲ្យមានការទទួលខុសត្រូវជាលក្ខណៈបុគ្គលក្នុងផ្នែកព្រហ្មទណ្ឌ ។ ក៏ប៉ុន្តែព្រហ្មទណ្ឌនៃអំពើឈ្លានពាននៅតែមានភាពមិនប្រាកដប្រជាខ្លះៗ ។

សារធាតុប្រពៃណីនៃឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពត្រូវបានចែងនៅក្នុងធម្មនុញ្ញរបស់តុលាការនូរិមប៊ឺកដូចតទៅ÷ ១) ការដាក់ផែនការ ការរៀបចំផ្តើមគំនិត ឬការធ្វើសង្គ្រាមឈ្លានពាន ឬសង្គ្រាមរំលោភលើសន្ធិសញ្ញា កិច្ចព្រមព្រៀង ឬក៏ការធានាអន្តរជាតិផ្សេងៗ ឬ ២) ការចូលរួមនៅក្នុងផែនការទូទៅមួយ ឬការសមគំនិតប្រព្រឹត្តអំពើដែលបានរៀបរាប់ខាងដើម ។ អំពើដែលអាចចូលទៅក្នុងបទដ្ឋាន (actus reus) បានពង្រីកខ្លួនចាប់តាំងពីតុលាការនៅនូរិមប៊ឺក ប៉ុន្តែលក្ខណៈជាក់ច្បាស់នៃច្បាប់ នៅក្នុងឆ្នាំ១៩៧៥មិនមានពេញលក្ខណៈឡើយ ។ ដូចនេះមានការពិបាកក្នុងការកំណត់ថាតើអំពើណាមួយដែលអាចបង្កើតជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ។

៨) ការរើសអើងជាតិសាសន៍

ការរើសអើងជាតិសាសន៍គឺច្បាស់ណាស់ជាការរំលោភទៅលើច្បាប់ទម្លាប់អន្តរជាតិ និងអនុសញ្ញាឆ្នាំ១៩៦៦ ស្តីអំពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងជាតិសាសន៍ ។ ក៏ប៉ុន្តែការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌអន្តរជាតិរបស់បុគ្គលចំពោះការរើសអើងជាតិសាសន៍ គឺមិនច្បាស់លាស់ទេ ។ ទោះបីជាការរើសអើងបណ្តាលឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោមអនុសញ្ញាអន្តរជាតិឆ្នាំ១៩៧៣ ស្តីអំពីការទប់ស្កាត់និងការដាក់ទណ្ឌកម្មទៅលើឧក្រិដ្ឋកម្មនៃការរើសអើងក៏ដោយ ក៏នៅត្រឹមឆ្នាំ១៩៧៥មានប្រទេសមួយចំនួនបានចុះហត្ថលេខាលើអនុសញ្ញានេះ ហើយប្រទេសកម្ពុជាទើបតែបានចុះហត្ថលេខានៅឆ្នាំ១៩៨១ ។ អ្នកសិក្សាជាន់ខ្ពស់បានកត់សម្គាល់ថា អនុសញ្ញាបង្ហាញពីដំហានរីកចម្រើនមួយនៅក្នុងច្បាប់អន្តរជាតិ មិនមែនសេចក្តីប្រកាសនៃច្បាប់ទម្លាប់ដែលមានស្រាប់នោះទេ ។ ដូចនេះព្រហ្មទណ្ឌភាពនៃការរើសអើងនៅក្នុងអំឡុងឆ្នាំ១៩៧៥ - ៧៩ គឺមិនមានលក្ខណៈច្បាស់លាស់ទេ ។

ការរើសអើងគឺជាទម្រង់មួយនៃការរើសអើងជាតិសាសន៍ដែលប្រហែលក្លាយជាទោសព្រហ្មទណ្ឌចាប់ពីឆ្នាំ១៩៧៥មក ។ ធាតុផ្សំរបស់ទោសព្រហ្មទណ្ឌនេះគឺ÷ ១) ការប្រព្រឹត្តអំពើអមនុស្សធម៌ដូចជា បដិសេធក្នុងការមានជីវិតនិងសេរីភាពដោយបង្កឲ្យមានលក្ខណៈផ្សេងៗដែលឈានទៅបំផ្លាញក្រុមមួយដោយចាត់វិធានការច្បាប់ឬវិធានការផ្សេងៗក្នុងការទប់ស្កាត់លទ្ធភាពរបស់ក្រុមមិនឲ្យចូលរួមក្នុងជីវិតនយោបាយ បែងចែកប្រជាជនតាមជាតិសាសន៍ កេងប្រវ័ញ្ចកម្លាំងពលកម្មពីក្រុមមួយ ឬធ្វើទុក្ខបុកម្នេញក្រុមផ្សេងៗ ដែលជាការផ្ទុយទៅនឹងប្រការដែលបានចែងពីខាងដើម ។ ២) ក្នុងគោលបំណងបង្កើតនិងថែរក្សាអំណាចគ្របសង្កត់ដោយក្រុមមួយទៅលើមនុស្សនៃក្រុមមួយទៀតនិងគាបសង្កត់ជាប្រព័ន្ធ ។ មិនមានលក្ខណៈច្បាស់លាស់ទេថាតើការរើសអើងបណ្តាលឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចាប់ពីឆ្នាំ១៩៧៥ដែរឬទេ? ហើយតើក្រុមជាតិសាសន៍ត្រូវបានកំណត់យ៉ាងដូចម្តេច?

## ខ) ធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មអន្តរជាតិ

១) អំពើពិរុទ្ធ

តម្រូវការនៃអំពើពិរុទ្ធ (ឬអំពើគួរដាក់ទណ្ឌកម្ម) គឺ“ការចូលរួម” ដែលការប្រព្រឹត្តរបស់ជនជាប់ចោទ បង្កើតបានជាការប្រព្រឹត្តបទឧក្រិដ្ឋ ។ ហើយត្រូវតែមានអំពើធ្វើឡើងដោយចេតនារបស់ជនជាប់ចោទដែលមានផលប៉ះពាល់ដល់ការប្រព្រឹត្តអំពើឧក្រិដ្ឋ ។ ជនជាប់ចោទមិនចាំបាច់មានវត្តមាននៅកន្លែងកើតហេតុបទឧក្រិដ្ឋទេ ហើយអំពើនេះអាចចូលជាទម្រង់ប្រយោលដូចជាការជំរុញ ការចូលរួមប្រព្រឹត្ត ឬចេញបញ្ជា ។

**(នៅមានត)** **ចន ឆរឆីអារី**

# បញ្ហាបន្ថែមនៅក្រោមច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិៈ ឧក្រិដ្ឋកម្មពាក់ព័ន្ធ ការការពារ និង ឧបសគ្គនានាចំពោះអំពើឧក្រិដ្ឋកម្ម

## ១) ឧក្រិដ្ឋកម្មពាក់ព័ន្ធ

ច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិក៏ដូចជាច្បាប់ឧក្រិដ្ឋកម្មក្នុងប្រទេសដែរ ជាទូទៅទទួលស្គាល់ថា បុគ្គលអាចត្រូវទទួលកំហុសចំពោះអំពើមួយចំនួនដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានរៀបចំនិងមានផែនការត្រឹមត្រូវ ថ្វីបើបុគ្គលនោះមិនប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់ក៏ដោយ ។

សញ្ញានៃ **ការឃុបឃិត** និង **ការចូលដៃ** បានទទួលការអនុម័តយល់ព្រមនៅក្នុងធម្មនុញ្ញនូរិមប៊ឺក ដែលមាត្រាទី៦ «ក» នៃធម្មនុញ្ញនេះបានដាក់ទោសឧក្រិដ្ឋទាំងការរៀបចំនិងអនុវត្តន៍នូវសង្គ្រាមរំលោភបំពាន និងដាក់ផែនការរួមឬឃុបឃិតក្នុងការធ្វើសង្គ្រាមនេះ ។ តុលាការយោធាអន្តរជាតិបានបកស្រាយនូវការចោទប្រកាន់ពីបទឃុបឃិតយ៉ាងតឹងរ៉ឹងដោយកម្រិតពាក្យនេះទៅនឹងអំពើដែលទាក់ទងស្និទ្ធបំផុតទៅនឹងការរៀបចំសង្គ្រាម ហើយដោយហេតុនេះ បានធ្វើឲ្យមេដឹកនាំណាហ្ស៊ីស្ទើរតែទាំងអស់ដែលត្រូវបានចោទប្រកាន់ពីបទឃុបឃិតនោះ រួចទោស ។ ច្បាប់ក្រុមប្រឹក្សាជាតិត្រួតពិនិត្យលេខ១០ បានអនុវត្តនូវទស្សនៈទូលំទូលាយបន្ថែមមួយទៀត ដោយរំលែកមុខជនចូលដៃដើងថាបានចូលរួម និងជនទាំងឡាយណាដែលពាក់ព័ន្ធជាមួយនឹងផែនការឧក្រិដ្ឋ និងសមាជិកអង្គការដែលពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋកម្ម ។

មាត្រាទី III នៃអនុសញ្ញាប្រល័យពូជសាសន៍ចែងថា ការឃុបឃិតក្នុងការប្រព្រឹត្តនិងចូលរួមនៅក្នុងអំពើប្រល័យពូជសាសន៍ក៏ត្រូវចាត់ចូលជាឧក្រិដ្ឋកម្មដែរ តែមាត្រានេះមិនទាន់ចែងនូវនិយមន័យសម្រាប់ពាក្យទាំងនេះនៅឡើយទេ ។ ការពង្រីករបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ទៅលើគោលការណ៍នូរិមប៊ឺករួមមានការចូលដៃក្នុងឧក្រិដ្ឋកម្មទាំង៣នៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ (មិនគ្រាន់តែឧក្រិដ្ឋកម្មប្រឆាំងសន្តិភាពឡើយ) ថាជាឧក្រិដ្ឋកម្មអន្តរជាតិ ហើយសេចក្តីព្រាងច្បាប់ឆ្នាំ១៩៥៤ រួមមានការឃុបឃិតនិងការចូលដៃ ។ ក៏ប៉ុន្តែបញ្ញត្តិទាំងនេះ ... បរិធានទាំងអស់នេះនៅតែខ្វះនូវឯកភាពក្នុងចំណោមប្រព័ន្ធច្បាប់ក្នុងការឲ្យនិយមន័យទៅលើពាក្យទាំងអស់នេះ បានធ្វើឲ្យការងាររាជអាជ្ញានិងតុលាការដែលប្រឈមមុខនឹងការគោរពសិទ្ធិរបស់ជនចុងចោទមានលក្ខណៈស្មុគស្មាញខ្លះៗ ។ លក្ខន្តិកៈតុលាការយូហ្គោស្លាវីនិងរ៉្វាន់ដាមានបំណងធ្វើឲ្យមានលក្ខណៈពិស្តារបន្តិចថែមទៀតក្នុងការដាក់ទោសដល់ជនទាំងឡាយណាដែល «រៀបចំផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬបើមិនអ៊ីចឹងទេជួយនិងជំរុញក្នុងការរៀបចំផែនការ រៀបចំចាត់ចែង ឬប្រតិបត្តិ» នូវឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលបានរៀបរាប់ហើយមកនោះ ។

បើទោះបីមានន័យមិនច្បាស់ជាប្រជាខ្លះៗនេះក៏ដោយ ក៏ជា









ទូទៅ ការឃុបឃិតត្រូវបានឯកភាពថាអាចឈានដល់គំនិតនៃការទទួលខុសត្រូវក្រោមការបញ្ជា ។ ជាការជាក់ស្តែងណាស់មេបញ្ជាការម្នាក់ដែលបញ្ជាឲ្យថ្នាក់ក្រោមប្រព្រឹត្តនូវឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ គឺទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តទាំងអស់នោះ ។ ក៏ប៉ុន្តែកាន់តែទូលំទូលាយថែមទៀត មេបញ្ជាការម្នាក់ជាទូទៅគឺទទួលខុសត្រូវចំពោះអំពើរបស់ថ្នាក់ក្រោមខ្លួន ប្រសិនបើៈ ១) បានដឹង ឬមានហេតុផលដើម្បីដឹងថាថ្នាក់ក្រោមរបស់ខ្លួនបានប្រព្រឹត្ត ឬហៀបនឹងប្រព្រឹត្តនូវអំពើបែបនេះ ។ និង ២) មិនបានចាត់វិធានការចាំបាច់និងសមហេតុផលដើម្បីទប់ស្កាត់នូវអំពើទាំងអស់នេះ ឬដើម្បីដាក់ទណ្ឌកម្មថ្នាក់ក្រោមរបស់ខ្លួន ។ "លក្ខន្តិកៈតុលាការយូហ្គោស្លាវីនិងរ៉ូវ៉ាន់ដា" ក៏បានអនុម័តនូវគំរូនេះដែរ ។

ក្រៅពីសញ្ញាណឃុបឃិតក្នុងច្បាប់ដែលឥតមានចែងជាលាយលក្ខណ៍អក្សរ (common law) ការប៉ុនប៉ងនៅតែមានន័យមិនច្បាស់លាស់ក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។ ការប៉ុនប៉ងនេះត្រូវដាក់បញ្ចូលនៅក្នុងធម្មនុញ្ញតុលាការអន្តរជាតិ ឬច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ដោយមានរាប់បញ្ចូលដែនការឧក្រិដ្ឋកម្មមួយចំនួន ។ វាអាចលេចឡើងជាឧក្រិដ្ឋកម្មនៅក្នុងមាត្រា III នៃអនុសញ្ញាប្រល័យពូជសាសន៍ ហើយនិងសេចក្តីព្រាងច្បាប់របស់គណៈកម្មាធិការច្បាប់អន្តរជាតិឆ្នាំ១៩៥៤ និងឆ្នាំ១៩៩១ ។ ឯកសារទាំង៣នេះដាក់ថា "ការញុះញង់ដោយផ្ទាល់"គឺជាឧក្រិដ្ឋកម្មដល់ (ដោយមានន័យបន្ថែមគុណនាម "សាធារណៈ" សម្រាប់អនុសញ្ញាប្រល័យពូជសាសន៍) ។ ក៏ប៉ុន្តែលក្ខខណ្ឌនេះជាធម្មតាមិនមានលេចឡើងនៅក្នុងបរិធានច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិផងទៃទៀតឡើយ ។

### ២) ការការពារ និង ឧបសគ្គនានាចំពោះអំពើឧក្រិដ្ឋកម្ម

បន្ថែមទៅនឹងសញ្ញាណនៃ (nullum crimen sine lege) ដែលបានពិភាក្សាក្នុងជំពូកទី២ ច្បាប់ឧក្រិដ្ឋអន្តរជាតិបានបង្កើតនូវទ្រឹស្តីជាមូលដ្ឋានមួយពាក់ព័ន្ធនឹងការការពារដែលមានលក្ខណៈរួមជាទីបំផុត ។

**ក) បញ្ជាថ្នាក់លើ ការបញ្ជាពីច្បាប់ និងការមិនដឹងមិនពុចំពោះច្បាប់ៈ** ចាប់តាំងពីនូរិមប៊ឺកមក បុគ្គលម្នាក់ត្រូវតែទទួលខុសត្រូវនូវការប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្រោមច្បាប់អន្តរជាតិប្រសិនបើបុគ្គលនោះបានដឹង ឬគួរតែបានដឹងនូវចរិតខុសច្បាប់របស់អំពើនេះ ។ ប្រការដែលថាថ្នាក់ក្រោមម្នាក់ធ្វើតាមតែបញ្ជាថ្នាក់លើ គឺមិនមែនជាចម្លើយការពារចំពោះច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិឡើយ ។ ប៉ុន្តែ ប្រសិនបើបញ្ជានោះមិនខុសច្បាប់ច្បាស់ពេកទេ ចុងចោទប្រហែលជាអាចឆ្លើយយកតែរួចខ្លួនថាមិនបានដឹងពីច្បាប់ ដូចដែលគោលការណ៍ (nullum crimen sine lege) បានផ្តល់នូវការការពារខ្លះៗប្រឆាំងនឹងការរំពឹងមិនសមហេតុផលចំពោះការដឹងពុអំពីច្បាប់ដែលមាននៅពេលនោះ ។ ក៏ប៉ុន្តែបញ្ជាខុសច្បាប់យ៉ាងច្បាស់ ហើយនិងករណីកិច្ចរបស់ថ្នាក់ក្រោម ដើម្បីស្វែងយល់ថាតើបញ្ជាខុសច្បាប់ឬស្របច្បាប់នៃបញ្ជាមួយជាបញ្ហាដ៏ស្មុគស្មាញណាស់ ។

**អេលីហ្សាប៊ែត វ៉ាន់ស្កាក់**

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក
**ទស្សនាវដ្តី "ស្វែងរកការពិត"**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
ឬ Email: dccam@bigpond.com.kh

## អត្ថន័យនៃពាក្យ "ហិង្សា"

◆ **ន័យរបស់ខ្មែរក្រហមៈ** *ហិង្សាៈ ភាពប្រើវាយកម្ទេចរបស់ប្រជាជនឬក្រុមនយោបាយណាមួយទៅលើគូទំនាស់ស្លាប់រស់របស់ខ្លួន។ (សៀវភៅ "ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" ថ្នាក់ទី២ បោះពុម្ពឆ្នាំ១៩៧៧)*

◆ **ន័យតាមសៀវភៅវចនានុក្រមខ្មែរ បោះពុម្ពឆ្នាំ១៩៦៧ៈ** *ហិង្សាៈ (ន.) ការបៀតបៀន ការពាធា ការធ្វើអាក្រក់រកគ្នា ការធ្វើទុក្ខគ្នា ។ ឧទាហរណ៍ៈ មនុស្សត្រូវកុំឲ្យមានហិង្សារកគ្នា ។*

# សេចក្តីព្រាងច្បាប់ខ្មែរក្រហមៈ ឧក្រិដ្ឋកម្មនានាដែលត្រូវបានលើកឡើង

សេចក្តីព្រាងច្បាប់ខ្មែរក្រហមគ្របដណ្តប់លើឧក្រិដ្ឋកម្មនានាដូចខាងក្រោម ដែលត្រូវបានប្រព្រឹត្តឡើងនៅអំឡុងពេលគិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ចូរកត់សម្គាល់ថា អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើ ត្រូវបានពន្យារពេលបន្ថែម២០ឆ្នាំទៀតទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ ។

**ក) មនុស្សឃាត (ច្បាប់ឆ្នាំ១៩៥៦ៈ មាត្រាទី ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង ៥០៨)**

មនុស្សឃាតអាចជាអំពើកើតឡើងដោយចេតនាព្រហើនគ្មានកោតក្រែង ឬសេចក្តីប្រមាថ ។ អំពើដែលអាចចាត់ចូលជាអំពើមនុស្សឃាតមានដូចជាការកាប់សម្លាប់ និងសភាពស្មារតីពិរុទ្ធៈ ចេតនាសម្លាប់ ការប្រមាថមិនគោរពជីវិតមនុស្ស ។ "កម្រិត" នៃអំពើមនុស្សឃាតគឺអាស្រ័យទៅតាមកម្រិតនៃសភាពស្មារតីពិរុទ្ធ ។

**ខ) ទារុណកម្ម (ច្បាប់ឆ្នាំ១៩៥៦ៈ មាត្រាទី ៥០០)**

ធាតុផ្សំខាងក្រោមនេះអាចបង្កើតជាអំពើ "ទារុណកម្ម" បាន÷

- ជនជាប់ចោទអាចជាមន្ត្រីសាធារណៈ ឬបុគ្គលដែលប្រព្រឹត្តអំពើដោយចេតនាតាមការញុះញង់របស់មន្ត្រីសាធារណៈដែលមានតួនាទីក្នុងរដ្ឋ ។
- ជនជាប់ចោទបង្កឲ្យជនរងគ្រោះមានការឈឺចាប់ ឬខូចខាតយ៉ាងធ្ងន់ធ្ងរលើរាងកាយ និងសតិបញ្ញា ។
- ជនជាប់ចោទធ្វើការរំលោភដើម្បី ១) ជម្រិតយកព័ត៌មាន ឬចម្លើយសារភាពពីជនរងគ្រោះនិងបុគ្គលទីបី ។ ២) ផ្តន្ទាទោសជនរងគ្រោះចំពោះអំពើដែលបានប្រព្រឹត្តកាលពីអតីតកាល ឬអំពើដែលត្រូវបានសង្ស័យថាបានប្រព្រឹត្ត ឬ ៣) ដើម្បីសម្លុតបំភ័យជនរងគ្រោះឬបុគ្គលទីបី ។

**គ) ការធ្វើទុក្ខបុកម្នេញលើសាសនា (ច្បាប់ឆ្នាំ១៩៥៦ៈ មាត្រាទី២០៩ និង ២១០)**

តម្រូវឲ្យមានការធ្វើទុក្ខបុកម្នេញដោយចេតនាទៅលើបុគ្គលម្នាក់ទៀតដោយហេតុផលជំនឿសាសនារបស់ជនរងគ្រោះ ។

**ឃ) ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌**

អំពើដែលនាំដល់បំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌នៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធមានដូចជាៈ ការបំផ្លាញស្នាដៃសិល្បៈ អក្សរសាស្ត្រ សាសនា ស្ថាបត្យកម្ម និងទ្រព្យសម្បត្តិវប្បធម៌ផ្សេងៗទៀត នៅក្នុងអំឡុងពេលសង្គ្រាម ។

**ង) អំពើប្រល័យពូជសាសន៍**

ដូចដែលបានកំណត់ជានិយមន័យនៅក្នុងអនុសញ្ញាស្តីពីការទប់ស្កាត់និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ ហើយថា អំពើប្រល័យពូជសាសន៍ដែលគ្មានអាជ្ញាយុកាលច្បាប់ជាអំពើទាំងឡាយណាដែលត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងបំផ្លាញចោលទាំងស្រុង ឬដោយផ្នែក ចំពោះប្រជាជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ ដូចជា÷

- ការសម្លាប់សមាជិកទាំងឡាយណានៅក្នុងក្រុម ។
- បង្កការឈឺចាប់និងខូចខាតជាធ្ងន់ធ្ងរខាងផ្នែករាងកាយឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម ។
- បង្កឡើងដោយចេតនានូវមហន្តរាយឬការហិនហោចដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្ស ដោយកម្ទេចបំផ្លិចបំផ្លាញក្រុមទាំងស្រុងឬផ្នែកខ្លះនៃសង្គម ។
- ដាក់បង្ខំនូវវិធានការនានាដែលបង្ការមិនឲ្យមានកំណើតទារកនៅក្នុងសង្គម ។
- យកកុមារចេញពីសង្គមមួយទៅដាក់នៅក្នុងសង្គមមួយទៀតដោយបង្ខំ ។

**ច) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលច្បាប់គឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទ្រង់ទ្រាយធំឬជាប្រព័ន្ធ ប្រឆាំងនឹងជនស៊ីវិលដោយមូលហេតុជាតិពន្ធុ

នយោបាយ ពូជសាសន៍ ឬសាសនាណាមួយ÷

◆ ការធ្វើមនុស្សឃាត ។

◆ ការសម្លាប់រង្គាលបំផុតពូជ ។

◆ ការធ្វើឲ្យទៅជាទាសករ ។

◆ ការនិរទេស ។

◆ ការដាក់ក្នុងឃុំឃាំង ។

◆ ការធ្វើទារុណកម្ម ។

◆ ការរំលោភលើផ្លូវភេទ ។

◆ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ។

◆ អំពើអមនុស្សធម៌ផ្សេងៗទៀត ។

### ឆ) ឧក្រិដ្ឋកម្មសង្គ្រាម

ការប្រព្រឹត្តដោយខ្លួនឯងឬបញ្ជាឲ្យមានការប្រព្រឹត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដូចជាអំពើប្រឆាំងនឹងមនុស្ស ឬទ្រព្យសម្បត្តិដែលត្រូវការពារដោយបទបញ្ញត្តិនៃអនុសញ្ញានេះ÷

◆ ការធ្វើមនុស្សឃាតដោយចេតនា ។

◆ ការធ្វើទារុណកម្មឬការធ្វើបាបដោយអមនុស្សធម៌ ។

◆ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរឬឲ្យមានការឈឺចាប់ដល់រាងកាយឬសុខភាព ។

◆ ការបំផ្លាញឬធ្វើឲ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិដោយមិនមានហេតុផលចាំបាច់ខាងយោធា ដែលធ្វើឡើងដោយខុសច្បាប់និងគ្មានត្រាប្រណី ។

◆ ការបង្ខំឲ្យឈ្លើយសឹកឬជនស៊ីវិលបម្រើការនៅក្នុងកងកម្លាំងរបស់គូបដិបក្ខ ។

◆ ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់ ។

◆ ការនិរទេស ការជម្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ។

◆ ការយកជនស៊ីវិលជាចំណាប់ខ្មាំង ។

### ជ) ឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ

ឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ដែលអនុលោមទៅតាមអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្តីអំពីទំនាក់ទំនងការទូត ។

**សួ ប៊ុនស៊ូ**

**(តមកពីទំព័រទី៦)** ចេញជាអ្វីទេ ។ អានេះដើរក្រឡឹងសិន ។ វិធានការៈ ល្ងាចនេះនឹងកំហែងពីរនាក់មិត្ត ហ៊ី ម្តងទៀត ។ ២១-១១-៧៧, ចាន់ ។

ចម្លើយសារភាពលើកទី២របស់ ពីនី ដែលធ្វើនៅថ្ងៃទី២២ ខែ១១ ឆ្នាំ១៩៧៧ គ្រាន់តែជាការបញ្ជាក់បន្ថែមខ្លះៗទៅលើចម្លើយសារភាពលើកទី១តែប៉ុណ្ណោះ ។ ពីនី នៅតែសម្តែងការដឹងកំហុសនិងអង្វរករសុំការលើកលែងទោសដាដដែល ។ ចម្លើយលើកទី៣ធ្វើនៅថ្ងៃទី២៣ ខែ១១ និងលើកទី៤ធ្វើនៅថ្ងៃទី៥ ខែ១២ ឆ្នាំ១៩៧៧ ក៏មិនទាន់មានការបរិយាយលម្អិតអំពីសកម្មភាពរបស់ ពីនី នៅឡើយដែរ ។ មានតែចម្លើយសារភាពលើកទី៥ ជាលើកចុងក្រោយ ធ្វើនៅថ្ងៃទី១៧ ខែ២ ឆ្នាំ១៩៧៨ ដែល ពីនី បានសរសេរយ៉ាងលម្អិតអំពីសកម្មភាពក្បត់របស់ខ្លួន ទៅតាមអ្វីដែលកម្មាភិបាលសួរចម្លើយចង់បានព្រមជាមួយនឹងការធ្វើបញ្ជីឈ្មោះមួយដែល ពីនី សរសេរថា «ឈ្មោះមនុស្សដែលពាក់ព័ន្ធរឿងក្បត់ជាមួយខ្ញុំ» ។ ឈ្មោះមនុស្សចំនួន១០៥នាក់ដែលភាគច្រើនជាអតីតសមាជិករណសិរ្សរួបរួមជាតិកម្ពុជា និងជាទូតនៅបរទេស ត្រូវបានចុះក្នុងបញ្ជីនោះ ។ ខ្ញុំសូមស្រង់ជូននូវឈ្មោះមនុស្សសំខាន់ៗមួយចំនួនមានដូចជាៈ សារិន ឆាក, អាំង ប៊ុនថៃ, អ៊ុំ ម៉ាណូរិន, ពុង ប៉េងចេង, សាយ បូរី, ធាម ប៊ុនស្រ៊ុន, លៀវ ធានអ៊ុម, សោម សារី, ហង់ ធុនហាក់, ឌុក រ៉ាស៊ី, ចៅ បាន, ឃី តាំងលឹម, ស៊ុម ម៉ានិត, ធុច វុធី, វ៉ា គីមហុង, ពិន យ៉ាថៃ, យុគ ចាន់ថា, រឿង ម៉ាជ, អ៊ុំ ម៉ុងគាត, កែ មាស, ទេព សំអាន, ភោគ ឆាយ, ហ៊ូ យន់, ហ៊ូ នឹម, ភូរិស្សរ៉ា, ចែម ស្នួន, តូច ខាំឌឿន, ហោ ណាំហុង, ចៅ សេង, វ៉ាន់ ស, ជា សាន, អៀវ បណ្ណាកា ។ល។ ឈ្មោះនីមួយៗសុទ្ធតែត្រូវបានបញ្ជាក់តួនាទីការងារយ៉ាងច្បាស់លាស់ ។

តាមបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១ដែលត្រូវកម្ទេច វ៉ាន់ ពីនី និងប្រពន្ធ (ឈ្មោះ គួន វឌ្ឍណា ហៅ ចាន់) ត្រូវសម្លាប់ព្រមគ្នានៅថ្ងៃទី៣១ ខែ៣ ឆ្នាំ១៩៧៨ ។

(សង្ខេបពីឯកសារលេខ V២៦) **សាន់ កល្យាណ**

# ជនកុម្មុយនិស្ដ ខ្មែរក្រហម និង វៀតណាម:

## ប្រវត្តិទំនាក់ទំនងរវាងខ្មែរក្រហម និង វៀតណាម

មកទល់នឹងថ្ងៃនេះ ប្រវត្តិនៃទំនាក់ទំនងរវាងជនកុម្មុយនិស្ដខ្មែរក្រហមនិងវៀតណាមស្ថិតនៅជាអាថ៌កំបាំងនៅឡើយ ។ ទោះបីជាមានការសិក្សាស្រាវជ្រាវក្នុងទ្រង់ទ្រាយធំទៅលើប្រធានបទនេះនៅក្នុងប្រទេសរុស្ស៊ី និងបរទេស ក៏នៅតែគ្មានចម្លើយឆ្លើយតបទៅនឹងសំណួរសំខាន់ៗជាច្រើន ។ ប្រវត្តិនៃទំនាក់ទំនងរវាង ប៉ុល ពត និងខ្មែរក្រហមជួនកាលត្រូវបានបកស្រាយខុសគ្នារវាងអ្វីដែលវៀតណាម និងលោកខាងលិចបានអធិប្បាយ ។ សម្ដីរបស់មេដឹកនាំខ្មែរក្រហមដូចជា អៀង សារី ឬ ខៀវ សំផន កាលពីឆ្នាំ១៩៩៩ ដែលបានចុះចូលទៅខាងរដ្ឋាភិបាលភ្នំពេញ ហើយបាននិយាយអ្វីដែលប្រជាជនកម្ពុជាចង់ស្ដាប់នោះក៏នៅមិនទាន់មានលក្ខណៈគួរឲ្យទុកចិត្តបានដែរ ។ ទាំងអស់នេះអាចទាញសេចក្ដីសន្និដ្ឋានថាការវិភាគទំនាក់ទំនងរវាងទីក្រុងហាណូយនិងខ្មែរក្រហមមិនមែនជារឿងប្រវត្តិសាស្ត្រតែម្យ៉ាងនោះទេ ។ នៅមានធាតុនយោបាយមួយទៀតដែលជាប្រធានបទសំខាន់នៅក្នុងការសិក្សានេះ ។

អ្នកនិពន្ធអត្ថបទនេះព្យាយាមដោះស្រាយបញ្ហា និងបង្ហាញពីគោលបំណង និងរូបភាពនៃភាពមិនលម្អៀងចំពោះអ្វីដែលបានកើតឡើងក្នុងអតីតកាល ។ ការសិក្សាស្រាវជ្រាវនេះគឺផ្អែកលើការសិក្សាមួយដោយផ្អែកលើឯកសារនៅបណ្ណសាររបស់អតីតសហភាពសូវៀត កំណត់ហេតុរបស់ឯកអគ្គរដ្ឋទូតសហភាពសូវៀតនិងវៀតណាម ឯកសារសន្ទនាជាមួយនឹងសមាជិករដ្ឋាភិបាលជាន់ខ្ពស់របស់វៀតណាម សំណេរវិភាគសំបុត្រនយោបាយរបស់ស្ថានទូតសូវៀតប្រចាំនៅសាធារណរដ្ឋសង្គមនិយមវៀតណាមនិងឯកសារផ្សេងៗមួយចំនួនទៀត តម្កល់ទុកនៅបណ្ណសារប្រវត្តិសាស្ត្រទំនើបរុស្ស៊ី ។

ដោយមានយោងប្រភពផ្សេងៗទៀតដូចជាបណ្ណសារអាណានិគមបារាំង និងកិច្ចសម្ភាសន៍ជាមួយជនជាតិវៀតណាមនិងកម្ពុជា (មើលសៀវភៅប្រវត្តិវិទូ ប៊ែន ឃៀនិនៈ តើប៉ុល ពតឡើងកាន់អំណាចដោយរបៀបណាៈ ប្រវត្តិកុម្មុយនិស្ដនៅកម្ពុជា ១៩៣០-១៩៧៥) ស្នាដៃនេះអាចផ្ដល់ចម្លើយប្រកបដោយភាពពិតប្រាកដ និងសមហេតុផលទៅនឹងបញ្ហានេះ ។

ទំនាក់ទំនងរវាងជនកុម្មុយនិស្ដខ្មែរក្រហមនិងវៀតណាមបានឆ្លងកាត់ដំណាក់កាលវិវត្តន៍ធំៗមួយចំនួន ។ នៅដំណាក់កាលទីមួយដែលអាចកំណត់ថានៅចន្លោះឆ្នាំ១៩៣០-១៩៥៤ ខ្មែរមួយក្រុមតូចនៅក្នុងបក្សកុម្មុយនិស្ដឥណ្ឌូចិនបានស្ថិតនៅក្រោមមនោគមវិជ្ជា និងការគ្រប់គ្រងចាត់តាំងរបស់ជនកុម្មុយនិស្ដវៀតណាម ។ នៅក្នុងអំឡុងនៃការតស៊ូរំដោះខ្លួនពីការគ្រប់គ្រងរបស់បារាំង(១៩៤៦-១៩៥៤) កម្លាំងក្រុមនេះបានកើនឡើងជាលំដាប់ដោយសារមានការកៀងគរអ្នកដែលមានការតាំងចិត្តដាច់ខាតនៅក្នុងចលនាប្រឆាំងនឹងអាណានិគមនិយមបារាំងពីសំណាក់បក្សកុម្មុយនិស្ដឥណ្ឌូចិន ។បក្សប្រជាជនបដិវត្តកម្ពុជាត្រូវបានបង្កើតឡើងនៅខែមិថុនា ឆ្នាំ១៩៥១ នៅលើមូលដ្ឋាននេះ ។ មេដឹកនាំបក្សដែលមានឈ្មោះ សឺង ង៉ុកមិញ, ស៊ីវ ហេង និង ទូ សាមុត បានការប្រកៀកស្មាគ្នាជាមួយនឹងវៀតណាមនៅក្នុងសង្គ្រាមប្រឆាំងនឹងអាណានិគមនិងជាសម្ព័ន្ធមិត្តពិតប្រាកដ និងគឺជាអ្នកធ្វើផែនការព្រាងឡើងដោយបក្សកុម្មុយនិស្ដឥណ្ឌូចិន ។

នៅឆ្នាំ១៩៥៤ កិច្ចព្រមព្រៀងនៅទីក្រុងហ្សឺណែវស្ដីអំពីបញ្ហាឥណ្ឌូចិនបានផ្លាស់ប្ដូរទំនាក់ទំនងជនកុម្មុយនិស្ដខ្មែរក្រហមនិងវៀតណាមយ៉ាងគំហុក ។ វៀតណាមបានដកកម្លាំងរបស់ខ្លួនចេញពីកម្ពុជាតាមកិច្ចព្រមព្រៀង ប៉ុន្តែមិនដូចប្រទេសឡាវទេ (ដែលនៅមានតំបន់សេរីដូចជា សាម នឿ ត្រូវបានកាន់កាប់ដោយជនកុម្មុយនិស្ដ) ទីក្រុងហាណូយមិនអាចទទួលបានលក្ខណៈបែបនេះពីសម្ព័ន្ធមិត្តខ្មែរឡើយ ។ វៀតណាមក្រោមការគាបសង្កត់ពីរបបសីហនុ និងសម្ព័ន្ធមិត្តលោកខាងលិចមិនអាចសូម្បីតែឲ្យខ្មែរកុម្មុយនិស្ដចូលរួមកិច្ចចរចានៅទីក្រុងហ្សឺណែវក៏មិនបានដែរ ហើយនៅចុងឆ្នាំ១៩៥៤ វៀតណាមបានដកទ័ពប្រយុទ្ធរបស់ខ្លួនចេញពីតំបន់នានានៅលើទឹកដីកម្ពុជាដែលស្ថិត

នៅក្រោមការកាន់កាប់របស់ខ្លួន ។ ចាប់តាំងពីពេលនោះមកកងកម្លាំងរាជានិយមបានចូលទៅក្នុងតំបន់ទាំងអស់ដែលស្ថិតនៅក្រោមការត្រួតត្រារបស់បក្សប្រជាជនបដិវត្តកម្ពុជាដែលជំរុញឲ្យបក្សនេះបន្ធុំចិត្តលាក់ខ្លួន ។ ការលួងចិត្តរបស់ទីក្រុងហាណូយដែលផ្តល់លទ្ធភាពក្នុងការលាក់ខ្លួនរបស់សម្ព័ន្ធមិត្តចំនួន២ពាន់នាក់នៅក្នុងទឹកដីវៀតណាមខាងជើង (ណាយ៉ាន ចាន់ដា ៈបងប្អូនដែលជាសត្រូវ ។ ទំព័រ៥៩) គឺមិនទាន់គ្រប់គ្រាន់ទេ ក្នុងការចូលរួមនៅក្នុងចលនាតស៊ូនេះ ។ ហេតុដូចនេះហើយបានជានៅក្នុងចំណោមខ្មែរក្រហមកុម្មុយនិស្តដែលនៅសេសសល់ក្នុងប្រទេសកម្ពុជានិយាយថាពួកហាណូយបានក្បត់នឹងខ្លួនហើយបានយកខ្លួនមកធ្វើជាចំណាប់ខ្មាំងដើម្បីឈានដល់កិច្ចព្រមព្រៀងជាមួយនឹងមេដឹកនាំកម្ពុជាគឺសម្តេចនរោត្តមសីហនុ ។ ការវាយតម្លៃទៅលើប្រតិបត្តិការរបស់វៀតណាមនៅអំឡុងកាលនោះថា “ជាការក្បត់មួយដ៏ធំនឹងបដិវត្តន៍កម្ពុជា” *(Shawcross, Sideshow: Kissinger, Nixon and the Destruction of Cambodia, N.Y., 1987, p. 238)* គឺលេចឡើងជាថ្មីច្រើនលើកនៅក្នុងឯកសារផ្លូវការរបស់ខ្មែរក្រហម ។ ប៉ុល ពត ខ្លួនឯងបានអះអាងដូចនេះជាច្រើនលើក ។ ប្រការគួរឲ្យចាប់អារម្មណ៍បំផុតគឺការសម្រេចចិត្តរបស់ពួកមេដឹកនាំទីក្រុងហាណូយតែងតែត្រូវបានចងចាំជានិច្ចនៅទីក្រុងភ្នំពេញ សូម្បីតែមកដល់ទសវត្សរ៍ឆ្នាំ៨០ហើយក្តីក៏នៅតែចាំ ។នៅក្នុងទសវត្សរ៍ឆ្នាំ៨០មន្ត្រីជាន់ខ្ពស់របស់ទីក្រុងភ្នំពេញដែលជាអគ្គលេខារណសិរ្សសង្គ្រោះជាតិកម្ពុជាដែលគាំទ្រវៀតណាម ចាន់ វ៉ែន បានមានយោបល់ថានៅឆ្នាំ១៩៥៣ “វៀតណាមធ្វើមិនត្រឹមត្រូវទេ ដែលទុកឲ្យយើងនៅម្នាក់ឯងប្រឈមមុខនឹងរបបកាន់អំណាច” (កិច្ចសន្ទនាជាមួយនឹង ចាន់ វ៉ែន ទីក្រុងភ្នំពេញថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨៤) ។

ព្រឹត្តិការណ៍នៅឥណ្ឌូចិនក្នុងឆ្នាំ១៩៥៤ គឺជាការចាប់ផ្តើមដំណាក់កាលថ្មីនៃទំនាក់ទំនងរវាងជនកុម្មុយនិស្តខ្មែរក្រហមនិងវៀតណាម ។ ភាពដៃគូដ៏ជិតស្និទ្ធក្នុងអំឡុងឆ្នាំ១៩៤៩-១៩៥៣ ក្លាយជាគ្មានន័យអ្វីទាំងអស់ ហើយបក្សប្រជាជនបដិវត្តន៍កម្ពុជាដែលបាត់បង់សមាជិករបស់ខ្លួន ជាច្រើនរូបបានសម្រេចចិត្តលាក់ខ្លួន ហើយមានភាពរកាំរកូសជាមួយគ្នាអស់រយៈពេលជាច្រើនឆ្នាំទៅលើទស្សនៈរបស់ទីក្រុងហាណូយ ។ មេដឹកនាំវៀតណាមខាងជើងដែលកំពុងតែរៀបចំឲ្យមានការតស៊ូប្រដាប់អាវុធសាជាថ្មីនៅវៀតណាមខាងត្បូងយល់ឃើញថាសម្តេច សីហនុ ដែលមានវោហារសាស្ត្រប្រឆាំងនឹងចក្រពត្តិអាមេរិកាំងគឺជាសម្ព័ន្ធមិត្តសំខាន់ជាងបក្សប្រជាជនបដិវត្តន៍កម្ពុជា ។ មិនតែប៉ុណ្ណោះសោត សម្តេច សីហនុ មានអំណាចពិតប្រាកដ ។ ទីក្រុងហាណូយសង្ឃឹមជឿជាក់យ៉ាងមុតមាំទៅលើសម្ព័ន្ធភាពជាមួយសម្តេច សីហនុ ដែលមិនត្រឹមតែរិះគន់សហរដ្ឋអាមេរិកទេ ថែមទាំងផ្តល់ឲ្យវៀតណាមខាងជើងនូវលទ្ធភាពប្រើប្រាស់ទឹកដីខ្លួនដើម្បីជាប្រយោជន៍បង្កើតសមរភូមិក្រោយនៅទីតាំងមួយដែលហៅថា “ច្រកផ្លូវលំហូជីមិញ” និងបញ្ជូនអាវុធគ្រាប់រំសេវដើម្បីទៅវាយវៀតណាមខាងត្បូងតាមរយៈកំពង់ផែក្រុងព្រះសីហនុនៅក្នុងទឹកដីកម្ពុជាទៀត ។ (ទោះជាយ៉ាងណាក៏ដោយខ្មែរបានទទួលប្រមាណតែ១០ភាគរយក្នុងចំណោមអាវុធគ្រាប់រំសេវដែលបញ្ជូននេះ ។ (ណាយ៉ាន់ ចាន់ដាៈបងប្អូនដែលជាសត្រូវ ។ ទំព័រទី៦១និង៤២០) ។ វៀតណាមបានប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការពង្រឹងរបបខ្លួនហើយបានចេញវាយកម្ទេចរាល់ផែនការជនកុម្មុយនិស្តមូលដ្ឋានក្នុងការវាយសម្តេច សីហនុ ។ ទីក្រុងហាណូយ ជឿជាក់ថា “ការតស៊ូប្រដាប់អាវុធជាមួយរដ្ឋាភិបាលសម្តេច សីហនុ បានធ្វើឲ្យខ្លួនចុះខ្សោយហើយបើកផ្លូវឲ្យចក្រពត្តិអាមេរិកប្រើឥទ្ធិពលបោកប្រាស់ប្រឆាំងនឹងកម្ពុជា” ។ មិនតែប៉ុណ្ណោះវៀតណាមថែមទាំងព្យាយាមមិនឲ្យខ្មែរកុម្មុយនិស្តចាកចេញពីទីក្រុងហាណូយទៅកម្ពុជាដើម្បីអនុវត្តការងារមិនស្របច្បាប់នៅប្រទេសរបស់ខ្លួនហើយព្យាយាមចាត់អ្នកទាំងនោះឲ្យកាន់មុខតំណែងផ្លូវការផ្សេងៗពីគ្នានៅក្នុងប្រទេសវៀតណាម(*RSAMH, Fund 5, inventory 50, file721: Document of the USSR Embassy in the DRV, April 1, 1965, p. 142*) ។

ចំពោះជនកុម្មុយនិស្តដែលកំពុងតែធ្វើប្រតិបត្តិការនៅលើទឹកដីកម្ពុជា អង្គការបង្កប់របស់ខ្លួនត្រូវបែកខ្ញែកជាក្រុមៗក្រោមសម្ពាធដ៏ធ្ងន់របស់អាជ្ញាធរ ហើយមេដឹកនាំស្របច្បាប់របស់ខ្លួនបានដើរតត្រុកគ្មានទីដៅច្បាស់លាស់ម្តងលាក់ខ្លួននៅទីនេះម្តងនៅទីនោះតាមដែលអាចធ្វើទៅបាន ។ ឯកសារដើមនៅសម័យនោះមិនត្រូវបានចងក្រងទុកឡើយ ។ ប៉ុន្តែយោងតាមសម្តីរបស់ ទេព ខេន អតីតឯកអគ្គរដ្ឋទូតនៃរបបភ្នំពេញ

ក្រោមការដឹកនាំរបស់ ហេង សំរិន បានឲ្យដឹងថាឯកសារទាំងអស់របស់បក្សត្រូវបានប្រមូលដាក់ក្នុងកាបូបរបស់ ទូ សាមុត និងអង្គរក្សពីរនាក់ដែលយកតាមខ្លួនរហូត ពេលដើរទៅណាមកណានៅក្នុងប្រទេសកម្ពុជា (កិច្ចសន្ទនាជាមួយនឹង ទេព ខេន នៅទីក្រុងម៉ូស្គូ ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៨៥) ។ អំពើក្បត់វៀចវេររបស់ ស៊ីវ ហេង ដែលជាមនុស្សសំខាន់ទីពីរ នៅក្នុងជួរបក្សប្រជាជនបដិវត្តន៍កម្ពុជា គឺជាការវាយសំពងមួយព្រនង់យ៉ាងដំណំទៅលើអង្គការដែលបង្កប់ខ្លួន ។ មេបក្សរូបនេះដែលទទួលខុសត្រូវការងាររបស់បក្សប្រជាជនកម្ពុជានៅក្នុងជួរប្រជាកសិករអស់ជាច្រើនឆ្នាំមកហើយនោះបានសហការយ៉ាងសំខាន់ជាមួយនឹងភ្នាក់ងារសម្ងាត់ ជាពិសេសពួកអ្នកកំពុងកាន់កាប់ប្រទេស ហើយនៅអំឡុងឆ្នាំ១៩៥៥ដល់ឆ្នាំ១៩៥៩ បានប្រគល់សកម្មជនកុម្មុយនិស្តនៅក្នុងប្រទេសឲ្យអាជ្ញាធរកាន់អំណាច ។

ភាពច្របូកច្របល់ដាក់ស្តែងដែលកើតឡើងនៅពេញផ្ទៃក្នុងបក្សនិងភាពគ្មានការគ្រប់គ្រងមាំទាំពីសំណាក់បក្សវៀតណាម បានផ្តល់ឲ្យ សាឡុត ស (ក្រោយមកដាក់ឈ្មោះបដិវត្តថា ប៉ុល ពត) ដែលទើបត្រឡប់មកពីប្រទេសបារាំងព្រមទាំងមិត្តភក្តិសំខាន់ៗមួយចំនួនទៀតដែលនៅសិក្សាជាមួយគ្នានូវលទ្ធភាពយ៉ាងច្រើនក្នុងការឡើងកាន់តំណែងធំៗនៅក្នុងអង្គការមួយដែលត្រូវរង្គោះរង្គើពាក់កណ្តាលនិងឯកោ ។ ភាពវៀចវេររបស់ ស៊ីវ ហេង មិនមានផលប៉ះពាល់ខ្លាំងណាស់ណាទៅលើអ្នកទាំងនេះទេ ពីព្រោះអ្នកទាំងនេះស្ថិតក្នុងក្រុមរបស់បក្សនៅទីក្រុងដឹកនាំដោយ ទូ សាមុត ។

ភាពរីកចម្រើនផ្នែកអាជីពរបស់ ប៉ុល ពត មានសភាពខ្លាំងក្លាណាស់ពោលគឺនៅឆ្នាំ១៩៥៣ ប៉ុល ពត បានក្លាយជាលេខាបក្សតំបន់ ហើយនៅក្នុងឆ្នាំ១៩៥៩ ប៉ុល ពត បានឡើងតំណែងជាលេខាគណៈកម្មការធិការទីក្រុងភ្នំពេញនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា (កិច្ចសន្ទនាជាមួយនឹង ចាន់ វ៉ែន នៅទីក្រុងភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨៤) ។

នៅឆ្នាំ១៩៦២ នគរបាលសម្ងាត់របស់សម្តេច សីហនុ បានធ្វើការវាយប្រហារនិងសម្លាប់ ទូ សាមុត នៅកន្លែងលាក់ខ្លួនសម្ងាត់នៅទីក្រុងភ្នំពេញ (៤ឆ្នាំមុន ពោលគឺនៅឆ្នាំ១៩៥៨ មេដឹកនាំសំខាន់មួយរូបទៀតនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា ដែលជានិពន្ធនាយកនៃសារព័ត៌មានរបស់បក្សឈ្មោះ ណុប បូដាន់ ត្រូវបានបាញ់សម្លាប់) ។ ប៉ុល ពត និងមិត្តភក្តិពេលនោះមានឱកាសល្អកម្ររកបានក្នុងការដឹកនាំបក្ស ឬច្បាស់ជាងនេះទៀតអ្វីៗដែលត្រូវបានបន្សល់ទុក ។ នៅដើមឆ្នាំ១៩៦០ ប៉ុល ពត បានធានាប្រាកដថាការវាយតម្លៃទៅលើសភាពការណ៍នៅក្នុងប្រទេស និងគំនិតរបស់ខ្លួនចំពោះកលល្បិចនិងយុទ្ធសាស្ត្រតស៊ូនយោបាយត្រូវបានទទួលយកជាមូលដ្ឋានក្នុងការធ្វើសេចក្តីព្រាងកម្មវិធីរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា ។ បក្សនេះប្រកាសការការភ្ញាក់រលឹកបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យថាជាបុព្វហេតុចម្បងរបស់បក្សពោលគឺមានន័យថា តស៊ូដើម្បីផ្តួលរំលំរបបដឹកនាំប្រទេសសព្វថ្ងៃដែលជានយោបាយប្រឆាំងនឹងផលប្រយោជន៍ទីក្រុងហាណូយ ។ មហាសន្និបាតបានអនុម័តធម្មនុញ្ញថ្មីមួយនិងបង្កើតគណៈកម្មាធិការមជ្ឈិមដែលមាន ប៉ុល ពត ធ្វើជាអនុប្រធានរបស់បក្ស ។

ការដាក់សមាសភាពថ្មីត្រូវបានពង្រឹងនៅក្នុងឱកាសមហាសន្និបាតបក្សធ្វើឡើងនៅក្នុងខែមករា ឆ្នាំ១៩៦៣ ។ មានសមាសភាពមួយចំនួនជាអ្នកបង្កប់ខ្លួនហើយបើយោងតាមសម្តីរបស់ជនកុម្មុយនិស្តដើមចាស់គឺសមាសភាពនេះមិនលើសពី២០នាក់ទេ (កិច្ចសន្ទនាជាមួយនឹង ចាន់ វ៉ែន នៅទីក្រុងភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៨៤) ។ នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំនេះគណៈកម្មាធិការមជ្ឈិមថ្មីមួយដែលមានមនុស្សសំខាន់ៗកាន់មុខដំណែងមួយភាគបីនៃតួនាទីចំនួន១២នោះត្រូវបានបោះឆ្នោតជ្រើសតាំងឡើង ។ ប៉ុល ពត ខ្លួនឯងធ្វើជាអគ្គលេខាបក្សហើយ អៀង សារី ធ្វើជាសមាជិកអចិន្ត្រៃយ៍ ។ ជាការមិនគួរឲ្យជឿទាល់តែសោះពីសំណាក់វៀតណាម ប៉ុល ពត បានផ្លាស់ឈ្មោះបក្សនេះពី «បក្សប្រជាជនបដិវត្តន៍កម្ពុជា» ទៅ «បក្សកុម្មុយនិស្តកម្ពុជា» (កិច្ចសន្ទនាជាមួយនឹង ទេព ខេន នៅទីក្រុងមូស្គូ ថ្ងៃទី១០ ខែ មីនា ឆ្នាំ១៩៨៥) ។ ក្រោយមកក្នុងរយៈពេលដ៏យូរសមល្មម ដោយពន្យល់អំពីមូលហេតុនៃការប្តូរឈ្មោះរបស់បក្សនេះ ប៉ុល ពត បានប្រកាសថា «បក្សកុម្មុយនិស្តឥណ្ឌូចិននិងអ្នកស្នងរបស់ខ្លួនគឺបក្សប្រជាជនបដិវត្តន៍កម្ពុជាត្រូវបានបង្កើតឡើងដោយវៀតណាមដើម្បីកាន់កាប់ទឹកដីនៃប្រទេសកម្ពុជានិងឡាវ (ប្រវត្តិសង្ខេបនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា)» ។

វៀតណាមដែលបានឃ្លាំមើលការប្រែប្រួលរបស់ខ្មែរកុម្មុយនិស្តបន្តប់យ៉ាងស្ងៀមស្ងាត់អស់ពេលយ៉ាងយូរដោយមិនជ្រៀតជ្រែកចូលកិច្ចការខ្មែរ មិនបានដឹងថាដោយមានជំនួយអបេតនារបស់ខ្លួន ក្រុមអាក្រក់ផ្តាច់ការដឹកនាំដោយ ប៉ុល ពត និង អៀង សារី បានកំពុងតែលេចឡើងនោះទេ ។ នៅខែមករា ឆ្នាំ១៩៧៨ អនុប្រធានទីមួយនៃមន្ទីរទំនាក់ទំនងផ្ទៃក្នុងរបស់គណៈមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តវៀតណាម ង្វៀន ថាញ់ ឡេ បាននិយាយទៅកាន់ឯកអគ្គរដ្ឋទូតសូវៀតថា «មានទំនាស់រវាង ប៉ុល ពត និងអៀងសារី ពីមុនមក ដូចនេះហើយបានជានៅក្នុងឆ្នាំ ១៩៦៣-៦៤ អៀង សារី បានចេញពី ប៉ុល ពត ដែលបន្តប់ខ្លួនទៅភ្នំពេញ ។ ពេលនោះ ប៉ុល ពត បញ្ចុះបញ្ចូលឲ្យមិត្តវៀតណាមជួយធ្វើឲ្យ អៀង សារី វិលមកវិញ» (ឯកសារលេខ ១០៦១ កិច្ចសន្ទនារបស់ឯកអគ្គរដ្ឋទូតសូវៀតនៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៧៨) ។ គឺជាការពិបាកនិយាយណាស់ថា ប្រសិនបើពត៌មានដែលផ្តល់ដោយ ង្វៀន ថាញ់ ឡេ ប្រាប់អំពីព្រឹត្តិការណ៍ពិតមែន ។ ប៉ុល ពត ជាទូទៅជា «អ្នកក្រៅ» របស់មេដឹកនាំទីក្រុងហាណូយ ហើយជាការពិបាកណាស់ក្នុងការស្មានថាដើម្បីផលប្រយោជន៍នៃការផ្សះផ្សាទំនាក់ទំនងរបស់ខ្លួនជាមួយនឹង អៀង សារី ដែលមិនសូវជា «អ្នកក្រៅ» ចំពោះទីក្រុងហាណូយ ប៉ុល ពត ត្រូវការជំនួយវៀតណាមនោះ ។ មើលទៅទំនងជាមន្ត្រីជាន់ខ្ពស់វៀតណាមបានព្យាយាមបញ្ចុះបញ្ចូលសម្ព័ន្ធមិត្តសូវៀតថា វៀតណាមបានកាន់កាប់មេដឹកនាំខ្មែរកុម្មុយនិស្តយ៉ាងណែននៅក្នុងដៃហើយ ។

ការបុះទ្រុឌទ្រោមរបស់ខ្មែរកុម្មុយនិស្តបានចាប់ផ្តើមប្រែប្រួលនៅក្នុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ៦០ នៅពេលដែលទីក្រុងហាណូយដឹងថាការគាំទ្ររបស់សម្តេច សីហនុ ចំពោះនយោបាយវៀតណាមខាងជើងកាន់តែចុះខ្សោយទៅៗហើយ ។ ជំហររបស់គូបដិបក្ខចំពោះចំណងមិត្តភាពជាមួយទីក្រុងហាណូយដូសមុខឲ្យសេនាប្រមុខ លន់ ណុល និងទ្រង់សិរិមតៈ កាន់តែមាំទៅៗនៅទីក្រុងភ្នំពេញ ។ ស្ថិតក្នុងស្ថានភាពបែបនេះ វៀតណាមបានរំពឹកសម្ព័ន្ធមិត្តរបស់ខ្លួនតាំងពីដើមដំបូងនិងសាជាថ្មីម្តងទៀត ពោលគឺខ្មែរកុម្មុយនិស្ត ប៉ុន្តែវៀតណាមត្រូវប្រឈមមុខនឹងបញ្ហាជាច្រើនដែលមិនអាចនឹកស្មានដល់ថានឹងកើតមានឡើង ។ បញ្ហាសំខាន់មួយគឺថាដោយសារតែការធ្វេសប្រហែសជាក់ស្តែងបានធ្វើឲ្យមានមនុស្សមួយចំនួននៅកាន់មុខនាទីខ្ពស់ៗនៅក្នុងជួរបក្សកុម្មុយនិស្តជាមនុស្សដែលវៀតណាមមិនសូវស្គាល់ ហើយមួយចំនួនជាជនសង្ស័យ ដោយសារតែអ្នកទាំងនោះបានសិក្សានៅប្រទេសបារាំង ហើយមិនបានសិក្សានៅទីក្រុងហាណូយ ។ ម្យ៉ាងទៀតគឺភាគច្រើននៃអ្នកទាំងនេះមិនបានចូលធ្វើសង្គ្រាមប្រឆាំងនឹងអាណានិគមទេហើយក៏មិនបានធ្វើសច្ចាប្រណិធានចំពោះ «បងៗជំនាន់មុន» ដែរ ។ ប៉ុន្តែមូលហេតុសំខាន់អ្នកទាំងនោះរិះគន់ដោយចំហរចំពោះនយោបាយរបស់វៀតណាមខាងជើងចំពោះរបបដឹកនាំកម្ពុជា ។ ប៉ុល ពត មិនដូចជាអ្នកដឹកនាំមុនៗនៅក្នុងជួរបក្សថ្នាក់លើទេគឺ ការពារដាច់ខាតដោយគ្មានបត់បែនចំពោះមាគ៌ាដែលខ្មែរកុម្មុយនិស្តនឹងអនុវត្តដោយឯករាជ្យដើម្បីបំពេញគោលបំណងរបស់ខ្លួនផ្ទាល់ និងផលប្រយោជន៍ជាងមុនហើយ «នឹងអនុវត្តនយោបាយឯករាជ្យពិសេសផ្អែកលើបញ្ហាជាមូលដ្ឋាននៃការតស៊ូបដិវត្តន៍ ទាំងទ្រឹស្តី និងយុទ្ធសាស្ត្រ» (ប្រវត្តិសាស្ត្រសង្ខេបនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា ។ ទំព័រទី៦) ។ ដូច្នេះហើយទីក្រុងហាណូយគួរគិតថាមនុស្សសំខាន់ដែលមានវ័យក្មេងៗទាំងនេះបានទាញយកប្រជាប្រិយភាពនិងការគាំទ្រនៅក្នុងមជ្ឈដ្ឋានបក្សដោយសារតែសកម្មភាពនិងភាពឯករាជ្យរបស់ខ្លួន ។ គំនិតរបស់អគ្គលេខាថ្មីដែលថា «ការតស៊ូនយោបាយមិនមានលទ្ធផលទេ» នោះត្រូវបានយកមកគិតពិចារណា (ប្រវត្តិសាស្ត្រសង្ខេបនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា ។ ទំព័រទី៧) ។ ហេតុនេះហើយបានជាការងាររទៅមុខរបស់ខ្មែរកុម្មុយនិស្តគឺកាន់កាប់អំណាចនៅក្នុងប្រទេសកម្ពុជា ហើយផលប្រយោជន៍របស់ «បងប្អូនវៀតណាម» គឺមានឥទ្ធិពលទៅលើការសម្រេចចិត្តនៃនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ការដែលសំខាន់ដូចគ្នាដែរនោះគឺមុនដំបូងឡើងដោយចាប់តាំងពីកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវមកខ្មែរកុម្មុយនិស្តទោះបីជាមានសេចក្តីណែនាំឲ្យគាំទ្រនយោបាយប្រឆាំងនឹងចក្រពត្តិរបស់សម្តេចសីហនុ ដែលទទួលដោយ ប៉ុល ពត នៅក្នុងព្រះរាជសំណាក់យ៉ាងសម្ងាត់នៅទីក្រុងហាណូយកាលពីរដូវក្តៅឆ្នាំ១៩៦៥ យ៉ាងណាក៏ដោយក៏បានរៀបចំខ្លួនជាស្រេចដើម្បីរំកិលទិសទៅរកសកម្មភាពជាក់ស្តែង ។ **(នៅមានត)**

**មិត្រ្ទី មូសយ៉ាកូវ**

# ទីបញ្ចប់នៃបដិវត្តន៍

**(តពីលេខមុន)**

ចំពោះអ្នកធ្លាប់វាយដោយប្រើអាវុធធុន បេ-៤០ ឬអាគេរី ការងាកមកប្រើប្រាស់ធ្នូនិងចម្រូងគឺបង្ហាញពីកង្វះភាពរីកចម្រើនរបស់កម្ពុជាប្រជាធិបតេយ្យ ។ នៅទន្ទឹមពេលនោះដែរ កង្វះគ្រាប់រំសេវនិងការចាំបាច់ក្នុងការការពារមូលដ្ឋានបាននាំដល់ការបញ្ចប់ការវាយប្រហារទៅលើ "ទីប្រជុំជន" និងការដកកងទ័ពពីខេត្តដែលនៅជ្រៅក្នុងផ្ទៃប្រទេស ហើយដែលមានភាពប្រទូសរ៉ាយអស់រយៈពេលជាយូរណាស់មកហើយ ដូចជាខេត្តកំពង់ចាមនិងកំពង់ធំ ។ ចុងបញ្ចប់កម្មាភិបាលគ្រប់ថ្នាក់នៃចលនាខ្មែរក្រហមនិយាយថា ពេលនេះការតស៊ូត្រូវបញ្ចប់ដោយឥតបានការអ្វីសោះ ។


ប៉ុល ពត និងកូនស្រី (រូបថតឆ្នាំ១៩៨៦)

ទី២ៈ ល្បែងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសបានហុចលទ្ធផលបញ្ច្រាសមកវិញ ។ សង្គ្រាមអូសបន្លាយប្រឆាំងនឹងជនជាតិកម្ពុជាដូចគ្នាអាក្រក់គ្រប់គ្រាន់ណាស់ទៅហើយ ។ ប៉ុន្តែក្រោយពីសង្គ្រាមអស់រយៈពេលជាង២០ឆ្នាំ ក្រោយពីស្តាប់ការសន្យាជាប់គ្នាមិនដាច់តាមរយៈវិទ្យុផ្សាយសំឡេងថានឹងបានទទួលជ័យជម្នះនៅពេលឆាប់ៗខាងមុខនេះ ក្រោយពីឃើញក្តីសង្ឃឹមលាយឡំក្តីអស់សង្ឃឹមថានឹងបានសន្តិភាពជាមួយអ៊ិនតាក់ អ្នកដែលធ្លាប់មាន"ភក្តីភាព"ចំពោះខ្មែរក្រហមយល់ថា នេះជាទឹកចុងក្រោយដែលលែងធ្វើការតស៊ូបាន ។ អតីតមន្ត្រីកងពលធំ ៤៥០ ម្នាក់បាននិយាយថា "ក្រោយពីការបោះឆ្នោត មេដឹកនាំចាប់ផ្តើមនិយាយថា "ប្រយុទ្ធទាល់តែដល់ទីបញ្ចប់" រហូតដល់ជំនាន់ក្រោយៗទៀត ។ ក្រោយពីការបោះឆ្នោតគ្មានលេចចេញនូវគំនិតណាច្បាស់លាស់ស្តីអំពីថាតើត្រូវបញ្ចប់សង្គ្រាមដោយវិធីណា ឬថាតើការវាយប្រយុទ្ធគ្នានេះដើម្បីអ្វីឡើយ ។ ខ្ញុំចាំថាបានសួរសំណួរមួយថា "តើគោលដៅចុងក្រោយគឺអ្វីទៅ? តើត្រូវបញ្ចប់សង្គ្រាមតាមរបៀបណាទៅ?" ប៉ុន្តែគ្មានអ្នកណាឆ្លើយសោះ ។ ដូច្នេះឃើញថា ប៉ុល ពត និងអ្នកដទៃទៀត ពូកែណាស់ខាងទ្រឹស្តី ដូចជាចំណុច "១០ខថាអីចេះ" "ចំណុច៨ខអីចុះ"... ប៉ុន្តែដល់បញ្ហាសំខាន់ថាតើត្រូវបញ្ចប់សង្គ្រាមយ៉ាងណា គ្មានអ្នកណាឆ្លើយរួចឡើយ" ។

ទី៣ៈ ការទទួលយកបណ្តោះអាសន្ននូវសេរីភាវូបនីយកម្មផ្នែកនយោបាយនិងសេដ្ឋកិច្ច ក្រោយឆ្នាំ១៩៩១ បានបំផ្លាញខ្មែរក្រហមយ៉ាងដំណំ ។ ទោះបីជា ប៉ុល ពត និយាយផ្ទុយពីនេះមែន តែកម្ពុជាប្រជាធិបតេយ្យមានសមត្ថភាពខ្សោយជាងភាគីដទៃទៀតក្នុងការទទួលយកផលប្រយោជន៍ផ្នែកនយោបាយ ។ របនាសម្ព័ន្ធ ការគិត និងការដឹកនាំ សុទ្ធតែហួសសម័យនិងមិនអាចបត់បែនបានតាមកាលៈទេសៈ ។ ការឃោសនារបស់

កម្ពុជាប្រជាធិបតេយ្យ ផ្តោតសំខាន់ទៅលើការប្រឆាំងនឹងវៀតណាម ហើយក្រោយពីការដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជាក្នុងឆ្នាំ១៩៨៩ ធ្វើឲ្យឥទ្ធិពលនៃការឃោសនានេះចុះថមថយជាលំដាប់ ។ ការប្រកាន់ខ្ជាប់នូវសតិអារម្មណ៍និងការចាត់តាំង គឺត្រូវបានផ្អែកទៅលើភាពឯកោដែលចេញមកពីការមិនទុកចិត្តក្នុងចំណោមកងទ័ពរបស់ខ្លួននិងប្រជាជនមកពីមជ្ឈដ្ឋានខាងក្រៅ ។ ការបញ្ចប់ ជំនួយផ្នែកហិរញ្ញវត្ថុនិងតម្រូវការបន្តបន្ទាប់ក្នុងការអនុញ្ញាតឲ្យអង្គភាពយោធានិងបុគ្គលម្នាក់ៗចិញ្ចឹមជីវិតដោយខ្លួនឯង បាននាំឲ្យប្រជាជនគិតដល់ការរកចំណូល ទាក់ទងជាមួយអ្នកខាងក្រៅ និងនាំដល់ការខុសប្លែកគ្នាផ្នែកសេដ្ឋកិច្ចនៅក្នុងតំបន់រំដោះ ។ ការដាក់ឲ្យទទួលយកនូវសេរីភាពថ្មីផ្នែកពាណិជ្ជកម្ម ការដើរហើរ ខាងសាសនា ខាងទ្រព្យសម្បត្តិ និងសន្តិភាព ព្រមទាំងសភាពធម្មតា បានកាត់បន្ថយនូវគំនិតចង់ធ្វើសង្គ្រាមក្នុងចំណោមខ្មែរក្រហមភាគច្រើន ។

## ១៩៩៤-៩៦: ត្រឡប់មករឿងអនាគតវិញម្តង

ដោយជួបនឹងសភាពបែបនេះ និងដោយសារវាជាផ្នែកមួយនៃទិសដៅរបស់ចលនាកម្ពុជាប្រជាធិបតេយ្យ ឆ្ពោះទៅរកការតស៊ូរយៈពេលយូរអង្វែងប្រឆាំងនឹង “រដ្ឋាភិបាលក្បាលពីរ” ដែលជាសត្រូវផ្គុំគ្នារវាងជនកុម្មុយនិស្តនិងមូលធន អាយ៉ងបរទេស និងខ្មាំងវណ្ណៈ ប៉ុល ពត បានដកហូតនូវសេរីភាពដែលមានក្រោយពីឆ្នាំ១៩៩១ ក៏ដូចជានយោបាយបន្ធូរបន្ថយរបស់ “រណសិរ្សរួបរួមជាតិ” ដែលដែលមានតាំងពីឆ្នាំ១៩៧៩មក ។ ដោយកម្លាំងលោកខាងលិចនិងគហបតីប្រឆាំងនឹងចលនារបស់ខ្មែរក្រហម ចលនាលែងមានការចាំបាច់ក្នុងការដើរតាមច្បាប់ទម្លាប់របស់ខ្លួនទៀតហើយ ។ ផ្ទុយមកវិញ ប៉ុល ពត បានប្រើប្រាស់ជាថ្មីនូវការឃោសនាតស៊ូវណ្ណៈមោះមុត វិន័យ និងយុទ្ធសាស្ត្រ ដែលចលនានេះប្រហែលជាបានបោះបង់ចោលម្តងរួចទៅហើយ ។

នយោបាយថ្មីដែលត្រូវបានយល់ឃើញជាលក្ខណៈផ្ទៃក្នុងជា “មាគ៌ាផ្តាច់ការកសិករ” ប៉ុន្តែដែលមិនត្រូវបានគិតជាទូទៅថាមានការខុសប្លែកពីលទ្ធិកុម្មុយនិស្តដែលអនុវត្តនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០នោះ ត្រូវបានយកមកអនុវត្តទាំងក្នុងវិស័យយោធា និងគ្រប់គ្រងនៅតំបន់រំដោះ ។ ដោយ “អាវុធថ្មីមាត់” ត្រូវបានសាកល្បងហើយបរាជ័យ ប៉ុល ពត ប្តូរមកប្រើវិធីសាស្ត្រចាស់របស់ខ្លួនវិញ ។ មន្ត្រីមូលដ្ឋានដែលមិនព្រមឈប់ធ្វើការឲ្យរដ្ឋាភិបាលនឹងត្រូវសម្លាប់ចោល ។ មួយទសវត្សរ៍ក្រោយពីប្រាប់កូនចៅរបស់ខ្លួនមិនឲ្យប៉ះពាល់ប្រជាជន មានបទបញ្ជាថ្មីឲ្យដុតផ្ទះអ្នកភូមិក្នុងគោលបំណងបង្កឲ្យមានជនភៀសសឹក ដើម្បីដាក់បន្ទុកទៅលើរដ្ឋាភិបាល ។

ជាលក្ខណៈផ្ទៃក្នុង គោលបំណងគឺប្រើប្រាស់វិន័យកាលពីមុន និងធ្វើឲ្យចលនាតស៊ូរស់ឡើងវិញ ។ ក្នុងការទប់ស្កាត់ភ្នាក់ងាររដ្ឋាភិបាលកុំឲ្យជ្រៀតចូល មេដឹកនាំខ្មែរក្រហមបានបញ្ចប់ការដើរហើរដោយសេរី និងការធ្វើជំនួញរវាងតំបន់នានារបស់ខ្មែរក្រហមជាមួយនឹងតំបន់កាន់កាប់ដោយរដ្ឋាភិបាល ហើយបានធ្វើបាបដោយឥតមេត្តាចំពោះអ្នកស្រុកអ្នកភូមិដែលបានចូលមកក្នុងតំបន់គ្រប់គ្រងដោយកម្ពុជាប្រជាធិបតេយ្យដោយគ្មានការអនុញ្ញាត ។ ដើម្បីធ្វើឲ្យប្រជាជនផ្តោតការយកចិត្តទុកដាក់ទៅលើចលនាតស៊ូ មានការសម្រេចថា “មិនចាំបាច់ឲ្យមានរថយន្ត ទោចក្រយានយន្ត និងរបស់ប្រើប្រាស់ នៅក្នុងតំបន់រំដោះទេ” ។ ទីផ្សារនិងវត្តនានាត្រូវបិទទ្វារដោយមូលហេតុមួយចំនួន ហើយមានសេចក្តីរាយការណ៍ថាមានការដាក់ចេញផែនការរឹបអូសទូរទស្សន៍ រទេះគោ គ្រឿងអលង្ការ និងហាមប្រាមមិនឲ្យប្រជាជនមានដីស្រែលើសពីមួយរ៉ៃកន្លះទេ ។ អ្នកណាហ៊ានតវ៉ានឹងត្រូវចោទប្រកាន់ថាជាខ្មាំង ដែលនៅក្នុងពាក្យកម្ពុជាប្រជាធិបតេយ្យហៅថា “សាច់ស្អុយរលួយ” “សាច់ហើមប៉ោង” “អ្នកធ្វើឲ្យច្របូកច្របល់” ឬ “គិញបង្កប់សម្ងាត់” ហើយនឹងត្រូវចាត់ការទៅតាមកម្រិតទោស ។

ការផ្លាស់ប្តូរនយោបាយត្រូវបានយល់ថាមានការចាំបាច់មិនត្រឹមត្រូវសម្រាប់ការបន្តគ្រងរស់របស់កម្ពុជាប្រជាធិបតេយ្យទេ តែដើម្បីធានាថាអ្វីដែលនៅសល់គឺជាចលនាមានភាពបរិសុទ្ធគួរឲ្យទុកចិត្ត និង “ដាច់ខាត” ជាងមុន ។ ដំបូង ប៉ុល ពត អនុវត្តសេរីភាវូបនីយកម្មដែលជាយុទ្ធសាស្ត្រសេដ្ឋកិច្ចនិងនយោបាយសម្រាប់សន្តិភាព តែឥឡូវនេះបែរជាជឿថាវាបាននាំឲ្យកងទ័ពរបស់ខ្លួនទទួលមេរោគ “សន្តិនិយម” និង “ភ្នាក់ងារខ្មាំង” ទៅវិញ ។

មិនតែប៉ុណ្ណោះ ប៉ុល ពត បានស្តីបន្ទោសថា នេះជាបរាជ័យរបស់កងទ័ពក្នុងការសម្រេចក្តីសង្ឃឹមដ៏ជ្រុលហួសហេតុរបស់ខ្លួន ។ នៅក្នុងវោហារសាស្ត្រមួយប្រហាក់ប្រហែលនឹងការព្រមានរបស់ ប៉ុល ពត មុនការបោសសម្អាតដែលបង្ហូរឈាមយ៉ាងច្រើននៅឆ្នាំ ១៩៧៦-៧៧ ឯកសារចុងឆ្នាំ១៩៩៤សរសេរថា ក្នុងជួរកងទ័ពពោរពេញទៅដោយសមាសភាពខ្មាំងៈ “នៅក្នុងអង្គភាពយើងខ្លះមានខ្មាំងចំនួន៥០-៦០ភាគរយក្នុងផ្នែកចាត់តាំង ហើយ៩០ភាគរយក្នុងផ្នែកទស្សនៈ គោលជំហរនយោបាយ ការរស់នៅ សេដ្ឋកិច្ច និងសីលធម៌ ជាដើម” ។

ឯកសារបានដាក់ ចុះនូវនយោបាយកាន់តែយោរយៅគួរឲ្យកត់សម្គាល់ចំពោះមន្ត្រីមូលដ្ឋាន ហើយកំណត់ថាការអនុវត្តជាការសាកល្បងយ៉ាងសំខាន់ទៅលើភក្តីភាពៈ “អ្នកដែលអនុវត្តនយោបាយនេះគឺខាងយើង អ្នកដែលមិនអនុវត្តគឺខាង“គេ” ឬ “ខ្មាំង” ។” ដូចជានៅក្នុងឆ្នាំ១៩៧៦ ប៉ុល ពត បានសម្រេចចិត្តច្បាស់ថាវាជាការចាំបាច់ក្នុងការសើរើផ្លាស់ប្តូរចលនានេះដើម្បីរកឲ្យឃើញថាអ្នកណានៅជាមួយខ្លួន ហើយអ្នកណាប្រឆាំងនឹងខ្លួន ។ បញ្ហាគឺដូចកាលពីម្ភៃឆ្នាំមុនដូច្នេះដែរ កាលនោះការសាកល្បងរបស់ ប៉ុល ពត បានរែកមុខស្មើរគ្រប់គ្នាថាសុទ្ធតែជាអ្នកប្រឆាំងនឹងខ្លួន ។ ហើយនៅពេលនេះ ប៉ុល ពត គ្មានក្រសួងសន្តិសុខដើម្បីបោសសម្អាត “ជនក្បត់” ទៀតទេ ហើយក៏គ្មានកម្លាំងឈរជើងនៅតាមព្រំដែនសម្រាប់ការពារមិនឲ្យប្រជាជនរត់ទៅខាង“ខ្មាំង”ដែរ ។

ផលប៉ះពាល់ដែលគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលនៃនយោបាយថ្មីគឺថា នៅពេលដាក់ចុះនយោបាយនេះភ្លាម ក៏មានការចេញមុខមកចុះចូលភ្លាមដែរៈ ជាការគួរឲ្យកត់សម្គាល់បំផុតនោះដូចជានៅក្នុងតំបន់របស់ តាម៉ុក នៅខេត្តសៀមរាបឧត្តរមានជ័យនៅចុងឆ្នាំ១៩៩៤ នៅក្នុងតំបន់ភាគខាងលិចប្រទេសដែល សុន សេន កាន់កាប់នៅពាក់កណ្តាលឆ្នាំ១៩៩៦ និងនៅចុងឆ្នាំ១៩៩៧ នៅពេលដែល តាម៉ុក ដាក់ចុះនូវគោលនយោបាយនេះសាជាថ្មីនៅលើទឹកដីអន្លង់វែង ។ ការផ្លាស់ប្តូរក្រោយឆ្នាំ១៩៩៤ មិនត្រឹមតែបាត់បង់ផលប្រយោជន៍សេដ្ឋកិច្ចរបស់ចលនានេះតែប៉ុណ្ណោះទេ តែថែមទាំងធ្វើឲ្យបាត់បង់ការលើកទឹកចិត្តនៅក្នុងការវាយប្រយុទ្ធដើម្បីជ័យជម្នះទៀតផង ។ ដូចដែលកម្មាភិបាលម្នាក់នៅភ្នំម៉ាឡៃបាននិយាយដូច្នេះដែរថា “ប៉ុល ពត តែងតែនិយាយថា បើប្រឹងតែបន្តិចទៀត ម្តងទៀតនឹងត្រូវដួលរលំ ហើយយើងនឹងឈ្នះ ប៉ុន្តែឥឡូវនេះប្រជាជនយល់ថា បើឈ្នះទៅ យើងនឹងវិលត្រឡប់ចូលក្នុងសម័យ “បីឆ្នាំ” ដដែល (សម័យ ១៩៧៥-៧៩)” ។

**កត្តារដ្ឋាភិបាល**

ចលនាទាំងមូលពោរពេញទៅដោយការមិនពេញចិត្តចំពោះសង្គ្រាមដែលមិនចេះចប់មិនចេះហើយ និងការងាកមករក “នយោបាយនិងការយកមកអនុវត្តនូវអតីតកាលថ្មីៗនេះ” ។ ប៉ុន្តែការវិវត្តនានានៅទីក្រុងភ្នំពេញក៏មានន័យថាទាហានខ្មែរក្រហមម្នាក់ៗ អង្គភាពនីមួយៗ និងតំបន់ទាំងអស់ មិនត្រឹមតែមានបំណងទេ ប៉ុន្តែថែមទាំងមានផ្លូវ “រត់ចុះចូល” ទៀតផង ។ ក្រោយឆ្នាំ១៩៩៣ កម្ពុជាប្រជាធិបតេយ្យតែបាត់បង់មិត្តអន្តរជាតិទេ ប៉ុន្តែថែមទាំងបាត់បង់សម្ព័ន្ធមិត្តរបស់ខ្លួននៅក្នុងស្រុកទៀតផង ។ អតីតសមមិត្តរួមសមរភូមិឥឡូវបានក្លាយទៅជាសត្រូវទៅវិញ ។ ការណ៍នេះមិនត្រឹមតែធ្វើឲ្យធ្លាក់ទឹកចិត្តទេ តែថែមទាំងធ្វើឲ្យកម្ពុជាប្រជាធិបតេយ្យកាន់តែចុះខ្សោយទាំងផ្នែកយោធា និងនយោបាយ ។ សំខាន់ជាងនេះទៅទៀត វាបានផ្តល់ដល់មនុស្សជាច្រើននៅក្នុងចលនានេះនូវការជឿជាក់ និងការទាក់ទងចរចារកផ្លូវចុះចូល ។ នៅដើមឆ្នាំ១៩៩៣និងបន្តរហូត៥ឆ្នាំក្រោយមក ចរន្តចុះចូលដ៏ធំមួយដែលបានធ្វើការទាក់ទងទាំងផ្នែកប្រវត្តិសាស្ត្រជាមួយនឹងមន្ត្រីយោធារបស់គណបក្សហ៊ុនស៊ីនប៉ិច និងចំណងទាក់ទងផ្នែកសេដ្ឋកិច្ចជាមួយមេបញ្ជាការយោធារបស់គណបក្សប្រជាជន បានឆ្ពោះទៅមុខយ៉ាងលឿននៅឆ្នាំ១៩៩១-១៩៩៤ នៅពេលដែលការធ្វើពាណិជ្ជកម្មបានក្លាយទៅជានយោបាយផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យនោះ ។ ចាប់ពីពេលនោះមក ម្នាក់ៗនៅក្នុងចលនានេះ សុទ្ធតែមានសាច់ញាតិធ្វើការនៅខាងរដ្ឋាភិបាលដែលអាចរៀបចំការទាក់ទងនិងការផ្លាស់ប្តូរទីកន្លែងរបស់ខ្លួន ។

**(នៅមានត)**

**ដេវីដ អាស្លី**

# ការអួតសរសើរបដិវត្តន៍

*តើអ្នកសិក្សាពីររូបដែលមាននយោបាយស្អាតស្អំ យល់ខុសអំពីកម្ពុជាយ៉ាងដូចម្តេចខ្លះ?*

**(តពីលេខមុន)** *ការវិភាគយ៉ាងហ្មត់ចត់ជាងនេះទៅទៀតដែលការពារដោយភ័ស្តុតាងជាក់ស្តែងបង្ហាញថា ខ្មែរក្រហមមានបំណងចង់កម្ទេចភ័ស្តុតាងទាំងអស់អំពីជីវិតគហបតីពុករលួយជីវិតនៅទីក្រុងនិងនៅរបបចាស់ទូទៅ ធ្វើឲ្យវណ្ណៈក្រឡាប់ចាក់និងកម្ទេចសេដ្ឋកិច្ចទីផ្សារដូចដែលមានកន្លងមក ។ ភាពចម្រូងចម្រាសទៅលើបញ្ហាថាតើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញស្របច្បាប់ដែរឬយ៉ាងណានោះ ចេះតែបន្តទៅរហូតរវាងអ្នកសិក្សាជាន់ខ្ពស់ដែលមាននយោបាយស្អាតស្អំនិងខ្មាំងរបស់ខ្លួនដែលមិនមែនជាអ្នកសិក្សាជាន់ខ្ពស់ (ជាអាទិ៍ប្រព័ន្ធឃោសនាភ្នាក់ងារសម្ងាត់) ទោះជាភ័ស្តុតាងមានទម្ងន់បញ្ជាក់ថាវាមិនមែនជាការចាំបាច់និងបង្កឲ្យមានមនុស្សស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់យ៉ាងណាក៏ដោយ ។ ការមើលងាយរបស់ខ្មែរក្រហមចំពោះអ្នករស់នៅទីក្រុង គឺស្តែងបានឡើងតាមរយៈការផ្សព្វផ្សាយតាមវិទ្យុរបស់ខ្មែរក្រហមនៅក្រោយពេលរំដោះថា៖*

*នៅពេលមកដល់ភ្នំពេញនិងទីក្រុងនានាភ្លាម បងប្អូនយុទ្ធជននៃកងទ័ពបដិវត្តកម្ពុជា...កុលបុត្រកុលធីតារបស់កម្មករកសិករយើង...បានភ្ញាក់ផ្អើលដោយឃើញក្រុមមនុស្សច្រើនសន្ធឹកសន្ធាប់រាប់មិនអស់ដែលមានសក់វែង និងយុវនយុវតីដែលស្លៀកពាក់ចម្លែកៗមើលទៅមិនដឹងអ្នកណាប្រុស អ្នកណាស្រី* (sic)*... គំនិតប្រពៃណី សីលធម៌ប្រពៃណី អក្សរសាស្ត្រ សិល្បៈ និង វប្បធម៌ត្រូវបានកម្ទេចចោលទាំងស្រុងដោយចក្រពត្តិអាមេរិកនិងខ្ញុំកញ្ជះដាច់ថ្លៃរបស់វា ។ ល្បែងកម្សាន្តប្រពៃណី របាំ និង ចម្រៀងជាដើម គឺសុទ្ធតែមានចរិតចក្រពត្តិទាំងអស់ ។ អាកប្បកិរិយាស្អាតស្អំនិងម៉ាំមួនតាំងពីបុរាណមកត្រូវបានបាត់បង់អស់រលីងជំនួសវិញដោយគន្លងថ្មីដែលមានលក្ខណៈចក្រពត្តិអាសអាភាសមិនចេះខ្មាសអៀន អាក្រក់ និងជ្រុលនិយម FBIS IV, May 15, 1975: H4)* ។

*ដំណើររឿងប្រឆាំងនឹងអាមេរិកគ្មានអ្វីថ្មីសោះ ។ ម្យ៉ាងវិញទៀត រណសិរ្សរួបរួមជាតិកម្ពុជាបានវាយប្រឆាំងនឹងចក្រពត្តិអាមេរិកនេះគឺជារឿងនយោបាយស្អាតស្អំដែលត្រូវធ្វើ ។ ផតធ័រ និង ហ៊ីលប្រែនដ៍ អះអាងថា ការជម្លៀសគឺជាសកម្មភាពសមហេតុផលនៅពេលនោះ ក្នុងខណៈដែលស្បៀងអាហារបម្រុងនៅសល់តិចដោយគ្មានឃើញជំនួយពីសហរដ្ឋអាមេរិកធ្លាក់មក ។ ប៉ុន្តែកាលនោះស្បៀងសម្រាប់ផ្គត់ផ្គង់នៅទីក្រុងភ្នំពេញមិនទាន់ដល់ថ្នាក់មិនគ្រប់គ្រាន់រហូតដល់តម្រូវឲ្យធ្វើការជម្លៀសប្រជាជនទៅជនបទនោះទេ ។ បើមានការខ្វះខាតមែននោះ គឺដោយសារតែការឡោមព័ទ្ធជាក់ទីក្រុងភ្នំពេញអស់រយៈពេលពីរខែរបស់រណសិរ្សរួបរួមជាតិកម្ពុជា ទើបបណ្តាលឲ្យមានការផ្អាកការដឹកនាំរបស់របរចូលមកភ្នំពេញ ។ មិនតែប៉ុណ្ណោះទៀតសោត ភ័ស្តុតាងដែលថា ការជម្លៀសត្រូវបានរៀបគម្រោងការទុកមុននៅខែមេសា ឆ្នាំ១៩៧៥នោះ បង្ហាញថា ផលប្រយោជន៍ជាយុទ្ធសាស្ត្រគឺជារឿងសំខាន់សម្រាប់ខ្មែរក្រហម មិនមែនសុខុមាលភាពរបស់ប្រជាជននោះទេ ។ មិនត្រឹមតែមានការផ្លាស់ប្តូរវណ្ណៈទេ សូម្បីតែប្រជាជនរស់នៅទីក្រុងក៏ត្រូវក្លាយទៅជាចំណីម៉ាស៊ីនកសិកម្មដែរ ។ លោក ឆាល ថ្វាញនីង ជាអន្តរទូតអាមេរិកាំង និងជាអ្នកសិក្សាជាន់ខ្ពស់មួយរូបដែលបានក្លាយជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញនាដើមទសវត្សរ៍ឆ្នាំ១៩៩០ ធ្វើការពន្យល់ថា មហាសន្និបាតឲ្យបក្សកុម្មុយនិស្តកម្ពុជាវិសាមញ្ញដែលធ្វើនៅខែកុម្ភៈ ឆ្នាំ១៩៧៥ ក្រោមអធិបតីភាពរបស់ ខៀវ សំផន ត្រូវបានគិតជាទូទៅថាបានធ្វើសេចក្តីសម្រេចជម្លៀសទីក្រុងនានានិងលុបបំបាត់រូបិយវត្ថុទាំងអស់ក្រោយពេលកាន់កាប់អំណាច ។ ការដែលទីក្រុងនានាត្រូវបានធ្វើឲ្យទទេស្អាតក្នុងអំឡុងប៉ុន្មានថ្ងៃនៃការដួលរលំ ប្រជាជនដែលសម្រាកបណ្តោះអាសន្ននៅតាមជនបទបានដឹងទិសដៅជាមុននោះ មិនបង្ហាញថាជាសកម្មភាពកើតឡើងភ្លាមៗមួយរំពេចនោះទេ ។ ហេតុការណ៍នេះសុទ្ធតែបានរៀបចំទុកជាមុនហើយស្រេច ។*

ការបង្ហាញនូវភាពសមហេតុផលមួយទៀតរបស់ ផតធ័រ និង ហ៊ីលប្រែនដ៍ ចំពោះការជម្លៀសទីក្រុងភ្នំពេញគឺថា ប្រជាជននៅទីក្រុងភ្នំពេញ៥ភាគ៦គឺជាជនភៀសសឹកមកពីជនបទ ។ ដូច្នេះអ្នកទាំងនេះត្រូវត្រឡប់ទៅស្រុកកំណើតនៅជនបទរបស់ខ្លួនវិញ ។ ការពន្យល់ដែលស្តាប់ទៅប្លែកបែបនេះ ហាក់ដូចជាសមហេតុផល ។ បើដូច្នេះសំណួរថាហេតុអ្វីបានជាប្រជាកសិករជាង៨សែននាក់ត្រូវស្លាប់ដោយសារបដិវត្តន៍ខ្មែរក្រហម ពិតជានៅតែជាអាថ៌កំបាំងនៅឡើយសម្រាប់អ្នកដែលជឿទៅលើការពន្យល់របស់ ផតធ័រ និង ហ៊ីលប្រែនដ៍ នេះ ។ ជាងនេះទៅទៀត ផតធ័រ និង ហ៊ីលប្រែនដ៍ មានការព្រួយបារម្ភខ្លាចក្រែងរូបភាពរបស់ខ្មែរក្រហមត្រូវបានមើលឃើញថាមានលក្ខណៈអមនុស្សធម៌ ។ មនោសញ្ចេតនារបស់អ្នកទាំងពីរចំពោះបដិវត្តន៍បង្ហាញឲ្យឃើញថា ខ្មែរក្រហមមានមនុស្សធម៌និងត្រឹមត្រូវ ។ ផតធ័រ និង ហ៊ីលប្រែនដ៍ និយាយអំពីជម្រើសដ៏លំបាកដែលខ្មែរក្រហមបានជួបប្រទះ និងថាតើសកម្មភាពរបស់ខ្មែរក្រហមសមហេតុផលតាមរបៀបណា÷ «សំខាន់ជាងអ្វីៗទាំងអស់ថ្នាក់ដឹកនាំរបស់រណសិរ្សរួបរួមជាតិកម្ពុជា ត្រូវតែព្រួយបារម្ភអំពីស្បៀងអាហារ និងសុខភាព ។ ការដែលមានចំនួនប្រជាជនដ៏ច្រើនមកផ្តុំគ្នានៅតាមទីក្រុងនានា ដោយគ្មានការផលិត និងពឹងផ្អែកទៅលើជំនួយបរទេសនោះ បង្កឲ្យមានគ្រោះថ្នាក់ធំណាស់ ។ ម្យ៉ាងការប៉ុនប៉ងរក្សាការផ្គត់ផ្គង់អង្ករឲ្យបានគ្រប់គ្រាន់សម្រាប់ប្រជាជនទីក្រុង ធ្វើឲ្យអាក់ខានដល់ប្រព័ន្ធបង្កបង្កើនផលដែលមានការរៀបចំយ៉ាងត្រឹមត្រូវ ។ ម្យ៉ាងវិញទៀត ចំនួនប្រជាជនដ៏ច្រើនកកកុញបែបនេះ រួមជាមួយសេវាសាធារណៈលែងដំណើរការ បានធ្វើឲ្យជំងឺដ៏ធំនេះកាន់តែរាលដាលឡើង» ។ ដោយមានគំនិតបែបនេះធ្វើឲ្យ ផតធ័រ និង ហ៊ីលប្រែនដ៍ យល់ថាការជម្លៀសពិតជាសមហេតុសមផល ។ ការឲ្យហេតុផលមានដូចតទៅនេះ÷ ទី១ ការប្រែក្លាយកម្លាំងមិនផលិតទៅជាកម្លាំងផលិត (ពីទីក្រុងទៅជនបទ) អាចទប់ស្កាត់មិនឲ្យមានការអត់ឃ្លាន ។ ទី២ ការរាលដាលជំងឺតម្រូវឲ្យមានការចាំបាច់ក្នុងការជម្លៀស ។ ផតធ័រ និង ហ៊ីលប្រែនដ៍ អះអាងថា ប្រជាជនទីក្រុងភ្នំពេញចំនួន៦សែននាក់ (ពោលគឺអ្នកដែលត្រូវឲ្យទៅទីនោះ) ត្រូវបាននាំយកទៅជនបទពីព្រោះជាកម្លាំងពលកម្មចាំបាច់សម្រាប់ការបង្កបង្កើនផលស្រូវ ។ អំណះអំណាងនេះគ្មានអ្វីក្រៅពីគំនិតរវើរវាយចង់បានភាពឥតខ្ចោះនោះទេត្រង់ចំណុចដែលអ្នកទាំងពីរសរសេរថា «ការដែលអ្នកទីក្រុងពី៥សែនទៅ៦សែននាក់បង្កបង្កើនផលគ្រប់គ្រាន់តាមរយៈការដាំដុះចិញ្ចឹមជីវិតខ្លួនឯង ដោយមិនឲ្យអ្នកផ្សេងជួយទំនុកបម្រុងស្បៀងសម្រាប់ខ្លួន នឹងធ្វើឲ្យផលិតផលកើនឡើងយ៉ាងខ្លាំង ។ ដោយនៅតែគ្មានផលិតកម្មអស់រយៈពេលជាច្រើនខែដែលមានការចាំបាច់ (ខ្មែរក្រហម) បានកាត់បន្ថយស្បៀងសម្រាប់មនុស្សម្នាក់ៗ» ។ វិធីនេះគឺមិនបានគិតទៅដល់ការស្លាប់របស់មនុស្សដោយសារការធ្វើការជាទម្ងន់ទាល់តែសោះ ។

មិនតែប៉ុណ្ណោះទៀតសោត នៅពេលដែលអ្នកទាំងពីរសន្មតយកការអះអាងរបស់អនុប្រធានខ្មែរក្រហមឈ្មោះ អៀង សារី ដែលថា «ទៅជនបទ កសិករយើងមានដំឡូងហូប មានចេកហូប និងអាហារគ្រប់យ៉ាង» នោះអ្នកទាំងពីរបាត់អស់ហើយនូវការពិតឬសត្យានុម័តិ ។ លោក ស៊ីវហ៊ិន ម៉ូរីស ជាអ្នកសិក្សាស្រាវជ្រាវនៅសកលវិទ្យាល័យហបគីន បាននិយាយថា «និស្សិតប្រាកដប្រជាដែលសិក្សាអំពីរបបកុម្មុយនិស្តដឹងថាការនិយាយជាសាធារណៈរបស់មន្ត្រីកុម្មុយនិស្តនិងប្រព័ន្ធឃោសនារបស់ខ្លួនអាចពិតឬអាចមិនពិត ។ ប៉ុន្តែសម្តីទាំងនោះតែងតែត្រូវបានធ្វើឡើងដើម្បីបម្រើឲ្យផលប្រយោជន៍នយោបាយ» ។ ផតធ័រ និង ហ៊ីលប្រែនដ៍ ទទួលយកនូវរាល់ដំហរនិងនយោបាយរបស់របបថ្មីនេះបោះផ្សាយដោយឥតលក្ខខណ្ឌនូវរូបថតឃោសនារបស់កម្មករកម្ពុជាដែលកំពុងតែធ្វើការនៅតាមចម្ការនិងរោងចក្រនានា ទាំងទឹកចិត្តសប្បាយរីករាយ ក្រោយពេលសង្គ្រាមផុតរលត់ទៅ ។ រឿងមួយទៀតដែល ផតធ័រ និង ហ៊ីលប្រែនដ៍ រិះរកមធ្យោបាយទាត់ចោលនោះ គឺការចោទប្រកាន់តាមរយៈអត្ថបទបោះពុម្ពផ្សាយរបស់ប្រព័ន្ធឃោសនាថា ការជម្លៀសគឺជា «ដំណើរមរណៈ» ។ អ្នកទាំងពីរទាញហេតុផលថា ទាំងនេះត្រូវបាន «ធ្វើឡើងដោយសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលសហរដ្ឋអាមេរិករួមទាំងឯកសារសម្ងាត់ផង» ។ ផតធ័រ និង ហ៊ីលប្រែនដ៍ លើកឡើងនូវព័ត៌មាននានាដែលប្រឆាំងជំទាស់ទៅនឹងអំណះអំណាងថាមានអំពើឃោរឃៅប្រព្រឹត្តឡើងដោយខ្មែរ

ក្រហមទៅលើប្រជាជននៅទីក្រុងភ្នំពេញ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ពត៌មានភាគច្រើនត្រូវបានដកស្រង់ចេញមកពីសៀវភៅដែលជាស្នាដៃនិពន្ធរបស់ ចេរ៉ូម និង ចូសេលីន ស្ទែនបាច មានចំណងជើងថា *Phnom Penh Libere: Cambodge de l'Autre Sourire (1976)* ជាសៀវភៅទីមួយដែលនិយាយល្អអំពីការជម្លៀសទីក្រុងភ្នំពេញបន្ទាប់ដោយខ្មែរក្រហម ។ ដោយផ្អែកលើមូលដ្ឋាននេះ ផតធ័រ និង ហ៊ីលប្រែនដ៍ សម្រេចថាការចាត់ទុកការជម្លៀសជា«ដំណើរមរណៈ» គឺ «គ្មានមូលហេតុត្រឹមត្រូវទេ» ។

ចុងបញ្ចប់ ផតធ័រ និង ហ៊ីលប្រែនដ៍ អះអាងថា «ការបោសសម្អាតតាមមន្ទីរពេទ្យជាបណ្តោះអាសន្នមិនមែនជាអំពើអមនុស្សធម៌ទាល់តែសោះ គឺជាការអាណិតអាសូរចំពោះអ្នកជំងឺទៅវិញទេ ។ អ្នកទាំងពីរទាញហេតុផលថា មន្ទីរពេទ្យនៅទីក្រុងភ្នំពេញមានមនុស្សសម្រាកច្រើនពេក ហើយគ្មានផ្តល់សុខុមាលភាពដល់អ្នកជំងឺឡើយ ។ ដូច្នេះ ដើម្បីសុខុមាលភាពរបស់អ្នកជំងឺ ចាំបាច់តម្រូវឲ្យមានការជម្លៀសអ្នកទាំងនោះចេញ ។ ទាក់ទងនឹងការថែទាំដែលអ្នកជំងឺរំពឹងថានឹងទទួលបាននៅកន្លែងផ្សេងទៀត ។ ផតធ័រ និង ហ៊ីលប្រែនដ៍ ផ្តល់នូវរូបថតក្រុមវះកាត់របស់ខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៤ ធ្វើជាភ័ស្តុតាងបង្ហាញថា នៅតាមជនបទឆ្ងាយៗមានការថែទាំសុខភាពល្អជាង ។ ហ្សង់ ឡាគូត ជាអ្នកនិពន្ធនិងអ្នករិះគន់ខ្មែរក្រហមដ៏ខ្លាំងក្លា បាននិយាយអំពីអ្វីដែលគាត់បានជួបប្រទះ ជាមួយនឹងអ្នកគាំទ្រខ្មែរក្រហមដែលនិយាយថា «នៅក្នុងរបប លន់ ណុល សេវាកម្មផ្នែកសុខាភិបាលស្ថិតនៅក្នុងដៃរបស់អាមេរិកាំងដែលពុករលួយនិងគ្មានសីលធម៌ ។ ស្ថានភាពមិនល្អរបៀបនេះត្រូវតែកម្ចាត់បញ្ហានេះចោលកុំឲ្យមាននៅក្នុងមន្ទីរពេទ្យជាដាច់ខាត» ។ ឡាគូត បានឆ្លើយថា «នោះជាការសមគំនិតរបស់វេជ្ជបណ្ឌិត» ។ ដោយបានធ្វើឲ្យអំពើគួរឲ្យស្អប់ខ្ពើមរបស់ខ្មែរក្រហមមើលទៅសមហេតុសមផល ផតធ័រ និង ហ៊ីលប្រែនដ៍ បានសរសើរ និងធ្វើឲ្យមេដឹកនាំខ្មែរក្រហមមានលក្ខណៈស្របច្បាប់ ។ ជំពូកទីពីរនៅក្នុងសៀវភៅ «កម្ពុជាៈ ការអត់អាហារនិងការធ្វើបដិវត្តន៍» ទាញសេចក្តីសន្និដ្ឋានផ្អែកលើគំនិតខ្លួនឯងថា៖ «ការពិនិត្យយ៉ាងដិតដល់ចំពោះការពិតទាក់ទងនឹងការជម្លៀសប្រជាជននៅប្រទេសកម្ពុជា បង្ហាញថាការពិពណ៌នានិងការបកស្រាយអំពីទង្វើសំដៅដាក់សាធារណជនអាមេរិកកាំងនោះ គឺជាការមួលបង្កាច់ការពិតដែលមិនអាចអត់ឱនឲ្យបាន ។ អ្វីដែលត្រូវបានយល់ថាជានយោបាយវិនាសកម្ម និងដើរថយក្រោយបន្តឡើងដោយការស្អប់លទ្ធិនោះ តាមពិតគឺជាយុទ្ធសាស្ត្រកើតចេញពីការគិតត្រឹមត្រូវសម្រាប់ដោះស្រាយបញ្ហាបន្ទាន់កើតឡើងក្នុងសម័យក្រោយសង្គ្រាម» ។

នៅក្នុងជំពូកទីបីនៃសៀវភៅនេះ ផតធ័រ និង ហ៊ីលប្រែនដ៍ ពន្យល់អំពីហេតុផលនៃបដិវត្តកសិកម្មរបស់កម្ពុជាដោយធ្វើឲ្យការដឹកនាំរបស់ខ្មែរក្រហមមានភាពស្របច្បាប់ ។ នៅក្នុងការនិយាយផ្គូផ្គងគ្នារវាងអ្នកសិក្សាជាន់ខ្ពស់និងកសិករ អ្នកទាំងពីរបានទាញហេតុផលថា ដោយសារតែមេដឹកនាំខ្មែរក្រហមមួយចំនួនមានសញ្ញាបត្រថ្នាក់បណ្ឌិតនយោបាយ ចាំបាច់ត្រូវតែគិតឲ្យបានហ្មត់ចត់និងមានលក្ខណៈស្របច្បាប់ ។ ការទាយទុកជាមុនថាមានគ្រោះទុរ្ភិក្សដោយប្រភពសម្ងាត់លោកខាងលិចសម្រាប់ឆ្នាំ១៩៧៧ ដែលជាឆ្នាំក្រោយពីមានការបោះពុម្ពផ្សាយនូវសៀវភៅ «កម្ពុជាៈ ការអត់ឃ្លាននិងការធ្វើបដិវត្តន៍» ត្រូវបានទាត់ចោលដោយ ផតធ័រ និង ហ៊ីលប្រែនដ៍ តាមរយៈការផ្សព្វផ្សាយរបស់រណសិរ្សរួបរួមជាតិកម្ពុជាថាមានស្រូវបរិបូណ៌ ដោយសារធ្វើស្រែបានពីរដងក្នុងមួយរដូវ ក្រោមការដឹកនាំរបស់ខ្មែរក្រហម ។ ផតធ័រ និង ហ៊ីលប្រែនដ៍ សរសេរថា៖

ទាវ ចិនឡេង អតីតគណៈកំពង់ផែក្រុងព្រះសីហនុ និងជាសមាជិករណសិរ្សរួបរួមជាតិកម្ពុជា ដែលសព្វថ្ងៃរស់នៅទីក្រុងប៉ារីស បានឲ្យដឹងថា ភោគផលស្រូវប្រមូលបានក្នុងឆ្នាំ១៩៧៥ មាន៣,២៥លានតោន ។ សម្រាប់ប្រជាជនកម្ពុជា ភោគផលប្រមូលបានហូរហៀនេះអាចចែកដល់មនុស្សពេញវ័យម្នាក់ៗបាន២៥០ក្រាមក្នុងមួយពេល ហើយ៣៥០ក្រាមសម្រាប់កម្លាំងនារីបង្កបង្កើនផលម្នាក់ៗ... ។ លើសពីនេះទៀត សាច់សម្រាប់បរិភោគបានកើនឡើង ។ កាលពីមុននៅក្រោមឥទ្ធិពលប្រពៃណីសាសនាព្រះពុទ្ធកសិករមិនសូវហ៊ានសម្លាប់សត្វហើយហូបសាច់តិចតួចណាស់ ។

ចំណុចទាំងពីរនេះ (រួមទាំងស្ថិតិផង) លេចឡើងជាថ្មីម្តងទៀតនៅក្នុងឯកលេខនារបស់ *Malcolm Caldwell* មុនពេលដែលគាត់បានទទួលមរណភាព អត្ថបទនោះមានចំណងជើងថា "កម្ពុជាៈ មូលហេតុនាំឲ្យមាននយោបាយជនបទ១៩៧(៩)" ។ *Caldwell* ដែលជាមនុស្សម្នាក់ធ្លាប់គាំទ្រខ្មែរក្រហមយ៉ាងខ្លាំងក្លានោះ ត្រូវបានសម្លាប់ដោយអាថ៌កំបាំងនៅទីក្រុងភ្នំពេញនៅមុនថ្ងៃដែលវៀតណាមវាយលុកចូលកម្ពុជា ។ ភាពឆាប់ជឿជាក់របស់ ផតធ័រ និង ហ៊ីលប្រែនដ៍ បើក្រឡេកមើលទៅខាងក្រោយ ហាក់ដូចជាមិនគួរឲ្យជឿទាល់តែសោះ ។ ក៏ប៉ុន្តែការណ៍នោះមិនទាន់ចប់សព្វគ្រប់នៅឡើយទេ ។ ខុទារហណ៍ ផតធ័រ និង ហ៊ីលប្រែនដ៍ ជឿថា ការផ្សឹកព្រះសង្ឃឲ្យលាចាកសិក្ខាបទមកធ្វើការងារ មិនមែនជាអំពើដែលអាច"ត្រូវបានចាត់ទុកថាជាការធ្វើទុកបុកម្នេញខាងសាសនា"នោះទេ ពីព្រោះអ្នកដទៃទៀតទោះចាស់ឬក្មេងសុទ្ធតែត្រូវបានបង្ខំឲ្យធ្វើការងារដូចៗគ្នា ។ ទោះបីជាសៀវភៅ "កម្ពុជាៈ ការអត់ឃ្លាននិងការធ្វើបដិវត្តន៍" និយាយអំពីកម្ពុជាក៏ពិតមែន តែមួយភាគធំផ្តោតសំខាន់តែទៅលើការស្តីបន្ទោសសហរដ្ឋអាមេរិកចំពោះគ្រោះទុរ្ភិក្សដែលអាចបណ្តាលមកពីខ្មែរក្រហម ។ ផតធ័រ និង ហ៊ីលប្រែនដ៍ និយាយថា បើមានការអត់អាហារមែននោះគឺបណ្តាលមកពីការអុកឡុកក្នុងការរំដោះទីក្រុងភ្នំពេញ និងការជម្លៀសធ្វើឡើងដោយខ្មែរក្រហម ទើបកើតទៅជារឿងដូច្នេះ ។ ផតធ័រ និង ហ៊ីលប្រែនដ៍ បានព្យាយាមរិះរកគ្រប់មធ្យោបាយដើម្បីរិះគន់ចំពោះអន្តរាគមន៍របស់អាមេរិក និងការបំផ្លាញរបស់ខ្លួនមកលើប្រទេសកម្ពុជា ។ ផតធ័រ និង ហ៊ីលប្រែនដ៍ ពិពណ៌នាការដកចេញដែលមុតដូចដាវកន្ត្រៃនោះ ថាជាយន្តការរឹបម្លែកដូចគ្នាទៅនឹងច្បាប់សូវៀតក្នុងយុគសម័យបុរាណនៃការប្រមូលផ្តុំបដិវត្តន៍ ។

ផតធ័រ និង ហ៊ីលប្រែនដ៍ អះអាងដូចនេះក្នុងពេលដែលខ្លួនពន្យល់ថាខស្សាហកម្មទំនើបនឹងត្រូវជំរុញឲ្យដើរទៅមុខដោយ "ដើមទុនបានមកពីការពង្រីកផលិតកម្មកសិកម្ម" ។ សេចក្តីសន្និដ្ឋានរបស់អ្នកទាំងពីរបង្ហាញថា កម្ពុជាមិនមែនជាជនរងគ្រោះរបស់ខ្មែរក្រហមទេ តែជាជនរងគ្រោះរបស់អាមេរិកនិងការមិនអភិវឌ្ឍទៅមុខពាក់កណ្តាលទសវត្សរ៍ និងជាជនរងគ្រោះនៃការបំផ្លិចបំផ្លាញដោយគ្រាប់បែករបស់សហរដ្ឋអាមេរិក ។ បន្ថែមពីលើនេះទៀត ប្រព័ន្ធឃោសនាអាមេរិកគឺជាអ្នកចូលរួមសមគំនិតក្នុងការលាក់បាំងការពិត ពីព្រោះប្រព័ន្ធឃោសនាមិនបានប្រព្រឹត្តត្រឹមត្រូវមកលើកម្ពុជាឡើយ ។ ផតធ័រ និង ហ៊ីលប្រែនដ៍ ទាញការសន្និដ្ឋានថា÷

កម្ពុជាគឺជាជនរងគ្រោះចុងក្រោយបង្អស់នៃការអនុវត្តមនោគមវិជ្ជាមួយដែលជឿថាបដិវត្តន៍សង្គម (តាមតែអាចធ្វើទៅបាន) មានភាពអវិជ្ជមានជាជាងការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់មនុស្សដែលរចនាសម្ព័ន្ធសង្គមនិងសេដ្ឋកិច្ចមានស្រាប់មិនអាចឆ្លើយតប ។ នៅក្នុងប្រទេសកម្ពុជាក៏ដូចជាវៀតណាមនិងឡាវដែរ ដំណើរការជាប្រព័ន្ធនៃការបង្កើតដំណើររឿងមិនពិតដែលតែងតែត្រូវបានជឿនិងមើលឃើញជាបំណង ធ្វើឲ្យម៉ាស៊ីនមរណៈដ៏ធំនេះមានភាពសមហេតុសមផលដែលត្រូវបានប្រើប្រាស់ប្រឆាំងនឹងប្រជាជនដែលគ្មានការការពារក្នុងកិច្ចប្រឹងប្រែងឥតប្រយោជន៍ដើម្បីបំផ្លាញបដិវត្តន៍ ។

នៅពេលបំផ្លើស "បដិវត្តសង្គម" នយោបាយស្អាតស្អំ ផតធ័រ និង ហ៊ីលប្រែនដ៍ បង្ហាញអំពីមូលហេតុពិតរបស់ខ្លួនថា÷ ការពារបដិវត្តន៍តាមគ្រប់មធ្យោបាយដែលចាំបាច់ ។ ផុយពីភាពសត្យានុម័តិនិងភាពជាអ្នកសិក្សា អ្នកទាំងពីរយកភាពលម្អៀងរបស់ខ្លួនជាភ័ស្តុតាង ដោយលើកឡើងការឃោសនា ដោយគ្មានការគ្រោងទុកជាមុនឬលក្ខណៈចាំបាច់ដែលការពារដល់បដិវត្តន៍ខ្មែរ និងជាងនេះទៀតគឺខ្មែរក្រហមតែម្តង ។ បើក្រឡេកមើលទៅខាងក្រោយវិញ អ្វីដែលអ្នកទាំងពីរសម្រេចបាននោះគឺភាពប្របូកប្របល់នៃព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្រោយពីខែមេសាឆ្នាំ១៩៧៥ ។ ដោយស្ថិតនៅពិភពមួយដាច់ស្រឡះពីកម្ពុជានិងបន្ទុំលើកោះអីសិក្សាដ៏ខ្ពស់ ហ្វារ៉េត ផតធ័រ និង ហ្វូច ហ៊ីលប្រែនដ៍ ដែលជាអ្នកសិក្សាជាន់ខ្ពស់ស្អាតស្អំតាមន័យនយោបាយ (ក្នុងចំណោមអ្នកសិក្សាជាច្រើនផ្សេងទៀត) ដើរតួយ៉ាងសំខាន់ក្នុងការបំផ្លើសបដិវត្តន៍ខ្មែរក្រហម និងធ្វើឲ្យខ្មែរក្រហមមានលក្ខណៈស្របច្បាប់អស់បីឆ្នាំក្រោយមកទៀត ។

**អឿ សុផល**

# កំណត់ហេតុស្តីអំពីអង្គប្រជុំរបស់សភាជាតិនៃព្រះរាជាណាចក្រកម្ពុជា លើសេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**(តពីលេខមុន) សម្តេច ហេង សំរិន:** *បន្ទាប់ពីការអនុម័តនៅជំពូកទី១២ សូមអញ្ជើញប្រធានគណៈកម្មាធិការអាននូវជំពូកទី១៣ ។*

**ឯកឧត្តម ម៉ោញ សាផាន:** *ជំពូកទី១៣ៈ ឋានៈ សិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ។ មាត្រា៤១ៈ ចៅក្រមបរទេស សហចៅក្រមស៊ើបអង្កេតបរទេស សហព្រះរាជអាជ្ញាបរទេស និងអនុប្រធានការិយាល័យរដ្ឋបាល រួមបញ្ចូលទាំងក្រុមគ្រួសាររបស់ពួកគេដែលជាផ្នែកនៃគ្រួសាររបស់ពួកគេ ត្រូវមានបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិទាំងអស់ ។ ការរួចពន្ធនិងគ្រឿងបរិក្ខារប្រើប្រាស់ដូចដែលផ្តល់ជូនដល់ភ្នាក់ងារការទូតដែលអនុលោមតាមអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូតឆ្នាំ១៩៦១ មន្ត្រីទាំងអស់នេះត្រូវបានរួចពីការជាប់ពន្ធលើប្រាក់បៀវត្សរ៍ បរិលាភ និងវិភាជន៍របស់ពួកគេនៅក្នុងប្រទេសកម្ពុជា ។ មាត្រា៤២ៈ ១) បុគ្គលិកខ្មែរត្រូវបានផ្តល់អភ័យឯកសិទ្ធិឱ្យរួចផុតពីដំណើរក្តីតាមផ្លូវច្បាប់ចំពោះពាក្យពេចន៍ដែលបាននិយាយឬសរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេ ។ ២) បុគ្គលិកបរទេសត្រូវបានផ្តល់បន្ថែមនូវ ក) អភ័យឯកសិទ្ធិឱ្យរួចផុតពីដំណើរក្តីតាមផ្លូវច្បាប់ចំពោះពាក្យពេចន៍ដែលបាននិយាយឬសរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់ពួកគេ ។ ខ) អភ័យឯកសិទ្ធិឱ្យរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្សរ៍ វិភាជន៍ និងបរិលាភ ដែលបានជួលពួកគេដោយបណ្តារដ្ឋាភិបាលដែលបានចូលរួមវិភាគទានចំពោះមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ ។ គ) អភ័យឯកសិទ្ធិឱ្យរួចផុតពីការដាក់កំហិតព្រំដែនអន្តោប្រវេសន៍ ។ ឃ) សិទ្ធិនាំចូលដោយរួចពន្ធអាករ គ្រឿងសង្ហារិម និងសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេ លើកលែងតែការចំណាយសម្រាប់សេវាកម្មនៅពេលដែលមកទទួលភារកិច្ចផ្លូវការជាលើកដំបូងនៅប្រទេសកម្ពុជា ។ ៣) មេធាវីរបស់ជនសង្ស័យឬជនជាប់ចោទដែលត្រូវបានទទួលស្គាល់ថាជាមេធាវីដោយអង្គជំនុំជម្រះ មិនត្រូវស្ថិតនៅក្រោមអំណាចរដ្ឋាភិបាលនូវវិធានការណាមួយដែលអាចប៉ះពាល់ដល់ការបំពេញមុខងារដោយសេរីនិងឯករាជ្យរបស់ខ្លួននៅក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ជាពិសេសមេធាវីត្រូវបានផ្តល់នូវ ក) អភ័យឯកសិទ្ធិឱ្យរួចផុតពីការចាប់ឃុំខ្លួន និងការរឹបអូសរបស់របរផ្ទាល់ខ្លួន ក្នុងក្របខ័ណ្ឌនៃការបំពេញភារកិច្ចរបស់ខ្លួនក្នុងរឿងក្តីនេះ ។ ខ) ភាពមិនអាចរំលោភបំពានបាននូវឯកសារទាំងអស់ដែលទាក់ទងដល់ការបំពេញមុខងាររបស់ខ្លួនជាមេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទ ។ គ) អភ័យឯកសិទ្ធិឱ្យរួចផុតពីយុត្តាធិការរដ្ឋប្បវេណីនិងព្រហ្មទណ្ឌចំពោះពាក្យពេចន៍ដែលបាននិយាយឬសរសេរ និងសកម្មភាពដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេក្នុងនាមជាមេធាវី ។ ៤) បណ្ណសារដ្ឋាននៃតុលាការ និងជាទូទៅ ឯកសារនិងសម្ភារទាំងអស់ដែលរកបាន ហើយដែលជាកម្មសិទ្ធិរបស់តុលាការ ឬប្រើប្រាស់ដោយតុលាការ ទោះស្ថិតនៅកន្លែងណានៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ នៅគ្រប់គ្រងដោយជនណាក៏ដោយ គឺមិនអាចត្រូវបានរំលោភបំពានបានក្នុងរយៈពេលនៃកិច្ចដំណើរការជំនុំជម្រះនេះឡើយ ។ ទូលព្រះបង្គំខ្ញុំបាទសូមដាក់ថ្វាយនិងជូនអង្គសភានូវជំពូកទី១៣ ដើម្បីពិភាក្សានិងអនុម័តតាមការគួរ ។ សូមអរព្រះគុណនិងអរគុណ ។*

**សម្តេច ហេង សំរិន:** *សូមអង្គសភាពិភាក្សានូវជំពូកទី១៣ ។ សូមអញ្ជើញឯកឧត្តម ប៉ែន បញ្ញា ។*

**ឯកឧត្តម ប៉ែន បញ្ញា:** *សូមគោរពសម្តេចប្រធាន ជារួមខ្ញុំបាទគាំទ្រជំពូកទី១៣ ហើយសូមចូលរួមយោបល់លើពីរចំណុច ។ ទីមួយ នៅមាត្រា៤២ មាត្រា៤២នេះនិយាយអំពីកំណត់អំពីអភ័យឯកសិទ្ធិ និងសិទ្ធិរបស់មនុស្សបីប្រភេទ គឺបុគ្គលិកខ្មែរ បុគ្គលិកបរទេស ហើយនិងមេធាវី ។ នៅចំណុចទីពីរ គឺបុគ្គលិកបរទេសត្រូវបានផ្តល់នូវអភ័យឯកសិទ្ធិប៉ុន្មាន និងនូវសិទ្ធិអ្វីខ្លះ? ដូច្នេះតាមខ្ញុំបាទគឺលុបពាក្យបន្ថែមនេះចោល មិនបាច់ដាក់ពាក្យបន្ថែម ប្រសិនជាសរសេរបន្ថែមត្រូវសរសេរតាមវិធីផ្សេង ចង់និយាយថា បុគ្គលិកខ្មែរបានប្រគល់តែអភ័យឯកសិទ្ធិមួយទេ ចំណែកបុគ្គលិកបរទេស គឺត្រូវបានផ្តល់នូវអភ័យឯកសិទ្ធិបី ហើយនិងសិទ្ធិមួយ អ៊ីចឹងមេធាវីគឺគេមានអភ័យឯកសិទ្ធិពីរ ហើយនិងការធានាមិនឲ្យ... សុំស្នើលុបពាក្យបន្ថែមនេះចេញ ។ ទីពីរៈ ខ្ញុំបាទសុំស្នើបញ្ជាក់នូវចំណុចទីមួយ បញ្ជាក់នូវឃ្លានូវបន្ទាត់ចុងក្រោយ "ទោះជាស្ថិតនៅកន្លែងណានៃព្រះរាជាណាចក្រកម្ពុជាក៏ដោយនិងគ្រប់គ្រងដោយជនណាក៏ដោយ" ខ្ញុំបាទសុំស្នើបញ្ជាក់ថា "គ្រប់គ្រងដោយជនណាក៏ដោយ"សំដៅទៅលើជនណា? ជនណាក៏ដោយនេះវាអត់មានក្របខ័ណ្ឌ អត់មានកំណត់ទេ ឬមួយក៏វានៅក្នុងក្របខ័ណ្ឌធ្វើការនៅកន្លែងណា? សុំស្នើបញ្ជាក់ ។ សូមអរគុណ ។*

**សម្តេច ហេង សំរិន:** *ខ្ញុំសូមអញ្ជើញតំណាងរាជរដ្ឋាភិបាល ទេសរដ្ឋមន្ត្រី ។*

**ឯកឧត្តម សុខ អាន:** សូមអរគុណ សូមឲ្យសំណួរទីពីរម្តងទៀត ។ ចាប់បានសំណួរទីមួយ ក៏ប៉ុន្តែសំណួរទីពីរ...។

**ឯកឧត្តម ប៉ែន បញ្ញា:** គឺខ្ញុំអានលឿនបន្តិច "ទោះជាស្ថិតនៅកន្លែងណានៃព្រះរាជាណាចក្រកម្ពុជាក៏ដោយនិងគ្រប់គ្រងដោយជនណាក៏ដោយ" ខ្ញុំបាទមិនទាន់ច្បាស់អា"គ្រប់គ្រងដោយជនណាក៏ដោយ"នេះ និង"គ្រប់គ្រងដោយជនណាក៏ដោយ"នៅបន្ទាត់ខាងក្រោមទៀត នៅត្រង់ហ្នឹង "ដោយជនណាក៏ដោយ" នេះតើចង់សំដៅទៅលើជនជាទូទៅ ឬមួយក៏ជនដែលទទួលធ្វើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះទេ? សូមអរគុណ ។

**ឯកឧត្តម សុខ អាន:** ខ្ញុំបាទសូមគោរពសម្តេចប្រធានជាថ្មីម្តងទៀត សំណួរទីពីររបស់ឯកឧត្តម ប៉ែន បញ្ញា ដែលលោកបានលើកឡើង ទីមួយ គឺនៅលើពាក្យបន្ថែម ខ្ញុំបាទយល់ថាអាចលុបបាន បុគ្គលិកបរទេសត្រូវបានផ្តល់នូវ អ៊ីចឹងគឺអាចំណុច ក ខ គ ឃ នេះ គឺរៀបរាប់នូវអភ័យឯកសិទ្ធិ សិទ្ធិដែលបុគ្គលិកបរទេសត្រូវទទួលបាន ។ ចំណុចនេះ ចំពោះសំណួរទីពីរបញ្ជាក់អំពីឯកសារសម្ភារទាំងអស់ដែលតុលាការដែលអង្គជំនុំជម្រះត្រូវការប្រើប្រាស់នេះគឺចង់បញ្ជាក់ថាមិនមែនត្រឹមតែនៅក្នុងតុលាការទេ គឺនៅកន្លែងណាក៏ដោយ គឺថាច្បាប់គេអនុវត្តសម្រាប់ទូទាំងប្រទេស ដូច្នេះ គឺនៅទូទាំងប្រទេសហ្នឹង ឯកសារហ្នឹង សម្ភារហ្នឹង ដែលជាកម្មសិទ្ធិរបស់តុលាការ ឬប្រើប្រាស់ដោយតុលាការ ទោះជាស្ថិតនៅកន្លែងណានៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ និងគ្រប់គ្រងដោយជនណាក៏ដោយ គឺត្រូវមិនអាចមិនមែន មិនអាចជាកម្មវត្ថុនៃការរំលោភបំពាននៅក្នុងរយៈនៃដំណើរការជំនុំជម្រះនេះ គឺចំណុចទីបួននៅក្នុងមាត្រា៤២នេះ គឺមានគោលដៅចង់ការពារនូវឯកសារ នូវសម្ភារ ដែលអង្គជំនុំជម្រះត្រូវប្រើប្រាស់នៅក្នុងដំណើរការវិនិច្ឆ័យទោសនេះ គឺមានន័យទូលាយដូច្នេះ ។ សូមអរគុណ ។

**សម្តេច ហេង សំរិន:** បាទសូមអញ្ជើញឯកឧត្តម ឯក សំអុល ។

**ឯកឧត្តម ឯក សំអុល:** សូមគោរពសម្តេចប្រធាន សូមគោរពឯកឧត្តមអនុប្រធានទី២នៃរដ្ឋសភា និងសូមគោរពអង្គសភាទាំងមូល ។ ទូលបង្គំខ្ញុំបាទសូមចាប់អារម្មណ៍ចំពោះសំណួរនិងចម្លើយរបស់ឯកឧត្តមទេសរដ្ឋមន្ត្រីចំពោះឯកឧត្តម ប៉ែន បញ្ញា លើមាត្រា៤២ ចំណុចទី២ ខ្ញុំបាទយល់ថាត្រូវរក្សាទុកចំណុចទី២នេះដដែល ហើយបុគ្គលិកបរទេសត្រូវបានផ្តល់បន្ថែមនូវចំណុច ក ខ គ ឃ នេះ ពីព្រោះថា ពាក្យថាបន្ថែមនេះ បន្ថែមទៅលើអភ័យឯកសិទ្ធិដែលបុគ្គលិកបរទេស មន្ត្រីបរទេស ដែលត្រូវតែបានទទួលក្នុងក្របខ័ណ្ឌនៃច្បាប់អន្តរជាតិគឺអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូតនៅក្នុងនោះគេនិយាយអំពីអភ័យឯកសិទ្ធិនៃមន្ត្រីការទូតដែលយើងហៅថាអភ័យឯកសិទ្ធិការទូតនោះ អ៊ីចឹងបានខ្ញុំបាទយល់ថាសុំអធ្យាស្រ័យពីឯកឧត្តមទេសរដ្ឋមន្ត្រី គឺរក្សាសិទ្ធិទុកអាហ្នឹង គឺថាមានន័យគ្រប់គ្រាន់ស្របតាមអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ ហើយដែលព្រះរាជាណាចក្រកម្ពុជាបានចូលទៅក្នុងសន្ធិសញ្ញាហ្នឹង ហើយដូច្នេះសូមរក្សាទុកគឺត្រឹមត្រូវ ។ សូមអរគុណ សូមកុំលុបពាក្យបន្ថែមហ្នឹងគឺត្រឹមត្រូវហើយ ។

**ឯកឧត្តម ប៉ែន បញ្ញា:** សូមអរគុណសម្តេចប្រធាន សូមបញ្ជាក់ជាថ្មីម្តងទៀត សុំចង់ថាសរសេរពាក្យបន្ថែម វាថាកន្លែងហ្នឹង វាអត់កន្លែងហ្នឹងទេ ខុសកន្លែង ត្រូវសរសេរថា "បុគ្គលិកបរទេសត្រូវបានផ្តល់នូវអភ័យឯកសិទ្ធិឲ្យរួចផុតពីដំណើរការក្តីតាមផ្លូវច្បាប់ចំពោះពាក្យពេចន៍ដែលបាននិយាយសរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់ពួកគេ ហើយត្រូវបានផ្តល់បន្ថែមនូវ..." អាហ្នឹងបានវាត្រឹមត្រូវប្រសិនបើចង់បញ្ជាក់ពាក្យបន្ថែម ប៉ុន្តែតាមខ្ញុំបាទយល់ ដកបន្ថែមចេញទៅវាមានន័យគ្រប់គ្រាន់ហើយ ក្រុងវីយែនក៏ដោយ ការទូតក៏ដោយ ប៉ុណ្ណេះវាគ្រប់គ្រាន់ ពីព្រោះចំណុចទីមួយ បុគ្គលិកខ្មែរគេឲ្យតែអភ័យឯកសិទ្ធិតែមួយទេ ចំណុចទីពីរបុគ្គលិកបរទេសនេះ គឺអភ័យឯកសិទ្ធមានដល់ទៅបី និងសិទ្ធិមួយទៀតវាមានបួន ក ខ គ ឃ ចាំបាច់ដាក់បន្ថែមធ្វើអីទៀត ចំណែកមេធាវីគឺមានអភ័យឯកសិទ្ធិពីរ ហើយនិងការធានាមិនឲ្យរំលោភបំពានបានអ៊ីចឹងបន្ថែមនេះអត់មានត្រូវបន្ថែមលើអ្នកណាទេ បុគ្គលិកខ្មែរមាន១ បុគ្គលិកបរទេសមាន៤ មេធាវីមាន៣ សូមអរគុណ ។

**សម្តេច ហេង សំរិន:** សូមញ្ជើញឯកឧត្តម ឃ្លោក ប៊ុតឌី ។

**ឯកឧត្តម ឃ្លោក ប៊ុតឌី:** សូមគោរពសម្តេចប្រធានអង្គប្រជុំ ឯកឧត្តមអនុប្រធានទី២ សូមគោរពឯកឧត្តមតំណាងរាជរដ្ឋាភិបាល ព្រមទាំងឯកឧត្តមជាសមាជិកសមាជិកានៃអង្គសភា ។ ទូលបង្គំខ្ញុំចង់មានអន្តរាគមន៍ទៅលើមាត្រា៤២នេះទាក់ទងនឹងអ៊ីដែលហៅថា"បន្ថែម"ដែលនិយាយស្តាប់គ្នាមិនបាន ។ ពាក្យបន្ថែមដែលយើងប្រើប្រាស់នៅក្នុងពេលនេះគឺបន្ថែមនៅលើ Convention នៅលើអនុសញ្ញាមួយហៅថា អនុសញ្ញាការទូតនោះ អនុសញ្ញាទីក្រុងវីយែនបន្ថែមពីលើហ្នឹង មិនមែនយកសិទ្ធិរបស់ខ្មែរហ្នឹងមកបន្ថែមពីលើហ្នឹងទេ មិនមែនទេ គឺសិទ្ធិដែលបានផ្តល់ឲ្យតាម Convention វីយែន រួចទៅហើយ បន្ថែមទៅលើហ្នឹង សិទ្ធិ ក ខ គ ឃ ង។ ដូច្នេះឯកឧត្តម ប៉ែន បញ្ញា លោកអត់យល់ លោកស្មានតែ ក ខ គ ឃ ង ហ្នឹង "ក"មួយទៅបន្តិចទៀត ខ គ ឃ តាមពិតអត់មាន មិនមែនទេ គឺថែមមកលើ Convention វីយែន លើអ៊ីដែលមាន ក ខ គ ឃ ។ ដូច្នេះបន្ថែមទៅលើហ្នឹង ។ សូមអរគុណ សូមអភ័យទោស មាត្រា៤២ តាមតែពង្រៀងរបស់រាជរដ្ឋាភិបាលគឺត្រឹមត្រូវ មិនមានអីគួរឲ្យយើងផ្លាស់ប្តូរបានទេ ។

**សម្តេច ហេង សំរិន:** សូមអញ្ជើញឯកឧត្តម ណាន់ ស៊ី ។

**ឯកឧត្តម ណាន់ ស៊ីៈ** ទូលព្រះបង្គំខ្ញុំបាទសូមគោរពសម្តេចប្រធានអង្គប្រជុំ សូមគោរពឯកឧត្តមអនុប្រធានទី២ សូមក្រាបថ្វាយបង្គំនិងគោរពអង្គប្រជុំទាំងមូលជាទីគោរព ។ ទូលព្រះបង្គំខ្ញុំបាទសូមចាប់អារម្មណ៍ចំពោះអ្វី ការស្នើសុំរបស់ឯកឧត្តម ប៉ែន បញ្ញា ទៅចំពោះឯកឧត្តមទេសរដ្ឋមន្ត្រី សុខ អាន ទូលព្រះបង្គំខ្ញុំបាទសូមទាញអារម្មណ៍ឯកឧត្តមទេសរដ្ឋមន្ត្រី សុខ អាន វិញថា យើងខ្ញុំសូមឲ្យឯកឧត្តមទេសរដ្ឋមន្ត្រីមានលំនឹងមួយទៅតាមសេចក្តីព្រាងរបស់រាជរដ្ឋាភិបាល ខ្ញុំបាទសូមឯកភាពទៅនឹងអ្វីជាការលើកឡើងរបស់ឯកឧត្តម ឯក សំអុល ដូចជាឯកឧត្តម ឃ្លោក ប៊ុតឌី ចំពោះអ្វីដែលយើងបន្ថែមថា បុគ្គលិកបរទេសត្រូវបានផ្តល់បន្ថែមនូវចំណុច ក ចំណុច ខ គ ឃ នេះ ដូច្នេះសូមឯកឧត្តមទេសរដ្ឋមន្ត្រី សុខ អាន មេត្តាឈរនៅអ្វីដែលរាជរដ្ឋាភិបាលបានស្នើមក ។ សូមអរព្រះគុណ សូមអរគុណ ។

**សម្តេច ហេង សំរិនៈ** បាទ សូមអញ្ជើញឯកឧត្តមទេសរដ្ឋមន្ត្រី ។

**ឯកឧត្តម សុខ អានៈ** ខ្ញុំបាទសូមគោរពសម្តេចប្រធានជាថ្មីម្តងទៀត សូមគោរពអង្គសភាអំពីចំណុចដែលត្រូវថារក្សាពាក្យបន្ថែមនេះ ឬក៏ត្រូវដកចេញនេះ ខ្ញុំបាទមិញបានមានយោបល់ហើយ គឺថាការបកស្រាយគឺមានច្រើន មានអាចមានការបកស្រាយផ្សេងៗគ្នា វាអ៊ីចឹង ឥឡូវបើបកស្រាយ ដូចឯកឧត្តម ឃ្លោក ប៊ុតឌី គឺថាត្រូវផ្អែកទៅលើមាត្រាទី៤១វិញ មាត្រាទី៤២នេះដែលវាមានពាក្យបន្ថែមចំណុចទី២នៃពាក្យបន្ថែមនេះ គឺឯកឧត្តម ឃ្លោក ប៊ុតឌី លោកបកស្រាយដោយផ្អែកមកលើមាត្រាទី៤១វិញ បានន័យថាបន្ថែមទៅលើអ្វីដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ៦១ ។ ហើយបើយើងបកស្រាយ និយាយមួយទៀតដូចឯកឧត្តម ប៉ែន បញ្ញា លោកលើកឡើងគឺថា យើងបកស្រាយពីចំណុចទី២នេះផ្អែកមកលើចំណុចទី១ បានន័យថា មាត្រាទី៤២ កឋាខណ្ឌទីមួយគឺនិយាយអំពីអភ័យឯកសិទ្ធិរបស់បុគ្គលិកខ្មែរដល់ចំណុចទី២នេះ គឺនិយាយអំពីអភ័យឯកសិទ្ធិរបស់បុគ្គលិកនិងសិទ្ធិរបស់បុគ្គលិកបរទេស ។ ដូច្នេះបកស្រាយដោយផ្អែកពីចំណុចទីពីរនេះទៅលើចំណុចទីមួយ ដូច្នេះហើយបានជា ខ្ញុំបាទយល់ឃើញថា ចំពោះឥឡូវនេះជំហររបស់ខ្ញុំបាទដែលជាអ្នកការពារច្បាប់នេះ គឺចំណុចនេះវាមិនជាចំណុចធំដុំពេកទេ អាចថាជាចំណុចពុកមាត់ពុកចង្កាទេ ហ្នឹងគឺថាដាក់ក៏បាន មិនដាក់ក៏បាន ដកក៏បាន មិនដកក៏បាន ព្រោះចំណុចតូចដែលមិនមានអ្វីដែលពាក់ព័ន្ធជ្រៅទៅក្នុងខ្លឹមសារនៃច្បាប់នេះទេ ខ្លឹមសារនៅដដែលទេ ការបកស្រាយផ្អែកទៅលើមាត្រា៤១ឬមាត្រាទី៤២ កឋាខ័ណ្ឌទីមួយដដែល ។ បើបកស្រាយទៅលើកឋាខ័ណ្ឌទី៤២ គឺត្រូវដកចេញព្រោះថាអ្វីដែលបានលើកឡើងនូវក្នុងចំណុចទីមួយនេះ យើងបានយកមកលើកឡើងម្តងទៀតនៅចំណុចទី២នៅ ចំណុចទី២ អក្សរ “ក”នេះ នៅចំណុចទី២អក្សរ “ក” គឺយើងលើកឡើង យើង Repété យើងលើកឡើងជាថ្មីម្តងទៀតនូវអ្វីដែលចែងនៅក្នុងចំណុចទីមួយ ដូច្នេះមិនបាច់មានពាក្យបន្ថែមទេ ដូចដែលឯកឧត្តម ប៉ែន បញ្ញា លោកលើក ប៉ុន្តែបើយើងផ្អែកទៅលើមាត្រាទី៤១ ខាងលើគឺអាចថារក្សាពាក្យបន្ថែមបាន ដូច្នេះហើយគឺក្នុងន័យអ៊ីចឹងដកក៏ខ្លឹមសារវាអត់ដូរ ទុកក៏ខ្លឹមសារអត់ដូរដែរ ដោយធ្វើការបកស្រាយទៅលើចំណុចពីរដែលផ្សេងគ្នា ។ អ៊ីចឹងហើយការបកស្រាយហ្នឹងវាបានដូចគ្នា បើវាបានដូចគ្នា ដូច្នេះហើយបានជាខ្ញុំបាទថាមិនយល់ទាស់ទេ ឥឡូវនេះ គឺថាទុកក៏បាន ដកក៏បាន មូលហេតុដែលខ្ញុំបាទលើកឡើងថាទុកក៏បាន ដកក៏បាន គឺត្រូវថាមានការបកស្រាយវាសមស្របដូចគ្នា អ៊ីចឹងមិនដឹងថាម៉េច ។ ប៉ុន្តែធម្មតាបើអ្នកសរសេរគម្រោងមកគឺតែងចង់រក្សាគម្រោងហើយ បើបានទុកគឺហាក់ដូចជាល្អជាង គឺថាមិនបាច់កែ ព្រោះថាអត់ខុសដែរ វាអត់ខុសដែរ ប៉ុន្តែក៏សុំបញ្ជាក់ដែរថា ការបកស្រាយសុំដកក៏មិនខុសដែរព្រោះថាសំអាងទៅលើមាត្រាលើនេះដែលយើងបាន *Repété* ឡើងវិញ បានរៀបរាប់ឡើងវិញនូវនូវមាត្រាខាងក្រោមរួចទៅហើយ ខ្ញុំបាទសុំមានយោបល់ប៉ុណ្ណឹង ។

**សម្តេច ហេង សំរិនៈ** អ៊ីចឹងសូមជំហរខាងប្រធានគណៈកម្មាធិការដើម្បីបំភ្លឺថែម ។

**ឯកឧត្តម ម៉ោញ សាផានៈ** ទូលបង្គំខ្ញុំបាទយល់ឃើញថានៅក្នុងនេះមាត្រា៤១ គឺនិយាយអំពីចៅក្រមបរទេសដែលយើងទុកយោងទៅលើការការពារនៃអនុសញ្ញាទីក្រុងវីយែន អ៊ីចឹងហើយដល់អាចំណុចទី២នេះ គឺយើងត្រូវបន្ថែមនៅលើចំណុចដែលគេការពារទីក្រុងវីយែននោះបានយើងដាក់ថាបន្ថែម អានេះដើម្បីផ្ទុះបញ្ចាំងនូវសិទ្ធិមួយចំនួនថែមទៀតលើសពីអនុសញ្ញាទីក្រុងវីយែន អ៊ីចឹងហើយទូលបង្គំខ្ញុំបាទយល់ឃើញថាសូមរក្សាទុកនៅដដែល សូមអរព្រះគុណ អរគុណ ។

**សម្តេច ហេង សំរិនៈ** អ៊ីចឹងសូមអង្គសភាធ្វើការអនុម័តនៅជំពូកទី១៣ ។

**អគ្គលេខាធិការនៃអង្គប្រជុំៈ** សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី១៣លើសេចក្តីព្រាងនៃច្បាប់នេះមាន៩២លើ៩២ សូមអរព្រះគុណ អរគុណ ។

**សម្តេច ហេង សំរិនៈ** អ៊ីចឹងបន្ទាប់ពីការអនុម័តនូវជំពូកទី១៣ សូមអញ្ជើញប្រធាននៃគណៈកម្មាធិការ អាននូវជំពូកទី១៤ ។

**ឯកឧត្តម ម៉ោញ សាផានៈ** ជំពូកទី១៤ៈ ទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ មាត្រា៤៣ៈ អង្គជំនុំជម្រះវិសាមញ្ញដែលធ្វើឡើងនៅថ្នាក់សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូលមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ។ ទូលបង្គំខ្ញុំបាទសូមដាក់ថ្វាយនិងជូនអង្គសភានូវជំពូកទី១៤ ដើម្បីពិភាក្សានិង

អនុម័តតាមការគួរ សូមអរព្រះគុណ និងអរគុណ ។

**សម្តេច ហេង សំរិន:** សូមអង្គសភាពិភាក្សានូវជំពូកទី១៤ សូមអញ្ជើញ ។

**ឯកឧត្តម សុខ អាន:** សូមគោរពសម្តេចប្រធានម្តងទៀត ហើយសូមធ្វើការបញ្ជាក់បន្ថែមលើមាត្រា៤៣នេះ គឺការជ្រើសរើសកន្លែងនេះក៏មានយោបល់ច្រើនដែរពីដំបូង គឺយោបល់ខ្លះថាចង់ទៅធ្វើនៅខេត្តតាកែវព្រោះថាមានផ្ទះតាម៉ុកមួយធំនៅហ្នឹងពីដើម ប៉ុន្តែយោបល់ខ្លះថា ហ៊ឺ! ធ្វើនៅភ្នំពេញវិញ អ៊ីចឹងចុងក្រោយអ្វីដែលខ្ញុំបាទចង់បញ្ជាក់ជូនសម្តេចប្រធាននិងអង្គសភាដ៏ខ្ពង់ខ្ពស់នេះ គឺថាចំណុចនេះបានលើកឡើងពិភាក្សានៅក្នុងការចរចាដែរ ដោយភាគីខាងឯកឧត្តមអគ្គលេខាអង្គការសហប្រជាជាតិហ្នឹង ជាពិសេសគឺតំណាងដែលបានអញ្ជើញមកចូលរួមចរចានេះ គឺគេបានសង្កត់សួរយើងថាតើរើសកន្លែងណា? ដូច្នេះនោះយើងក៏បានបង្ហាញនូវសាលចតុមុខ សាលចតុមុខដែលកំពុងជួសជុលថាអាចធ្វើជាសាលសវនាការបាន...

**ឯកឧត្តម សុខ អាន:**...ជូនសម្តេចប្រធាន និងអង្គសភាដ៏ខ្ពង់ខ្ពស់ដែរ គឺថាគេបានចាប់អារម្មណ៍ខ្ពស់ចំពោះទីកន្លែងនេះដោយលើកឡើងថាគេអាចចលនាមតិប្រទេសផ្សេងៗឲ្យជួយរួមចំណែកសង់ជាអគារមួយនៅជិតនោះដើម្បីយកជាអគារជាការិយាល័យធ្វើការ ។ ហើយប្រើប្រាស់សាលចតុមុខជាសាលសវនាការ ដូច្នេះអគារនោះប្រហែលជាមិនតូចប៉ុន្មានទេ អគារនោះអាចធំមានបន្ទប់គ្រប់គ្រាន់ដើម្បីជាការិយាល័យបម្រើការជាការិយាល័យរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ហើយបន្ថែមលើនេះគឺគេបំពាក់គ្រឿងសម្ភារសម្រាប់ការផ្សារដល់អគារនេះគ្រប់គ្រាន់បន្ថែមពីលើនេះទៀត គឺគេបានគិតគូរថានឹងខិតខំចលនាមតិប្រទេសផ្សេងៗដែលអាចរួមចំណែកនោះឲ្យរួមចំណែកជាមូលនិធិដើម្បីសាងសង់ជាវិមានយុត្តិធម៌មួយនៅកម្ពុជាដែលគេហៅថា palace de justice អ៊ីចឹងនេះជាការដែលគេបានលើកឡើងសន្យាច្បាស់លាស់អ៊ីចឹង ប៉ុន្តែលទ្ធភាពដែលថាអនុវត្តទៅបានកម្រិតណានោះ អាហ្នឹងគឺវានៅលើការដាក់ស្តែងថាការជំរុញទៅមុខនេះ វាអភិវឌ្ឍបានកម្រិតណា ប៉ុន្តែខ្ញុំបាទក៏បានទទួលពត៌មានថានៅពេលដែលប្រជុំធ្វើចរចាចប់នៅទីក្រុងភ្នំពេញ ហើយគណៈប្រតិភូគេបានត្រឡប់ទៅដល់អង្គការសហប្រជាជាតិវិញនោះគឺគេបានធ្វើការប្រជុំមួយយ៉ាងធំ អញ្ជើញប្រទេសដែលពាក់ព័ន្ធ ហើយគេបានលើក គេបានធ្វើចលនាមតិរឿងហ្នឹងមែន គេគិតគូរពីការរៀបចំធ្វើអគារថ្មីមួយសម្រាប់ជាការិយាល័យនៅជិតសាលចតុមុខហ្នឹង ហើយគេក៏បានលើកឡើងអំពីអ្វីដែលថាជាវិមានយុត្តិធម៌ដែលគេអាចរួមចំណែកសាងសង់នោះ បើយើងគិតទៅវាអាចថា បើការផ្សារនេះគេធ្វើឲ្យម៉ត់ចត់នោះគឺវាមានលទ្ធភាពមែនព្រោះថាកន្លងមកនេះឧទាហរណ៍ ដូចថាតុលាការនៅអតីតយូហ្គោស្លាវី គេប្រើប្រាស់ថវិកា១០០លានដុល្លារមួយឆ្នាំ តុលាការនៅរ៉្វាន់ដា គេប្រើប្រាស់ថវិកាប្រហែលជា៩០លានដុល្លារក្នុងមួយឆ្នាំ ដូច្នេះបើប្រៀបធៀបទំហំថវិកានេះក៏ឃើញថាអាចបើគេចលនាមតិ គឺអាចនឹងសម្រេចបានមែននូវអគារសម្រាប់ជាការិយាល័យ ហើយនិងវិមានយុត្តិធម៌ដែលគេបានលើកឡើងថា គេខិតខំដើម្បីជួយកសាងមានយោបល់តែប៉ុណ្ណឹង ។

**សម្តេច ហេង សំរិន:** បាទ! អ៊ីចឹងបើអង្គសភាមិនមានមតិអីទេ សូមធ្វើការអនុម័តនូវជំពូកទី១៤ ។

**អគ្គលេខាធិការនៃអង្គប្រជុំ:** សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន និងអង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី១៤ លើសេចក្តីព្រាងនៃច្បាប់នេះមាន៩២លើ៩២ សូមអរព្រះគុណ អរគុណ ។

**សម្តេច ហេង សំរិន:** អ៊ីចឹងសូមអញ្ជើញប្រធានគណៈកម្មាធិការអាននូវជំពូកទី១៥ ។

**ឯកឧត្តម ម៉ោញ សាផាន:** ជំពូកទី១៥ៈ ការចំណាយ មាត្រា៤៤ៈ ការចំណាយនិងប្រាក់បៀវត្សរ៍របស់អង្គជំនុំជម្រះវិសាមញ្ញមាន ១) ការចំណាយនិងប្រាក់បៀវត្សរ៍ចំពោះមន្ត្រីរដ្ឋាភិបាលនិងបុគ្គលិកខ្មែរ ចំពោះចៅក្រមជម្រះក្តីនិងចៅក្រមជម្រះក្តីបម្រុង ចៅក្រមស៊ើបអង្កេតនិងចៅក្រមស៊ើបអង្កេតបម្រុង ព្រះរាជអាជ្ញានិងព្រះរាជអាជ្ញាបម្រុងខ្មែរទាំងអស់ជាបន្ទុករបស់ថវិកាជាតិខ្មែរ ។ ២) ការចំណាយចំពោះមន្ត្រីរដ្ឋបាល និងបុគ្គលិកបរទេសចៅក្រមជម្រះក្តី សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបរទេសដែលបញ្ជូនមកដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាបន្ទុករបស់មូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ ។ ៣) ប្រាក់បៀវត្សរ៍របស់មន្ត្រីរដ្ឋបាល និងបុគ្គលិកបរទេសសហចៅក្រមជម្រះក្តីបរទេស ចៅក្រមស៊ើបអង្កេតបរទេស និងសហព្រះរាជអាជ្ញាបរទេសជាបន្ទុករបស់ប្រទេសដែលបានបញ្ជូនមកតាមសំណើរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ៤) មេធាវីការពារក្តីអាចទទួលប្រាក់កម្រៃពីកិច្ចការពារក្តីរបស់ខ្លួន ។ ៥) ការចំណាយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក៏អាចទទួលបន្ថែមនូវមូលនិធិស្ម័គ្រចិត្តដទៃទៀតដូចជារដ្ឋាភិបាលបរទេស ស្ថាប័នអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា ហើយនិងបុគ្គលដែលមានបំណងចង់ជួយដល់កិច្ចដំណើរការនេះ ។ ទូលព្រះបង្គំខ្ញុំបាទសូមថ្វាយនិងជូនអង្គសភាទាំងមូលនូវជំពូកទី១៥ ដើម្បីពិភាក្សានិងអនុម័តតាមការគួរ សូមអរព្រះគុណ អរគុណ ។

**សម្តេច ហេង សំរិន:** ខ្ញុំសូមអង្គសភាពិភាក្សានូវជំពូកទី១៥ ។ បើអង្គសភាឯកភាពនៅលើជំពូកទី១៥នេះ សូមធ្វើការអនុម័តដោយលើកដៃ ។

**អគ្គលេខាធិការនៃអង្គប្រជុំ:** សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី១៥ លើសេចក្តីព្រាងនៃច្បាប់នេះមាន៩២លើ៩២ សូមអរព្រះគុណ និងអរគុណ ។

**សម្តេច ហេង សំរិន:** អ៊ីចឹងសូមអញ្ជើញប្រធានគណៈកម្មការអាននូវជំពូកទី១៦ ។

**ឯកឧត្តម ម៉ោញ សាផាន:** ជំពូកទី១៦ៈ ភាសាការងារ មាត្រា៤៥ៈ ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ គឺភាសាខ្មែរ ហើយបកប្រែជាភាសាអង់គ្លេស ភាសាបារាំង និងរុស្ស៊ី សូមដាក់ថ្វាយនិងជូនអង្គសភាទាំងមូលនូវជំពូកទី១៦ ដើម្បីពិភាក្សានិងអនុម័តតាមការគួរ សូមអរព្រះគុណនិងអរគុណ ។

**សម្តេច ហេង សំរិន:** សូមអង្គសភាពិភាក្សានូវជំពូកទី១៦ ។ បើអង្គសភាមិនមានមតិអីទេ ហើយឯកភាពលើជំពូកទី១៦នេះ សូមធ្វើការអនុម័ត ។

**អគ្គលេខាធិការនៃអង្គប្រជុំ:** សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី១៦លើសេចក្តីព្រាងនៃច្បាប់នេះមាន៩២លើ៩២ សូមអរព្រះគុណ អរគុណ ។

**សម្តេច ហេង សំរិន:** អ៊ីចឹង សូមប្រធានគណៈកម្មការអាននូវជំពូកទី១៧ ។

**ឯកឧត្តម ម៉ោញ សាផាន:** ជំពូកទី១៧ៈ ករណីគ្មានចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេស ។ មាត្រា៤៦ៈ ដើម្បីធានាការអនុវត្តច្បាប់នេះបានទាន់ពេលវេលា និងមិនរអាក់រអួលក្នុងករណីដែលចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេសណាមួយមិនបានចូលរួម ឬបដិសេធមិនចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាផ្សេងទៀតឲ្យ បំពេញកន្លែងទំនេរក្នុងចំណោមបញ្ជីបេក្ខជនបរទេសដែលមានចែងក្នុងមាត្រា១១ ១៨ និងមាត្រា២៦ នៃច្បាប់នេះ ។ ក្នុងករណីដែលឈ្មោះក្នុងបញ្ជីត្រូវបានប្រើអស់កន្លែងទំនេរទាំងនោះត្រូវបំពេញបន្ថែមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពីបណ្តាបេក្ខជនដែលបានស្នើឡើងដោយរដ្ឋាភិបាលនៃបណ្តារដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ ឬពីក្នុងចំណោមឥស្សរជនច្បាប់បរទេសដទៃទៀត ។ បន្ទាប់ពីអនុវត្តនីតិវិធីនេះហើយ បើនៅតែគ្មានចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេសចូលរួមក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយគ្មានបេក្ខជនបរទេសណាត្រូវបានជ្រើសរើសឲ្យបំពេញបន្ថែម បំពេញតំណែងទំនេរនេះទេ នៅពេលនោះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាខ្មែរជំនួស ។ ទូលបង្គំខ្ញុំបាទសូមដាក់ថ្វាយនិងជូនអង្គសភាទាំងមូលនូវជំពូកទី១៧ដើម្បីពិភាក្សា និងអនុម័តតាមការគួរ សូមអរព្រះគុណ និងអរគុណ ។

**សម្តេច ហេង សំរិន:** សូមអង្គសភាពិភាក្សានូវជំពូកទី១៧ ។ អ៊ីចឹងអង្គសភាឯកភាពនូវជំពូកទី១៧នេះ សូមធ្វើការអនុម័ត ។

**អគ្គលេខាធិការនៃអង្គប្រជុំ:** សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី១៥ លើសេចក្តីព្រាងនៃច្បាប់នេះមាន... ។

**សម្តេច ហេង សំរិន:** ជំពូកទី១៧ ។

**អគ្គលេខាធិការនៃអង្គប្រជុំ:** សូមទោសជំពូកទី១៦ ។

**សម្តេច ហេង សំរិន:** ជំពូកទី១៧ ។

**អគ្គលេខាធិការនៃអង្គប្រជុំ:** សូមទោសជំពូកទី១៧ មាន៩២លើ៩២ សូមអរព្រះគុណ និងអរគុណ ។

**សម្តេច ហេង សំរិន:** អ៊ីចឹង សូមឲ្យប្រធានគណៈកម្មការអាននូវជំពូកទី១៨ ។

**ឯកឧត្តម ម៉ោញ សាផាន:** ជំពូកទី១៨ៈ អត្ថិភាពនៃអង្គជំនុំជម្រះវិសាមញ្ញ ។ មាត្រាទី៤៧ៈ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវរលាយ សូមលុបស្រះ "ំ" ចេញ ត្រូវរលាយខ្លួនជាស្វ័យប្រវត្តិ ក្រោយពេលដែលការវិនិច្ឆ័យទោសក្នុងរឿងក្តីនេះបានចប់ជាស្ថាពរ សូមដាក់ថ្វាយនិងជូនអង្គសភាទាំងមូលនូវជំពូកទី១៨ ដើម្បីពិភាក្សានិងអនុម័តតាមការគួរ សូមអរព្រះគុណ និងអរគុណ ។

**សម្តេច ហេង សំរិន:** អ៊ីចឹងខ្ញុំសូមអង្គសភាពិភាក្សានូវជំពូកទី១៨ ។ បើអង្គសភាឯកភាពនូវជំពូកទី១៨ សូមធ្វើការអនុម័ត ។

**អគ្គលេខាធិការនៃអង្គប្រជុំ:** សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី១៨លើសេចក្តីព្រាងនៃច្បាប់នេះមាន៩២លើ៩២ សូមអរព្រះគុណ អរគុណ ។

**សម្តេច ហេង សំរិន:** អ៊ីចឹងសូមប្រធានគណៈកម្មការនូវជំពូកទី១៩ ។

**ឯកឧត្តម ម៉ោញ សាផាន:** ជំពូកទី១៩ៈ អវសានបញ្ញត្តិ មាត្រា៤៨ៈ ច្បាប់នេះត្រូវបានប្រកាសជាប្រញាប់ ។ សូមដាក់ថ្វាយនិងជូនអង្គសភានូវជំពូកទី១៩ ដើម្បីពិភាក្សានិងអនុម័តតាមការគួរ សូមអរព្រះគុណ និងអរគុណ ។

**សម្តេច ហេង សំរិន:** *អ៊ីចឹងសូមអង្គសភាពិភាក្សានូវជំពូកទី១៩ ។ សូមអញ្ជើញឯកឧត្តម ជាម ចន្ទនី ។*

**ឯកឧត្តម ជាម ចន្ទនី:** *ទូលបង្គំខ្ញុំបាទ ជាម ចន្ទនី សូមគោរពសម្តេចអនុប្រធានទី១ សូមគោរពឯកឧត្តមអនុប្រធានទី២ សូមគោរពអង្គសភាជាទីគោរព សូមគោរពតំណាងរាជរដ្ឋាភិបាលទាំងអស់ដែលលោកបានអញ្ជើញមកការពារច្បាប់នេះប្រកបដោយជោគជ័យក្នុងជំពូកចុងក្រោយអវសានបញ្ញត្តិ ទូលព្រះបង្គំខ្ញុំបាទសូមធ្វើការគាំទ្រនូវឯកសារនេះដល់តំណាងរាជរដ្ឋាភិបាលដល់អង្គការសហប្រជាជាតិដែលត្រៀមខ្លួនដើម្បីចូលអនុវត្តច្បាប់នេះ ។ ចំពោះសមាសភាពកម្ពុជា ជាពិសេសអង្គចៅក្រម និងបេក្ខភាពទាំងអស់ និងសមាជិកទាំងអស់ដែលមានការពាក់ព័ន្ធនេះ សូមមេត្តាប្រយ័ត្នប្រយែងដោយហេតុថា ការកាត់ក្តីនេះគឺជាការកាត់ក្តីប្រវត្តិសាស្ត្ររបស់មនុស្សជាតិយើងអត់អាចធ្វើការកាត់ក្តីបន្ថែបន្ថយឡុកឡាយឡ សទៅជាខ្មៅដូចដែលចៅក្រមមួយចំនួនបានអនុវត្តកន្លងមកទេ ខ្ញុំមិនចង់លើកករណីណាមួយដែលថាសទៅជាខ្មៅនោះមកប្រាប់នៅពេលនេះបានទេ ខ្ញុំគ្រាន់តែផ្តាំ ជាពិសេសចៅក្រមនៅក្នុងសាលាឧទ្ធរណ៍បច្ចុប្បន្ន ខ្ញុំសូមជម្រាបសូមផ្តាំដោយសារថា លោកជំទាវជាប្រធាននៅទីនេះមេត្តាប្រាប់ទៅកូនចៅផង មេត្តាពិនិត្យឡើងវិញ រឿងសឲ្យទៅសទៅ រឿងខ្មៅឲ្យទៅខ្មៅទៅ កុំពូកែ កែគេ ហើយខ្ញុំមានសង្ឃឹមនិងមានជំនឿថា យើងនឹងធ្វើការកែទម្រង់ ហើយយើងប្រយ័ត្នប្រយែងជាទីបំផុត ព្រោះនេះគឺជាការកាត់ក្តីមួយដែលពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រមនុស្សជាតិ មិនមែនចំពោះតែកម្ពុជាមួយប៉ុណ្ណោះទេ ។ មួយទៀតខ្ញុំមានយោបល់ខ្លីទេ ចំពោះអង្គការសហប្រជាជាតិ ច្បាប់នេះចេញបានលឿនខ្ញុំសូមជម្រាបគឺយើងមានសង្ឃឹមទៅលើអង្គការសហប្រជាជាតិដែលធ្លាប់បានឆ្លងកាត់ការកាត់ក្តីចំពោះបទប្រល័យពូជសាសន៍បទឧក្រិដ្ឋសង្គ្រាមនៅតាមបណ្តាប្រទេសមួយចំនួនដែលមានរយៈពេលកន្លងមក ដូច្នេះយើងសង្ឃឹមថាអង្គការសហប្រជាជាតិនិងធ្វើឲ្យភាពយុត្តិធម៌មួយមាននៅក្នុងកម្ពុជាដូចមាននៅការកាត់ក្តីនៅបណ្តាប្រទេសដទៃដូចជានៅរ៉្វាន់ដា នៅសម័យណាស៊ីហ្វាស៊ីស និងបណ្តាប្រទេសដទៃទៀត ។ ជាទីបញ្ចប់ខ្ញុំសូមជំរុញថា នៅពេលដែលច្បាប់នេះចេញទៅ សូមឲ្យមានការអនុវត្តឲ្យបានលឿន កុំបង្អែរបង្អង់ពន្យឺតពន្យារ ហើយសូមភាគីទាំងអស់មេត្តាគាំទ្រច្បាប់នេះឲ្យដូចសភាគាំទ្រថ្ងៃនេះ សូមមេត្តាកុំឲ្យមានការរារាំងថាមានការមិនឯកភាពអ៊ីចេះមិនឯកភាពអ៊ីចុះ និងមានផ្ទុះអ៊ីចេះ និងមានផ្ទុះអ៊ីចុះនៅកម្ពុជាទៀត ហើយភាគីដែលជាប់ពាក់ព័ន្ធត្រូវចូលខ្លួនមកឲ្យតុលាការរាស្ត្រកាត់ទោសដោយមិនអាចឲ្យប្រកែកបាន ទូលព្រះបង្គំខ្ញុំបាទសុំចប់សូមអរគុណ ។*

**សម្តេច ហេង សំរិន:** *អ៊ីចឹងសូមអង្គសភាអនុម័តជំពូកទី១៩ ។*

**អគ្គលេខាធិការនៃអគ្គប្រជុំ:** *សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព សំឡេងគាំទ្រលើជំពូកទី១៩លើសេចក្តីព្រាងនៃច្បាប់នេះមាន៩២លើ៩២ សូមអរព្រះគុណ អរគុណ ។*

**សម្តេច ហេង សំរិន:** *អ៊ីចឹងសូមអង្គសភាទាំងមូលអនុម័តនូវខ្លឹមសាររួមនៃច្បាប់នេះ ។*

**អគ្គលេខាធិការនៃអគ្គប្រជុំ:** *សូមគោរពទូលថ្វាយសម្តេចប្រធាន ឯកឧត្តមអនុប្រធាន អង្គសភាទាំងមូលជាទីគោរព ការគាំទ្រលើខ្លឹមសាររួមលើសេចក្តីព្រាងនៃច្បាប់នេះមាន៩២លើ៩២ សូមអរព្រះគុណ អរគុណ ។*

**សម្តេច ហេង សំរិន:** *អ៊ីចឹង សូមតំណាងរាជរដ្ឋាភិបាលមានមតិ ។*

**ឯកឧត្តម សុខ អាន:** *សូមគោរពសម្តេចប្រធានជាថ្មីម្តងទៀត សូមគោរពឯកឧត្តមអនុប្រធានទី២ បាទសូមគោរពអង្គសភាដ៏ឧត្តុង្គឧត្តម ទូលបង្គំខ្ញុំបាទឡើងមានយោបល់ចុងក្រោយនេះ គឺដើម្បីសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអង្គសភាដ៏ឧត្តុង្គឧត្តមដែលលោកបានយល់ជ្រួតជ្រាបច្បាស់លាស់អំពីខ្លឹមសារនៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនេះ ដូចដែលទូលបង្គំខ្ញុំបាទបានលើកឡើងតាំងពីដើមទីការធ្វើសេចក្តីព្រាងច្បាប់នេះគឺជាការប្រមូលផ្តុំនូវបញ្ញាញាណយ៉ាងច្រើន ទាំងឯកឧត្តមអស់លោកជាអ្នកច្បាប់នៅក្នុងប្រទេស ទាំងអ្នកជំនាញការអ្នកច្បាប់ពីខាងក្រៅប្រទេសដើម្បីឲ្យបានជាសេចក្តីព្រាងច្បាប់មួយយ៉ាងសមស្របទៅនឹងសភាពការណ៍របស់យើងផង ទៅនឹងសភាពការណ៍ខាងក្រៅប្រទេសផង ដើម្បីប្រមូលផ្តុំបាននូវការឯកភាពការជឿទុកចិត្តមកលើដំណើរការនៃការវិនិច្ឆ័យទោសនេះ ហើយថ្ងៃនេះទូលបង្គំខ្ញុំបាទមានការសោមនស្សរីករាយដោយរដ្ឋសភាដ៏ឧត្តុង្គឧត្តមបានយល់ច្បាស់លាស់អំពីខ្លឹមសារពិតប្រាកដនៃសេចក្តីព្រាងច្បាប់ ហើយអាចនិយាយបានថាជាប្រវត្តិសាស្ត្រនៅក្នុងរដ្ឋសភាដ៏ឧត្តុង្គឧត្តមដែរដែលសេចក្តីព្រាងច្បាប់បានត្រូវអនុម័តគាំទ្រដោយសកម្មបំផុត ហើយព្រឹកនេះ គឺថាតាំងពីព្រឹកគឺយើងអាចចប់បាន អាចអនុម័តបាន ហើយដែលឯកច្ឆ័ន្ទបំផុតសំឡេង១០០ភាគ១០០នៃសមាជិកសភាដែលមានវត្តមានក្នុងការអនុម័តមកលើសេចក្តីព្រាងច្បាប់ដ៏មានសារសំខាន់នេះ ទូលបង្គំខ្ញុំបាទសូមមានយោបល់ប៉ុណ្ណឹង ។*

**សម្តេច ហេង សំរិន:** *ហើយសូមជម្រាបជូនអង្គសភាថា ដោយមានសំណូមពរពីរាជរដ្ឋាភិបាល សូមរដ្ឋសភាពិនិត្យពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីច្បាប់បោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ជាការប្រញាប់ ទុកជាការប្រញាប់ ខ្ញុំស្នើលើកអង្គប្រជុំរហូតមានលិខិតអញ្ជើញជាថ្មី ដើម្បីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាប្រជុំដាក់ចូលក្នុងរបៀបវារៈនៃអង្គប្រជុំនូវច្បាប់នេះ សូមអរគុណ ហើយសូមបិទអង្គប្រជុំ ។* **ចប់**

# រឿងចាស់ ប៉ុន្តែថ្មីចំពោះខ្ញុំ

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃដែលខ្ញុំកើតមិនទាន់ទេ គឺវាកើតមុនខ្ញុំដល់ទៅ៥ឆ្នាំឯណោះ ។ ដូច្នេះខ្ញុំមិនអាចដឹងបានទេថាថ្ងៃនោះមានព្រឹត្តិការណ៍អ្វីកើតឡើង ។ ប៉ុន្តែនៅពេលដែលខ្ញុំមកធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាជាអ្នកកុំព្យូទ័រក្រាហ្វិករៀបរៀងទស្សនាវដ្តីស្វែងរកការពិតនិងដោយសារឪពុកម្តាយរបស់ខ្ញុំធ្លាប់បានរៀបរាប់ប្រាប់ផងនោះអាចធ្វើឲ្យខ្ញុំដឹងថាថ្ងៃនោះគឺជាថ្ងៃដែលទីក្រុងភ្នំពេញត្រូវបានរំដោះដោយពួកខ្មែរក្រហម ។ ឪពុកម្តាយខ្ញុំបានប្រាប់ថា ប្រជាជនកម្ពុជាមានការអបអរសាទរខ្លាំងណាស់ចំពោះជ័យជម្នះនេះតែក្នុងពេលនោះដែរ ក៏ជាថ្ងៃដែលធ្វើឲ្យប្រជាជនកម្ពុជាប្រែពីការសប្បាយមកកើតទុក្ខក្រៀមក្រំអស់មួយជីវិតទៅវិញ ។


ឆ្នាំ១៩៩៣


ឆ្នាំ២០០០

នៅប្រមាណម៉ោង១១ យោធាខ្មែរក្រហមបានដើរប្រាប់ប្រជាជនឲ្យរៀបចំឥវ៉ាន់ចេញពីផ្ទះក្នុងអំឡុងពេល ៣ថ្ងៃ ដើម្បីរៀបចំទីក្រុងឡើងវិញ ។ ប្រជាជនម្នាក់ៗធ្វើភ្នែកមូល ព្រោះគ្មាននរណាម្នាក់ដឹងពីផែនការជម្លៀសនេះទេ ។ ប្រជាជនខ្លះវេចសម្ពាយដាក់សម្លៀកបំពាក់និងប្រាក់កាសបានខ្លះ ចំណែកប្រជាជនខ្លះទៀតវេចសម្ពាយសឹងតែមិនទាន់ ដោយយោធាខ្មែរក្រហមប្រាប់ថាមិនបាច់យកអ្វីទៅច្រើនពេកទេ បីថ្ងៃក្រោយអង្គការនឹងឲ្យចូលស្រុកវិញហើយ ។ នៅតាមផ្លូវសម្បូរទៅដោយហ្វូងមនុស្សត្រៀបត្រានិងស្នូរគ្រាប់កាំភ្លើងរប៉េះរប៉ោះ ប្រជាជនខ្លះធ្វើដំណើរដោយថ្មើរជើង ខ្លះទៀតធ្វើដំណើរដោយកង់ រទេះទៅតាមលទ្ធភាពរៀងៗខ្លួន ។ ឪពុកម្តាយ បងប្រុស និងបងស្រីរបស់ខ្ញុំ បានធ្វើដំណើរដោយថ្មើរជើង គឺកាន់ដៃគ្នាជាប់ បើហ៊ានតែរបូតដៃប្រាកដជាបែកគ្នាមិនខាន ពីព្រោះមនុស្សច្រើនពេក ។ នៅលើផ្លូវនីមួយៗសម្បូរទៅដោយសាកសពមនុស្សដែលមិនដឹងជាស្លាប់ដោយសារមូលហេតុអ្វីទេ ។ ឪពុកម្តាយរបស់ខ្ញុំបានឃើញយោធាខ្មែរក្រហមស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ៣-៤នាក់ ដែលមានកាំភ្លើងនៅក្នុងដៃ បណ្តើរទាហាន លន់ ណុល ប្រហែលជា៥-៦នាក់ សុទ្ធតែដោះអាវ (មិនដឹងជាបណ្តើរយកទៅណាទេ) ។ ចំណែកឯនៅក្នុងមន្ទីរពេទ្យវិញ ឪពុកម្តាយរបស់ខ្ញុំឃើញអ្នកជំងឺខ្លះត្រូវពួកយោធាខ្មែរក្រហមជម្លៀសឲ្យចេញទៅដែរ ។ ថ្ងៃនោះពួកខ្មែរក្រហមបានដើរជម្លៀសប្រជាជនដែលស្នាក់នៅទីក្រុងឲ្យទៅនៅតាមខេត្ត និងអ្នកនៅតាមខេត្តឲ្យទៅនៅទីជនបទឆ្ងាយៗ ។ រឿងរ៉ាវក្នុងរបបខ្មែរក្រហមគឺជារឿងចាស់ ប៉ុន្តែវាជារឿងថ្មីសន្ធាងសម្រាប់ខ្ញុំ ។ ខ្ញុំនិងមិត្តភក្តិស្មើរទាំងអស់មិនបានទទួលការសិក្សាប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមនៅក្នុងថ្នាក់រៀនទេ ។ នេះគឺអាចជាគ្រោះថ្នាក់មួយដែលថារបបនេះអាចនឹងកើតឡើងវិញបាន ។ ខ្ញុំនៅតែមិនអស់ចិត្តថាហេតុអ្វីបានជាខ្មែរក្រហមដែលមានឈាមជ័រខ្មែរដូចខ្ញុំដែរនោះបានប្រព្រឹត្តអំពើព្រៃផ្សៃបែបនេះមកលើប្រជាជនខ្លួនឯង ។តើអ្នកណាជាមេក្លោងក្នុងរឿងនេះ?

**ស៊ឹម សុភ័ក្រ្ត**

*ប៉ារីស ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០១*

## គោរពជូន
## លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសហការី

*នាងខ្ញុំឈ្មោះ ប៉ោ ពេជ្រ កើតនៅឆ្នាំ១៩៥១ អាសយដ្ឋានលេខ 14 Ave. DE LA COMMUNE DE PARIS 9440 VITRY SUR SEINE (FRANCE) ដែលជាជនរងគ្រោះម្នាក់ដែរក្នុងរបបខ្មែរក្រហមប្រល័យពូជសាសន៍ ។ នាងខ្ញុំបានលួចរត់ចេញពីប្រទេសជាតិមាតុភូមិក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៨ មកដល់ប្រទេសថៃថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៨ និងបន្តការរស់នៅប្រទេសបារាំងរហូតសព្វថ្ងៃនេះ ។*

*ដោយសារបានអានទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា "ស្វែងរកការពិត" រួមផ្សំនូវការយល់ដឹងក្នុងការឆ្លងកាត់នៃជីវិតរស់នៅ ធ្វើឲ្យនាងខ្ញុំកាន់តែភ្លឺស្វាងមួយកម្រិតទៀត ។ ដោយបានមើលហើយមើលទៀតយ៉ាងជក់ចិត្តបំផុត ធ្វើឲ្យអារម្មណ៍នាងខ្ញុំមានបំណងចង់សូមភ្ជាប់ចំណងរាប់អានចូលរួមដោយស្ម័គ្រស្មោះក្នុងការធ្វើវិភាគជុំវិញបញ្ហាពាក់ព័ន្ធឧក្រិដ្ឋកម្មអន្តរជាតិប្រព្រឹត្តឡើងដោយខ្មែរក្រហម សម្រាប់ប្រវត្តិសាស្ត្រនិងយុត្តិធម៌ប្រល័យពូជសាសន៍ ដើម្បីឈានទៅដល់ការកាត់ទោសជនឧក្រិដ្ឋនេះតាមរយៈតុលាការជាតិនិងអន្តរជាតិ ។*

*ជាប្រាកដណាស់ ភារកិច្ចនេះមានការលំបាកពោរពេញទៅដោយឧបសគ្គយ៉ាងច្រើននៅចំពោះមុខអ្នកកាន់អំណាចនយោបាយភាគច្រើនមួយចំនួនដែលធ្លាប់បានចូលរួមនិងគាំទ្រ ដើម្បីផលប្រយោជន៍អំណាចផ្ទាល់ខ្លួន ដែលកំពុងខិតខំធ្វើការយ៉ាងខ្លាំងក្លាបំផុតដើម្បីរួចផុតពីនិទណ្ឌភាព ដោយធ្វើការឃោសនាតាមរយៈគណបក្សរបស់គេផ្សព្វផ្សាយដល់ប្រជារាស្ត្រថា÷*

*១) ការតស៊ូធ្វើការកាត់ទោសខ្មែរក្រហមជាការខាតពេលឥតប្រយោជន៍ ដែលប្រទេសជាតិសព្វថ្ងៃកំពុងប្រឈមមុខដោះស្រាយបញ្ហាក្រីក្រនិងអត់ឃ្លានជាការចាំបាច់ជាងការកាត់ទោសខ្មែរក្រហមទៅទៀត ។*

*២) គឺជារឿងអតីតកាលដែលប្រជារាស្ត្រភ្លេចអស់ទៅហើយ និងដែលអាចបង្កសង្គ្រាមចិត្តសាស្ត្រក្នុងសង្គមខ្មែរ ។*

*៣) ដោយសារនៅពីក្រោយក្រុមស្រាវជ្រាវនេះជាពួកចក្រពត្តិអាមេរិកឈ្លានពានតែប៉ុណ្ណោះ ។*

*៤) ជាញឹកញាប់ ខ្ញុំតែងជួបប្រទះពេលបងប្អូនខ្មែរជួបជុំគ្នាម្តងៗ គេតែងមានទំនាស់នឹងគ្នា ឧទាហរណ៍ៈ បើមាននរណាម្នាក់និយាយរំឭកប្រវត្តិរងគ្រោះរបស់ខ្លួនកាលសម័យខ្មែរក្រហមកាន់អំណាច ត្រូវបានម្នាក់ទៀតជំទាស់ដោយហិង្សាថាបម្រើនយោបាយយួនដែលចង់លេបទឹកដី ។*

*ការចោទប្រកាន់ មើលស្រាល ហាមឃាត់មិនឲ្យនិយាយការពិត ព្រោះខ្លាចប៉ះពាល់នយោបាយ នេះជាឧបសគ្គមួយចម្បងដែលយើងត្រូវតែចាប់អារម្មណ៍យកមកវិភាគក្នុងយុទ្ធនាការ ដើម្បីធានាកម្រិតយុត្តិធម៌ បរិសុទ្ធ ទៀងត្រង់ ឈានដល់ការចេះដឹងកម្រិតខ្ពស់ដែលអាចឆ្លើយតបទៅនឹងការឃោសនាអកុសលទាំងនេះ ។*

*លោកនាយកនិងសហការីទាំងអស់ពិតជាតំណាងកុលបុត្រកុលធីតាខ្មែរដែលធ្លាប់មានកេរ្តិ៍ឈ្មោះល្បីល្បាញនាសម័យអង្គរដែលបានធ្វើការតស៊ូដើម្បីបុព្វហេតុពង្រឹងឫសគល់ឲ្យមាំក្នុងការកសាងជាតិ ការពារទឹកដី ពូជសាសន៍ ក្នុងកម្រិតចេះដឹងខ្ពស់ដោយមិនចាញ់ជនជាតិដទៃឡើយ ។ ជាពិសេស នាងខ្ញុំសូមជូនពរឲ្យលោកនិងសហការីទាំងអស់មានសុខភាពល្អ អាយុយឺនយូរ និងឲ្យកាន់តែមានប្រាជ្ញាភ្លឺស្វាង ក្លាហានអង់អាច ឈ្នះអស់ឧបសគ្គរាំងរាទាំងឡាយ ។*

ចម្រៀងខ្មែរក្រហមៈ

# រស្មីកម្ពុជាថ្មី ភ្លឺស្រែយើងថ្មីល្អណាស់

កយកគន់ស័ក្តិសម ឈើត្រង់ក្រឡា ភ្លឺស្រែសោភា ស្នាដៃកសិករ ស្នាដៃយុទ្ធជន
យុទ្ធនារីបវរ ប្រជាពលករ សហករណ៍យើង ។

ភ្លឺមេត្រង់ភ្លឺង ជាប់ស៊ីងខាងនាយ មើលទៅសែនឆ្ងាយ ឆ្ងាយវែងសន្ធឹម ត្រង់ដូចបន្ទាត់
គំនូរឥតធ្មឹម កម្ពុជាឧបត្ថម្ភ ញញឹមពព្រាយ ។

ប្រឡាយវែងខ្វាត់ បែនបត់តាមភ្លឺ ស្រែក្រោមស្រែលើ ទឹកហូរបែកខ្វាយ ប្រឡាយតូចធំ
នាំទឹកហូរទៅឆ្ងាយ ពីស៊ីងខាងនាយ ជាប់ជាយភូមិដង ។

មើលទំខៀវស្រស់ សម្រស់សន្ទូង ផាកទៅខាងត្បូង ស៊ីងហូរគ្រាំគ្រេង ផាកទៅខាងជើង
ភ្នំខ្ពស់បែកផ្សែង វាលស្រែធំធេង ចាំងចែងដោយភ្លឺ ។

ភ្លឺស្រែអើយ ភ្លឺស្រែយើងថ្មី អ្នកល្អប្រិមប្រិយ ដោយដៃប្រជា ក្រោមការដឹកនាំ
ឧបត្ថម្ភអង្គការ អ្នកស្រែកម្ពុជា សោភាស្រឡាង ។

យើងកសិករ សាទរពេកក្រៃ ដូចបានកើតថ្មី សម័យភ្លឺស្វាង សម័យបវរ
មហារុងរឿង ក្រោមអង្គការយើង ថ្កុំថ្កើងអស្ចារ្យ ។

អង្គរបវរ ល្អល្អះមែនពិត តែល្អប្រាកដ ពិតពេជ្រស្រស់ថ្លា គឺភ្លឺស្រែយើង
រាប់លានហិកតា ពេញទាំងកម្ពុជា នាំផលាផល ។

ភ្លឺស្រែប្រែពិត មានឫទ្ធិមាតុភូមិ ជាសួនមនោរម្យ ផ្ដុំសុភមង្គល រាប់លានហិកតា
នាំនូវភោគផល ទឹកដីនិមល ផ្ដល់វឌ្ឍនភាព ។

ឱស!ឱ!អង្គរ មាគ៌ាប្រពៃ ដឹកនាំឈ្លាសវៃ យកជ័យជំនះ ១៧មេសា
ជាប្រវត្តិសាស្ត្រ មហាអស្ចារ្យណាស់ រំដោះយើងខ្ញុំ ។

មាគ៌ាកសាង ភ្លឺស្វាងចែងចាំង ដោគជ័យធំធេង សាងមាតុភូមិ យើងខ្ញុំកសិករ
ប្ដេជ្ញារួបរួម គ្នាប្រមូលផ្ដុំ កម្លាំងសម្រុក ។

ប្រយុទ្ធលើកភ្លឺ បន្តប្រឡាយ សោមនស្សរីករាយ ដោះស្រាយទៅមុខ ម្ចាស់ការលើទឹក
ធ្វើស្រែសម្រុក ផលពេញបន្ទុក បរិបូរធូរធារ ។

យើងប្រែក្លាយនូវ ឧបករណ៍ដ៏ធូន់ អង្គការមានគុណ ជាមហាចលនា មហាលោតផ្លោះ
មហាអស្ចារ្យ សាងរដ្ឋកម្ពុជា មហាថ្កុំថ្កើង ។

មានកេរ្តិ៍មានឈ្មោះ ពីរោះសុសសាយ ក្រអូបឈ្ងុយឆ្ងាយ ល្បាញល្បីរុងរឿង ក្រោមការដឹកនាំ
អង្គការភ្លឺស្វាង ប្រជាជនយើង សម្រេចសុភមង្គលអើយ ។

**កត់ត្រាចងក្រងជាឯកសារ**

**កញ្ញា រសី សាយ្យាណា**

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់នៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 17, May 2001.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance;
Canadian International Development Agency (CIDA) through the Civil Society Fund; the Royal Danish Government
and the Royal Netherlands Government, *The Hague*.